BIC Bank

របាយការណ៍ប្រចាំឆ្នាំ ២០២០

មាតិកា

04 សាររបស់ប្រធានក្រុមប្រឹក្សាភិបាល

08 ព័ត៌មានអំពីធនាគារ

09 បេសកកម្ម ចក្ខុវិស័យ ទស្សនវិស័យ

10 រចនាសម្ព័ន្ធនៃធនាគារ

12 ក្រុមប្រឹក្សាភិបាល

16 គណៈគ្រប់គ្រង

20 ព័ត៌មានហិរញ្ញវត្ថុសង្ខេប

21 ព័ត៌មានសំខាន់ៗ អំពីអាជីវកម្ម គោលដៅសំខាន់ៗ

22 លទ្ធផលប្រចាំឆ្នាំ ២០២០
- ឥណទាន
- ប្រាក់បញ្ញើ

ការរីកចម្រើន និងការអភិវឌ្ឍ
- ការជំរុញការយកចិត្តទុកដាក់ចំពោះអតិថិជន
- ការអភិវឌ្ឍនិយោជិត
- ការធ្វើទំនើបកម្មហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងសុវត្ថិភាពតាមប្រព័ន្ធអ៊ីនធឺណេត
- សេវាធនាគារឌីជីថល
- ការរៀបចំម៉ាកសញ្ញាថ្មី
- ការពង្រីកបណ្តាញសាខា
- ទំនួលខុសត្រូវសង្គមរបស់ធនាគារ

32 របាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍របស់សវនករឯករាជ្យ

សាររបស់
ប្រធានក្រុមប្រឹក្សាភិបាល

“

ដោយមានសុទិដ្ឋិនិយមបែបនេះ ខ្ញុំសង្ឃឹមថា ធនាគារ ប៊ី.អាយ.ស៊ី របស់យើង រួមទាំងព្រះរាជាណាចក្រកម្ពុជាទាំងមូល កំពុងត្រៀមខ្លួនសម្រាប់អនាគតកាន់តែល្អប្រសើរនាពេលដ៏ខ្លីខាងមុខ ហើយនៅពេលដែលស្ថានភាពមានការលំបាក គឺវាអាចនឹងធ្វើឱ្យយើងខិតខំ "សម្របខ្លួន គិតគូរឡើងវិញ ច្នៃប្រឌិតឡើងវិញ" ទៀតផង។

”

ភាគទុនិក និងភាគីពាក់ព័ន្ធទាំងអស់ជាទីរាប់អាន!

ខ្ញុំមានក្តីសោមនស្សសូមរាយការណ៍អំពីលទ្ធផលរបស់ធនាគារ ប៊ី.អាយ.ស៊ី (ខេមបូឌា) ប៊ែង ម.ក ("ធនាគារ" ឬ "ធនាគារ ប៊ី.អាយ.ស៊ី") សម្រាប់ឆ្នាំដែលបានបញ្ចប់នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០។

ឆ្នាំនៃបញ្ហាប្រឈមដ៏ធំធេងបំផុត និងការត្រឡប់មករកស្ថានភាពល្អប្រសើរឡើងវិញនាពេលខាងមុខ

ជាបឋម ខ្ញុំសង្ឃឹមថា អ្នកទាំងអស់គ្នាបាន និងកំពុងបន្តរស់នៅប្រកបដោយសុខភាពល្អ និងសុខមាលភាពពេញលេញគ្រប់ៗគ្នា។

ឆ្នាំ២០២០ គឺជាឆ្នាំដែលយើងជួបប្រទះនូវបញ្ហាប្រឈមដែលពុំធ្លាប់មានពីមុនមក ហើយប្រហែលជាលើកទីមួយនៅក្នុងប្រវត្តិសាស្ត្រដែលពិភពលោកទាំងមូលជួបប្រទះនូវបញ្ហាប្រឈមបែបនេះ។ វិស័យសំខាន់ៗ ដែលក្នុងនោះរួមមានទាំងវិស័យធនាគារ និងហិរញ្ញវត្ថុរបស់យើងផងដែរ គឺមានការប្រែប្រួលយ៉ាងខ្លាំង ដែលភាគច្រើនគឺចេញមកពីបច្ចេកវិទ្យាដែលជាវិធីសាស្ត្រមួយក្នុងការជួយដោះស្រាយបញ្ហាប្រឈមផ្សេងៗដែលបង្កឡើងដោយការរាតត្បាតនៃជំងឺកូវីដ-១៩។

ទោះជាស្ថិតនៅក្នុងបរិបទដែលវិស័យជាច្រើនត្រូវតែ "សម្របខ្លួន គិតគូរឡើងវិញ ច្នៃប្រឌិតឡើងវិញ" ដើម្បីរក្សានូវភាពរឹងមាំក៏ដោយ ក៏យើងនៅតែសង្ឃឹមថា នៅក្នុងពេលវេលាដែលមានការច្នៃប្រឌិតដ៏អស្ចារ្យបែបនេះ ការត្រឡប់មករកស្ថានភាពប្រក្រតី និងភាពធូរស្រាលឡើងវិញនៃសេដ្ឋកិច្ចពិភពលោក និងសេដ្ឋកិច្ចកម្ពុជាគឺកាន់តែខិតចូលមកដល់ឆាប់ឡើងៗជាងការព្យាករណ៍របស់មនុស្សភាគច្រើនទៅទៀត។

ជាងនេះទៅទៀត យោងតាម IMF Data Mapper របស់មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) កំណើនផលិតផលក្នុងស្រុកសរុបពិតប្រាកដ (GDP) ត្រូវបានព្យាករណ៍ថានឹងមានចំនួនប្រមាណ ៤,២% សម្រាប់ឆ្នាំ២០២១ ដែលមានកំណើនថយចុះនៃផលិតផលក្នុងស្រុកសរុបពិតប្រាកដ -៣,៥% នៅក្នុងឆ្នាំ២០២០។ នៅឆ្នាំបន្ទាប់ របាយការណ៍ស្តីពីចក្ខុវិស័យសេដ្ឋកិច្ចពិភពលោករបស់មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) ដែលបានចេញផ្សាយកាលពីខែមេសា ឆ្នាំ២០២១ កន្លងទៅ បានព្យាករណ៍អំពីអត្រាកំណើនផលិតផលក្នុងស្រុកសរុបពិតប្រាកដកាន់តែល្អប្រសើរ ពោលគឺប្រមាណ ៥,៧% នៅក្នុងចំណាត់ថ្នាក់ប្រទេសរបស់ខ្លួន (បណ្តាប្រទេសអាស៊ីដែលមានសេដ្ឋកិច្ចកំពុងងើបឡើង និងប្រទេសកំពុងអភិវឌ្ឍ) ដែលបង្ហាញអំពីពន្លកថ្មីនៃសុទិដ្ឋិនិយមចំពោះការងើបឡើងដ៏រឹងមាំនាពេលឆាប់ៗខាងមុខនេះ។

ដោយមានសុទិដ្ឋិនិយមបែបនេះ ខ្ញុំសង្ឃឹមថា ធនាគារ ប៊ី.អាយ.ស៊ី របស់យើង រួមទាំងព្រះរាជាណាចក្រកម្ពុជាទាំងមូល កំពុងត្រៀមខ្លួនសម្រាប់អនាគតកាន់តែល្អប្រសើរនាពេលដ៏ខ្លីខាងមុខ ហើយនៅពេលដែលស្ថានភាពមានការលំបាក គឺវាអាចនឹងធ្វើឱ្យយើងខិតខំ "*សម្របខ្លួន គិតគូរឡើងវិញ ច្នៃប្រឌិតឡើងវិញ*" ទៀតផង។

ចក្ខុវិស័យសេដ្ឋកិច្ច

ទោះបីកំណើនផលិតផលក្នុងស្រុកសរុបពិតប្រាកដដែលបានព្យាករណ៍ថាមានការថយចុះពី -១,៦% ទៅ -៣,៥% ក្នុងឆ្នាំ២០១៩ និងពី ៦% មក ៤,២% ក្នុងឆ្នាំ២០២០ យ៉ាងណាក្តី ផលប៉ះពាល់មានកម្រិតទាបជាងការព្យាករណ៍នៅក្នុងគំរូសេណារីយ៉ូអាក្រក់បំផុត ជាពិសេសទោះបីជាមានការកើនឡើងនូវករណីជំងឺកូវីដ-១៩ រហូតដល់ដំណាច់ឆ្នាំ២០២០ នៅក្នុងប្រទេសកម្ពុជាក៏ដោយ។ ទោះបីការចាក់វ៉ាក់សាំងនៅក្នុងប្រទេសកម្ពុជាកំពុងដំណើរការល្អ ហើយប្រទេសផ្សេងៗកំពុងរៀនសូត្រអំពីស្ថានភាពនេះយ៉ាងណាក្តី ក៏យើងនៅតែត្រូវគិតគូរអំពីតុល្យភាពមិនទៀងទាត់រវាងការរក្សាសកម្មភាពសេដ្ឋកិច្ចប្រចាំថ្ងៃ និងការគ្រប់គ្រងហានិភ័យនៃជំងឺកូវីដ-១៩ ដែលអាចអូសបន្លាយរយៈពេលយូរ។

ទោះបីសេដ្ឋកិច្ចប្រទេសចិនដើរតួនាទីយ៉ាងសំខាន់នៅក្នុងខឿនសេដ្ឋកិច្ចពិភពលោកសម្រាប់ឆ្នាំ២០២០ ដែលផ្តល់ប្រយោជន៍ដល់ដៃគូពាណិជ្ជកម្មសំខាន់ៗរបស់ខ្លួន រួមទាំងប្រទេសកម្ពុជាផងដែរ ក៏ដោយ ចក្ខុវិស័យឆ្នាំ២០២១ ដែលកាន់តែមានភាពស្មុគស្មាញ អាចនឹងមានភាពធូរស្រាលមកវិញតាមរយៈទស្សនៈសេដ្ឋកិច្ចកាន់តែមានភាពល្អប្រសើរដែលរំពឹងថានឹងកើតឡើងនៅក្នុងប្រទេសជិតខាងរហូតដល់ដំណាច់ឆ្នាំនេះ ដែលរួមមានប្រទេសវៀតណាម និងប្រទេសថៃជាដើម។ ជាងនេះទៅទៀត ជាមួយនឹងកំណើនផលិតផលក្នុងស្រុកសរុបពិតប្រាកដដែលព្យាករណ៍ថាមានភាពល្អប្រសើរ ៤,២% ព្រមទាំងកំណើនដែលបានព្យាករណ៍ ៣,១% ដែលមានស្ថិរភាពក្នុងរយៈពេលកន្លងមក (ហើយអ្វីដែលសំខាន់ ពុំមានបរិវត្តជរណា) ទៅលើថ្លៃទំនិញប្រើប្រាស់សម្រាប់ឆ្នាំ២០២១ (IMF Data Mapper ខែមេសា ឆ្នាំ២០២១) ការរំពឹងទុកចំពោះស្ថានភាពសេដ្ឋកិច្ចនៃប្រទេសកម្ពុជាប្រហាក់ប្រហែលនឹងឆ្នាំកន្លងទៅដែរ ទោះបីជាមានស្ថានភាពជំងឺកូវីដ-១៩ នៅក្នុងឆ្នាំកន្លងទៅក្តី។

សេចក្តីសង្ខេបអាជីវកម្ម

ធនាគារ ប៊ី.អាយ.ស៊ី មានភាពរឹងមាំនៅក្នុងឆ្នាំ២០២០ ដែលមិនត្រឹមតែនៅក្នុងការរក្សាដំណើរការកំណើនដែលមានស្ថិរភាពនៅក្នុងសមិទ្ធផលហិរញ្ញវត្ថុ និងប្រតិបត្តិការរបស់ខ្លួនប៉ុណ្ណោះទេ ទោះបីជាមានបញ្ហាប្រឈមធ្ងន់ធ្ងរដោយសារជំងឺកូវីដ ១៨ យ៉ាងណាក្តី ប៉ុន្តែធនាគារនៅតែបន្តអភិវឌ្ឍសេវា និងសមត្ថភាពរបស់ខ្លួននៅក្នុងការផ្តល់សេវាដល់អតិថិជន និងភ្ញៀវរបស់ខ្លួនផងដែរ។ ជាងនេះទៅទៀត នៅក្នុងការពង្រីកសេវាធនាគារអនឡាញ កម្មវិធី BIC Mobile ត្រូវបានដាក់ឱ្យប្រើប្រាស់ ហើយខ្ញុំមានក្តីសោមនស្សសូមប្រកាសថា កាលពីពេលថ្មីៗនេះ យើងបានដាក់ឱ្យប្រើប្រាស់នូវកម្មវិធីជំនាន់ថ្មីកាន់តែល្អប្រសើរ ដែលនឹងមានការកែលម្អ និងអភិវឌ្ឍបន្ថែមទៀតនៅពេលយើងប្រមូលបានមតិត្រឡប់ពីអតិថិជន និងភ្ញៀវរបស់យើង។ ទន្ទឹមនឹងនេះដែរ យើងបន្តជំរុញការអភិវឌ្ឍសមត្ថភាពនៃប្រព័ន្ធធនាគារស្នូលថ្មីរបស់យើង ដែលនឹងមានការកែលម្អ និងអភិវឌ្ឍបន្ថែមទៀត ដែលផ្តោតការយកចិត្តទុកដាក់ខ្ពស់ទៅលើហេដ្ឋារចនាសម្ព័ន្ធឌីជីថល ព្រមទាំងធានានូវសុវត្ថិភាព និងលក្ខណៈពិសេសខ្ពស់បំផុត និងល្អបំផុតនៅក្នុងវិស័យនេះ។

សមិទ្ធផលហិរញ្ញវត្ថុរបស់ធនាគារ

នៅពេញមួយឆ្នាំការិយបរិច្ឆេទទីពីរនៃប្រតិបត្តិការ នៅក្នុងរយៈពេល ១២ ខែ បិទបញ្ជីនៅត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ ធនាគារមានប្រាក់ចំណូលសុទ្ធចំនួន ០,៤៤ លានដុល្លារអាមេរិក (ឆ្នាំ២០១៩៖ ប្រាក់ចំណូលសុទ្ធចំនួន ១,១៤ លានដុល្លារអាមេរិក) ដែលមានប្រាក់ចំណូលដុលមុនបង់ពន្ធចំនួន ០,៥៩ លានដុល្លារអាមេរិក (ឆ្នាំ២០១៩៖ ប្រាក់ចំណូលដុលមុនបង់ពន្ធចំនួន ១,៤៧ លានដុល្លារអាមេរិក)។ នៅក្នុងអំឡុងពេលធ្វើរបាយការណ៍ ធនាគារ ប៊ី.អាយ.ស៊ី បន្តមានកំណើនប្រាក់ចំណូលប្រតិបត្តិការរបស់ខ្លួនដល់ ៧,៦១ លានដុល្លារអាមេរិក (ឆ្នាំ២០១៩៖ មានចំនួន ៥,៥៥ លានដុល្លារអាមេរិក) ហើយអាចបង្កើនទ្រព្យសកម្មសរុបដល់ ២៦៨,៩៨ លានដុល្លារអាមេរិក (ឆ្នាំ២០១៩៖ ចំនួន១៩៧,៩១ លានដុល្លារអាមេរិក) ដែលផលបត្រកម្ចីមានចំណែកធំជាងគេចំនួន ៧៤,៦៤ លានដុល្លារអាមេរិក (ឆ្នាំ២០១៩៖ ចំនួន ៦៧,៧៧ លានដុល្លារអាមេរិក)។ ទន្ទឹមនឹងនេះ ប្រាក់បញ្ញើមានចំនួន ១៩០,០៦ លានដុល្លារអាមេរិកសម្រាប់រយៈពេល (ឆ្នាំ២០១៩៖ ចំនួន ១២០,២៤ លានដុល្លារអាមេរិក)។

ប្រាក់ចំណូល
០,៤៤ លានដុល្លារអាមេរិក

ផលបត្រកម្ចី
៧៤,៦៤ លានដុល្លារអាមេរិក

ទ្រព្យសកម្ម
២៦៨,៩៨ លានដុល្លារអាមេរិក

ប្រាក់បញ្ញើ
១៩០,០៦ លានដុល្លារអាមេរិក

ការផ្លាស់ប្តូរសមាសភាពក្រុមប្រឹក្សាភិបាល

នៅក្នុងអំឡុងពេលនេះ បណ្ឌិត Sathit Limpongpan ដែលបានចាកចេញពីតំណែងរបស់លោកជាប្រធានក្រុមប្រឹក្សាភិបាលនៅក្នុងឆ្នាំ២០១៩ បានលាឈប់ពីក្រុមប្រឹក្សាភិបាល។ យើងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការប្តេជ្ញាចិត្ត និងកិច្ចខិតខំប្រឹងប្រែងដ៏ស្មោះស្ម័គ្រអស់ពីចិត្តរបស់លោកនៅក្នុងការជួយធនាគារនៅអំឡុងពេលដែលលោកកាន់តំណែងជាប្រធានក្រុមប្រឹក្សាភិបាល។

អ្នកដែលមកជំនួសតំណែងរបស់លោកគឺ លោកស្រី Adel Leilanie G. Legarta ដែលជាអភិបាលប្រតិបត្តិនៅក្នុងក្រុមប្រឹក្សាភិបាល ដែលបច្ចុប្បន្នកំពុងបំពេញតួនាទីជានាយកប្រតិបត្តិអភិវឌ្ឍន៍អាជីវកម្ម និងលោក MC Cosh John Edward ជាអភិបាលឯករាជ្យ។ តាមរយៈការធ្វើកិច្ចការរួមគ្នា ពួកគាត់ទាំងពីរបានផ្តល់នូវភាពជាអ្នកដឹកនាំដ៏ល្អនៅក្នុងក្រុមប្រឹក្សាភិបាលរបស់ធនាគារ ដោយលោកស្រី Adel ផ្តល់នូវបទពិសោធន៍យ៉ាងស៊ីជម្រៅអំពីវិស័យធនាគារក្នុងប្រទេសកម្ពុជា ហើយលោក JONH ផ្តល់នូវទស្សនវិស័យស៊ីជម្រៅពីតួនាទីគ្រប់គ្រង និងប្រតិបត្តិការផ្សេងៗរបស់គាត់នៅជុំវិញពិភពលោក។ យើងមានក្តីសោមនស្សយ៉ាងក្រៃលែងដែលពួកគាត់ទាំងពីរបានចូលរួម និង ពង្រឹងក្រុមប្រឹក្សាភិបាលរបស់យើង ដោយរំពឹងថានឹងទទួលបានការណែនាំ និងការដឹកនាំដ៏មុតមាំរបស់គាត់ នៅពេលធនាគារឈានចូលទំព័រសករាជថ្មី។

ការផ្តោតលើអនាគតរបស់ធនាគារ

ធនាគារប៊ី.អាយ.ស៊ី (ខេមបូឌា) ប៊ែង ម.ក គឺជាធនាគារមួយរបស់ក្រុមហ៊ុន BIC Group ("គ្រុប") ដែលជាក្រុមហ៊ុនវិនិយោគយ៉ាងសកម្មនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ នៅក្នុងវិស័យធនាគារ អចលនទ្រព្យ ថាមពល និងហិរញ្ញវត្ថុ។

ដោយសារប្រទេសកម្ពុជាជាទីផ្សារស្នូលមួយដែលគ្រុបធ្វើប្រតិបត្តិការ យើងនឹងបន្តការវិនិយោគរបស់យើងទៅលើការធ្វើឱ្យល្អប្រសើរនូវប្រតិបត្តិការ សេវា និងភាពប្រកួតប្រជែងរបស់ធនាគារ។ ការយកចិត្តទុកដាក់ដ៏សំខាន់មួយឆ្ពោះទៅការបន្តកិច្ចខិតខំប្រឹងប្រែងរបស់យើងគឺទៅលើបច្ចេកវិទ្យាឌីជីថល ទាំងជាកម្មវិធី Apps មុខងារតាមប្រព័ន្ធអនឡាញ សុវត្ថិភាព និងការកសាងភាពជាដៃគូដើម្បីផ្តល់មុខងារថ្មី និងបច្ចុប្បន្នដល់អតិថិជន និងភ្ញៀវរបស់យើង។

ផ្នែកសំខាន់មួយទៀតដែលយើងផ្តោតទៅលើគឺផ្សារមូលធន ជាពិសេសនៅបន្ទាប់ពីវិបត្តិជំងឺកូវីដ-១៩ ត្រូវបានបញ្ចប់ ដែលយើងមើលឃើញឱកាសអាជីវកម្មកាន់តែច្រើន ដែលឯកទេសធនាគាររបស់យើងត្រូវបានរៀបចំយ៉ាងល្អប្រសើរ។ យើងមានគោលដៅប្រើប្រាស់អាជីវកម្មគ្រុបរបស់យើង និងរបស់ដៃគូយុទ្ធសាស្ត្រ និងបច្ចេកវិទ្យារបស់យើងដើម្បីពាំនាំផ្នែកដែលទើបចាប់ពន្លកថ្មីនៃវិស័យរបស់យើងនេះជូនដល់ប្រទេសកម្ពុជា ដោយសង្ឃឹមថា យើងអាចទទួលបានជោគជ័យនៅក្នុងការអនុវត្តគម្រោងសម្រាប់បង្ហាញជូន ទាំងនៅក្នុងវិស័យហិរញ្ញវត្ថុ ធនាគារ៉ាប់រងធនាគារ ការបញ្ចូលគ្នា និងការទិញយកក្រុមហ៊ុន និងវិស័យធនាគារឯកជន។

សេចក្តីថ្លែងអំណរគុណ

តាងនាមធនាគារ ប៊ី.អាយ.ស៊ី ខ្ញុំសូមយកឱកាសនេះថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះក្រុមប្រឹក្សាភិបាល មន្ត្រី និងបុគ្គលិកទាំងអស់របស់ធនាគារជាតិនៃកម្ពុជា ចំពោះការបន្តផ្តល់ការដឹកនាំ និងការណែនាំដោយរក្សាបាននូវស្ថិរភាពរូបិយវត្ថុ និងការឆ្លើយតបដ៏រឹងមាំ ជាពិសេសនៅក្នុងអំឡុងឆ្នាំកន្លងទៅ ក៏ដូចជាឆ្នាំបច្ចុប្បន្នដែលមានជំងឺរាតត្បាតនេះ។

ខ្ញុំក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅផងដែរចំពោះអតិថិជន និងដៃគូអាជីវកម្មដ៏មានតម្លៃទាំងអស់ដែលបានបន្តស្មោះស្ម័គ្រ គាំទ្រ និងផ្តល់ទំនុកចិត្តយ៉ាងមុតមាំមកលើធនាគាររបស់យើង។ យើងមានមោទនភាពចំពោះការផ្តល់ភាពជឿជាក់មកលើធនាគាររបស់យើង ហើយយើងនឹងខិតខំពង្រឹងទំនាក់ទំនងនេះឱ្យកាន់តែរឹងមាំ និងស៊ីជម្រៅនៅក្នុងពេលវេលាដ៏លំបាកនេះ ព្រមទាំងឆ្នាំដែលមានភាពល្អប្រសើរនៅក្នុងពេលខាងមុខផងដែរ។

ជាចុងក្រោយ ខ្ញុំសូមយកឱកាសនេះថ្លែងអំណរគុណចំពោះសមាជិកក្រុមប្រឹក្សាភិបាល គណៈគ្រប់គ្រងធនាគារ និងបុគ្គលិក ទីប្រឹក្សាក៏ដូចជាភាគទុនិករបស់យើងដែលបានផ្តល់ការគាំទ្រ ការយកចិត្តទុកដាក់ និងការប្តេជ្ញាចិត្តក្នុងការបំពេញការងារ។ ខ្ញុំកាន់តែមានក្តីសង្ឃឹមយ៉ាងមុតមាំថា ធនាគាររបស់យើងនឹងបន្តទទួលបានការគាំទ្រដោយឥតងាករេបន្ថែមទៀតនាឆ្នាំខាងមុខ។

ដោយក្តីគោរពរាប់អាន!

យឹម លក្ខណ៍

ប្រធានក្រុមប្រឹក្សាភិបាល

ព័ត៌មានអំពីធនាគារ

ធនាគារ ប៊ី.អាយ.ស៊ី (ខេមបូឌា) ប៊ែង ម.ក គឺជាធនាគារពាណិជ្ជដែលបានបង្កើតឡើង និងចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ធនាគារត្រូវបានបង្កើតឡើងនៅថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្របតាមច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម និងទទួលបានអាជ្ញាប័ណ្ណយោងតាមបទប្បញ្ញត្តិរបស់ធនាគារជាតិនៃកម្ពុជា (“NBC”) ហើយធនាគារបានទទួលអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជានៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៨ ព្រមទាំងបានចាប់ផ្តើមដំណើរការអាជីវកម្មរបស់ខ្លួននៅថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៨ ផងដែរ។

ធនាគារបានចូលរួមយ៉ាងសកម្មនៅក្នុងគ្រប់ទិដ្ឋភាពនៃធុរកិច្ចធនាគារទាំងអស់ ហើយថែមទាំងបានផ្តល់សេវាហិរញ្ញវត្ថុពាក់ព័ន្ធផ្សេងៗនៅក្នុងព្រះរាជាណាចក្រកម្ពុជាទៀតផង។

ធនាគារមានទីស្នាក់ការកណ្តាល

ស្ថិតនៅអគារលេខ៤៦២ មហាវិថីព្រះមុនីវង្ស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

ធនាគារត្រូវបានបង្កើតជាលើកដំបូងដោយក្រុមហ៊ុន

Asia Investment and Financial Services Sole Co., Ltd នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ក្រុមហ៊ុន Paradise Investment Co., Ltd. នៃព្រះរាជាណាចក្រកម្ពុជា និងក្រុមហ៊ុន Prime Street Advisory Co., Ltd នៃព្រះរាជាណាចក្រថៃ។ នៅថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២០ ធនាគារជាតិនៃកម្ពុជាបានអនុម័តឱ្យធ្វើការផ្ទេរនូវរាល់ភាគហ៊ុនទាំងអស់របស់ក្រុមហ៊ុន Paradise Investment Co., Ltd (Cambodia) និងក្រុមហ៊ុន Prime Street Advisory Co., Ltd (Thailand) ជូនទៅលោក យឹម លក្ខណ៍ ដោយជំរុញឱ្យមានការពង្រឹងនូវចក្ខុវិស័យ និងបេសកកម្មរបស់ក្រុមប្រឹក្សាភិបាលនៃធនាគារ ប៊ី.អាយ.ស៊ី បន្ថែមមួយកម្រិតទៀត។

រចនាសម្ព័ន្ធ ភាគទុនិក



បេសកកម្ម

ដើម្បីក្លាយជាដៃគូហិរញ្ញវត្ថុក្នុងស្រុកដ៏ល្អបំផុត យើងត្រូវតែមានភាពឆ្លាតវៃ និងភាពរហ័សរហួនជាងគេក្នុងការផ្តល់អត្ថប្រយោជន៍កាន់តែសម្បូរបែបថែមទៀតជូនដល់អតិថិជនរបស់យើង តាមរយៈការផ្តល់ដំណោះស្រាយមានភាពច្នៃប្រឌិតនិងជាក់ស្តែង ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់អតិថិជនទាំងអស់។ យើងក៏បានប្តេជ្ញាចិត្តខ្ពស់ក្នុងការបង្កើតអត្ថប្រយោជន៍សម្រាប់អតិថិជន និងភាគទុនិកទាំងអស់របស់យើង ហើយនឹងខិតខំប្រឹងប្រែងកែលម្អសេវាធនាគាររបស់យើងជាប់ជាប្រចាំផងដែរ តាមរយៈការវិនិយោគជាបន្តបន្ទាប់ទៅលើផ្នែកធនធានមនុស្ស គំនិតច្នៃប្រឌិតថ្មី និងបច្ចេកវិទ្យា។ យើងពង្រឹងទំនាក់ទំនងភាពជាដៃគូជាមួយនឹងអតិថិជនរបស់យើង តាមរយៈការគោរពគ្នាទៅវិញទៅមក បើកចំហ ស្មោះត្រង់ និងការយល់ដឹងអំពីតម្រូវការរបស់អតិថិជន។

ចក្ខុវិស័យ

មានគោលបំណងក្លាយជាធនាគារដៃគូដ៏ល្អបំផុត តាមរយៈការផ្តល់សេវាបុគ្គលល្អបំផុតទៅតាមតម្រូវការរបស់អតិថិជនម្នាក់ៗ និងការផ្តល់ផលិតផល និងដំណោះស្រាយប្រកបដោយភាពច្នៃប្រឌិតដោយប្រើបច្ចេកវិទ្យាទំនើប ដើម្បីបំពេញតាមតម្រូវការ និងការរំពឹងទុករបស់អតិថិជន។

ទស្សនវិស័យ

ទស្សនៈចំពោះ អតិថិជន៖

- ផ្តល់សេវាល្អបំផុត និងសេវាធនាគារមានសុវត្ថិភាពដល់អតិថិជន។
- បំពេញតាមតម្រូវការសេវាធនាគារនិងហិរញ្ញវត្ថុជូនអតិថិជន។

ទស្សនៈចំពោះ បុគ្គលិក៖

- ធនធានមនុស្សគឺជាទ្រព្យសកម្មដ៏ល្អបំផុតរបស់យើង ដូច្នេះយើងបានផ្តោតការយកចិត្តទុកដាក់យ៉ាងសំខាន់ទៅលើការអភិវឌ្ឍធនធានមនុស្សរបស់យើង។ ដំណើរការអភិវឌ្ឍន៍ធនធានមនុស្សដ៏សកម្ម គឺជាកត្តាបង្កើនឧត្តមភាពប្រកួតប្រជែងរបស់យើង។

ទស្សនៈចំពោះ សហគមន៍៖

- គាំទ្រដល់គោលនយោបាយ និងគោលបំណងរបស់រាជរដ្ឋាភិបាលនិងចូលរួមចំណែកអភិវឌ្ឍសហគមន៍ ក៏ដូចជាប្រទេសជាតិទាំងមូលឱ្យមានការរីកចំរើន។

ទស្សនៈចំពោះ ភាគទុនិក៖

- បង្កើតគុណតម្លៃភាគទុនិកកម្រិតខ្ពស់ និងផលរបរនិរន្តរភាពលើទ្រព្យសកម្ម។

រចនាសម្ព័ន្ធនៃធនាគារ




គណៈកម្មាធិការសវនកម្ម
គណៈកម្មាធិការគ្រប់គ្រង
គណៈកម្មាធិការ
បច្ចេកវិទ្យា
គណៈកម្មាធិការ
អភិវឌ្ឍន៍ផលិតផល
គណៈកម្មាធិការ
ឥណទាន
គណៈកម្មាធិការគ្រប់គ្រង
ទ្រព្យសកម្ម និងបំណុល
នាយកប្រតិបត្តិ
បច្ចេកវិទ្យា
នាយកប្រតិបត្តិ
អភិវឌ្ឍន៍អាជីវកម្ម
ប្រធានគ្រប់គ្រងទូទៅ
ផ្នែកព័ត៌មានវិទ្យា
ផ្នែកសេវាធនាគារឌីជីថល
និងបច្ចេកវិទ្យាកាត
ផ្នែកសុវត្ថិភាពប្រព័ន្ធ
អ៊ីនធឺណេត
ផ្នែកប្រតិបត្តិការ
ផ្នែកអភិវឌ្ឍន៍អាជីវកម្ម
ភ្នាក់ងារទូទាត់សាច់ប្រាក់
ពាក់ព័ន្ធនឹងមូលបត្រ
បណ្តាញសាខា
ផ្នែកឥណទាន
ផ្នែកហិរញ្ញវត្ថុ
ផ្នែកសវនកម្មផ្ទៃក្នុង

ក្រុមប្រឹក្សាភិបាល

លោក យឹម លក្ខណ៍
ប្រធានក្រុមប្រឹក្សាភិបាល

លោក យឹម លក្ខណ៍ មានតួនាទីនៅក្នុងក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុនមួយចំនួន ដូចជា ប្រធានក្រុមប្រឹក្សា ធនាគារ ប៊ី.អាយ.ស៊ី (តាំងពីឆ្នាំ២០២០ ដែលបម្រើការងារនៅក្នុងក្រុមប្រឹក្សាភិបាលនៅមុនពេលនោះ) និង ក្រុមហ៊ុន BIC Insurance (តាំងពីឆ្នាំ២០១៩) ដែលក្រុមហ៊ុនទាំងពីរនេះជាក្រុមហ៊ុនមហាជនទាំងអស់ ព្រមទាំងជាប្រធានក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុន One Central Tower និងក្រុមហ៊ុន U. Property Management ដែលជាក្រុមហ៊ុនឯកជនសកម្មនៅក្នុងវិស័យអចលនទ្រព្យ ព្រមទាំងក្រុមហ៊ុនមួយចំនួនទៀតក្នុងតំណែងជាប្រធានក្រុមប្រឹក្សាភិបាល និងសមាជិកក្រុមប្រឹក្សាភិបាល។

ដោយបានបម្រើការងារនៅក្នុងប្រទេស និងមាតុប្រទេសរបស់លោកយ៉ាងខ្ជាប់ខ្ជួននៅក្នុងអំឡុងពេលយុវវ័យរបស់ខ្លួន លោក យឹម លក្ខណ៍ បានចាប់ផ្តើមបង្កើតចក្ខុវិស័យប្រកបដោយមហិច្ឆិតាសម្រាប់ប្រទេសកម្ពុជា ហើយចក្ខុវិស័យនេះត្រូវបានពង្រីកគួរឱ្យកត់សម្គាល់យ៉ាងឆាប់រហ័សនៅក្នុងដំណាក់កាលអាជីវកម្ម និងសេដ្ឋកិច្ចសកល។ នេះគឺជាចក្ខុវិស័យដែលនៅជាប់នឹងបេះដូងដែលលោកទទួលបានពីគ្រួសាររបស់លោក និងបានបង្ហាញច្បាស់លាស់មិនត្រឹមនៅក្នុងការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ និងសេវាធនាគារនៅកម្ពុជាប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងនៅក្នុងគម្រោងបឹងស្នោរដែលមានចក្ខុវិស័យយ៉ាងធំធេង ដែលជាគម្រោងអភិវឌ្ឍន៍អចលនទ្រព្យពហុគោលបំណងដោយមានទេសភាពលើកកម្ពស់កម្រិតជីវភាពរស់នៅក្នុងសហគមន៍នេះឱ្យលេចធ្លោផងដែរ។

លោក ZULKIFLEE KUAN SHUN BIN ABDULLAH
អភិបាល / នាយកប្រតិបត្តិ

បច្ចុប្បន្ន លោក ZULKIFLEE មានបទពិសោធន៍ជាង ៣០ ឆ្នាំ ផ្នែកប្រតិបត្តិការ និងគ្រប់គ្រងសេវាកម្មធនាគារ ដោយចាប់ផ្តើមពីធនាគារ Affin Bank (M) Bhd ហើយក្រោយមកទៀត លោកចូលបម្រើការងារក្នុងធនាគារធំបំផុតមួយរបស់ម៉ាឡេស៊ីគឺធនាគារ Public Bank Berhad។ ក្រៅពីប្រទេសម៉ាឡេស៊ី លោក ZULKIFLEE ក៏ធ្លាប់បម្រើការនៅធនាគារ VID Public Bank ក្នុងប្រទេសវៀតណាម នៅឆ្នាំ១៩៩៦ រហូតដល់ឆ្នាំ២០០០ ផងដែរ។ នៅក្នុងអំឡុងពេលលោកបម្រើការងារនៅក្នុងប្រទេសវៀតណាម លោកបានបម្រើការងារនៅទីក្រុងហាណូយ ទីក្រុងហូជីមិញ និងការិយាល័យក្រុងដាណាងផងដែរ។ នៅក្នុងឆ្នាំ២០០៣ លោក ZULKIFLEE បានបម្រើការងារនៅធនាគារ Public Bank Berhad សាខាទីក្រុងវៀងចន្ទ ហើយក្រោយមកទៀត នៅក្នុងឆ្នាំ២០០៨ លោកបានបង្កើតធនាគារ International Commercial Bank Lao Limited ឱ្យក្រុមហ៊ុន ICB Financial Group Holdings AG ដែលពេលនេះបានប្តូរឈ្មោះទៅជាធនាគារ BIC Bank Lao Co., Ltd។

លោក ZULKIFLEE បានបញ្ចប់ការសិក្សាថ្នាក់អនុបណ្ឌិតមកពីសាកលវិទ្យាល័យ Multimedia ប្រទេសម៉ាឡេស៊ី និងសញ្ញាបត្រផ្នែកគ្រប់គ្រងមកពី Institute of Supervisory Management ចក្រភពអង់គ្លេស។

លោកស្រី ADEL LEILANIE G. LEGARTA
អភិបាលប្រតិបត្តិ / នាយកប្រតិបត្តិអភិវឌ្ឍន៍អាជីវកម្ម

លោកស្រី ADEL បានបញ្ចប់ការសិក្សាលើមុខជំនាញគ្រប់គ្រងអាជីវកម្មពី Pontifical University of Santo Tomas ទីក្រុងម៉ានីល ប្រទេសហ្វីលីពីន។ ជាមួយនឹងបទពិសោធន៍ធនាគារ ៣០ ឆ្នាំ, លោកស្រី ADEL បានចាប់ផ្តើមអាជីពរបស់ខ្លួននៅធនាគារ Rizal Commercial Bank ក្នុងឆ្នាំ ១៩៩១។ នៅឆ្នាំ ២០០១ លោកស្រីបានមកដល់ប្រទេសកម្ពុជាហើយបានបម្រើការងារនៅធនាគារកាណាឌីយ៉ា សម្រាប់មុខតំណែងជាច្រើន ដូចជា ប្រធានផ្នែករៀបចំផែនការ ប្រធានផ្នែកទីផ្សារ Card Center និងជាប្រធានផ្នែកទំនាក់ទំនងធុរកិច្ចអន្តរជាតិ។ នៅខែឧសភា ឆ្នាំ ២០០៦ លោកស្រីក៏បានចូលរួមក្នុងការិយាល័យមេធាវី និងវិនិយោគ Sciaroni and Associates។ បន្ទាប់មក នៅខែមេសា ឆ្នាំ២០០៨ លោកស្រីបានបម្រើការងារនៅធនាគារ ABA ក្នុងមុខតំណែងគ្រប់គ្រងជាន់ខ្ពស់ជាច្រើនដូចជាប្រធានផ្នែកទីផ្សារ ប្រធានផ្នែកទំនាក់ទំនងអតិថិជន និងប្រធានសាខាធំផងដែរ។ លោកស្រីបានឈានមុខដោយជោគជ័យនូវការណែនាំសេវាកម្មផ្ទេរប្រាក់ក្រៅប្រទេសរបស់ (ធនាគារអភិវឌ្ឍន៍ហ្វីលីពីន) DBP EC-Remit ទៅកាន់ធនាគារពាណិជ្ជសម្រាប់សម្រួលដល់ប្រជាជនហ្វីលីពីនដែលរស់នៅក្នុងប្រទេសកម្ពុជាក្នុងការផ្ទេរប្រាក់ត្រឡប់មកស្រុកកំណើតវិញ។

បច្ចុប្បន្ន លោកស្រី ADEL កំពុងបម្រើការងារនៅធនាគារ ប៊ី.អាយ.ស៊ី (ខេមបូឌា) ប៊ែង ម.ក ក្នុងនាមជា នាយកប្រតិបត្តិអភិវឌ្ឍន៍អាជីវកម្ម។

លោក MC COSH JOHN EDWARD
អភិបាលឯករាជ្យ

លោក MC COSH JOHN EDWARD បានបម្រើការងារនៅសហរដ្ឋអាមេរិក អឺរ៉ុប អាហ្វ្រិក និងអាស៊ី ក្នុងតួនាទីគ្រប់គ្រង និងប្រតិបត្តិការផ្សេងៗ។ បច្ចុប្បន្នលោក JONH គឺជាអនុប្រធានផ្នែកអភិវឌ្ឍន៍របស់ក្រុមហ៊ុន BIC Group ដែលពីមុន គាត់គឺជានាយកប្រតិបត្តិរបស់ក្រុមហ៊ុន Sapparot Group និងពីមុនជាមួយនឹងក្រុមហ៊ុន Four Seasons Hotels and Resorts ដែលបានបើកអចលនទ្រព្យថ្មីៗ ដឹកនាំក្រុម និងរៀបចំនីតិវិធីប្រតិបត្តិការ និងស្តង់ដារសេវា និងផលិតផល។

លោក JONH បានបញ្ចប់ការសិក្សាថ្នាក់អនុបណ្ឌិតផ្នែកគ្រប់គ្រងធុរកិច្ចពី HEC Paris និងសាកលវិទ្យាល័យ Witwatersrand និងថ្នាក់ undergraduate degree ពីសាលា Ecole Hôtelière de Lausanne។

ក្រុមប្រឹក្សាភិបាល

លោក RUTSARAN MOONSAN
អភិបាលឯករាជ្យ

លោក RUTSARAN MOONSAN គឺជាអនុប្រធានរបស់ក្រុមហ៊ុន AIF Group ទទួលបន្ទុកផ្នែក ជួញដូរលោហៈមានតម្លៃ ផ្នែកជួញដូរទូទៅ និងក្រុមហ៊ុនបុត្រសម្ព័ន្ធចំណីអាហារ និងភេសជ្ជៈរបស់គ្រុប។ លោក RUTSARANទទួលបានបរិញ្ញាបត្រផ្នែកកសិឧស្សាហកម្មមកពី សាកលវិទ្យាល័យ Kasetsart ប្រទេសថៃ និងសញ្ញាបត្រថ្នាក់អនុបណ្ឌិតផ្នែកធុរកិច្ចអន្តរជាតិពី University of Greenwich ទីក្រុងឡុងដ៍ រួមមានទាំងវិញ្ញាបនបត្រ កិត្តិយសកម្រិតពីរផងដែរ។

មុនពេលចូលរួមបម្រើការងារជាមួយនឹងក្រុមហ៊ុន AIF Group លោក RUTSARAN ធ្លាប់មានបទពិសោធន៍បម្រើការងារជាង ៨ ឆ្នាំ ផ្នែកជួញដូរ និងសេវាធនាគារ។ នៅអំឡុងពេលបម្រើការងារក្នុងធនាគារ លោកត្រូវបានចាត់តាំងឱ្យធ្វើជាប្រធានផ្នែកទំនាក់ទំនងសម្រាប់អតិថិជនសំខាន់ៗមួយចំនួនរបស់ធនាគារ រួមទាំងប្រតិបត្តិការគណនីបង្គរដែលមានទឹកប្រាក់ជាង ១ ពាន់លានបាត ហើយអាចកើនទ្វេដងលើតម្លៃប្រតិបត្តិការគណនីក្នុងរយៈពេលតែមួយឆ្នាំទៀតផង។ ក្រោយមកទៀត លោក RUTSARAN បានចូលរួមបម្រើការងារជាមួយនឹង YLG Bullion International ហើយត្រូវបានចាត់តាំងឱ្យបង្កើតសាខាក្រុមហ៊ុននៅក្នុងប្រទេសសិង្ហបុរី និងធ្វើការជ្រើសរើសអតិថិជនអន្តរជាតិថ្មីៗ។ ដោយមានទេពកោសល្យផ្នែកទំនាក់ទំនង និងជំនាញជួញដូរលោកបានចូលរួមចំណែកជួយ YLG ឱ្យក្លាយជាក្រុមហ៊ុន Bullion Trading ដ៏ធំបំផុតមួយនៅប្រទេសថៃ។ នៅពេលចូលរួមបម្រើការងារ ជាមួយក្រុមហ៊ុន AIF Group លោក RUTSARAN បានជួយអភិវឌ្ឍក្រុមហ៊ុន AIF Gold Trading ដើម្បីឱ្យក្លាយជាក្រុមហ៊ុននាំចូលមាសធំបំផុត និងសកម្មតែមួយគត់នៅក្នុងប្រទេសឡាវ។

លោកក៏បានជួយរៀបចំឱ្យក្រុមហ៊ុន Asia Loyal ក្លាយជា ក្រុមហ៊ុនចែកចាយដែលមានភាពជោគជ័យ លើវិស័យជាច្រើន ដូចជា យានយន្ត និងសម្ភារសំណង់ និងវិស័យផ្សេងទៀតជាច្រើន។ ក្នុងការគាំទ្រអាជីវកម្មអភិវឌ្ឍន៍អចលនទ្រព្យរបស់គ្រុបនេះ លោកក៏បានផ្តួចផ្តើម និងបង្កើតក្រុមហ៊ុនបុត្រសម្ព័ន្ធចំណីអាហារ និងភេសជ្ជៈឱ្យក្រុមហ៊ុន AIF Group ផងដែរ។

បច្ចុប្បន្ន លោក RUTSARAN MOONSAN មានតួនាទីជាក្រុមប្រឹក្សាប្រតិបត្តិនៅធនាគារ BIC Bank Lao Co., Ltd និង ជាអភិបាលឯករាជ្យនៃក្រុមប្រឹក្សាភិបាលនៃធនាគារ ប៊ី.អាយ.ស៊ី (ខេមបូឌា) ប៊ែង ម.ក។

គណៈគ្រប់គ្រង

គណៈគ្រប់គ្រង

លោក អ៊ាត ចិត្រាសុវិរិវង្ស
នាយកប្រតិបត្តិបច្ចេកវិទ្យា

លោក វង្ស មានបទពិសោធន៏ជាង ១៥ ឆ្នាំ ជាមួយផ្នែកធនាគារ និងទូរគមនាគមន៍។ លោកបានចាប់ផ្តើមការងារពីឆ្នាំ ២០០៥ ក្នុងក្រុមហ៊ុនទូរគមនាគមន៍មួយ បន្ទាប់មកបានផ្លាស់តួនាទីផ្នែកបច្ចេកទេសសំខាន់ៗ នៃធនាគារកម្ពុជាសាធារណៈ បន្ទាប់មកទៀតបានកាន់តួនាទីជា ប្រធានគ្រប់គ្រងបច្ចេកទេស ជាមួយបណ្តាធនាគារក្នុងស្រុក និងធនាគារពាណិជ្ជក្នុងតំបន់ ដូចជា នាយករងប្រតិបត្តិព័ត៌មានវិទ្យា ប្រធាននាយកដ្ឋានកម្មវិធីព័ត៌មានវិទ្យា នាយកប្រតិបត្តិព័ត៌មានវិទ្យាស្តីទី នៃធនាគារស្ថាបនា ប្រធាននាយកដ្ឋានព័ត៌មានវិទ្យា នៃធនាគារហ្វីលីព ប្រធានផ្នែកព័ត៌មានវិទ្យា នៃធនាគារមេយប៊ែង និងលោកជាសហស្ថានិក ដែលបានរៀបចំហេដ្ឋារចនាសម្ព័ន្ធរបស់ប្រព័ន្ធធនាគារពាណិជ្ជចំនួនពីរនៅក្នុងប្រទេសកម្ពុជា ជាមួយនឹងមុខជំនាញសំខាន់ៗ ដូចជាការគ្រប់គ្រងកម្មវិធីស្មុគស្មាញនិងផលប័ត្រគម្រោងដែលគ្របដណ្តប់លើគ្រប់ផ្នែករបស់ព័ត៌មានវិទ្យា រួមបញ្ចូលទាំងការអភិវឌ្ឍកម្មវិធី និងការគាំទ្រសេវាកម្មហេដ្ឋារចនាសម្ព័ន្ធ សុវត្ថិភាពព័ត៌មាន ការអភិវឌ្ឍយុទ្ធសាស្រ្តបច្ចេកវិទ្យា ដំឡើងប្រព័ន្ធបច្ចេកទេសអោយស្របនឹងដំណើរការសាជីវកម្មធនាគារ ជាមួយការវិវត្តវិស័យឌីជីថល។

លោក វង្ស បានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រវិស្វករព័ត៌មានវិទ្យា នៃសកលវិទ្យាល័យន័រតុន លោកកំពុងបន្តសិក្សាថ្នាក់អនុបណ្ឌិតផ្នែកគ្រប់គ្រង ពាណិជ្ជកម្ម ពីសាលកវិទ្យាល័យ Charles Sturt នៃប្រទេសអូស្ត្រាលី។ លោកក៏បានបញ្ចប់ វគ្គបណ្តុះបណ្តាលជឿនលឿនខាងបច្ចេកវិទ្យា និង សិក្ខាសាលានៅបរទេសផ្សេងៗ ដូចជា សហរដ្ឋអាមេរិក កាណាដា ម៉ិចស៊ិកូ និង សិង្ហបុរី។

លោក វង្ស បានចាប់ផ្តើមការងារនៅធនាគារ ប៊ី.អាយ.ស៊ី (ខេមបូឌា) ប៊ែង ម.ក ជានាយកប្រតិបត្តិបច្ចេកវិទ្យា។

លោក យឹម ច័ន្ទដារ៉ា
ប្រធានគ្រប់គ្រងទូទៅ

លោក ដារ៉ា បានចូលរួមបម្រើការងារជាមួយនឹងធនាគារ ប៊ី.អាយ.ស៊ី (ខេមបូឌា) ប៊ែង ម.ក ជាប្រធានគ្រប់គ្រងជាន់ខ្ពស់។ លោកមានបទពិសោធន៍ជាង ១៤ ឆ្នាំ នៅធនាគារពាណិជ្ជចំនួនពីរ រួមមានធនាគារកាណាឌីយ៉ា ភីអិលស៊ី និងធនាគារភ្នំពេញពាណិជ្ជ។ លោកមានបទពិសោធន៍ផ្នែកគ្រប់គ្រង និងវាយតម្លៃឥណទានទំនាក់ទំនងអតិថិជនឥណទានពាណិជ្ជកម្ម សហគ្រាសធុនតូច និងមធ្យម (SME) ប្រធានគ្រប់គ្រងសាខាជាន់ខ្ពស់ និងប្រធានគ្រប់គ្រងសាខា VIP។

លោកបានបញ្ចប់ថ្នាក់បរិញ្ញាបត្រផ្នែកគណនេយ្យ នៅឆ្នាំ ២០០៥ និងថ្នាក់អនុបណ្ឌិតផ្នែកហិរញ្ញវត្ថុ នៅឆ្នាំ២០០៧ ពីសាកលវិទ្យាល័យជាតិគ្រប់គ្រង។

លោក បាន ម៉ារ៉ា
ប្រធានជាន់ខ្ពស់ ផ្នែកហិរញ្ញវត្ថុ និងរតនាគារ

លោក ម៉ារ៉ា បានចូលបម្រើការងារនៅធនាគារ ប៊ី.អាយ.ស៊ី (ខេមបូឌា) ប៊ែង ម.ក ក្នុងខែកញ្ញា ឆ្នាំ២០១៨ ជាប្រធានផ្នែកហិរញ្ញវត្ថុ។ លោកមានបទពិសោធន៍ជាង ១០ ឆ្នាំ ផ្នែកហិរញ្ញវត្ថុ នៅធនាគារពាណិជ្ជចំនួនពីរ ដូចជាធនាគារ ភ្នំពេញពាណិជ្ជ និងធនាគារ ហ្វីលីពភីអិលស៊ី។ លោកមានបទពិសោធន៍ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ពន្ធដារ ការគ្រប់គ្រងហិរញ្ញវត្ថុ ការរៀបចំថវិកា ការរៀបចំផែនការអាជីវកម្ម ហើយក៏មានបទពិសោធន៍គ្រប់គ្រងគម្រោងនានាផងដែរ រួមមានការផ្លាស់ប្តូរស្តង់ដារគណនេយ្យដោយអនុលោមតាម CIFRS និងប្រព័ន្ធស្នូលធនាគារ។

លោកបានបញ្ចប់បរិញ្ញាបត្រផ្នែកហិរញ្ញវត្ថុ និងធនាគារពីសាកលវិទ្យាល័យជាតិគ្រប់គ្រងនៅឆ្នាំ២០១០ ហើយបច្ចុប្បន្ន លោកកំពុងបន្តការសិក្សាកម្រិត ACCA នៅសាលា CamED Business School នៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

លោក Thongsavath Pranyvong
ប្រធានផ្នែកប្រតិបត្តិការ

លោក THONGSAVATH បានបញ្ចប់ការសិក្សាថ្នាក់អនុបណ្ឌិតផ្នែកការគ្រប់គ្រងធុរកិច្ច និងរដ្ឋបាល ពីសាកលវិទ្យាល័យ London School of Commerce (សាលានៅក្នុងទីក្រុងឡុងដ៍) ដែលជាសាកលវិទ្យាល័យសាខារបស់សាកលវិទ្យាល័យ Cardiff Metropolitan University ទីក្រុងឡុងដ៍ ចក្រភពអង់គ្លេស។

លោក THONGSAVATH បានចាប់ផ្តើមបម្រើការងារនៅធនាគារ BIC Bank Lao Co., Ltd ចាប់តាំងពីចុងឆ្នាំ២០១០ មកក្នុងនាមជាបុគ្គលិកបម្រើសេវាកម្មអតិថិជន និងបេឡាករ។ ចាប់តាំងពីពេលនោះមក លោកត្រូវបានដំឡើងតំណែងជាមន្ត្រីឥណទាន និងមន្ត្រីឥណទានជាន់ខ្ពស់។ ក្នុងឆ្នាំ២០១៧ លោក Thongsavath បានប្តូរតំណែងមកជាប្រធានផ្នែករតនាគារ និងប្រធានផ្នែកទំនាក់ទំនង។ ជាមួយនឹងបទពិសោធន៍ទាំងអស់របស់លោក លោកត្រូវបានជ្រើសរើសឱ្យបម្រើការងារជាប្រធានផ្នែកប្រតិបត្តិការនៅក្នុងធនាគារ ប៊ី.អាយ.ស៊ី (ខេមបូឌា) ប៊ែង ម.ក ចាប់តាំងពីឆ្នាំ២០១៩ រហូតមកដល់ពេលបច្ចុប្បន្ននេះ។

គណៈគ្រប់គ្រង

លោក យុន វ៉េត
ប្រធានផ្នែកធនធានមនុស្ស និងរដ្ឋបាល

លោក វ៉េត បានបញ្ចប់បរិញ្ញាបត្រ ផ្នែកអក្សរសាស្ត្រអង់គ្លេស ពីសាកលវិទ្យាល័យភ្នំពេញអន្តរជាតិ (PPIU) នៅឆ្នាំ២០១០ និងបានបញ្ចប់ថ្នាក់អនុបណ្ឌិត ផ្នែករដ្ឋបាលអាជីវកម្ម (MBA) នៅសាកលវិទ្យាល័យន័រតុននៅឆ្នាំ២០១៦។

ដោយសារតែការប្តេជ្ញាចិត្ត និងការចូលចិត្តរបស់ខ្លួន លោក វ៉េត បានវិវត្តការងាររបស់ខ្លួនពីជំនួយការរដ្ឋបាល នៅសាកលវិទ្យាល័យខ្លួន ទៅជាមន្ត្រីរដ្ឋបាលនៅធនាគារភ្នំពេញពាណិជ្ជ ជាមន្ត្រីប្រតិបត្តិរដ្ឋបាលជាន់ខ្ពស់ នៅធនាគារហ្វីលីព ភីអិលស៊ី បន្ទាប់មកត្រូវបានដំឡើងតួនាទីជា ប្រធានរដ្ឋបាលនៅក្នុងរយៈពេល ៧ ឆ្នាំ។ លោកមានបទពិសោធន៍ជាង១០ ឆ្នាំជាមួយធនាគារពាណិជ្ជនៅក្នុងផ្នែកជំនាញរបស់គាត់។

លោក វ៉េត បានចូលរួមបម្រើការងារជាមួយនឹងធនាគារ ប៊ី.អាយ.ស៊ី (ខេមបូឌា) ប៊ែង ម.ក ជាប្រធានផ្នែកធនធានមនុស្ស និងរដ្ឋបាល។

លោក ហុង ប៊ុនថ្ងៃ
ប្រធានផ្នែកសវនកម្មផ្ទៃក្នុង

លោក ប៊ុនថ្ងៃ ចូលបម្រើការងារនៅក្នុងធនាគារ ប៊ី.អាយ.ស៊ី (ខេមបូឌា) ប៊ែង ម.ក ក្នុងតំណែងជាប្រធានផ្នែកសវនកម្មផ្ទៃក្នុង ក្នុងខែកញ្ញា ឆ្នាំ២០១៩។ លោកមានបទពិសោធន៍រហូតដល់ទៅ ៨ ឆ្នាំលើការងារសវនកម្មផ្ទៃក្នុង និងខាងក្រៅ នៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុ និងធនាគារ អង្គការមិនមែនរដ្ឋាភិបាល និងក្រុមហ៊ុនក្នុងប្រទេស និងអន្តរជាតិ។ ជំនាញឯកទេសរបស់លោកគឺពាក់ព័ន្ធនឹងការត្រួតពិនិត្យ វាយតម្លៃ និងផ្តល់យោបល់លើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង គ្រប់គ្រងហានិភ័យ អភិបាលកិច្ចក្រុមហ៊ុន និងការស៊ើបអង្កេតការក្លែងបន្លំ/ការប្រព្រឹត្តិមិនត្រឹមត្រូវនៅក្នុងស្ថាប័ន។

មុនពេលចូលរួមជាមួយធនាគារ ប៊ី.អាយ.ស៊ី (ខេមបូឌា) ប៊ែង ម.ក លោកធ្លាប់បានកាន់តំណែងជាច្រើនដូចជាជំនួយការសវនកម្មក្នុងក្រុមហ៊ុន KPMG Cambodia Ltd ប្រធានគ្រប់គ្រងសវនកម្មផ្ទៃក្នុងនៅធនាគារ ABA និងតួនាទីថ្នាក់គ្រប់គ្រងផ្សេងៗទៀត។ លោកប៊ុនថ្ងៃ បានបញ្ចប់បរិញ្ញាបត្រផ្នែកគណនេយ្យពីសាកលវិទ្យាល័យជាតិគ្រប់គ្រង (NUM) និងបរិញ្ញាបត្រផ្នែកទំនាក់ទំនងអន្តរជាតិ (សេដ្ឋកិច្ចអន្តរជាតិ) ពីវិទ្យាស្ថានភាសាបរទេស (IFL)។ លោកទើបតែបានបញ្ចប់ បរិញ្ញាបត្រជាន់ខ្ពស់ធុរកិច្ច ឯកទេសហិរញ្ញវត្ថុ ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងកំពុងបន្តការសិក្សាថ្នាក់សញ្ញាបត្រ ACCA ពីសាលា CamEd Business School។ លើសពីនេះ លោកមានវិញ្ញាបនបត្រវិជ្ជាជីវៈជាច្រើនពីស្ថានប័ន និងគ្រឹះស្ថានវិជ្ជាជីវៈក្នុងប្រទេស និងក្រៅប្រទេសផងដែរ ដូចជា KPMG, CIF, IIA, IBF KHR, IBF SG, CEB ជាដើម។

លោក ទែន និមល
អនុប្រធានគ្រប់គ្រងហានិភ័យ និងប្រតិបត្តិតាម

លោក ទែន និមល មានបទពិសោធន៍ការងារលើវិស័យផ្សេងគ្នាជាង១០ឆ្នាំ ដូចជាវិស័យអង្គការក្រៅរដ្ឋាភិបាល វិស័យធនាគារ និងវិស័យធានារ៉ាប់រងជាដើម។ លោក កំពុងបម្រើការងារនៅធនាគារ ប៊ី.អាយ.ស៊ី (ខេមបូឌា) ប៊ែង ម.ក ក្នុងតួនាទីជា អនុប្រធានគ្រប់គ្រងហានិភ័យ និងប្រតិបត្តិតាម ហើយមុខងារសំខាន់របស់លោក គឺដឹកនាំនាយកដ្ឋានហានិភ័យ និងប្រតិបត្តិតាមទាំងមូល។ មុនពេលចាប់ផ្តើមការងារជាមួយធនាគារប៊ីអាយស៊ី លោកបានបម្រើការងារនៅក្រុមហ៊ុន អេច.អាយ ម៉ាយក្រូ-អ៊ិនសួរេន ម.ក ក្នុងមុខតំណែងជា ប្រធានគ្រប់គ្រងហានិភ័យ និងប្រតិបត្តិតាម និងជាប្រធានប្រតិបត្តិតាម នៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហ្វាមីលី ម.ក ព្រមទាំងជាមន្ត្រីជាន់ខ្ពស់ផ្នែកនីតិកម្ម និងប្រតិបត្តិតាម នៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រសិទ្ធភាព ហ្វាយនែន ភីអិលស៊ី។

មុនពេលលោក ទែន និមល ចាប់បម្រើការងារក្នុងវិស័យហិរញ្ញវត្ថុ លោកបានទទួលបទពិសោធន៍ការងារសង្គមមួយចំនួនក្នុងវិស័យអង្គការក្រៅរដ្ឋាភិបាល។ លោកបានបម្រើការងារនៅអង្គការ ហាហ្គា កម្ពុជា ក្នុងតួនាទីជាមន្ត្រីបណ្តុះបណ្តាលវិជ្ជាជីវៈ ហើយនៅអង្គការ មជ្ឈមណ្ឌលសហសង្គ្រោះកម្ពុជា ក្នុងតួនាទីជា មន្ត្រីគម្រោង និងគាំពារសហគមន៍។ ហើយលោកក៏ធ្លាប់ធ្វើការងារស្ម័គ្រចិត្តនៅការិយាល័យមេធាវី ដឹ យី ជាជំនួយការមេធាវី និងជាសមាជិកសមាគមអ្នកច្បាប់នៅទីនោះផងដែរ។

លោក ទែន និមល បានបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ (អនុបណ្ឌិត) នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ផ្នែកនីតិឯកជន ក្នុងឆ្នាំ ២០១៨ ហើយលោកក៏បានបញ្ចប់ថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ នៅសាកលវិទ្យាល័យជាតិគ្រប់គ្រង ក្នុងឆ្នាំ២០១៦ និងបានបញ្ចប់ថ្នាក់បរិញ្ញាបត្រផ្នែកអក្សរសាស្ត្រអង់គ្លេស នៅវិទ្យាស្ថានអភិវឌ្ឍន៍អាស៊ីសច្ច:ក្នុងឆ្នាំ២០១៤។

ព័ត៌មានហិរញ្ញវត្ថុសង្ខេប

	ឆ្នាំហិរញ្ញវត្ថុ ២០២០	ឆ្នាំហិរញ្ញវត្ថុ ២០១៩
លទ្ធផលប្រតិបត្តិការ (០០០ ដុល្លារអាមេរិក)		
ចំណូលប្រតិបត្តិ	៧,៤៩៦	៥,៥៤៨
ចំណេញ / (ខាត) មុនបង់ពន្ធ	៥៩២	១,៤៦៦
ចំណេញ / (ខាត) សុទ្ធសម្រាប់ឆ្នាំ	៤៣៩	១,១៣៩
ទិន្នន័យតារាងតុល្យការគន្លឹះ (០០០ ដុល្លារអាមេរិក)		
ទ្រព្យសកម្មសរុប	២៦៨,៩៨១	១៩៧,៩១៣
ឥណទាន និងបុរេប្រទានដល់អតិថិជន	៧៤,៦៣៥	៦៧,៧៧១
ទ្រព្យអសកម្មសរុប	១៩៣,២៧៧	១២២,៦៤៨
ប្រាក់បញ្ញើរបស់ធនាគារ និងអតិថិជន	១៩០,០៦០	១២០,២៣៧
មូលធនភាគទុនិក	៧៥,០០០	៧៥,០០០
ទ្រព្យម្ចាស់របស់ភាគទុនិក	៧៥,៧០៥	៧៥,២៦៥
អនុបាតហិរញ្ញវត្ថុ (%)		
ផលលើទ្រព្យសកម្ម (ROA)	០.១៦%	១.០០%
ផលលើមូលធន (ROE)	០.៥៨%	២.០០%
អនុបាតសាច់ប្រាក់ងាយស្រួល	១៦៨%	១១១៣%
អនុបាតឥណទានធៀបនឹងប្រាក់បញ្ញើ	៤២%	៥៧%
អនុបាតឥណទានមិនដំណើរការធៀបនឹងឥណទានសរុប	0%	0%
ការគ្រប់គ្រងទុន		
អនុបាតសោធនភាព (%)	៣៩%	៤៦%

ព័ត៌មានសំខាន់ៗអំពីអាជីវកម្ម គោលដៅសំខាន់ៗ

2018-2019

- ទីស្នាក់ការកណ្ដាល (សាខាព្រះមុនីវង្ស)
- សាខាខេត្តព្រះសីហនុ
- ដំណើរការ ATMs
- កម្មវិធី BIC Value Loyalty Program

2020

- សេវាធនាគារចល័ត BIC Mobile version 1 (Retail MB)
- សេវាធនាគារតាមអ៊ីនធឺណេត BIC Online version 1 (Retail IB)
- BIC Pay តាមរយៈ BIC QR
- ដកប្រាក់ដោយមិនប្រើកាត នៅតាម ATMs
- បណ្ដាញសង្គមផ្លូវការរបស់ធនាគារ ប៊ី.អាយ.ស៊ី

2021

Q1

- សេវាធនាគារចល័ត BIC Mobile Version 2 (Personalized & Split Bill feature)
- សាខាទួលគោក
- ផ្នែកបម្រើសេវាអតិថិជន (Customer Care)
- ATM CSS
- Premium Banking

Q2

- សេវាធនាគារតាមអ៊ីនធឺណេត BIC Online Version 2
- មុខងារ បញ្ចូលលុយទូរស័ព្ទតាមរយៈ BIC Mobile & Online
- បង់វិកយបត្រសម្រាមតាមរយៈ ធនាគារ ACLEDA
- សេវាធនាគារតាមរយៈបណ្ដាញសង្គម (Telegram)
- Temenos go-live

Q3

- ការទូទាត់តាម បាគង នៃធនាគារជាតិនៃកម្ពុជា
- ការផ្ទេរប្រាក់ Realtime Fund Transfer (RFT) នៃធនាគារជាតិនៃកម្ពុជា
- BIC Corporate Banking
- MasterCard Acquiring & E-Commerce
- MasterCard (Debit & Credit)
- ការធ្វើឲ្យប្រសើរឡើងនៃសេវាផ្ទេរប្រាក់ក្រៅប្រទេស DBP Remittance
- សាខាមហាវិថីព្រះសីហនុ

Q4

- ដំណើរការលក្ខណៈពិសេស តួយ៉ាងដូចជា block card, activate, pin change of MasterCard on BIC Mobile
- MasterCard និមិត្ត
- សេវាធនាគារតាមរយៈបណ្ដាញសង្គម (WhatsApp/Facebook Messenger)
- គណនីសន្សំ Smart Savings Account

លទ្ធផលប្រចាំឆ្នាំ២០២០

ឆ្នាំ២០២០ គឺជាឆ្នាំដែលកើតមានបញ្ហាប្រឈមនៅទូទាំងសាកលលោក ដោយស្ថិតនៅក្នុងដំណាក់កាលដ៏លំបាកនេះ ធនាគារ ប៊ី.អាយ.ស៊ី (ខេមបូឌា) ប៊ែង ម.ក រក្សាបាននូវលទ្ធផលការងារដ៏ល្អប្រសើរ ដោយស្ថានភាពមូលធន និងសន្ទនីយភាពមានភាពរឹងមាំ ដែលបានផ្តល់នូវមូលដ្ឋានដ៏រឹងមាំសម្រាប់ការរីកចម្រើន និងការអភិវឌ្ឍ។

ធនាគារទទួលបានកំណើនយ៉ាងខ្លាំងទៅលើប្រាក់បញ្ញើ ឥណទាន និងការបើកគណនី។ ការអភិវឌ្ឍផ្នែកធនគារអនឡាញក្នុងផ្នែកមុខងារសុវត្ថិភាពបានផ្តល់នូវភាពប្រកួតប្រជែង។ ការស្ថិតនៅក្នុងបណ្តាញឌីជីថលផ្សេងៗបានទទួលការយល់ដឹងកាន់តែច្រើនពីសាធារណៈជន ហើយការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធព័ត៌មានវិទ្យាបានត្រួសត្រាយផ្លូវឱ្យធនាគារមានឱកាសចាប់យកចំណែកទីផ្សារកាន់តែធំ។ លទ្ធផលសម្រេចបានរបស់យើងសម្រាប់ឆ្នាំ២០២០ គឺទទួលបានដោយសារការប្តេជ្ញាចិត្តពីសំណាក់ថ្នាក់គ្រប់គ្រង និងបុគ្គលិករបស់យើងដែលខិតខំផ្តល់សេវាដល់អតិថិជនដោយស្ម័គ្រស្មោះអស់ពីចិត្ត។

ធនាគារ ប៊ី.អាយ.ស៊ី (ខេមបូឌា) ប៊ែង ម.ក បានទទួលជោគជ័យក្នុងការរៀបចំម៉ាកសញ្ញាថ្មី។ មុខមាត់ថ្មីរបស់ធនាគារបានរួមចំណែកយ៉ាងធំធេងនៅក្នុងការកសាងទំនុកចិត្ត និងភាពជឿជាក់សម្រាប់អតិថិជនបច្ចុប្បន្ន និងអនាគតរបស់ខ្លួន។

ឥណទាន

៧៤,៦៤ លានដុល្លារ

ដោយសារសេដ្ឋកិច្ចទទួលរងនូវផលប៉ះពាល់នៃជំងឺរាតត្បាត ធនាគារបានអនុវត្តគោលនយោបាយផ្តល់ឥណទានបែបអភិរក្សចាប់តាំងពីការពិនិត្យពាក្យស្នើសុំឥណទាន រហូតទៅដល់ការផ្តល់ឥណទានដើម្បីកាត់បន្ថយនូវហានិភ័យផ្សេងៗ។ ដោយសារនៅក្នុងទីផ្សារនៅតែមានតម្រូវការឥណទាន ផលបត្រឥណទានរបស់ធានាបានកើនឡើងដល់ ៧៤,៦៤ លានដុល្លារ ដោយផ្តល់ជូនអតិថិជនរបស់យើងនូវលក្ខខណ្ឌដែលមានភាពទាក់ទាញ និងភាពប្រកួតប្រជែងសម្រាប់ផលិតផល និងសេវាកម្មរបស់យើង។

ប្រាក់បញ្ញើ

១៩០,០៦ លានដុល្លារ

កំណើនប្រាក់បញ្ញើទទួលបានជាចម្បងពីគណនីបញ្ញើសន្សំ គណនីចរន្ត និងគណនីបញ្ញើមានកាលកំណត់។ ប្រាក់បញ្ញើបានកើនឡើងដល់ ១៩០,០៦ លានដុល្លារអាមេរិក នៅក្នុងឆ្នាំ២០២០។ កត្តាចម្បងដែលនាំឱ្យប្រាក់បញ្ញើកើនឡើងគឺ កំណើន និងការបង្កើនល្បឿនការផ្តត់ផ្គង់សាច់ប្រាក់កាន់តែខ្ពស់នៅក្នុងប្រាក់បញ្ញើរបស់ម្ចាស់គណនីបុគ្គល។ យើងក៏បានពង្រឹងសេវាអតិថិជនរបស់យើងដោយផ្តល់នូវអត្រាការប្រាក់ទាក់ទាញ លក្ខខណ្ឌមានលក្ខណៈប្រកួតប្រជែង ដែលធ្វើឱ្យយើងទទួលបាននូវភាពស្មោះស្ម័គ្រពីអតិថិជន។

ការរីកចម្រើន
និងការអភិវឌ្ឍ

ការជំរុញការយកចិត្តទុកដាក់ចំពោះអតិថិជន

យើងត្រូវបង្កើន និងរក្សាការយកចិត្តទុកដាក់ចំពោះអតិថិជន

យើងផ្តល់នូវការរីកចម្រើនប្រកបដោយទំនួលខុសត្រូវ ដោយយកចិត្តទុកដាក់ចំពោះអតិថិជនរបស់យើង និងតម្រូវការរបស់ពួកគាត់នៅក្នុងការរក្សាស្ថានភាពហិរញ្ញវត្ថុរបស់ខ្លួន។ រាល់ការរីកចម្រើនរបស់យើងមានភាពរលូន។ យើងមើលឃើញលទ្ធផលពីការយកចិត្តទុកដាក់ចំពោះអតិថិជននៅក្នុងផ្នែកជាច្រើន ដោយពិន្ទុភាពពេញចិត្តរបស់អតិថិជននៅតែមានកម្រិតខ្ពស់នៅគ្រប់ពេលវេលាទាំងអស់។ ម៉ាកសញ្ញារបស់យើងនៅតែមានភាពរឹងមាំ និងនៅតែមានលទ្ធភាពទាក់ទាញអតិថិជនថ្មី ហើយអ្វីដែលសំខាន់ អតិថិជនបច្ចុប្បន្នរបស់យើងនៅតែបន្តប្រើប្រាស់សេវារបស់យើងជាច្រើនថែមទៀត ដែលមានន័យថា យើងបានផ្តល់សេវាដ៏ល្អដល់ពួកគាត់។

ការកសាងបន្ថែមទៅលើចំណុចខ្លាំងរបស់យើង

នៅក្នុងរូបភាពជាច្រើន ការឆ្លើយតបចំពោះបញ្ហាប្រឈមនៃឆ្នាំ២០២០ បានបង្ហាញអំពីភាពដ៏រឹងមាំរបស់ ធនាគារ ប៊ី.អាយ.ស៊ី (ខេមបូឌា) ប៊ែង ម.ក។ ចំណុចខ្លាំងដ៏ចម្បងរបស់ធនាគារ ប៊ី.អាយ.ស៊ី (ខេមបូឌា) ប៊ែង ម.ក គឺជា, និងនៅតែ, ជាសហការីដែលមានការប្តេជ្ញាចិត្តខ្ពស់ដែលខិតខំផ្តល់សេវាដល់អតិថិជនដោយមិនចេះនឿយហត់។ សហការីរបស់យើងគឺជាកត្តាចម្បងដែលធានាថាធនាគារ ប៊ី.អាយ.ស៊ី (ខេមបូឌា) ប៊ែង ម.ក អាចសម្រេចបំណងប្រាថ្នារបស់ខ្លួនក្នុងការក្លាយទៅជាដៃគូដ៏ល្អបំផុត តាមរយៈការផ្តល់សេវាបុគ្គលដែលល្អប្រសើរបំផុតទៅតាមតម្រូវការរបស់អតិថិជនម្នាក់ៗ និងការផ្តល់នូវផលិតផល និងដំណោះស្រាយប្រកបដោយភាពច្នៃប្រឌិតដោយប្រើបច្ចេកវិទ្យាទំនើប ដើម្បីបំពេញតម្រូវការ និងការរំពឹងទុករបស់អតិថិជន។ ធនាគារផ្តោតការយកចិត្តទាំងស្រុងទៅលើអតិថិជនរបស់ខ្លួន។

យើងបង្កើតផលិតផល និងសេវាដែលបំពេញតម្រូវការរបស់អ្នក

ធនាគារ ប៊ី.អាយ.ស៊ី (ខេមបូឌា) ប៊ែង ម.ក ផ្តល់ជូននូវកញ្ចប់ផលិតផល និងសេវាធនាគារពេញលេញសម្រាប់ទាំងអតិថិជនទូទៅ និងអតិថិជនដែលជាក្រុមហ៊ុន។ ដោយសារតម្រូវការ និងការរំពឹងទុករបស់អតិថិជនមានការប្រែប្រួល យើងបង្កើតនូវផលិតផលដែលផ្តល់នូវអត្ថប្រយោជន៍ទាំងសម្រាប់ធនាគារ និងអតិថិជន។

យើងបានបង្កើត BIC Value ដើម្បីពង្រីកការប្តេជ្ញាចិត្តរបស់យើងនៅក្នុងការកសាងបទពិសោធន៍ល្អៗជូនអតិថិជន។ នៅក្នុងចំនួន ១១០ ហើយចំនួននឹងនៅតែបន្តកើនឡើងនៃដៃគូសហការដែលជាក្រុមហ៊ុនចម្រុះ អតិថិជនរបស់យើងអាចទទួលបានបុព្វសិទ្ធិ និងការបញ្ចុះថ្លៃពិសេសតាមរយៈការបង្ហាញប័ណ្ណធនាគារ ប៊ី.អាយ.ស៊ី (ខេមបូឌា) ប៊ែង ម.ក ដល់ដៃគូសហការ។

ការវិនិយោគទៅលើ សេវាធនាគារលំដាប់ខ្ពស់ (Premium Banking Lounge) នៅក្នុងពេលឆាប់ៗខាងមុខនេះ ដើម្បីបើកបណ្តាញសាខា ដែលមានអ្នកគ្រប់គ្រងផ្នែកទំនាក់ទំនង និងអ្នកជំនាញផ្តល់ឥណទាននឹងកាន់តែមានភាពងាយស្រួលសម្រាប់អតិថិជនដែលមានទ្រព្យសម្បត្តិច្រើន នៅក្នុងការភ្ជាប់ជាមួយផលិតផល និងសេវាទាំងអស់របស់យើង។

ធនាគារបានវិនិយោគទៅលើបច្ចេកវិទ្យា ដែលផ្តល់នូវសេវាធានាគារតាមទូរស័ព្ទ និងតាមអ៊ីនធឺណិតដែលងាយស្រួលសម្រាប់អ្នកប្រើប្រាស់ និងមានសុវត្ថិភាព។ នៅឆ្នាំនេះ ធនាគារក៏នឹងបង្កើតសេវាធនាគារតាមអ៊ីនធឺណេត (Corporate Online Banking) ដើម្បីផ្តល់សេវាដល់អតិថិជនដែលជាក្រុមហ៊ុនផងដែរ។ សេវាធនាគារឌីជីថលមានសារៈសំខាន់ ដោយសារឥរិយាបថរបស់អតិថិជននៅក្នុងការប្រើប្រាស់សេវាធនាគារក៏មានការប្រែប្រួលជាបន្តបន្ទាប់ផងដែរ។

យើងយកចិត្តទុកដាក់ខ្ពស់ចំពោះអតិថិជនរបស់យើង យើងខិតខំផ្តល់សេវាដែលផ្តល់នូវកម្រិតពេញចិត្តខ្ពស់បំផុតសម្រាប់អតិថិជន ដោយយើងយកចិត្តទុកដាក់ក្នុងការតាមដាននូវកម្រិតពេញចិត្តរបស់អតិថិជន និងខិតខំធ្វើការកែលម្អជាបន្តបន្ទាប់ដើម្បីធ្វើឱ្យអតិថជនរបស់យើងកាន់តែមានភាពស្មោះស្ម័គ្រ ហើយចុងក្រោយធ្វើឱ្យពួកគាត់ក្លាយជាអ្នកផ្សព្វផ្សាយម៉ាកសញ្ញារបស់យើង។

ការអភិវឌ្ឍនិយោជិត

ធនាគារ ប៊ី.អាយ.ស៊ី (ខេមបូឌា) ប៊ែង ម.ក បានចាប់ផ្តើមប្រតិបត្តិការរបស់ខ្លួនតាំងពីខែសីហា ឆ្នាំ២០១៨ ដោយមានបុគ្គលិកចំនួន ២៦ នាក់ ហើយនៅក្នុងឆ្នាំ២០២០បុគ្គលិករបស់យើងបានកើនឡើងដល់ ៩៤ នាក់។

ក្នុងនាមជាធនាគារថ្មីមួយ យើងបានផ្តល់ការសិក្សារៀនសូត្រ ការបណ្តុះបណ្តាល និងឱកាសអភិវឌ្ឍន៍ជាច្រើនទាំងនៅក្នុងធនាគារ និងនៅស្ថាប័នខាងក្រៅផងដែរ ដើម្បីគាំទ្រដល់គ្រប់ដំណាក់កាលនៃដំណើរការអភិវឌ្ឍខ្លួនទាំងអស់ សម្រាប់ទាំងបុគ្គលិកថ្មី និងបុគ្គលិកចាស់របស់យើង។ កម្មវិធីចល័តបុគ្គលិកគឺជា កម្មវិធីមួយនៅក្នុងចំណោមវិធីសាស្ត្ររបស់យើងក្នុងការអភិវឌ្ឍ និងផ្តល់ឱកាសដល់បុគ្គលិកមានសក្តានុពលម្នាក់ៗ ដែលមានបំណងបង្កើនទេពកោសល្យ និងជោគវាសនាអនាគតរបស់ខ្លួន។

ការអភិវឌ្ឍនិយោជិតត្រូវបានទទួលស្គាល់ស្ទើរតែជុំវិញពិភពលោកថាជា ឧបករណ៍យុទ្ធសាស្ត្រសម្រាប់ធានាដល់និរន្តរភាពនៃការរីកចម្រើន ផលិតភាព និងលទ្ធភាពរបស់ធនាគារនៅក្នុងការរក្សានិយោជិតដែលមានគុណវុឌ្ឍិខ្ពស់។

ការបណ្តុះបណ្តាល និងការបង្រៀនបុគ្គលិកនូវជំនាញផ្សេងពីការងាររបស់ខ្លួនធ្វើឱ្យបុគ្គលិកកាន់តែមានបទពិសោធន៍ និងជំនាញ ដោយផ្តល់ជូនបុគ្គលិកនូវមតិយោបល់ និងការណែនាំដើម្បីជួយឱ្យពួកគាត់ទទួលបាននូវជំនាញថ្មីៗ បង្កើនលទ្ធផលការងារ ក៏ដូចជាលើកកម្ពស់អាជីពរបស់គាត់ផងដែរ។

ការផ្តល់ផលិតផល និងសេវាកម្មហិរញ្ញវត្ថុងាយស្រួល និងមានទំនុកចិត្តដល់អតិថិជនរបស់យើងអាចសម្រេចបាន លុះត្រាតែធនាគាររបស់យើងមានធនធានមនុស្សដែលពោរពេញដោយទេពកោលស្យធ្វើការជាមួយយើង។ យើងសូមស្វាគមន៍ និងលើកទឹកចិត្តដល់បុគ្គលិកវ័យក្មេង និងបុគ្គលិកមានទេពកោសល្យ ដែលមានបំណងបង្កើនចំណេះដឹង និងបន្តរៀនសូត្រចំណេះដឹងថ្មីៗ ជាមួយយើងដើម្បីស្វែងយល់ និងបំពេញតម្រូវការរបស់អតិថិជន ព្រមទាំងគាំទ្រ និងជួយគ្នា ទៅវិញទៅមក។

ការបន្តកិច្ចខិតខំប្រឹងប្រែងរបស់យើងក្នុងការផ្តល់ឱកាសជាច្រើនសម្រាប់វឌ្ឍនភាពការងារ ដោយយល់ដឹងថា បុគ្គលិកគឺជា ទ្រព្យសកម្មដើម្បីសម្រេចនូវទស្សនវិស័យរបស់ធនាគារ ធនាគារខិតខំធ្វើការទាក់ទាញ និងជ្រើសរើសបេក្ខជន ដែលមានភាពជឿជាក់ ឥរិយាបថ និង កម្រិតបទពិសោធន៍ត្រឹមត្រូវ ដែលធនាគារត្រូវការដើម្បីសម្រេចបានជោគជ័យរបស់ខ្លួន។ ធនាគារជឿជាក់ថា ក្របខណ្ឌអភិវឌ្ឍន៍ធនធានមនុស្ស ដែលអាចជួយបុគ្គលិកក្នុងការ អភិវឌ្ឍជំនាញ ចំណេះដឹង និងសមត្ថភាពផ្ទាល់ខ្លួន និងធនាគារ គឺជាកត្តាដ៏សំខាន់ក្នុងការអភិវឌ្ឍធនធានមនុស្ស ដែលអាចសម្រេចបាននូវគោលដៅរបស់ធនាគារប្រកបដោយភាពជោគជ័យ។

ការធ្វើទំនើបកម្មហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យា និងសុវត្ថិភាពប្រព័ន្ធអ៊ីនធឺណិត



ធនាគារ ប៊ី.អាយ.ស៊ី (ខេមបូឌា) ប៊ែង ម.ក ប្តេជ្ញាកសាងហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មានប្រកបដោយចីរភាព ដើម្បីដោះស្រាយបញ្ហាប្រឈមនាពេលបច្ចុប្បន្ន និងអនាគត។ ហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មាន គឺជាចំណុចស្នូលនៃបណ្តាញទាំងមូលរបស់ធនាគារ ព្រមទាំងមានគ្រប់ប្រព័ន្ធ និងព័ត៌មានដែលគាំទ្រដល់ការគ្រប់គ្រង ភាពអាចប្រើប្រាស់បាននៃទិន្នន័យ និងព័ត៌មាន ក៏ដូចជាមូលដ្ឋានគ្រឹះសម្រាប់សេវាឌីជីថល និងសេវាធម្មតារបស់ធនាគារ ប៊ី.អាយ.ស៊ី (ខេមបូឌា) ប៊ែង ម.ក ផងដែរ។ បរិក្ខារព័ត៌មានវិទ្យាផ្សេងៗ ដូចជាម៉ាស៊ីនមេ កន្លែងផ្ទុកទិន្នន័យ និងឧបករណ៍ភ្ជាប់បណ្តាញត្រូវបានរក្សាទុកនៅក្នុងទិន្នន័យចុងក្រោយបង្អស់របស់ Smart Data Center, Vertiv SmartRow ដែលជាមជ្ឈមណ្ឌលទិន្នន័យត្រូវបានបញ្ចូលគ្នាពេញលេញ។ ធនាគារបានធ្វើការអភិវឌ្ឍសមត្ថភាពប្រព័ន្ធបច្ចេកវិទ្យាដើម្បីបង្កើនរយៈពេលប្រតិបត្តិការ និងសុវត្ថិភាពបណ្តាញផងដែរ។ ជាងនេះទៅទៀតធនាគារកំពុងអនុវត្តតាមគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជាស្តីពីការគ្រប់គ្រងហានិភ័យបច្ចេកវិទ្យា។

សុវត្ថិភាពប្រព័ន្ធអ៊ីនធឺណិតគឺជាចំណុចអាទិភាពមួយរបស់ធនាគារ ដោយធនាគារបានធ្វើការបណ្តុះបណ្តាលដើម្បីលើកកម្ពស់ការយល់ដឹង និងការធ្វើតេស្តអំពីប្រសិទ្ធភាពដល់បុគ្គលិកទាំងអស់ដែលធ្វើការងារពីនៅផ្នែកជួរមុខ ដល់ការិយាល័យក្រោយ។ ធនាគារក៏បានដាក់ឱ្យអនុវត្តកម្មវិធីយល់ដឹងសម្រាប់អតិថិជនតាមរយៈបណ្តាញសង្គមដើម្បីឱ្យពួកគាត់មានការយល់ដឹងអំពីរបៀបការពារខ្លួនពីការបោកប្រាស់តាមប្រព័ន្ធអ៊ីនធឺណេត។ ធនាគារបានដាក់ឱ្យប្រើប្រាស់កម្មវិធី Firewall នៅលើបណ្តាញដ៏រឹងមាំ (strong network based firewalls) ព្រមទាំងកម្មវិធី Firewall នៅលើកម្មវិធីវេបសាយត៍ (web application based firewalls) ផងដែរដើម្បីតាមដាន និងធានាសុវត្ថិភាពរាល់ប្រតិបត្តិការទាំងអស់នៅក្នុងបណ្តាញរបស់ធនាគារ។

ជាការឆ្លើយតបចំពោះការវិវត្តផ្នែកឌីជីថល ធនាគារ ប៊ី.អាយ.ស៊ី (ខេមបូឌា) ប៊ែង ម.ក បាននិងកំពុងអនុវត្តប្រព័ន្ធធនាគារស្នូលឌីជីថល Temenos ដើម្បីសម្រួលដល់ការធ្វើសមាហរណកម្មដោយរលូនជាមួយនឹងកម្មវិធីទូទាំងធនាគារនៃបរិក្ខារបច្ចុប្បន្ន financial switches delivery channels ហើយក៏ផ្តល់ដំណើរការជួរក្រោយរឹងមាំដើម្បីធ្វើយ៉ាងណាឱ្យសេវាជួរមុខមានប្រសិទ្ធភាពខ្ពស់ ល្អប្រសើរ ឆាប់រហ័ស និងចំគោលដៅ ដើម្បីឱ្យអតិថិជនទទួលបានបទពិសោធន៍ល្អក្នុងការប្រើប្រាស់សេវា និងផ្តល់លទ្ធភាពឱ្យធនាគារអាចដាក់ឱ្យប្រើប្រាស់ផលិតផល និងសេវាថ្មីៗសម្រាប់អតិថជនប្រកបដោយប្រសិទ្ធភាពផងដែរ។

សេវាធនាគារឌីជីថល

ធនាគារបានធ្វើការកែលម្អកម្មវិធី BIC Mobile ដែលផ្តល់នូវពិភពងាយស្រួលថ្មីសម្រាប់អតិថិជន ដោយនឹងមានការបញ្ចូលមុខងារពិសេសៗ បន្ថែមទៀតនៅក្នុងឆ្នាំ២០២១ ដូចជា បញ្ចូលលុយទូរស័ព្ទ, ការដកប្រាក់ដោយមិនប្រើកាត, បង់វិក្កយបត្រ, Control & Review the Finance Transaction Setting នៅក្នុងកម្មវិធីនោះតែម្តង និងសេវាផ្សេងៗទៀត ដោយធានានូវសុវត្ថិភាពឈានមុនគេនៅក្នុងទីផ្សារ។

បច្ចុប្បន្ន អតិថិជនអាចធ្វើការដកប្រាក់នៅទូទាំងប្រទេសតាមរយៈសមាជិក CSS របស់យើងនៅក្នុងប្រទេសកម្ពុជា ហើយធនាគារបាន និងកំពុងអនុវត្តប្រព័ន្ធ Card Management System, CompassPlus ដើម្បីគាំទ្រដល់សេវាប័ណ្ណឥណទាន ដើម្បីឱ្យមុខងារ MasterCard អាចបំពេញតម្រូវការរបស់អតិថជនមានទ្រព្យធនច្រើនដែលចូលចិត្តប្រណីតភាព និងកិត្យានុភាពដើម្បីទទួលបានរបៀបរស់នៅដែលខ្លួនចូលចិត្ត។

ធនាគារបានបង្កើតទំព័របណ្តាញសង្គមផ្លូវការមួយចំនួន ដូចជា Facebook, LinkedIn, Instagram និង Telegram ដែលជាបណ្តាញសម្រាប់ផ្តល់ព័ត៌មានជូនអតិថិជនអំពីផលិតផល និងសេវាថ្មីៗ កម្មវិធីផ្តល់ជូនពិសេសៗ ដំណឹងជ្រើសរើសបុគ្គលិក ការយល់ដឹងអំពីសុវត្ថិភាពប្រព័ន្ធអ៊ីនធឺណិត និងសេចក្តីប្រកាសផ្សេងៗរបស់ធនាគារ។



ការរៀបចំម៉ាកសញ្ញាថ្មី (អនឡាញ/អហ្វឡាញ)

ចក្ខុវិស័យនៃការរៀបចំម៉ាកសញ្ញាថ្មីនេះគឺដើម្បីធ្វើទំនើបកម្មរូបសញ្ញាដើមរបស់យើងឱ្យមានលក្ខណៈជាម៉ាកសញ្ញាសកល និងមានភាពច្នៃប្រឌិតបន្ថែមទៀត ប៉ុន្តែរក្សាទុកនូវសមាសធាតុដើមពីធនាគារ ប៊ី.អាយ.ស៊ី ឡាវ ដដែល។

គោលបំណងនៃការរៀបចំម៉ាកសញ្ញាឡើងវិញនេះ គឺដើម្បីកែប្រែរូបភាពក្រុមហ៊ុនឱ្យស្របទៅតាមគោលបំណងនៃភាពរីកចម្រើន ការវិវត្តផ្នែកឌីជីថល និងការពង្រីកទីតាំងភូមិសាស្ត្រផងដែរ។

ជាមួយ ដំណើរការរៀបចំម៉ាកសញ្ញាថ្មីនេះនឹងមិនអាចទទួលបានជោគជ័យឡើយ ប្រសិនបើគ្មានឯកសារណែនាំអំពីស្លាកសញ្ញាផ្លូវការដែលជួយបង្ហាញផ្លូវដល់ក្រុមការងារផ្នែកលក់ និងទីផ្សារក្នុងការរចនា និងរក្សាទំនាក់ទំនងជាមួយអតិថិជន។ ចំណុចនេះរួមបញ្ចូលទាំងការកំណត់ពណ៌ជាក់លាក់ និងប្រែប្រួល ម៉ូតអក្សរ និងការបកស្រាយរូបសញ្ញាដែលអាចប្រើប្រាស់។ នៅពេលមានចំណុចទាំងអស់នេះហើយ យើងអាចធានាបានថា ការផ្សព្វផ្សាយរបស់យើងនឹងមានសង្គតិភាព និងបំពេញបន្ថែមទៅលើម៉ាកសញ្ញាថ្មីនេះ។

ជាលទ្ធផលនៅក្នុងឆ្នាំ២០២០ ធនាគារបានបង្កើតទំព័របណ្តាញសង្គមផ្លូវការមួយចំនួន ដូចជា Facebook, LinkedIn, Instagram និង Telegram ជាបណ្តាញសម្រាប់ផ្តល់ព័ត៌មានជូនអតិថិជនអំពីផលិតផល និងសេវាថ្មីៗ កម្មវិធីផ្តល់ជូនពិសេសៗ ដំណឹងជ្រើសរើសបុគ្គលិក ការយល់ដឹងអំពីសុវត្ថិភាពប្រព័ន្ធអ៊ីនធឺណេត និងសេចក្តីណែនាំផ្សេងៗរបស់ធនាគារ។ ម៉្យាងវិញទៀត ធនាគារបានធ្វើការអភិវឌ្ឍ សម្ភារៈ Marketing (Marketing Materials) ដោយមានរួមបញ្ចូលនូវការកែលម្អអគារទាំងខាងមុខ និងផ្ទៃខាងក្នុងរបស់ធនាគារ និង POSM ដូចជា ខិត្តប័ណ្ណ ល។ល ផងដែរ។

ការពង្រីកបណ្ដាញសាខា

ការពង្រីកបណ្ដាញសាខាមានសារៈសំខាន់ចំពោះភាពជោគជ័យរបស់ធនាគារ ប៊ី.អាយ.ស៊ី (ខេមបូឌា) ប៊ែង ម.ក។ ជាប្រការសំខាន់ដែលគ្រឹះស្ថានហិរញ្ញវត្ថុត្រូវធានាផ្ដល់ជូនអតិថិជននូវបទពិសោធន៍ល្អៗ ដោយជំរុញនូវទំនាក់ទំនងកាន់តែច្រើនជាមួយបុគ្គលិក និងអតិថិជន។

នៅក្នុងខែឧសភា ឆ្នាំ២០២០ យើងបានបើកសាខាខេត្តព្រះសីហនុ ដើម្បីផ្ដល់សេវាជូនអតិថិជនរបស់យើងស្របតាមតម្រូវការរបស់ពួកគាត់។ យើងមានសាខាចំនួនពីរបន្ថែមទៀតដែលកំពុងរៀបចំ ហើយនឹងអាចចាប់ផ្ដើមដំណើរការនៅដើមឆ្នាំ២០២១ ខាងមុខនេះ។

យើងយល់ថា ការពង្រីកធនាគារ គឺជាយុទ្ធសាស្ត្រសម្រាប់ផ្សាភ្ជាប់ទំនាក់ទំនងជាមួយអតិថិជនរបស់យើង និងផ្ដល់នូវជំនួយហិរញ្ញវត្ថុសំខាន់ៗ ជាពិសេសសម្រាប់តម្រូវការសេវាធនាគារទ្រង់ទ្រាយធំមួយចំនួនរបស់ពួកគាត់។ "ជាការពិតណាស់ បណ្ដាញសាខានៅតែជាយុទ្ធសាស្ត្រទំនាក់ទំនងដ៏រឹងមាំបំផុតសម្រាប់ធនាគារ។ សាខាកាន់តែបង្ហាញអំពីសារៈសំខាន់នៅពេលដែលគ្រឹះស្ថានហិរញ្ញវត្ថុយល់ថា ប្រតិបត្តិការមិនដូចគ្នាទៅនឹងការទំនាក់ទំនងឡើយ ហើយអតិថិជនរំពឹងចង់បានបទពិសោធន៍ដោយផ្ទាល់សម្រាប់សេវាធនាគារជាច្រើន"។

សាខាថ្មីក៏នឹងដាក់ឱ្យដំណើរការ សេវាធនាគារលំដាប់ខ្ពស់ (Premium Banking Lounge) ដែលផ្ដល់សេវាបុគ្គល ផ្ដល់នូវអត្ថប្រយោជន៍ និងអ្វីៗដែលថ្មីអស្ចារ្យជាច្រើនដើម្បីទទួលបាននូវសេវាធនាគារដ៏ល្អ។

ការប្រើប្រាស់សាខាដើម្បីទំនាក់ទំនងជាមួយសមាជិក និងអតិថិជន អាចជួយបង្កើតបទពិសោធន៍ផ្ទាល់ខ្លួនជាមួយអតិថិជន ដោយជំរុញអតិថិជនចាស់ និងអតិថិជនថ្មីឱ្យមានទំនាក់ទំនងជាមួយគ្រឹះស្ថានហិរញ្ញវត្ថុ ដែលជាយុទ្ធសាស្ត្រនាំមកនូវភាពរីកចម្រើនសម្រាប់អាជីវកម្មទាំងមូលរបស់គាត់ ក៏ដូចជាទទួលបាននូវភាពស្មោះស្ម័គ្ររបស់គាត់ផងដែរ។

ការយល់ដឹងតាមរយៈទំនាក់ទំនងដែលមានស្រាប់ ការណែនាំ និងកេរ្តិ៍ឈ្មោះមានឥទ្ធិពលខ្លាំងនៅពេលធ្វើការសម្រេចចិត្តអំពីកន្លែងដែលត្រូវទិញផលិតផល និងសេវាហិរញ្ញវត្ថុ។ ភាពងាយស្រួលក្នុងការធ្វើដំណើរមកកាន់សាខានៅតែជាចំណុចសំខាន់សម្រាប់អតិថិជន និងម្ចាស់អាជីវកម្មខ្នាតតូចនៅក្នុងការជ្រើសរើសថាតើត្រូវប្រើប្រាស់សេវានៅធនាគារមួយណា។

ទំនួលខុសត្រូវសង្គមរបស់ធនាគារ

"ការងារធនាគារ ចេញពីបេះដូង"

នេះគឺជាវិធីសាស្ត្ររបស់យើងនៅក្នុងការតបស្នងចំពោះប្រទេសកម្ពុជា។

ធនាគារ ប៊ី.អាយ.ស៊ី (ខេមបូឌា) ប៊ែង ម.ក មានវប្បធម៌អាជីវកម្មដែលយកចិត្តទុកដាក់ខ្លាំងទៅលើសប្បុរសធម៌។ អ្វីដែលសំខាន់ជាងនេះ ការយល់ដឹងកាន់តែទូលំទូលាយអំពីទំនួលខុសត្រូវសង្គមបាននាំឱ្យធនាគារមានការចូលរួមនៅក្នុងទំនួលខុសត្រូវនេះ ដែលនេះគឺជាវិធីសាស្ត្ររបស់យើងនៅក្នុងការធានាចីរភាពនៃការអភិវឌ្ឍតាមរយៈការផ្តល់អត្ថប្រយោជន៍សេដ្ឋកិច្ច សង្គម និងបរិស្ថានដល់ប្រទេសកម្ពុជា។ នៅក្នុងឆ្នាំ២០២០ យើងបានចូលរួមយ៉ាងស្មោះស្ម័គ្រនៅក្នុងសកម្មភាពសប្បុរសធម៌ធំៗជាច្រើន៖

១០០.០០០ ដុល្លារអាមេរិក
ប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ ១៩

នៅក្នុងឆ្នាំ២០២០ ពលរដ្ឋកម្ពុជារបស់យើងប្រឈមមុខនឹងការរាតត្បាតនៃជំងឺកូវីដ ១៩ (COVID-19)។ ដោយឈរលើស្មារតីនេះ លោក យឹម លក្ខណ៍ ដែលជាប្រធានក្រុមប្រឹក្សាភិបាល បានផ្តល់ជំនួយដល់រាជរដ្ឋាភិបាលកម្ពុជា ដោយបានបរិច្ចាគទឹកប្រាក់ចំនួន ១០០.០០០ (ដប់ម៉ឺន) ដុល្លារអាមេរិក ដើម្បីប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ ១៩។ សកម្មភាពនេះគឺជាកាតព្វកិច្ចរបស់យើងនៅក្នុងការការពារសុខភាព និងជួយសង្គ្រោះអាយុជីវិតរបស់ពលរដ្ឋកម្ពុជា។

ខែមីនា ឆ្នាំ២០២០ | ខែឧសភា ឆ្នាំ២០២០ | ខែតុលា ឆ្នាំ២០២០



ធនាគារ ប៊ី.អាយ.ស៊ី (ខេមបូឌា) ប៊ែង ម.ក បានបរិច្ចាគ
អង្ករចំនួន ៤ តោន

ដើម្បីជួយដល់ខណ្ឌទួលគោកក្នុងការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ ១៩។

១០០.០០០ ដុល្លារអាមេរិក
ជួយសង្គ្រោះពលរដ្ឋដែលរងគ្រោះដោយសារទឹកជំនន់

ធនាគារ ប៊ី.អាយ.ស៊ី (ខេមបូឌា) ប៊ែង ម.ក ដែលដឹកនាំដោយ លោក យឹម លក្ខណ៍ ដែលជាប្រធានក្រុមប្រឹក្សាភិបាល បានផ្តល់ជំនួយដល់រាជរដ្ឋាភិបាលកម្ពុជានូវទឹកប្រាក់ចំនួន ១០០.០០០ (ដប់ម៉ឺន) ដុល្លារអាមេរិក ដើម្បីរួមចំណែកនៅក្នុងប្រតិបត្តិការជួយសង្គ្រោះពលរដ្ឋដែលរងគ្រោះដោយសារទឹកជំនន់។

របាយការណ៍ហិរញ្ញវត្ថុ

សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០២០
និងរបាយការណ៍របស់សវនករឯករាជ្យ



របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាល ("អភិបាល") មានសេចក្តីរីករាយសូមដាក់បង្ហាញរបាយការណ៍របស់ខ្លួន និងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ប៊ី.អាយ.ស៊ី (ខេមបូឌា) ប៊ែង ម.ក ហៅកាត់ថា ("ធនាគារ") ដែលបានធ្វើសវនកម្មរួចសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ (ដែលហៅកាត់ថា "របាយការណ៍ហិរញ្ញវត្ថុ")។

ព័ត៌មានអំពីធនាគារ

ធនាគារ ប៊ី.អាយ.ស៊ី (ខេមបូឌា) ប៊ែង ម.ក ហៅកាត់ថា ("ធនាគារ") ត្រូវបានបង្កើតឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជានៅថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៧ ក្រោមលេខចុះបញ្ជី ០០០២៩២០០ ហើយបានចាប់ផ្តើមប្រតិបត្តិការបន្ទាប់ពីទទួលបានអាជ្ញាប័ណ្ណពីធនាគារជាតិ នៃកម្ពុជានៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៨។

ការិយាល័យចុះបញ្ជីរបស់ធនាគារបច្ចុប្បន្នមានទីតាំងនៅផ្ទះលេខ៤៦២ ផ្លូវ៩៣ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

ធនាគារ មាននិយោជិតចំនួន ៩៤ នាក់ នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ (ឆ្នាំ២០១៩៖ និយោជិតចំនួន ៥០ នាក់)។

សកម្មភាពចម្បង

សកម្មភាពចម្បងរបស់ធនាគារ រួមមានការធ្វើប្រតិបត្តិការលើរាល់សកម្មភាពអាជីវកម្មធនាគារ និងការផ្តល់សេវាកម្មហិរញ្ញវត្ថុ ដែលពាក់ព័ន្ធនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

លទ្ធផល និងភាគលាភ

លទ្ធផលនៃប្រតិបត្តិការរបស់ធនាគារ សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ និងស្ថានភាពនៃប្រតិបត្តិការ របស់ធនាគារនាកាលបរិច្ឆេទនោះ ត្រូវបានកំណត់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុដែលបានបង្ហាញខាងក្រោមនេះ។

ពុំមានការស្នើបែងចែក ឬការប្រកាសភាគលាភដោយធនាគារ ចាប់តាំងពីចុងការិយបរិច្ឆេទថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០២០ (ឆ្នាំ២០១៩៖ គ្មាន) មុនឡើយ។

ក្រុមប្រឹក្សាភិបាល

សមាជិកក្រុមប្រឹក្សាភិបាលរបស់ធនាគារក្នុងការិយបរិច្ឆេទ និងនាកាលបរិច្ឆេទនៃរបាយការណ៍នេះ មានដូចខាងក្រោម៖

ឈ្មោះ	មុខតំណែង	កាលបរិច្ឆេទនៃការតែងតាំង
លោក យឹម លក្ខណ៍	ប្រធានក្រុមប្រឹក្សាភិបាល	ថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៩
លោក. Zulkiflee Kuan Shun Bin Abdullah	អភិបាល	ថ្ងៃទី៩ ខែសីហា ឆ្នាំ២០១៨
លោកស្រី. Adel Leilanie Gaba Legarta	អភិបាល	ថ្ងៃទី១ ខែមេសា ឆ្នាំ២០២០
លោក. Rutsaran Moonsan	អភិបាលឯករាជ្យ	ថ្ងៃទី៩ ខែសីហា ឆ្នាំ២០១៨
លោក. John Edward Mc Cosh	អភិបាលឯករាជ្យ	ថ្ងៃទី១ ខែមេសា ឆ្នាំ២០២០

សវនករ

របាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០២០ ត្រូវបានធ្វើសវនកម្ម ដោយក្រុមហ៊ុន ហ្គ្រេន សនថុន (ខេមបូឌា) លីមីតធីត។

ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលលើរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាល មានភារៈទទួលខុសត្រូវក្នុងការអះអាងបញ្ជាក់ថា របាយការណ៍ហិរញ្ញវត្ថុគ្រប់ទិដ្ឋភាពជាសារវន្តទាំងអស់ បង្ហាញនូវភាពត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ និងលទ្ធផលហិរញ្ញវត្ថុ និងលំហូរទឹកប្រាក់ សម្រាប់ការិយបរិច្ឆេទ ដែលបានបញ្ចប់។ នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះ ក្រុមប្រឹក្សាភិបាលចាំបាច់ត្រូវ៖

(i). អនុម័តនូវគោលនយោបាយគណនេយ្យដែលសមស្រប ដោយផ្អែកលើការវិនិច្ឆ័យ និងការប៉ាន់ប្រមាណ យ៉ាងសមហេតុផល និងប្រុងប្រយ័ត្ន ហើយធ្វើការអនុវត្តប្រកបដោយសង្គតិភាព

(ii). អនុវត្តទៅតាមតម្រូវការនៃស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ("ស.រ.ទ.ហ.អ.ក") និងសេចក្តីណែនាំរបស់ធនាគារជាតិនៃកម្ពុជា ឬប្រសិនបើមានការប្រាសចាកណាមួយ ក្នុងការបង្ហាញនូវភាពពិត និងត្រឹមត្រូវក្រុមប្រឹក្សាភិបាលត្រូវប្រាកដថា ការប្រាសចាកទាំងនេះត្រូវបានលាតត្រដាង ពន្យល់ និងកំណត់បរិមាណឱ្យបានត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ

(iii). ត្រួតពិនិត្យប្រព័ន្ធដំណើរការនៃរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ និងរក្សាទុកនូវបញ្ជីគណនេយ្យឱ្យបានគ្រប់គ្រាន់ និងប្រព័ន្ធគ្រប់គ្រង ផ្ទៃក្នុងឱ្យមានប្រសិទ្ធភាព

(iv). វាយតម្លៃនូវលទ្ធភាពរបស់ធនាគារក្នុងការបន្តនិរន្តរភាពអាជីវកម្ម ទទួលខុសត្រូវលើការលាតត្រដាងព័ត៌មាន ប្រសិនបើពាក់ព័ន្ធ នូវបញ្ហា ទាំងឡាយដែលទាក់ទងទៅនឹងនិរន្តរភាពអាជីវកម្ម និងប្រើប្រាស់មូលដ្ឋាននិរន្តរភាពនៃគណនេយ្យ លើកលែងតែអ្នកគ្រប់គ្រងមាន បំណងចង់ជម្រះបញ្ជីផ្អាកដំណើរការធនាគារ ឬគ្មានជម្រើសសមរម្យដទៃទៀតក្រៅពីធ្វើបែបនេះ និង

(v). ត្រួតពិនិត្យ និងដឹកនាំធនាគារឱ្យមានប្រសិទ្ធភាព លើរាល់សេចក្តីសម្រេចដែលមានសារៈសំខាន់ទាំងអស់ ដែលប៉ះពាល់ដល់ សកម្មភាពប្រតិបត្តិការ និងដំណើរការរបស់ធនាគារ ហើយត្រូវប្រាកដថាកិច្ចការនេះត្រូវបានឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវនៅក្នុង របាយការណ៍ហិរញ្ញវត្ថុ។

ក្រុមប្រឹក្សាភិបាល ក៏ជាអ្នកទទួលខុសត្រូវក្នុងការថែរក្សាទ្រព្យសម្បត្តិរបស់ធនាគារ ហើយក៏ត្រូវចាត់វិធានការឱ្យសមស្រប ដើម្បីទប់ស្កាត់ និងរកឱ្យឃើញការក្លែងបន្លំ និងភាពមិនប្រក្រតីផ្សេងៗ។

ក្រុមប្រឹក្សាភិបាលសូមបញ្ជាក់ថា ធនាគារបានអនុវត្តតាមលក្ខខណ្ឌតម្រូវចាំបាច់នានា ដូចដែលបានបញ្ជាក់ខាងលើ ក្នុងការរៀបចំរបាយ ការណ៍ហិរញ្ញវត្ថុនេះ។

អត្ថប្រយោជន៍របស់ក្រុមប្រឹក្សាភិបាល

នៅក្នុងអំឡុងការិយបរិច្ឆេទ និងនៅចុងការិយបរិច្ឆេទនៃរបាយការណ៍ហិរញ្ញវត្ថុនេះ គឺមិនមានកិច្ចព្រមព្រៀងណាមួយដែលធនាគារជាភាគីម្ខាងដែលកម្មវត្ថុនៃកិច្ចព្រមព្រៀងនោះអាចផ្តល់លទ្ធភាពដល់អភិបាលណាម្នាក់អោយទទួលបាននូវអត្ថប្រយោជន៍តាមមធ្យោបាយផ្សេងៗ ដូចជាការទិញភាគហ៊ុន ឬប័ណ្ណបំណុលរបស់ធនាគារ ឬសាជីវកម្មដទៃ។

ចាប់តាំងពីចុងការិយបរិច្ឆេទឆ្នាំចាស់មក ពុំមានអភិបាលណាម្នាក់របស់ធនាគារបានទទួល ឬ មានសិទ្ធិទទួលបាននូវអត្ថប្រយោជន៍ណាមួយ (ក្រៅពីអត្ថប្រយោជន៍ដែលបានរាប់បញ្ចូលនៅក្នុងបរិលាភសរុបដែលទទួលបាន ឬដល់កំណត់ទទួលបានដោយក្រុមប្រឹក្សាភិបាល ដូចបានបង្ហាញនៅក្នុងកំណត់សម្គាល់ ៣០ នៃរបាយការណ៍ហិរញ្ញវត្ថុ) តាមរយៈការចុះកិច្ចសន្យាធ្វើឡើងដោយធនាគារ ឬដោយក្រុមហ៊ុនពាក់ព័ន្ធជាមួយនឹង ធនាគារដែលអភិបាលនោះជាសមាជិក ឬក៏ជាមួយធនាគារ ដែលអភិបាលនោះមានផលប្រយោជន៍ ផ្នែកហិរញ្ញវត្ថុច្រើននោះទេ លើកលែងតែការបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

សេចក្តីថ្លែងការណ៍របស់ក្រុមប្រឹក្សាភិបាល

តាមមតិយោបល់របស់ក្រុមប្រឹក្សាភិបាល របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ អមដោយ របាយការណ៍ចំណូលលម្អិត របាយការណ៍ បម្រែបម្រួលមូលធន និងរបាយការណ៍លំហូរសាច់ប្រាក់ រួមជាមួយនឹងកំណត់សម្គាល់នានា ត្រូវបានបង្ហាញនូវទិដ្ឋភាពពិត និងត្រឹមត្រូវ ពីស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារនាការិយបរិច្ឆេទគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ ព្រមទាំងលទ្ធផលនៃប្រតិបត្តិការអាជីវកម្ម និង ស្ថានភាពលំហូរសាច់ប្រាក់សម្រាប់ដំណាច់ឆ្នាំ ត្រូវបានរៀបចំឡើងដោយអនុលោមតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុ អន្តរជាតិនៃកម្ពុជា និងសេចក្តីណែនាំរបស់ធនាគារជាតិនៃកម្ពុជា។

ចុះហត្ថលេខាដោយយោងលើសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលៈ

លោក Zulkiflee Kuan Shun Bin Abdullah
អភិបាល

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
កាលបរិច្ឆេទថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២១

របាយការណ៍របស់សវនករឯករាជ្យ

ជូនចំពោះភាគហ៊ុននិករបស់
ធនាគារ ប៊ី.អាយ.ស៊ី (ខេមបូឌា) ប៊ែង ម.ក

មតិយោបល់

យើងខ្ញុំបានធ្វើសវនកម្មទៅលើ របាយការណ៍ហិរញ្ញវត្ថុ របស់ធនាគារ ប៊ី.អាយ.ស៊ី (ខេមបូឌា) ប៊ែង ម.ក ហៅកាត់ថា ("ធនាគារ") ដែលរួមមានរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុនាការិយបរិច្ឆេទ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ របាយកាណ៍ ចំណេញ ឬខាត និងចំណូលលម្អិតផ្សេងៗ របាយការណ៍បម្រែបម្រួលមូលធន និងរបាយកាណ៍លំហូរសាច់ប្រាក់ នាចុងការិយបរិច្ឆេទ និងកំណត់សំគាល់របាយការណ៍ហិរញ្ញវត្ថុ រួមទាំងគោលនយោបាយគណនេយ្យសង្ខេបសំខាន់ៗ និងសេចក្តីពន្យល់ព័ត៌មានផ្សេងៗ។

តាមមតិរបស់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុបានបង្ហាញនូវភាពត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុ របស់ធនាគារ ប៊ី.អាយ.ស៊ី (ខេមបូឌា) ម.ក គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ ព្រមទាំងលទ្ធផលនៃប្រតិបត្តិការអាជីវកម្ម និងស្ថានភាពលំហូរ សាច់ប្រាក់សម្រាប់ដំណាច់ឆ្នាំ ដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុ អន្តរជាតិនៃកម្ពុជា និង សេចក្តីណែនាំរបស់ធនាគារជាតិនៃកម្ពុជា។

មូលដ្ឋាននៃការបញ្ចេញមតិយោបល់

យើងខ្ញុំបានធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា("CISAs")។ ការទទួលខុសត្រូវ របស់យើងខ្ញុំអនុលោមតាមស្តង់ដារទាំងនោះត្រូវបានរៀបរាប់បន្ថែមទៀតនៅ ក្នុងផ្នែកការទទួលខុសត្រូវរបស់សវនករ ទៅលើការធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុ។ យើងខ្ញុំប្រកាន់ខ្ជាប់នូវឯករាជ្យភាពពីធនាគារ ហើយអនុវត្តតាមស្តង់ដារ នៃវិជ្ជាជីវៈគណនេយ្យអន្តរជាតិស្តីពី ក្រមសីលធម៌របស់គណនេយ្យករជំនាញ (រួមជាមួយនឹងស្តង់ដារឯករាជ្យភាព អន្តរជាតិ) ដែលហៅកាត់ថា ("IESBA Code") ព្រមទាំង តម្រូវការក្រមសីលធម៌ដទៃទៀត ដែលពាក់ព័ន្ធទៅនឹងការធ្វើ សវនកម្មរបស់យើងខ្ញុំទៅលើរបាយការណ៍ហិរញ្ញវត្ថុក្នុងប្រទេសកម្ពុជា។ យើងខ្ញុំជឿជាក់ថា ភស្តុតាងសវនកម្មទាំងអស់ ដែលយើងទទួលបានមានលក្ខណៈគ្រប់គ្រាន់ និងសមរម្យដើម្បីផ្តល់ជូនជាមូលដ្ឋានសម្រាប់ការបញ្ចេញមតិរបស់ យើងខ្ញុំ។

បញ្ហាផ្សេងៗ

របាយការណ៍ហិរញ្ញវត្ថុគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ ត្រូវបានធ្វើសវនកម្មដោយសវនករផ្សេងទៀតដែលបានផ្តល់នូវ មតិយោបល់ត្រឹមត្រូវលើរបាយការណ៍ហិរញ្ញវត្ថុនោះ នៅថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០។

ព័ត៌មានផ្សេងៗ

គណៈគ្រប់គ្រងមានទំនួលខុសត្រូវទាំងស្រុងទៅលើព័ត៌មានផ្សេងៗ។ ព័ត៌មានផ្សេងៗរួមមានរបាយការណ៍របស់ ក្រុមប្រឹក្សាភិបាល ដែលបានផ្តល់ជូនយើងខ្ញុំ មុនកាលបរិច្ឆេទនៃរបាយការណ៍របស់សវនករ និងរបាយការណ៍ប្រចាំឆ្នាំដែល រំពឹងទុកថាបានរៀបចំរួចរាល់ សម្រាប់យើងខ្ញុំបន្ទាប់ពីកាលបរិច្ឆេទនោះ។ ប៉ុន្តែមិនរួមបញ្ចូលនូវរបាយការណ៍ហិរញ្ញវត្ថុ និង របាយការណ៍របស់សវនករយើងខ្ញុំឡើយ។

មតិរបស់យើងខ្ញុំនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ មិនបានគ្របដណ្តប់ទៅលើព័ត៌មានផ្សេងៗ ហើយយើងខ្ញុំមិនបង្ហាញពី ទម្រង់បែបបទនៃការធានាណាមួយ ឬធ្វើសេចក្តីសន្និដ្ឋានណាមួយឡើយ។

ពាក់ព័ន្ធនឹងការធ្វើសវនកម្មរបស់យើងខ្ញុំលើរបាយការណ៍ហិរញ្ញវត្ថុ ការទទួលខុសត្រូវរបស់យើងខ្ញុំ គឺត្រូវអានព័ត៌មានផ្សេងៗ ហើយពិចារណាថាតើព័ត៌មានផ្សេងៗនោះ មានវិសមភាពជាសារវន្តជាមួយនឹងរបាយការណ៍ហិរញ្ញវត្ថុឬទេ ឬការយល់ដឹង របស់យើងខ្ញុំ ដែលទទួលបានពីការធ្វើសវនកម្ម ថាតើព័ត៌មានទាំងនោះអាចមានកំហុសឆ្គងជាសារវន្ត ឬទេ។

ប្រសិនបើ ការអានព័ត៌មានផ្សេងៗ ដែលយើងខ្ញុំទទួលបានមុនកាលបរិច្ឆេទនៃរបាយការណ៍របស់សវនករអាចឱ្យ យើងខ្ញុំ សន្និដ្ឋានថា មានកំហុសឆ្គងជាសារវន្តកើតឡើងលើព័ត៌មាន ផ្សេងៗនេះ យើងខ្ញុំត្រូវរាយការណ៍ទៅតាមស្ថានភាព ជាក់ស្តែង។ យើងខ្ញុំពុំមានអ្វីដែលត្រូវរាយការណ៍ពាក់ព័ន្ធនឹងព័ត៌មានផ្សេងៗនេះទេ។

នៅពេលដែលយើងខ្ញុំអានរបាយការណ៍ប្រចាំឆ្នាំ ប្រសិនបើយើងខ្ញុំសន្និដ្ឋានថាមានកំហុសឆ្គងជាសារវន្តណាមួយកើតមានឡើង យើងខ្ញុំត្រូវធ្វើការទាក់ទងជាមួយក្រុមប្រឹក្សាភិបាល និងឆ្លើយតបទៅលើបញ្ហាទាំងនេះដោយអនុលោមតាមការតម្រូវ របស់ CISA ៧២០ (បានធ្វើការកែតម្រូវ)។

ការទទួលខុសត្រូវរបស់គណៈគ្រប់គ្រងលើរបាយការណ៍ហិរញ្ញវត្ថុ

គណៈគ្រប់គ្រងទទួលខុសត្រូវក្នុងការរៀបចំ និងការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុទាំងនេះឱ្យបានត្រឹមត្រូវដោយអនុលោម ទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា និងទទួលខុសត្រូវលើការត្រួតពិនិត្យផ្ទៃក្នុង ដែលគណៈគ្រប់គ្រង កំណត់ថាវាមានភាពចាំបាច់ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ មិនឱ្យមានការរាយការណ៍ខុសជាសារវន្ត ដែលបណ្តាលមកពីការក្លែងបន្លំ ឬកំហុសឆ្គងផ្សេងៗ។

ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ គណៈគ្រប់គ្រងមានទំនួលខុសត្រូវចំពោះការវាយតម្លៃទៅលើនិរន្តរភាពអាជីវកម្ម របស់ធនាគារ និងធ្វើការលាតត្រដាង (ប្រសិនជាមាន) នូវបញ្ហាទាក់ទងនឹងនិរន្តរភាពអាជីវកម្ម និងការប្រើប្រាស់មូលដ្ឋាន និរន្តរភាពអាជីវកម្ម នៅក្នុងការកត់ត្រាគណនេយ្យ លុះត្រាតែគណៈគ្រប់គ្រងមានគោលបំណងរំលាយ ឬបញ្ឈប់ប្រតិបត្តិការ របស់ធនាគារ ឬក៏គ្មានជម្រើសជាក់ស្តែងណាមួយក្រៅពីអនុវត្តដូច្នេះ។

ក្រុមប្រឹក្សាភិបាលមានទំនួលខុសត្រូវក្នុងការត្រួតពិនិត្យទៅលើដំណើរការនៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ។

ការទទួលខុសត្រូវរបស់សវនករទៅលើការធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុ

គោលបំណងរបស់យើងខ្ញុំ គឺដើម្បីទទួលបាននូវការធានាអះអាងដ៏សមហេតុផល ទៅលើរបាយការណ៍ហិរញ្ញវត្ថុត្រូវបាន រៀបចំដោយបង្ហាញពីទិដ្ឋភាពពិតនិង ពុំមានលក្ខណៈខុសឆ្គងជាសារវន្ត ដែលបណ្តាលមកពីការក្លែងបន្លំ ឬកំហុសឆ្គងនានា ដើម្បីធ្វើជាមូលដ្ឋានក្នុងការបញ្ចេញមតិយោបល់លើរបាយការណ៍សវនកម្មរបស់យើងខ្ញុំ។ ការធានាអះអាង ដែលសមហេតុផល គឺជាការធានាមួយដែលមានកម្រិតខ្ពស់ ប៉ុន្តែវាមិនបានធានាថាការធ្វើសវនកម្មដោយផ្អែកទៅលើ ស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា នឹងតែងតែរកឃើញនូវការ រាយការណ៍ខុសជាសារវន្តដែលមានឡើយ។ ការរាយការណ៍ខុសអាចកើតមានឡើងពីការក្លែងបន្លំ ឬកំហុសឆ្គងដែល អាចចាត់ទុកថាមានលក្ខណៈជាសារវន្ត នៅពេល ដែលកំហុសមួយ ឬកំហុសរួមគ្នាបានធ្វើឱ្យប៉ះពាល់ដល់សេចក្តីសម្រេចចិត្ត ផ្នែកសេដ្ឋកិច្ចរបស់អ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុនេះ។

ជាផ្នែកមួយនៃការធ្វើសវនកម្មដោយយោងទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា យើងខ្ញុំបានធ្វើការវិនិច្ឆ័យ និងរក្សារមជ្ឈធាតុនិយមប្រកបដោយវិជ្ជាជីវៈក្នុងដំណើរការសវនកម្ម។ យើងខ្ញុំក៏បាន៖

- កំណត់ និងវាយតម្លៃនូវហានិភ័យទាក់ទងនឹងការរាយការណ៍ខុសជាសារវន្ត នៃរបាយការណ៍ហិរញ្ញវត្ថុ ថាតើវាកើតឡើងដោយការ ក្លែងបន្លំ ឬជាកំហុសឆ្គង ធ្វើការរៀបចំ និងអនុវត្តនិតិវិធីសវនកម្មដើម្បីឆ្លើយតប ទៅនឹងហានិភ័យទាំងនោះ រួមទាំង ការប្រមូលយកភស្តុតាងសវនកម្មឱ្យបានគ្រប់គ្រាន់ និងសមស្របដើម្បីជា មូលដ្ឋានសម្រាប់បញ្ចេញមតិយោបល់ របស់យើងខ្ញុំ។ ហានិភ័យដែលមិនអាចរកឃើញដោយការរាយការណ៍ខុស ជាសារវន្តដែលបណ្តាលមកពីការ ក្លែងបន្លំ វាមានទំហំធំជាងហានិភ័យដែលបណ្តាលមកពីកំហុសឆ្គងដោយ អចេតនា ដោយសារតែការក្លែងបន្លំ រួមបញ្ចូលទាំងការរួមគំនិត ការក្លែងបន្លំឯកសារ ការលុបចោលដោយចេតនា ការបង្ហាញខុស ឬការល្មើសទៅលើការត្រួតពិនិត្យផ្ទៃក្នុង។
- ស្វែងយល់អំពីការគ្រប់គ្រងផ្ទៃក្នុងដែលទាក់ទងទៅនឹងការធ្វើសវនកម្ម ដើម្បីបង្កើតនូវនិតិវិធីសវនកម្មដែល សមស្របទៅនឹងកាលៈទេសៈ ប៉ុន្តែមិនមែនជាគោលបំណងក្នុងការបង្ហាញនូវមតិយោបល់លើប្រសិទ្ធភាព នៃការត្រួតពិនិត្យផ្ទៃក្នុងរបស់ធនាគារនោះទេ។
- វាយតម្លៃភាពសមស្របលើគោលនយោបាយគណនេយ្យដែលបានប្រើប្រាស់ និងភាពសមហេតុផលនៃ គណនេយ្យប៉ាន់ស្មាន និងការបង្ហាញដែលជាប់ទាក់ទងផ្សេងទៀតដែលធ្វើឡើងដោយគណៈគ្រប់គ្រង។
- ធ្វើសេចក្តីសន្និដ្ឋានដ៏សមស្របមួយទៅលើការប្រើប្រាស់មូលដ្ឋានគណនេយ្យនិរន្តរភាព របស់គណៈគ្រប់គ្រង ដោយផ្អែកលើភស្តុតាងសវនកម្មដែលទទួលបាន ថាតើមានវត្តមាន នៃភាពមិនប្រាកដប្រជាជាសារវន្តទាក់ទង នឹងព្រឹត្តការណ៍នានា ឬកាលៈទេសៈទាំងឡាយណាដែលនាំឱ្យមានមន្ទិលសង្ស័យខ្លាំង ទៅលើលទ្ធភាពក្នុង ការបន្តនិរន្តរភាពរបស់ធនាគារ ឬទេ។ ប្រសិនបើយើងខ្ញុំសន្និដ្ឋាន ថាមានវត្តមាននៃភាពមិនប្រាកដប្រជាជាសារវន្ត យើងខ្ញុំតម្រូវឱ្យទាញចំណាប់អារម្មណ៍ ក្នុងរបាយការណ៍សវនករ លើកំណត់សម្គាល់ពាក់ព័ន្ធនៅក្នុង របាយការណ៍ហិរញ្ញវត្ថុ ឬប្រសិនបើការលាតត្រដាងនេះពុំមាន លក្ខណៈគ្រប់គ្រាន់ទេនោះ យើងខ្ញុំនឹងធ្វើការ បញ្ចេញមតិយោបល់ថារបាយការណ៍ហិរញ្ញវត្ថុមិនបានបង្ហាញពីទិដ្ឋភាពពិត និងត្រឹមត្រូវ។ ការសន្និដ្ឋានរបស់ យើងខ្ញុំ គឺពឹងផ្អែកលើភស្តុតាងសវនកម្មដែលទទួលបានរហូតដល់កាលបរិច្ឆេទនៃរបាយការណ៍របស់សវនករ។ តែទោះជាយ៉ាងនេះក្តី ព្រឹត្តិការណ៍ ឬកាលៈទេសៈនាពេលអនាគត ក៏អាចបង្កឱ្យធនាគារមិនអាចបន្តនិរន្តរភាពអាជីវកម្មបានផងដែរ។
- វាយតម្លៃការបង្ហាញទូទៅ និងខ្លឹមសារ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរួមបញ្ចូលទាំងការលាតត្រដាងនានា ថាតើ របាយការណ៍ហិរញ្ញវត្ថុតំណាងឱ្យប្រតិបត្តិការ និងព្រឹត្តិការណ៍ដែលជាមូលដ្ឋាន ដើម្បីសម្រេចបាននូវការបង្ហាញដ៏ត្រឹមត្រូវ។

យើងខ្ញុំប្រាស្រ័យទាក់ទងជាមួយក្រុមប្រឹក្សាភិបាលទៅលើបញ្ហាផ្សេងៗ ដូចជា វិសាលភាព និងពេលវេលា នៃការធ្វើ សវនកម្ម និងការរកឃើញពីសវនកម្ម រួមទាំងកង្វះខាតសំខាន់ៗនៃការត្រួតពិនិត្យផ្ទៃក្នុងដែលយើងខ្ញុំបានរកឃើញ នៅក្នុងអំឡុងពេលធ្វើសវនកម្ម។

យើងខ្ញុំក៏ផ្តល់ជូនក្រុមប្រឹក្សាភិបាល នូវសេចក្តីថ្លែងការណ៍មួយដែលយើងខ្ញុំបានអនុវត្តទៅតាមតម្រូវការក្រមសីលធម៌ ដែលទាក់ទងនឹងឯករាជ្យភាព ហើយយើងខ្ញុំធ្វើការប្រាស្រ័យទាក់ទងជាមួយនឹងក្រុមប្រឹក្សាភិបាលនូវបញ្ហាទាំងអស់ដែល នឹងគិតថាសមហេតុផលទៅលើឯករាជ្យភាពរបស់យើងខ្ញុំ និងការការពារដែលអាចមាន។

ហ្គ្រេន សនថុន ខេមបូឌា លីមីតធីត
គណនេយ្យករជំនាញ
សវនករប្រតិស្រុតចុះបញ្ជី

Ronald C. Almera
នាយកសវនករជំនាញ

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
កាលបរិច្ឆេទថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២១

របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ

	កំណត់សម្គាល់	ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០		ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩	
		ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ ២.៤)	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ ២.៤)
ទ្រព្យសកម្ម					
សាច់ប្រាក់-សុទ្ធ	៧	៦៨.៣៦៤.៩៥៥	២៧៦.៥៣៦.២៤៣	៦១.២៥៤.៥១៣	២៤៩.៦១២.១៤០
សមតុល្យនៅធនាគារផ្សេងៗ	៨	៦.៤០៥.៨៧៥	២៥.៩១១.៧៦៤	១៨.០៥៨.០៨១	៧៣.៥៨៦.៦៨០
ប្រាក់បញ្ញើតាមបទប្បញ្ញត្តិ	៩	២០.៧៧១.១៨០	៨៤.០១៩.៤២៣	២៣.៧៧១.១៣៥	៩៦.៨៦៧.៣៧៥
ឥណទាន និងបុរេប្រទានផ្តល់ដល់ អតិថិជន-សុទ្ធ	១០	៧៤.៥០៨.០៩២	៣០១.៣៨៥.២៣២	៦៧.៧១១.០២៦	២៧៥.៩២២.៤៣១
ការវិនិយោគផ្សេងៗ	១១	២៣.១២៧.២៦៧	៩៣.៥៤៩.៧៩៥	២២.៣៩២.២៦៩	៩១.២៤៨.៤៩៦
ទ្រព្យសកម្មអរូបី-សុទ្ធ	១២	៦១៥.១៩៥	២.៤៨៨.៤៦៤	៨៥៦.១៥៧	៣.៤៨៨.៨៤០
ទ្រព្យសម្បត្តិ និងបរិក្ខារ-សុទ្ធ	១៣	៣.៩៥៣.៥៣៣	១៥.៩៩២.០៤១	១.២៣០.៤៤១	៥.០១៤.០៤៧
សិទ្ធិនៃការប្រើប្រាស់ទ្រព្យសកម្ម-សុទ្ធ	១៤	២.៤៥៤.៩៥៣	៩.៩៣០.២៨៥	១.៧៤៨.៨៥៤	៧.១២៦.៥៨០
ទ្រព្យសកម្មផ្សេងៗ	១៥	៦៨.៦៦១.១៤៨	២៧៧.៧៣៤.៣៤៤	៨១៣.៨៩៩	៣.៣១៦.៦៣៨
ពន្ធពន្យាជាទ្រព្យសកម្ម-សុទ្ធ	២០	១១៩.២៥២	៤៨២.៣៧៥	៧៦.៤៣៩	៣១១.៤៨៩
ទ្រព្យសកម្មសរុប		**២៦៨.៩៨១.៤៥០**	**១.០៨៨.០២៩.៩៦៦**	**១៩៧.៩១២.៨១៤**	**៨០៦.៤៩៤.៧១៦**
បំណុល និងមូលធន					
បំណុល					
ប្រាក់បញ្ញើពីធនាគារផ្សេងៗ	១៦	១៥.៦៨០.៥០០	៦៣.៤២៧.៦២៣	៣២១.៨៤៣	១.៣១១.៥១០
ប្រាក់បញ្ញើពីអតិថិជន	១៧	១៧៤.៣៨០.១៥៩	៧០៥.៣៦៧.៧៤៣	១១៩.៩១៤.៨៧០	៤៨៨.៦៥៣.០៩៥
បំណុលភតិសន្យា	១៨	២.៥០៧.៤៣១	១០.១៤២.៥៥៨	១.៧២១.៤៧០	៧.០១៤.៩៩០
បំណុលផ្សេងៗ	១៩	៦១៤.១៦៨	២.៤៨៤.៣១០	៥១៣.៨៨៥	២.០៩៤.០៨១
បំណុលពន្ធលើប្រាក់ចំណូលចរន្ត	២០	៩៤.៥៣៧	៣៨២.៤០២	១៧៥.៨៣៨	៧១៦.៥៤០
បំណុលសរុប		**១៩៣.២៧៦.៧៩៥**	**៧៨១.៨០៤.៦៣៦**	**១២២.៦៤៧.៩០៦**	**៤៩៩.៧៩០.២១៦**
មូលធន					
ដើមទុន	២១	៧៥.០០០.០០០	៣០០.០០០.០០០	៧៥.០០០.០០០	៣០០.០០០.០០០
ប្រាក់បម្រុងតាមបទប្បញ្ញត្តិ		៧៥៤.៣២៦	៣.០៦៩.៦១៦	១.៤១០.៤៦៨	៥.៧២៣.៧១០
ខាតបង់បង្គរ		(៤៩.៦៧១)	(១៩៧.២៤០)	(១.១៤៥.៥៦០)	(៤.៦៤៤.១៨៣)
លម្អៀងពីការប្តូររូបិយប័ណ្ណ		-	៣.៣៥២.៩៥៤	-	៥.៦២៤.៩៧៣
មូលធនសរុប		**៧៥.៧០៤.៦៥៥**	**៣០៦.២២៥.៣៣០**	**៧៥.២៦៤.៩០៨**	**៣០៦.៧០៤.៥០០**
បំណុល និងមូលធនសរុប		**២៦៨.៩៨១.៤៥០**	**១.០៨៨.០២៩.៩៦៦**	**១៩៧.៩១២.៨១៤**	**៨០៦.៤៩៤.៧១៦**

របាយការណ៍ចំណេញ ឬខាត និងចំណូលលម្អិតផ្សេងៗ

	កំណត់សម្គាល់	សម្រាប់ចុងការិយបរិច្ឆេទ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០		សម្រាប់ចុងការិយបរិច្ឆេទ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩	
		ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ ២.៤)	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ ២.៤)
ចំណូលការប្រាក់	២២	៧.០២៨.៣៥៧	២៨.៦៥៤.៦១១	៥.២៣៩.៤៦៨	២១.២៣០.៣២៤
ចំណាយការប្រាក់	២៣	(៣.៤៩៤.២៣៩)	(១៤.២៤៦.០១២)	(៨១៩.៩៨៥)	(៣.៣២២.៥៧៩)
ចំណូលការប្រាក់សុទ្ធ		**៣.៥៣៤.១១៨**	**១៤.៤០៨.៥៩៩**	**៤.៤១៩.៤៨៣**	**១៧.៩០៧.៧៤៥**
ចំណូលសេវាកម្ម និងកម្រៃជើងសារ-សុទ្ធ	២៤	៣៩៣.៧៧៦	១.៦០៥.៤២៥	២៣៤.០៦៦	៩៤៨.៤៣៧
ចំណូលផ្សេងៗ	២៥	៧៣.៥៩៤	៣០០.០៤៣	៤០.៨៧៦	១៦៥.៦៣០
ចំណូលប្រត្តិបត្តិការសរុប		**៤.០០១.៤៨៨**	**១៦.៣១៤.០៦៧**	**៤.៦៩៤.៤២៥**	**១៩.០២១.៨១២**
ចំណាយលើបុគ្គលិក	២៦	(១.៣៦៦.៦៨៩)	(៥.៥៧១.៩៩២)	(៨០៩.២៩២)	(៣.២៧៩.២៥២)
រំលស់ទ្រព្យរូបី និងទ្រព្យអរូបី	២៧	(១.០៣២.២២១)	(៤.២០៨.៣៦៥)	(៦៥៦.៨៨៦)	(២.៦៦១.៧០២)
ចំណាយប្រត្តិបត្តិការផ្សេងៗ	២៨	(៩៦៧.៤១៨)	(៣.៩៤៤.១៦២)	(១.៦៧៧.៩៦៦)	(៦.៧៩៩.១១៩)
ឱនភាពតម្លៃនៃឧបករណ៍ហិរញ្ញវត្ថុ	១០	(៤២.៦៧៤)	(១៧៣.៩៨២)	(៨៤.៤៣៦)	(៣៤២.១៣៥)
ប្រាក់ចំណេញមុនបង់ពន្ធ		**៥៩២.៤៨៦**	**២.៤១៥.៥៦៦**	**១.៤៦៥.៨៤៥**	**៥.៩៣៩.៦០៤**
ចំណាយពន្ធលើប្រាក់ចំណូល	២០	(១៥២.៧៣៩)	(៦២២.៧១៧)	(៣២៦.៦៣៨)	(១.៣២៣.៥៣៧)
ចំណេញសុទ្ធក្នុងការិយបរិច្ឆេទ		**៤៣៩.៧៤៧**	**១.៧៩២.៨៤៩**	**១.១៣៩.២០៧**	**៤.៦១៦.០៦៧**
ចំណូល/(ខាត) លម្អិតផ្សេងៗ					
លម្អៀងពីការប្តូររូបិយប័ណ្ណ		-	(២.២៧២.០១៩)	-	៤.២៥១.៣៦៦
ចំណូលលម្អិតសរុបសម្រាប់ការិយបរិច្ឆេទ		**៤៣៩.៧៤៧**	**(៤៧៩.១៧០)**	**១.១៣៩.២០៧**	**៨.៨៦៧.៤៣៣**

របាយការណ៍បម្រែបម្រួលមូលធន

	ដើមទុន		ទុនបម្រុងបទប្បញ្ញត្តិ		ខាតបង់បង្គរ		លម្អៀងពីការប្តូររូបិយប័ណ្ណ	សរុប	
	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ ២.៤)	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ ២.៤)	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ ២.៤)	ពាន់រៀល (កំណត់សម្គាល់ ២.៤)	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ ២.៤)
សមតុល្យនៅថ្ងៃទី១ ខែមករា ឆ្នាំ២០២០	៧៥.០០០.០០០	៣០០.០០០.០០០	១.៤១០.៤៦៨	៥.៧២៣.៧១០	(១.១៤៥.៥៦០)	(៤.៦៤៤.១៨៣)	៥.៦២៤.៩៧៣	៧៥.២៦៤.៩០៨	៣០៦.៧០៤.៥០០
ចំណេញសុទ្ធក្នុងការិយបរិច្ឆេទ	-	-	-	-	៤៣៩.៧៤៧	១.៧៩២.៨៤៩	-	៤៣៩.៧៤៧	១.៧៩២.៨៤៩
ផ្ទេរទៅទុនបម្រុងតាមបទប្បញ្ញត្តិ (កំណត់សម្គាល់ ១០)	-	-	(៦៥៦.១៤២)	(២.៦៥៤.០៩៤)	៦៥៦.១៤២	២.៦៥៤.០៩៤	-	-	-
លម្អៀងពីការប្តូររូបិយប័ណ្ណ	-	-	-	-	-	-	(២.២៧២.០១៩)	-	(២.២៧២.០១៩)
សមតុល្យនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០	**៧៥.០០០.០០០**	**៣០០.០០០.០០០**	**៧៥៤.៣២៦**	**៣.០៦៩.៦១៦**	**(៤៩.៦៧១)**	**(១៩៧.២៤០)**	**៣.៣៥២.៩៥៤**	**៧៥.៧០៤.៦៥៥**	**៣០៦.២២៥.៣៣០**
សមតុល្យនៅថ្ងៃទី១ ខែមករា ឆ្នាំ២០១៩	៧៥.០០០.០០០	៣០០.០០០.០០០	៤២០.១៣៩	១.៦៨៨.១១៩	(១.២៩៤.៤៣៨)	(៥.២២៤.៦៥៩)	១.៣៧៣.៦០៧	៧៤.១២៥.៧០១	២៩៧.៨៣៧.០៦៧
ចំណេញសុទ្ធក្នុងការិយបរិច្ឆេទ	-	-	-	-	១.១៣៩.២០៧	៤.៦១៦.០៦៧	-	១.១៣៩.២០៧	៤.៦១៦.០៦៧
ផ្ទេរទៅទុនបម្រុងតាមបទប្បញ្ញត្តិ (កំណត់សម្គាល់ ១០)	-	-	៩៩០.៣២៩	៤.០៣៥.៥៩១	(៩៩០.៣២៩)	(៤.០៣៥.៥៩១)	-	-	-
លម្អៀងពីការប្តូររូបិយប័ណ្ណ	-	-	-	-	-	-	៤.២៥១.៣៦៦	-	៤.២៥១.៣៦៦
សមតុល្យនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩	**៧៥.០០០.០០០**	**៣០០.០០០.០០០**	**១.៤១០.៤៦៨**	**៥.៧២៣.៧១០**	**(១.១៤៥.៥៦០)**	**(៤.៦៤៤.១៨៣)**	**៥.៦២៤.៩៧៣**	**៧៥.២៦៤.៩០៨**	**៣០៦.៧០៤.៥០០**

របាយការណ៍លំហូរសាច់ប្រាក់

	កំណត់សម្គាល់	សម្រាប់ចុងការិយបរិច្ឆេទ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០		សម្រាប់ចុងការិយបរិច្ឆេទ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩	
		ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ ២.៤)	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ ២.៤)
លំហូរសាច់ប្រាក់ពីសកម្មភាពប្រតិបត្តិការ					
ប្រាក់ចំណេញមុនបង់ពន្ធ		៥៩២.៤៨៦	២.៤១៥.៥៦៦	១.៤៦៥.៨៤៥	៥.៩៣៩.៦០៤
និយ័តកម្មសម្រាប់៖					
រំលស់ទ្រព្យរូបី និងរំលស់ទ្រព្យអរូបី	២៧	១.០៣២.២២១	៤.២០៨.៣៦៥	៦៥៦.៨៨៦	២.៦៦១.៧០២
ចំណូលការប្រាក់	២២	(៧.០២៨.៣៥៧)	(២៨.៦៥៤.៦១១)	(៥.២៣៩.៤៦៨)	(២១.២៣០.៣២៤)
ចំណាយការប្រាក់	២៣	៣.៤៩៤.២៣៩	១៤.២៤៦.០១២	៨១៩.៩៨៥	៣.៣២២.៥៧៩
ការខាតបង់ឱនភាពតម្លៃសុទ្ធនៃឧបករណ៍ហិរញ្ញវត្ថុ	១០	៤២.៦៧៤	១៧៣.៩៨២	៨៤.៤៣៦	៣៤២.១៣៥
ការលុបចោលទ្រព្យសម្បត្តិ និងបរិក្ខារ	១៣	-	-	៩៥២	៣.៨៥៨
ការខាតបង់ក្នុងប្រតិបត្តិការមុនបម្រែបម្រួលទុនបង្វិល		**(១.៨៦៦.៧៣៧)**	**(៧.៦១០.៦៨៦)**	**(២.២១១.៣៦៤)**	**(៨.៩៦០.៤៤៦)**
បម្រែបម្រួលទុនបង្វិលសុទ្ធ៖					
បញ្ញើជាមួយធនាគារផ្សេងៗ		១២.៨៣២.៤៣៣	៥២.៣១៧.៨២៩	(១៨.០៥៨.០៨១)	(៧៣.១៧១.៣៤៤)
ឥណទាន និងបុរេប្រទានផ្តល់ដល់អតិថិជន		(៦.៨២៥.៤១៧)	(២៧.៨២៧.២២៥)	(៣១.៦២៤.១៣៧)	(១២៨.១៤១.០០៣)
ប្រាក់បញ្ញើតាមបទប្បញ្ញត្តិ		៣.០២១.២៥០	១២.៣១៧.៦៣៦	(១៣.៨៦៩.៨៩១)	(៥៦.២០០.៧៩៨)
ទ្រព្យសកម្មផ្សេងៗ		(៥៣៥.៦៩៩)	(២.១៨៤.០៤៥)	(១១៦.៥១៤)	(៤៧២.១១៥)
ប្រាក់បញ្ញើពីធនាគារផ្សេងៗ		១៥.៣៥៨.៦៥៧	៦២.៦១៧.២៤៥	(៩០២.២៥៧)	(៣.៦៥៥.៩៤៥)
ប្រាក់បញ្ញើពីអតិថិជន		៥២.៧១៤.០១៤	២១៤.៩១៥.០៣៦	១០២.៧៥០.៤០៨	៤១៦.៣៤៤.៦៥៤
បំណុលផ្សេងៗ		១០០.២៨៣	៤០៨.៨៥៤	៤០១.៨៦៨	១.៦២៨.៣៦៩
សាច់ប្រាក់សុទ្ធបានពីកម្មភាពប្រតិបត្តិការ		**៧៤.៧៩៨.៧៨៤**	**៣០៤.៩៥៤.៦៤៤**	**៣៦.៣៧០.០៣២**	**១៤៧.៣៧១.៣៧២**
ការប្រាក់ដែលបានទទួល		៤.៤១៣.៣៤៩	១៧.៩៩៣.២២៤	៥.២០១.៣៩៥	២១.០៧៦.០៥៣
ការប្រាក់ដែលបានបង់		(១.៦២០.៣០០)	(៦.៦០៥.៩៦៤)	(៣៥៦.៩៦៩)	(១.៤៤៦.៤៣៩)
ពន្ធលើប្រាក់ចំណូលដែលបានបង់		(២៧៦.៨៥៣)	(១.១២៨.៧៣០)	(៥២.០៧៩)	(២១១.០២៤)
ពន្ធអប្បរមាដែលបានបង់		-	-	(៣.៦៥៨)	(១៤.៨២២)
សាច់ប្រាក់សុទ្ធប្រើក្នុងសកម្មភាពប្រតិបត្តិការ		**៧៧.៣១៤.៩៨០**	**៣១៥.២១៣.១៧៤**	**៤១.១៥៨.៧២១**	**១៦៦.៧៧៥.១៤០**
លំហូរសាច់ប្រាក់ពីសកម្មភាពវិនិយោគ					
ការទិញទ្រព្យសម្បត្តិ និងបរិក្ខារ	១២ & ១៣	(៣.២៧៧.២៤៤)	(១៣.៣៦១.៣២៤)	(១.៨៨២.០៣០)	(៧.៦២៥.៩៨៦)
បុរេប្រទានសម្រាប់ការវិនិយោគពេលអនាគត	១៥	(៤៧.៣០០.០០០)	(១៩២.៨៤២.១០០)	-	-
ការទូទាត់មុនដល់ម្ចាស់ភាគហ៊ុន	១៥	(២០.០០០.០០០)	(៨១.៥៤០.០០០)	-	-
ការទិញការវិនិយោគផ្សេងៗ	១១	៦៣៥.៧២៦	២.៥៩១.៨៥៥	៥០.៤៦៧	២០៤.៤៩២
សាច់ប្រាក់សុទ្ធប្រើក្នុងសកម្មភាពវិនិយោគ		(៦៩.៩៤១.៥១៨)	(២៨៥.១៥១.៥៦៩)	(១.៨៣១.៥៦៣)	(៧.៤២១.៤៩៤)
លំហូរសាច់ប្រាក់ពីសកម្មភាពហិរញ្ញប្បទាន					
ការទូទាត់បំណុលភតិសន្យា	**១៨**	**(២៩១.៤៥៩)**	**(១.១៨៨.២៧៨)**	**(២១៣.១១៨)**	**(៨៦៨.៤៥៦)**
បម្រែបម្រួលសាច់ប្រាក់សុទ្ធ		៧.០៨២.០០៣	២៨.៨៧៣.៣២៧	៣៩.១១៤.០៤០	១៥៨.៤៨៥.១៩០
សាច់ប្រាក់ដើមគ្រា		៦១.៣១៦.៣៨៦	២៤៩.៨៦៤.២៧៣	២២.២០២.៣៤៦	៨៩.២០៩.០២៦
លម្អៀងពីការប្តូររូបិយប័ណ្ណ		-	(២.០៦៦.១១៧)	-	២.១៧០.០៥៧
សាច់ប្រាក់ចុងគ្រា		**៦៨.៣៩៨.៣៨៩**	**២៧៦.៦៧១.៤៨៣**	**៦១.៣១៦.៣៨៦**	**២៤៩.៨៦៤.២៧៣**

ព័ត៌មានបន្ថែមលើសកម្មភាពហិរញ្ញប្បទានមិនមែនសាច់ប្រាក់៖

ក្នុងឆ្នាំ២០២០ ធនាគារបានទទួលសិទ្ធិប្រើប្រាស់លើទ្រព្យសកម្មដែលមានតម្លៃស្មើនឹង ៩៥៤.៧៥៦ ដុល្លារអាមេរិក (ឆ្នាំ២០១៩៖ ១.៥៣៨.១០៣ ដុល្លារអាមេរិក) ដូចបានបង្ហាញនៅក្នុងកំណត់សម្គាល់ ១៤។

កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ

១. ព័ត៌មានទូទៅ

ធនាគារ ប៊ី.អាយ.ស៊ី (ខេមបូឌា) ប៊ែង ម.ក ហៅកាត់ថា ("ធនាគារ") ត្រូវបានបង្កើតឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជានៅថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៧ ក្រោមលេខចុះបញ្ជី ០០០២៩២០០ ហើយបានចាប់ផ្តើមប្រតិបត្តិការបន្ទាប់ពីទទួលបានអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា នៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៨ ។

សកម្មភាពចម្បងៗរបស់ធនាគាររួមមានប្រតិបត្តិការអាជីវកម្មធនាគារជាមូលដ្ឋាន និងការផ្តល់សេវាហិរញ្ញវត្ថុពាក់ព័ន្ធនៅក្នុង ព្រះរាជាណាចក្រកម្ពុជា។

ការិយាល័យដែលបានចុះបញ្ជីរបស់ធនាគារបច្ចុប្បន្នមានទីតាំងនៅផ្ទះលេខ៤៦២ ផ្លូវ៩៣ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។ បច្ចុប្បន្ននេះ ធនាគារមានសាខាមួយនៅខេត្តព្រះសីហនុ។

ធនាគារ មាននិយោជិតចំនួន ៩៤ នាក់ នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ (ឆ្នាំ២០១៩៖ និយោជិតមានចំនួន ៥០ នាក់) ។

ការរីករាលដាលនៃជំងឺកូវីដ១៩ និងប្រព័ន្ធអនុគ្រោះពន្ធ អ៊ីប៊ីអេ

វីរុសប្រភេទថ្មី កូរ៉ូណា ("កូវីដ-១៩") ត្រូវបានកំណត់ថាជាជម្ងឺរាតត្បាតជាសកល ដែលបានរីករាលដាលនៅក្នុងប្រទេសកម្ពុជាចាប់តាំង ពីខែមករា ឆ្នាំ២០២០។ ចាប់តាំងពីពេលនោះមកប្រទេសកម្ពុជាប្រឈមមុខនឹងហានិភ័យនៃការរីករាលដាលបន្ថែមទៀតដែលបណ្តាល ឱ្យមានការរំខានទៅដល់សកម្មភាពអាជីវកម្ម និងសេដ្ឋកិច្ចជាតិ។

នៅអំឡុងពេលនៃការរីកសាយភាយខ្លាំងនៃវីរុស កូវីដ១៩ នៅក្នុងប្រទេសកម្ពុជា ស្ថានការណ៍ដ៏អាក្រក់នេះបានជះឥទ្ធិពលដល់ ការផ្គត់ផ្គង់នូវវត្ថុធាតុដើម សម្រាប់រោងចក្រកាត់ដេរនៅក្នុងប្រទេសកម្ពុជា ហើយរោងចក្រមួយចំនួនបានបិទជាបណ្តោះអាសន្ន ចាប់តាំងពីខែមីនា ដល់ខែឧសភា ឆ្នាំ២០២០។ វិស័យផ្សេងៗទៀតដូចជា សណ្ឋាគារ និងទេសចរណ៍ ក៏ទទួលរងនូវផលប៉ះពាល់ផងដែរ ដោយសារតែការហោះហើរដែលមានកំណត់វាបានជះឥទ្ធិពលដល់វិស័យទេសចរណ៍ជា សកលផងដែរ។

នៅខែកុម្ភៈ ឆ្នាំ២០២០ គណកម្មការសហភាពអឺរ៉ុប បានសម្រេចដកផ្នែកមួយចំនួនជាបណ្តោះអាសន្ននូវការអនុគ្រោះពន្ធដល់កម្ពុជា ក្នុងការធ្វើពាណិជ្ជកម្មអ្វីៗគ្រប់យ៉ាងលើកលែងតែអាវុធ ហៅកាត់ថា (អ៊ីប៊ីអេ) របស់សហភាពអ៊ឺរ៉ុប ហើយបានសម្រេចដកនូវការ អនុគ្រោះពន្ធនេះទាំងស្រុងនៅថ្ងៃទី១២ ខែសីហា ឆ្នាំ២០២០ លើកលែងតែចក្រភពអង់គ្លេស និងអៀឡង់ដ៏ខាងជើង ដែលបាន សម្រេចឱ្យមានគោលនយោបាយពាណិជ្ជកម្មឯករាជ្យដោយឡែកជាមួយនឹងកម្ពុជាចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២១។

នៅថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២០ ធនាគារជាតិនៃកម្ពុជាបានចេញផ្សាយសារាចរណែនាំស្តីអំពីផលប៉ះពាល់ពីការរីករាលដាលនៃជំងឺ កូវីដ-១៩ ក្នុងគោលបំណងរក្សាស្ថិរភាពហិរញ្ញវត្ថុ គាំទ្រដល់សកម្មភាពសេដ្ឋកិច្ច និងកាត់បន្ថយបន្ទុករបស់អ្នកខ្ចីដែលកំពុងប្រឈម នឹងការលំបាកក្នុងការទូទាត់សងត្រឡប់មកវិញ ដោយសារតែការធ្លាក់ចុះនៃប្រភពចំណូលសំខាន់ៗ។ ធនាគារជាតិនៃកម្ពុជាបាន ធ្វើការណែនាំទៅកាន់ធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុឱ្យយកចិត្តទុកដាក់ទៅលើអតិថិជន ដែលប្រឈម និងផលប៉ះពាល់ពិតប្រាកដ ហើយនិងអនុញ្ញាតឱ្យធ្វើឥណទានរៀបចំឡើងវិញសម្រាប់សហគ្រាសដែលរងផលប៉ះពាល់ ពិតប្រាកដ។

ក្នុងខែមេសា ឆ្នាំ២០២១ យោងតាមអនុសាន៍របស់រាជរដ្ឋាភិបាល រាជធានីភ្នំពេញ ខេត្តព្រះសីហនុ រួមទាំងតំបន់មួយចំនួននៃ ខេត្តសៀមរាបគឺត្រូវបានដាក់ជាតំបន់បិទខ្ទប់។ ជាលទ្ធផលការិយាល័យកណ្តាលរបស់ធនាគារនៅក្នុងក្រុងភ្នំពេញ និងសាខានៅ ខេត្តព្រះសីហនុបានដាក់កម្រិតប្រតិបត្តិការរបស់ពួកគេដោយមានបុគ្គលិកស្ទើរតែទាំងអស់ដែលធ្វើការពីផ្ទះ។ គិតត្រឹមកាលបរិច្ឆេទ នៃការចេញរបាយការណ៍ហិរញ្ញវត្ថុការិយាល័យកណ្តាល និងសាខាបានចាប់ផ្តើមប្រតិបត្តិការរបស់ខ្លួនឡើងវិញហើយ។

គិតត្រឹមកាលបរិច្ឆេទនៃការចេញរបាយការណ៍ហិរញ្ញវត្ថុ ការផ្ទុះឡើងនៅក្នុងប្រទេសកម្ពុជានៅអាចគ្រប់គ្រងបាន ដោយមានកម្មវិធី ចាក់វ៉ាក់សាំងជាតិរបស់ខ្លួន និងអន្តរាគមន៍ពីរដ្ឋាភិបាលឱ្យបានទាន់ពេលវេលាតាមរយៈបទប្បញ្ញត្តិបន្ថែមដើម្បីទប់ស្កាត់ការ រីករាល ដាលនៃវីរុសនេះនៅក្នុងប្រទេសកម្ពុជា។

ក្នុងអំឡុងពេលមានរោគរាតត្បាតធនាគាររក្សាទំនាក់ទំនងទៀងទាត់ជាមួយអតិថិជន និងណែនាំនូវគំនិតផ្តួចផ្តើមផ្សេងៗដើម្បីផ្តល់ជំនួយ ភ្លាមៗ ដល់អតិថិជនរបស់ខ្លួន។ គំនិតផ្តួចផ្តើមទាំងនេះរួមមានការដាក់ឱ្យប្រើប្រាស់នូវកម្រិតនៃការដកប្រាក់កាន់តែខ្ពស់ តាមរយៈ ការដក ប្រាក់តាមម៉ាស៊ីនATM ដោយប្រើប្រាស់ QR និងបានអនុញ្ញាតឱ្យមានការណែនាំអំពីការទូទាត់ប្រាក់សំណងភ្លាមៗតាមរយៈ អ៊ីមែល។ ធនាគារបានចាត់វិធានការដើម្បីកាត់បន្ថយការរំខានដល់អាជីវកម្មរបស់ខ្លួន។ ជារួមគណៈគ្រប់គ្រងបានវាយតំលៃលើ ប្រតិបត្តិការ របស់ធនាគារដែលមិនបានរងផលប៉ះពាល់ធ្ងន់ធ្ងរពីការរីករាលដាលនៃជម្ងឺ Covid-១៩ ។

គណៈគ្រប់គ្រងក៏បានកំណត់នូវផលប៉ះពាល់នៃជំងឺកូវីដ-១៩ ដោយៈ

ក). ពិចារណាពីផលប៉ះពាល់លើផលិតផលក្នុងស្រុកសរុបក្នុងការកំណត់ភាពធ្ងន់ធ្ងរ និងលទ្ធភាពនៃសេណារីយ៉ូពីការ ធ្លាក់ចុះនៃសេដ្ឋកិច្ចដែលត្រូវបានប្រើដើម្បីប៉ាន់ស្មានការខាតបង់ឥណទានដែលប៉ាន់ស្មានទុក (ECL) ។

ខ). ចាត់វិធានការចាំបាច់ទាំងអស់ដើម្បីធានាថាធនាគារនៅតែបើកចំហសម្រាប់អាជីវកម្ម និងជៀសវាងការរំខានដល់ ដំណើរការអាជីវកម្ម។

គ). ធានាឱ្យបានថាបុគ្គលិកទាំងអស់ប្រកាន់ខ្ជាប់នូវវិធានការរបស់ធនាគារក្នុងការទប់ស្កាត់ការរីករាលដាលនៃជម្ងឺ Covid-១៩ ។

២. គម្រោងនៃរបាយការណ៍ហិរញ្ញវត្ថុ និងមូលដ្ឋាននៃការរៀបចំ និងការបង្ហាញនូវរបាយការណ៍ហិរញ្ញវត្ថុ

២.១. របាយការណ៍ដែលអនុលោមតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា

របាយការណ៍ហិរញ្ញវត្ថុត្រូវបានរៀបចំឡើងដោយអនុលោមតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (ហៅ កាត់ថា "CIFRSs")។ CIFRSs ដូចគ្នាទៅនឹងស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ("IFRSs") ដែលបានចេញផ្សាយដោយ ក្រុមប្រឹក្សា ស្តង់ដារគណនេយ្យអន្តរជាតិ ("IASB") ពីព្រោះIFRSs ត្រូវបានអនុម័តដោយក្រុមប្រឹក្សាគណនេយ្យជាតិ ("NAC") ដោយគ្មានការ កែប្រែទៅលើCIFRSsឡើយ។

២.២. មូលដ្ឋាននៃការរៀបចំ

របាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ដែលបានបង្ហាញជាប្រាក់ដុល្លារអាមេរិក ("USD") ត្រូវបានរៀបចំឡើងក្រោមអនុសាស្រ្ត ថ្លៃដើមប្រវត្តិសាស្រ្ត និងបានរៀបចំឡើងដោយអនុលោមតាម CIFRSs។

ថ្លៃដើមប្រវត្តសាស្រ្ត ជាទូទៅផ្អែកទៅលើតម្លៃសមស្រប ដែលបានផ្តល់ឱ្យនៅក្នុងការដោះដូរទំនិញ និងសេវាកម្ម។

តម្លៃសមស្រប គឺជាតម្លៃដែលនឹងត្រូវទទួលបានពីការលក់ទ្រព្យសកម្ម ឬបានទូទាត់ដើម្បីផ្ទេរបំណុលទៅក្នុងប្រតិបត្តិការសមស្រប រវាងអ្នកចូលរួមទីផ្សារនៅកាលបរិច្ឆេទនៃការវាស់វែង ដោយមិនគិតថាតម្លៃនោះអាចតាមដានបានដោយផ្ទាល់ ឬត្រូវបានប៉ាន់ស្មាន ដោយប្រើប្រាស់បច្ចេកទេសវាយតម្លៃផ្សេងទៀត។

ក្នុងការប៉ាន់ស្មានតម្លៃសមស្របនៃទ្រព្យសកម្ម និងបំណុល ធនាគារគិតពី លក្ខណៈនៃទ្រព្យសកម្ម ឬបំណុល ប្រសិនបើអ្នកចូលរួមទីផ្សារដែលគិតពីលក្ខណៈទាំងនោះនៅពេលដែលកំណត់តម្លៃនៃទ្រព្យសកម្ម និងបំណុលនៅកាលបរិច្ឆេទនៃ ការវាស់វែង។ តម្លៃសមស្របសម្រាប់ការវាស់វែង និង/ឬ ក្នុងគោលបំណងដាក់បង្ហាញនៅក្នុង របាយការណ៍ហិរញ្ញវត្ថុរួមត្រូវបាន កំណត់ជាមូលដ្ឋាន។

បន្ថែមពីនេះទៀត ក្នុងគោលបំណងនៃការធ្វើរបាយការណ៍ហិរញ្ញវត្ថុ ការវាស់វែងនៃតម្លៃសមស្រប គឺត្រូវបានធ្វើចំណាត់ថ្នាក់ទៅជា កម្រិតទី១ កម្រិតទី២ និងកម្រិតទី៣ ផ្អែកទៅលើកម្រិតនៃធាតុចូលដើម្បីវាស់វែងតម្លៃសមស្របដែលអាចតាមដានបាន រួមទាំង ធាតុចូលសំខាន់ៗដើម្បីវាស់វែងតម្លៃសមស្របទាំងអស់ដែលបានពិពណ៌នាដូចខាងក្រោមៈ

- កម្រិតទី១ ធាតុចូលត្រូវបានដាក់តម្លៃ (មិនបានធ្វើនិយ័តកម្ម) នៅក្នុងទីផ្សារសកម្មរបស់ទ្រព្យសកម្ម និងបំណុល ដែលសហគ្រាសអាចទទួលបាននៅកាលបរិច្ឆេទនៃការវាស់វែង
- កម្រិតទី២ ធាតុចូលក្រៅពីធាតុចូលដែលបានដាក់តម្លៃដោយរួមបញ្ចូលនៅក្នុងកម្រិតទី១ ដែលអាចតាមដានបាន ទៅលើទ្រព្យសកម្ម ឬបំណុលមិនថាដោយផ្ទាល់ ឬដោយប្រយោល និង
- កម្រិតទី៣ ធាតុចូល គឺជាធាតុចូលទាំងឡាយណាដែលមិនអាចតាមដានបានរបស់ទ្រព្យសកម្ម ឬបំណុល។

២.៣ មូលដ្ឋាននៃការបង្ហាញ

គណៈគ្រប់គ្រងបង្ហាញរបាយការណ៍ហិរញ្ញវត្ថុដោយផ្អែកលើលទ្ធភាពនៃការទូទាត់សងបំណុល។ ព័ត៌មានអំពីទ្រព្យសម្បត្តិរយៈពេលខ្លី និង រយៈពេលវែង និងបំណុលគឺត្រូវបានបង្ហាញនៅក្នុងផ្នែកការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ។ ការវិនិយោគផ្សេងៗ ទ្រព្យសកម្មអរូបី ទ្រព្យសម្បត្តិ និងបរិក្ខារ ទ្រព្យសកម្មដែលមានសិទ្ធិប្រើប្រាស់ និងពន្ធពន្យាលើទ្រព្យសកម្មគឺជាទ្រព្យសកម្មរយៈពេលវែង។

រូបិយប័ណ្ណគោល និងរូបិយប័ណ្ណសម្រាប់បង្ហាញ

រូបិយវត្ថុជាតិនៃព្រះរាជាណាចក្រកម្ពុជា គឺខ្មែររៀល ("KHR")។ ប៉ុន្តែដោយសារធនាគារមានប្រតិបត្តិការអាជីវកម្ម និងការរក្សាកំណត់ត្រាគណនេយ្យបឋមជាដុល្លារអាមេរិក គណៈគ្រប់គ្រងបានកំណត់យករូបិយប័ណ្ណដុល្លារអាមេរិកជារូបិយប័ណ្ណរបស់ធនាគារ សម្រាប់គោលបំណងនៃការវាស់វែង និងបង្ហាញ ព្រោះវាបានឆ្លុះបញ្ចាំងពីព្រឹត្តិការណ៍នៃស្ថានភាពសេដ្ឋកិច្ច និងស្ថានការណ៍ របស់ធនាគារ។

ប្រតិបត្តិការជារូបិយប័ណ្ណបរទេសក្រៅពីដុល្លារអាមេរិក ត្រូវបានប្តូរទៅជាដុល្លារអាមេរិក ដោយប្រើប្រាស់អត្រាប្តូរប្រាក់ទូទៅនៅកាលបរិច្ឆេទនៃប្រតិបត្តិការនោះ។ ទ្រព្យសកម្ម ឬបំណុល ដែលគិតជារូបិយប័ណ្ណក្រៅពីដុល្លារអាមេរិក នៅកាលបរិច្ឆេទនៃ របាយការណ៍ ត្រូវបានប្តូរទៅជាដុល្លារអាមេរិក ដោយប្រើប្រាស់អត្រាប្តូរប្រាក់នាកាលបរិច្ឆេទនៃរបាយការណ៍នោះ។ ភាពលម្អៀងពីការប្តូររូបិយប័ណ្ណ ដែលបានកើតឡើងពីការប្តូរប្រាក់ត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណូលលម្អិត។

ការប្តូររូបិយប័ណ្ណពីប្រាក់ដុល្លារអាមេរិក ទៅជាខ្មែររៀល បានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ គឺក្នុងគោលបំណង ដើម្បីអនុលោម តាមច្បាប់ស្តីពីគណនេយ្យ និងសវនកម្មនៃកម្ពុជា (ខែមេសា ឆ្នាំ២០១៦) ព្រមទាំងត្រូវបានធ្វើឡើង ដោយប្រើប្រាស់អត្រាប្តូរប្រាក់ ជាផ្លូវការដែលបានបង្ហាញជាប្រាក់រៀល ដោយយោងទៅតាមអត្រាប្តូរប្រាក់ក្នុង ១ដុល្លារអាមេរិកដូចដែលបានប្រកាសដោយ ធនាគារជាតិនៃកម្ពុជា និងអគ្គនាយកដ្ឋានពន្ធដារ ("GDT") សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ និង ឆ្នាំ២០១៩ មានដូចខាងក្រោម ៖

	ឆ្នាំ២០២០	ឆ្នាំ២០១៩
អត្រាបិទ	**៤.០៤៥**	៤.០៧៥
អត្រាមធ្យម	**៤.០៧៧***	៤.០៥២

* អត្រាមធ្យមត្រូវបានកំណត់ដោយការប្រើប្រាស់អត្រាប្តូរប្រាក់ប្រចាំថ្ងៃ ដែលបានចេញផ្សាយធនាគារជាតិនៃកម្ពុជាចាប់ពីខែមករា ដល់ខែធ្នូ ឆ្នាំ២០២០ ដោយអនុលោមតាមសេចក្តីណែនាំលេខ ២៧៦១៧ ដែលបានចេញផ្សាយដោយអគ្គនាយកដ្ឋានពន្ធដារ។

ការប្តូររូបិយប័ណ្ណទាំងនេះមិនមែនជាមូលដ្ឋានត្រូវបានបកស្រាយថាចំនួនទឹកប្រាក់ដុល្លារអាមេរិក ត្រូវបាន ឬគួរត្រូវបានទៅជា ប្រាក់រៀលនៅថ្ងៃអនាគត តាមអត្រាដែលបានបង្ហាញនេះ ឬអត្រាប្តូរប្រាក់ផ្សេងទៀតទេ។

២.៤ ការបង្គត់ចំនួន

ចំនួនទឹកប្រាក់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុត្រូវបានបង្គត់ទៅចំនួនប្រាក់ដុល្លារអាមេរិក ("USD") និងខ្មែរពាន់រៀល ("KH'000") ដែលជិតបំផុត។

២.៥ មូលដ្ឋាននៃការដាក់បញ្ចូលគ្នា

របាយការណ៍ហិរញ្ញវត្ថុរួមមានរបាយការណ៍ហិរញ្ញវត្ថុរបស់ស្នាក់ការកណ្តាល និងសាខាបន្ទាប់ពីការលុបចោលសមតុល្យ និង ប្រតិបត្តិការសំខាន់ៗរបស់អន្តសាខាទាំងអស់។

៣. ស្តង់ដារថ្មី វិសោធនកម្ម និងការបកស្រាយទៅលើស្តង់ដារដែលមានស្រាប់តែមិនទាន់បានអនុវត្តដោយធនាគារ

ស្តង់ដារថ្មី ការធ្វើវិសោធនកម្មស្តង់ដារ និងការបកស្រាយមួយចំនួន បានចូលជាធរមាន សម្រាប់ការិយបរិច្ឆេទដែលចាប់ផ្តើម បន្ទាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២១ ដែលការអនុវត្តមុនកាលកំណត់ត្រូវបានអនុញ្ញាត ប៉ុន្តែធនាគារ មិនបានអនុវត្តស្តង់ដារមុនកាលកំណត់ក្នុងការរៀបចំ របាយការណ៍ហិរញ្ញវត្ថុនេះនៅឡើយទេ។

ស្តង់ដារដែលបានធ្វើវិសោធនកម្មខាងក្រោមនេះ មិនត្រូវបានរំពឹងថានឹងមានផលប៉ះពាល់ជាសារវន្តទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារទេ៖

- ការបកស្រាយទៅលើគោលនយោបាយគណនេយ្យ (ការធ្វើវិសោធនកម្មលើ ស.គ.អ.ក ១)
- និយមន័យការប៉ាន់ស្មានគណនេយ្យ (ការធ្វើវិសោធនកម្មលើ ស.គ.អ.ក ៨) និង
- សម្បទានការជួលដែលទាក់ទងនឹង កូវីដ ១៩ ដែលហួសពីថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ (ការធ្វើវិសោធនកម្មចំពោះស.រ.ហ.អ.ក ១៦)

៤. សេចក្តីសង្ខេបលើគោលនយោបាយគណនេយ្យសំខាន់ៗ

គោលនយោបាយគណនេយ្យសំខាន់ៗដែលត្រូវបានប្រើក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុទាំងនេះត្រូវបានសង្ខេបដូចខាងក្រោម។ គោលនយោបាយគណនេយ្យទាំងនេះត្រូវបានប្រើប្រាស់គ្រប់ពេលវេលាដែលបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ លើកលែងតែមានការបញ្ជាក់ផ្សេងពីនេះ។

៤.១ ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ

ការទទួលស្គាល់ និងការវាស់វែងដំបូង

ធនាគារទទួលស្គាល់ជាលើកដំបូងនូវតំណទាន ប្រាក់កម្ចី និងបុរេប្រទានផ្តល់ដល់អតិថិជន ប្រាក់បញ្ញើពីធនាគារផ្សេង បំណុល ភតិសន្យា ទ្រព្យសកម្មផ្សេងៗ និងបំណុលផ្សេងៗនៅកាលបរិច្ឆេទដែលកើតមានប្រតិបត្តិការ។ រាល់ទ្រព្យសកម្ម និងបំណុល ហិរញ្ញវត្ថុផ្សេងទៀតត្រូវបានទទួលស្គាល់នៅកាលបរិច្ឆេទដែលធនាគារក្លាយជាភាគីកិច្ចសន្យា។

ទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ ត្រូវបានវាស់វែងដំបូងតាមតម្លៃសមស្រប (សម្រាប់សមាសធាតុដែលមិនត្រូវបានវាស់វែង តាមចំណេញ ឬខាត "FVTPL") បូកនឹងថ្លៃប្រតិបត្តិការផ្សេងទៀត ដែលពាក់ព័ន្ធដោយផ្ទាល់ទៅនឹងប្រតិបត្តិការទិញចេញផ្សាយ ទ្រព្យសកម្ម ឬបំណុលហិរញ្ញវត្ថុទាំងនោះ។

ការធ្វើចំណាត់ថ្នាក់

នៅក្នុងការទទួលស្គាល់ដំបូង ទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានចាត់ថ្នាក់តាមការវាស់វែង រំលស់ថ្លៃដើម តម្លៃសមស្របតាមចំណូលលម្អិត ផ្សេងៗ FVOCI ឬ FVTPL។

ទ្រព្យសកម្មហិរញ្ញវត្ថុ ត្រូវបានវាស់វែងតាមរំលស់ថ្លៃដើម ប្រសិនបើវាបំពេញទៅនឹងលក្ខខណ្ឌដូចខាងក្រោមហើយមិនត្រូវបានកំណត់ជា FVTPL នោះទេ៖

- ទ្រព្យសកម្មដែលមាននៅក្នុងគំរូអាជីវកម្ម ក្នុងគោលបំណងរក្សាទុកដើម្បីការប្រមូលសាច់ប្រាក់តាមកិច្ចសន្យា និង
- លក្ខខណ្ឌកិច្ចសន្យារបស់ទ្រព្យសកម្មហិរញ្ញវត្ថុ ផ្តល់នូវកាលបរិច្ឆេទជាក់លាក់ចំពោះលំហូរទឹកប្រាក់ដែលសម្រាប់ទូទាត់តែប្រាក់ដើម និងការប្រាក់ ("SPPI") ។

ឧបករណ៍បំណុល ត្រូវបានវាស់វែងនៅ FVOCI លុះត្រាតែវាបានបំពេញនឹងលក្ខខណ្ឌទាំងពីរដូចខាងក្រោម ហើយមិនត្រូវបានកំណត់ជា FVTPL នោះទេ៖

- ទ្រព្យសកម្មដែលមាននៅក្នុងគំរូអាជីវកម្ម ក្នុងគោលបំណងរក្សាទុកដើម្បីការប្រមូលសាច់ប្រាក់តាមកិច្ចសន្យា និងលក់ ទ្រព្យសកម្មហិរញ្ញវត្ថុ និង
- លក្ខខណ្ឌកិច្ចសន្យារបស់ទ្រព្យសកម្មហិរញ្ញវត្ថុ ផ្តល់នូវកាលបរិច្ឆេទជាក់លាក់ ចំពោះលំហូរទឹកប្រាក់ដែលសម្រាប់ទូទាត់តែប្រាក់ដើម និងការប្រាក់ ("SPPI") ។

សម្រាប់ការទទួលស្គាល់ការវិនិយោគលើមូលធនជាលើកដំបូង ដែលមិនត្រូវបានកាន់កាប់សម្រាប់ជួញដូរជើងសាធនាគារត្រូវតែជ្រើសរើសការបង្ហាញការប្រែប្រួលនាពេលបន្ទាប់តាមរយៈលទ្ធផលលម្អិតផ្សេងៗ។ ការជ្រើសរើសនេះធ្វើឡើងដោយផ្អែកលើការវិនិយោគនីមួយៗ ។

ទ្រព្យសកម្មហិរញ្ញវត្ថុទាំងអស់ផ្សេងទៀតត្រូវបានចាត់ថ្នាក់តាមការវាស់វែងតាម FVTPL

លើសពីនេះ សម្រាប់ការទទួលស្គាល់ជាលើកដំបូង ធនាគារអាចនឹងកំណត់ទ្រព្យសកម្មហិរញ្ញវត្ថុ ដែលបំពេញតាមលក្ខខណ្ឌ ក្នុងការវាស់វែងតាមរំលស់ថ្លៃដើម ឬតាម FVOCI ប្រសិនបើវាស់វែងតាម FVTPL នឹងលុបបំបាត់ ឬកាត់បន្ថយជាសារវន្តនូវភាពមិនស៊ីគ្នា នៃគណនេយ្យដែលនឹងកើតឡើង។

ការវាយតម្លៃគំរូអាជីវកម្ម

ធនាគារ ធ្វើការវាយតម្លៃអំពីគោលបំណងនៃគំរូអាជីវកម្ម លើទ្រព្យសកម្មក្នុងកម្រិតសំណុំឥណទាននីមួយៗ ព្រោះគំរូនេះបង្ហាញ យ៉ាងច្បាស់ពីវិធីគ្រប់គ្រងអាជីវកម្ម និងវិធីផ្តល់ព័ត៌មានទៅអ្នកគ្រប់គ្រង។ ព័ត៌មានទាំងនោះរួមមាន៖

- គោលនយោបាយ និងគោលបំណងដែលបានបញ្ជាក់សម្រាប់សំណុំឥណទាន និងអនុវត្តនូវគោលនយោបាយ ទាំងនោះ។ ជាពិសេសថាតើយុទ្ធសាស្ត្ររបស់អ្នកគ្រប់គ្រង ផ្តោតលើការស្វែងរកចំណូលការប្រាក់តាមកិច្ចសន្យា រក្សានូវទម្រង់អត្រាការប្រាក់ជាក់លាក់មួយ ធ្វើឱ្យស៊ីសង្វាក់គ្នារវាង រយៈពេលនៃទ្រព្យសកម្មហិរញ្ញវត្ថុ ទៅនឹងរយៈពេលនៃបំណុលដែលជាហិរញ្ញប្បទានរបស់ទ្រព្យសកម្មទាំងនោះ ឬការធ្វើឱ្យមានលំហូរទឹកប្រាក់តាមរយៈការលក់ទ្រព្យសកម្ម
- វិធីក្នុងការវាយតម្លៃលទ្ធផលនៃសំណុំឥណទាន និងវិធីរាយការណ៍ទៅអ្នកគ្រប់គ្រងរបស់ធនាគារ

- ហានិភ័យដែលប៉ះពាល់ដល់លទ្ធផលនៃគំរូអាជីវកម្ម (និងទ្រព្យសកម្មហិរញ្ញវត្ថុដែលមាននៅក្នុងគំរូអាជីវកម្មនោះ) និង យុទ្ធសាស្ត្រសម្រាប់គ្រប់គ្រងហានិភ័យទាំងនោះ
- របៀបដែលអ្នកគ្រប់គ្រងអាជីវកម្មទទួលបានការទូទាត់ (ឧទាហរណ៍៖ តើការទូទាត់សំណងផ្អែកលើតម្លៃសមស្របនៃទ្រព្យសកម្មដែលបានគ្រប់គ្រង ឬសាច់ប្រាក់តាមកិច្ចសន្យាដែលបានប្រមូល) និង
- ភាពញឹកញាប់ បរិមាណ និងរយៈពេលនៃការលក់ក្នុងគ្រាមុន មូលហេតុនៃការលក់នោះ និងការរំពឹងទុកអំពីសកម្មភាពលក់ នាពេលអនាគត។ ទោះជាយ៉ាងណាក៏ដោយ ព័ត៌មានអំពីសកម្មភាពលក់មិនត្រូវបានចាត់ទុកថាដាច់ដោយឡែកឡើយ ប៉ុន្តែជាផ្នែកមួយនៃការវាយតម្លៃទូទៅអំពីរបៀបដែលធ្វើឱ្យសម្រេចបាននូវគោលបំណងក្នុងការគ្រប់គ្រងទ្រព្យសកម្មហិរញ្ញវត្ថុ និងលំហូរទឹកប្រាក់របស់ធនាគារ។

ទ្រព្យសកម្មហិរញ្ញវត្ថុសម្រាប់ការជួញដូរ ឬចាត់ចែង ហើយដែលលទ្ធផលត្រូវបានវាយតម្លៃតាមមូលដ្ឋានតម្លៃសមស្រប ត្រូវបាន វាស់វែងតាម FVTPL ព្រោះទ្រព្យសកម្មទាំងនោះមិនមែនសម្រាប់ប្រមូលសាច់ប្រាក់តាមកិច្ចសន្យា ឬមិនមែនសម្រាប់ទាំង ការប្រមូលសាច់ប្រាក់តាមកិច្ចសន្យា និងសម្រាប់លក់ឡើយ ។

ការវាយតម្លៃថាតើលំហូរទឹកប្រាក់តាមកិច្ចសន្យាគឺសម្រាប់ទូទាត់តែប្រាក់ដើម និងការប្រាក់

ចំពោះគោលបំណងនៃការវាយតម្លៃនេះ "ប្រាក់ដើម" គឺជាតម្លៃសមស្របនៃទ្រព្យសកម្មហិរញ្ញវត្ថុនៅពេលទទួលស្គាល់ជាលើកដំបូង។ "ការប្រាក់" គឺជាតម្លៃតបស្នងមួយសម្រាប់ពេលវេលានៃការប្រើប្រាស់ទឹកប្រាក់ សម្រាប់រយៈពេលណាមួយ និងសម្រាប់ហានិភ័យ ដែលពាក់ព័ន្ធនឹងបរិមាណប្រាក់ដើមនៅជាប់ជំពាក់ក្នុងអំឡុងពេលជាក់លាក់មួយ និងសម្រាប់ការចំណាយរួមទាំងហានិភ័យក្នុងការផ្តល់កម្ចីជាមូលដ្ឋានផ្សេងៗទៀត (ដូចជាហានិភ័យសាច់ប្រាក់ងាយស្រួល និងចំណាយរដ្ឋបាល) រួមទាំងប្រាក់ចំណេញ ។

ដើម្បីវាយតម្លៃថាតើលំហូរទឹកប្រាក់តាមកិច្ចសន្យាគឺសម្រាប់តែទូទាត់ប្រាក់ដើម និងការប្រាក់ ធនាគារត្រូវពិចារណាលក្ខខណ្ឌ កិច្ចសន្យារបស់ឧបករណ៍ហិរញ្ញវត្ថុ រួមបញ្ចូលការវាយតម្លៃថាតើ ទ្រព្យសកម្មហិរញ្ញវត្ថុ មានលក្ខខណ្ឌកិច្ចសន្យាដែលអាចផ្លាស់ប្តូរ ពេលវេលា ឬចំនួនលំហូរទឹកប្រាក់តាមកិច្ចសន្យា ដែលអាចធ្វើឱ្យខុសពីលក្ខខណ្ឌនៃការទូទាត់ប្រាក់ដើម និងការប្រាក់ ។

ក្នុងការវាយតម្លៃ ធនាគារពិចារណាលើ៖

- ព្រឹត្តិការណ៍ជាយថាភាពដែលអាចផ្លាស់ប្តូរចំនួន និងរយៈពេលនៃលំហូរទឹកប្រាក់
- លក្ខខណ្ឌពិសេស
- លក្ខខណ្ឌសងប្រាក់មុនកាលកំណត់ និងការពន្យាពេលសង
- លក្ខខណ្ឌដែលកម្រិតធនាគារ ក្នុងការទាមទារមកវិញនូវសាច់ប្រាក់ពីទ្រព្យសកម្មជាក់លាក់ (ដូចជាឥណទានដែលមិនអាចប្រមូលមកវិញបាន) និង
- លក្ខណៈពិសេសដែលកែប្រែតម្លៃតបស្នងអំពីតម្លៃប្រាក់តាមពេលវេលា (ឧទាហរណ៍ ការកំណត់អត្រាការប្រាក់ ឡើងវិញតាមកាលកំណត់)។

ឥណទានដែលមិនអាចប្រមូលមកវិញបាន

ក្នុងករណីខ្លះ ឥណទានដែលផ្តល់ដោយធនាគារ ដែលត្រូវបានការពារដោយទ្រព្យដាក់ធានារបស់អតិថិជន ក៏មានកំហិតធនាគារក្នុងការទាមទារសាច់ប្រាក់មកវិញដែរ (ឥណទានដែលមិនអាចប្រមូលមកវិញបាន)។ ក្នុងករណីនេះ ធនាគារធ្វើការវិនិច្ឆ័យក្នុងការវាយតម្លៃថា តើឥណទាននោះអាចប្រមូលមកវិញបានតែប្រាក់ដើម និងការប្រាក់ឬទេ។ ជាទូទៅធនាគារពិចារណាលើព័ត៌មានខាងក្រោមក្នុងការវិនិច្ឆ័យ៖

- ថាតើកិច្ចសន្យាមានបញ្ជាក់ច្បាស់ពីចំនួន និងកាលបរិច្ឆេទនៃការបង់សងកម្ចីដែរ ឬទេ
- តម្លៃសមស្របនៃទ្រព្យបញ្ចាំពាក់ព័ន្ធនឹងចំនួននៃទ្រព្យសកម្មហិរញ្ញវត្ថុដែលមានការធានា
- សមត្ថភាព និងឆន្ទៈរបស់អតិថិជន ក្នុងការទូទាត់សងតាមកិច្ចសន្យា ទោះបីមានឱនភាពនៃតម្លៃទ្រព្យបញ្ចាំក៏ដោយ
- ថាតើអតិថិជនគឺជារូបវន្តបុគ្គល ឬជាអង្គភាពប្រតិបត្តិការសំខាន់ ឬជាអង្គភាពដែលមានគោលបំណងពិសេស
- ហានិភ័យរបស់ធនាគារក្នុងការបាត់បង់ទ្រព្យសកម្ម ទាក់ទងនឹងឥណទានដែលមិនអាចប្រមូលមកវិញបាន
- ថាតើទ្រព្យដាក់ធានាគឺជាទ្រព្យទាំងអស់ដែលអតិថិជនមាន ឬជាផ្នែកមួយនៃទ្រព្យសកម្មផ្សេងៗទៀតរបស់អតិថិជន និង
- ថាតើធនាគារទទួលបានអត្ថប្រយោជន៍ពីទ្រព្យសកម្មនេះ ឬទេ។

ការធ្វើចំណាត់ថ្នាក់ឡើងវិញ

ទ្រព្យសកម្មហិរញ្ញវត្ថុមិនត្រូវបានធ្វើចំណាត់ថ្នាក់ឡើងវិញ បន្ទាប់ពីការទទួលស្គាល់តម្លៃដំបូងឡើយ លើកលែងតែក្នុងអំឡុងពេល ដែលធនាគារផ្លាស់ប្តូរគំរូអាជីវកម្មរបស់ខ្លួន ក្នុងការគ្រប់គ្រងទ្រព្យសកម្មហិរញ្ញវត្ថុ ។

បំណុលហិរញ្ញវត្ថុ

ធនាគារចាត់ថ្នាក់បំណុលហិរញ្ញវត្ថុរបស់ខ្លួនដូចបានវាស់វែងតាមរំលស់ថ្លៃដើម ឬ FVTPL។ បំណុលហិរញ្ញវត្ថុ ត្រូវបានចាត់ថ្នាក់តាម FVTPL ប្រសិនបើត្រូវចាត់ថ្នាក់សម្រាប់ការជួញដូរ ជានិស្សន្ទ ឬបំណុលហិរញ្ញវត្ថុផ្សេងៗ ត្រូវបានចាត់ថ្នាក់ដំបូងតាមតម្លៃសមស្រប។ បំណុលហិរញ្ញវត្ថុតាម FVTPL ត្រូវបានវាស់វែងតាមតម្លៃសមស្រប ហើយចំណេញ ឬខាតសុទ្ធរួមទាំងការប្រាក់ត្រូវបានទទួលស្គាល់ជាចំណេញ ឬខាត។ បន្ទាប់ពីការទទួលស្គាល់លើកដំបូង បំណុលត្រូវបានវាស់វែងតាមរំលស់ថ្លៃដើមដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព។ ចំណាយការប្រាក់ ប្រាក់ចំណេញ និងខាតលើការប្តូររូបិយប័ណ្ណបរទេស ត្រូវបានទទួលស្គាល់ជាចំណេញ ឬខាត។ ប្រាក់ចំណេញ ឬខាតណាមួយលើការឈប់ទទួលស្គាល់ ត្រូវបានទទួលស្គាល់ផងដែរនៅក្នុងប្រាក់ចំណេញ ឬខាត ។

ការឈប់ទទួលស្គាល់

ទ្រព្យសកម្មហិរញ្ញវត្ថុ

ធនាគារឈប់ទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុ នៅពេលដែលសិទ្ធិក្នុងកិច្ចសន្យាក្នុងការទទួលលំហូរទឹកប្រាក់ពីទ្រព្យសកម្មហិរញ្ញវត្ថុផុតកំណត់ ឬការផ្ទេរសិទ្ធិទទួលលំហូរទឹកប្រាក់តាមកិច្ចសន្យាក្នុងប្រតិបត្តិការ ដែលហានិភ័យទាំងអស់ និងភាពជាកម្មសិទ្ធិនៃ ទ្រព្យសកម្មហិរញ្ញវត្ថុ ត្រូវបានផ្ទេរ ឬក្នុងករណីដែលធនាគារមិនផ្ទេរ ឬមិនរក្សាទុកនូវរាល់ហានិភ័យ និងភាពជាកម្មសិទ្ធិហើយវា មិនរក្សាការគ្រប់គ្រងទ្រព្យសកម្មហិរញ្ញវត្ថុ ។

ចំពោះការឈប់ទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុ ភាពលម្អៀងរវាងតម្លៃយោងរបស់ទ្រព្យសកម្ម (ឬតម្លៃយោងដែលជាចំណែកនៃ ទ្រព្យសកម្មដែលឈប់ទទួលស្គាល់) និងផលបូកនៃ (i). តម្លៃតបស្នងដែលទទួលបាន (រាប់បញ្ចូលទាំងទ្រព្យសកម្មថ្មីដែលទទួលបាន ដកបំណុលថ្មីដែលទទួលយក) និង (ii) ចំណេញ ឬខាតដែលបានទទួលស្គាល់ក្នុង OCI ត្រូវបានទទួលស្គាល់នៅក្នុងចំណេញ និងខាត ។

បំណុលហិរញ្ញវត្ថុ

ធនាគារឈប់ទទួលស្គាល់បំណុលហិរញ្ញវត្ថុ នៅពេលដែលកាតព្វកិច្ចក្រោមកិច្ចសន្យាត្រូវបានរំលាយ ឬលុបចោល ឬផុតអាណត្តិ។

ការកែប្រែទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ

ទ្រព្យសកម្មហិរញ្ញវត្ថុ

ប្រសិនបើលក្ខខណ្ឌនៃទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានកែប្រែ នោះធនាគារវាយតម្លៃថាតើលំហូរទឹកប្រាក់នៃទ្រព្យសកម្មដែលបានកែប្រែ នោះមានភាពខុសគ្នាខ្លាំង ឬទេ។

ប្រសិនបើលំហូរទឹកប្រាក់មានភាពខុសគ្នាខ្លាំង នោះសិទ្ធិតាមកិច្ចសន្យាចំពោះលំហូរទឹកប្រាក់ពីទ្រព្យសកម្ម ហិរញ្ញវត្ថុដើម ត្រូវបានចាត់ទុកថាផុតអាណត្តិ។ ក្នុងករណីនេះទ្រព្យសកម្មហិរញ្ញវត្ថុដើម ត្រូវឈប់ទទួលស្គាល់ (សូមមើល(iii)) ហើយទ្រព្យសកម្មហិរញ្ញវត្ថុថ្មី ត្រូវបានទទួលស្គាល់តាមតម្លៃសមស្របបូកនឹងថ្លៃចំណាយប្រតិបត្តិការ។ ថ្លៃសេវានានាដែលទទួលបានជាផ្នែកនៃការកែប្រែនេះ ត្រូវបានរាប់បញ្ចូលដូចខាងក្រោម៖

- ថ្លៃសេវា ដែលត្រូវបានពិចារណាក្នុងការកំណត់តម្លៃសមស្របនៃទ្រព្យសកម្មថ្មី និងថ្លៃសេវាដែល ទទួលបានមកវិញ លើថ្លៃចំណាយប្រតិបត្តិការដែលកើតឡើង ត្រូវបានរាប់បញ្ចូលក្នុងការវាស់វែងដំបូងនៃទ្រព្យសកម្ម និង
- ថ្លៃសេវាផ្សេងទៀតត្រូវបានរាប់បញ្ចូលក្នុងចំណេញ និងខាត ដែលជាផ្នែកមួយនៃការចំណេញ ឬខាតលើទ្រព្យសកម្ម ដែលឈប់ទទួលស្គាល់។
- ប្រសិនបើលំហូរទឹកប្រាក់ត្រូវបានកែប្រែនៅពេលដែលអតិថិជនជួបការលំបាកផ្នែកហិរញ្ញវត្ថុ នោះគោលបំណងនៃ ការកែប្រែជាទូទៅ គឺដើម្បីទទួលបានមកវិញជាអតិបរមាលើលក្ខខណ្ឌនៃកិច្ចសន្យាដើម ជាជាងបង្កើតទ្រព្យសកម្មថ្មី ដែលមានលក្ខខណ្ឌខុសគ្នាខ្លាំង។ ប្រសិនបើធនាគារមានគម្រោងកែប្រែទ្រព្យសកម្មហិរញ្ញវត្ថុតាមរបៀបមួយ ដែលអាចនាំ ឱ្យមានការលើកលែងចំពោះលំហូរទឹកប្រាក់ ទ្រព្យសកម្មនោះ ត្រូវបានយកមកពិចារណាជាមុន ថាតើផ្នែកមួយនៃ ទ្រព្យសកម្មគួរតែត្រូវបានលុបចេញពីបញ្ជីមុនពេលធ្វើការកែប្រែ ឬទេ (សូមមើលខាងក្រោមសម្រាប់គោលនយោបាយ ការលុបចេញពីបញ្ជី)។វិធីសាស្ត្រនេះជះឥទ្ធិពលដល់លទ្ធផលនៃការវាយតម្លៃបរិមាណ ហើយក្នុងករណីនេះមានន័យថាលក្ខណៈវិនិច្ឆ័យនៃការឈប់ទទួលស្គាល់ទ្រព្យ ជាទូទៅមិនអាចអនុវត្តបាននោះទេ។
- ប្រសិនបើការកែតម្រូវទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានវាស់វែងតាមរំលស់ថ្លៃដើម ឬ FVOCI មិនបណ្តាលឱ្យមាន ការឈប់ទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុទេនោះ នោះធនាគារនឹងគណនាឡើងវិញនូវតម្លៃយោងនៃទ្រព្យសកម្ម ហិរញ្ញវត្ថុជាមុន ដោយប្រើអត្រាការប្រាក់ប្រសិទ្ធភាពដំបូងនៃទ្រព្យសកម្ម និងទទួលស្គាល់លទ្ធផលនៃការកែតម្រូវ ជាចំណេញ ឬខាត។ សម្រាប់ទ្រព្យសកម្មហិរញ្ញវត្ថុដែលមានអត្រាថេរអត្រាការប្រាក់ប្រសិទ្ធភាពដំបូងដែលប្រើដើម្បី គណនាចំណេញ ឬខាតពីការកែតម្រូវ ត្រូវបានកែប្រែដើម្បីឆ្លុះបញ្ចាំងពីលក្ខខណ្ឌទីផ្សារបច្ចុប្បន្ន នៅពេលដែលធ្វើការកែតម្រូវ។

- រាល់ការចំណាយ ឬថ្លៃសេវាដែលកើតឡើង និងថ្លៃសេវាទទួលបាន ដែលជាផ្នែកមួយនៃការកែតម្រូវទាក់ទងនឹង តម្លៃយោងដុលនៃទ្រព្យសកម្មហិរញ្ញវត្ថុ ដែលបានធ្វើការកែតម្រូវ ត្រូវបានរំលស់ផ្អែកលើរយៈពេលដែលនៅសល់ នៃទ្រព្យសកម្មហិរញ្ញវត្ថុដែលបានកែតម្រូវនោះ។
- ប្រសិនបើការកែតម្រូវនេះ ត្រូវបានធ្វើឡើងដោយសារតែអតិថិជនជួបការលំបាកផ្នែកហិរញ្ញវត្ថុ នោះចំណេញ ឬខាតត្រូវបានបង្ហាញជាមួយគ្នានឹងការខាតបង់លើឱនភាពនៃតម្លៃ នៃទ្រព្យសកម្ម។ ក្នុងករណីផ្សេងទៀត វាត្រូវបាន បង្ហាញជាចំណូលការប្រាក់ ដែលគណនាដោយប្រើវិធីសាស្ត្រអត្រាការប្រាក់ប្រសិទ្ធភាព។

បំណុលហិរញ្ញវត្ថុ

ធនាគារ ឈប់ទទួលស្គាល់បំណុលហិរញ្ញវត្ថុ នៅពេលដែលលក្ខខណ្ឌរបស់វាត្រូវបានកែតម្រូវ ហើយលំហូរទឹកប្រាក់នៃបំណុល ដែលបានកែតម្រូវនោះមានភាពខុសគ្នាខ្លាំង។ ក្នុងករណីនេះ បំណុលហិរញ្ញវត្ថុថ្មី ត្រូវបានទទួលស្គាល់តាមតម្លៃសមស្រប។ ភាពលម្អៀងរវាងតម្លៃយោងនៃបំណុលហិរញ្ញវត្ថុដែលមិនត្រូវបានទទួលស្គាល់ និងតម្លៃតបស្នង ត្រូវបានទទួលស្គាល់នៅក្នុងចំណេញ និងខាត។ តម្លៃតបស្នងរួមមានទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុដែលបានផ្ទេរ (ប្រសិនបើមាន) និងការទទួលយកបំណុលរួមទាំងបំណុលហិរញ្ញវត្ថុដែលបានកែតម្រូវថ្មី។

ប្រសិនបើការកែតម្រូវបំណុលហិរញ្ញវត្ថុនេះមិនធ្វើឱ្យមានការឈប់ទទួលស្គាល់ទេ នោះរំលស់ថ្លៃដើមនៃបំណុល ត្រូវគណនាឡើងវិញ ដោយធ្វើអប្បហារលំហូរទឹកប្រាក់ដែលបានកែប្រែ តាមអត្រាការប្រាក់ប្រសិទ្ធភាពដំបូង ហើយលទ្ធផលនៃការចំណេញ ឬខាត ត្រូវបានទទួលស្គាល់នៅក្នុងចំណេញ និងខាត។ សម្រាប់បំណុលហិរញ្ញវត្ថុមានអត្រាអថេរ អត្រាការប្រាក់ប្រសិទ្ធភាពដំបូងដែលប្រើដើម្បីគណនាចំណេញ ឬខាតពីការកែតម្រូវ ត្រូវបានកែប្រែដើម្បីឆ្លុះបញ្ចាំងពីលក្ខខណ្ឌទីផ្សារបច្ចុប្បន្ន នៅពេលដែលធ្វើការកែតម្រូវ។ រាល់ការចំណាយ និងថ្លៃសេវាដែលកើតមាន ត្រូវបានទទួលស្គាល់ជាការកែតម្រូវទៅលើតម្លៃយោងនៃបំណុល និងរំលស់តាមរយៈពេលដែលនៅសល់នៃបំណុលហិរញ្ញវត្ថុដែលបានកែតម្រូវដោយគណនាអត្រាការប្រាក់ប្រសិទ្ធភាពឡើងវិញលើឧបករណ៍ហិរញ្ញវត្ថុ។

ការកាត់កង

ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ អាចត្រូវកាត់កងគ្នាបាន និងត្រូវបង្ហាញជាចំនួនសុទ្ធនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ លុះត្រាតែធនាគារមានសិទ្ធិតាមច្បាប់ដើម្បីធ្វើការកាត់កងគ្នាបាន និងមានបំណងធ្វើការទូទាត់ដោយផ្អែកលើមូលដ្ឋានចំនួននៅសល់សុទ្ធ ឬក៏ទទួលស្គាល់ទ្រព្យសកម្ម និងទូទាត់បំណុលក្នុងពេលដំណាលគ្នា។

ការវាស់វែងតម្លៃសមស្រប

តម្លៃសមស្រប គឺជាតម្លៃដែលនឹងទទួលបានដោយការលក់ទ្រព្យសកម្ម ឬតម្លៃដែលបានទូទាត់ចំពោះការផ្ទេរបំណុលនៅក្នុងប្រតិបត្តិការធម្មតារវាងអ្នកចូលរួមក្នុងទីផ្សារ នាកាលបរិច្ឆេទនៃការវាស់វែងនៅក្នុងទីផ្សារគោល ឬក្នុងករណីមិនមានទីផ្សារគោល គឺយកទីផ្សារជាអាទិភាពបំផុត ដែលធនាគារអាចកំណត់រកបាននៅកាលបរិច្ឆេទនៃការវាស់វែងនោះ។ តម្លៃសមស្របរបស់បំណុល ឆ្លុះបញ្ចាំងពីហានិភ័យការមិនអនុវត្តកាតព្វកិច្ច។

ធនាគារវាស់វែងតម្លៃសមស្របរបស់ឧបករណ៍ហិរញ្ញវត្ថុមួយ ដោយប្រើសម្រង់តម្លៃនៅក្នុងទីផ្សារសកម្មរបស់ឧបករណ៍នោះ ប្រសិនបើមាន។ ទីផ្សារមួយចាត់ទុកជាទីផ្សារសកម្ម ប្រសិនបើប្រតិបត្តិការរបស់ទ្រព្យសកម្ម ឬបំណុល កើតឡើងញឹកញាប់ ហើយទំហំប្រតិបត្តិការមានភាពគ្រប់គ្រាន់ក្នុងការផ្តល់ព័ត៌មានតម្លៃជាទៀងទាត់។

ប្រសិនបើពុំមានសម្រង់តម្លៃនៅក្នុងទីផ្សារសកម្មទេ នោះធនាគារត្រូវប្រើបច្ចេកទេសវាយតម្លៃណាដែលអាចប្រើប្រាស់ទិន្នន័យដែលអាចអង្កេតបានជាអតិបរមា និងកាត់បន្ថយនូវការប្រើប្រាស់ទិន្នន័យដែលមិនអាចអង្កេតបាន។ បច្ចេកទេសវាយតម្លៃដែលបានជ្រើសរើស ត្រូវរួមបញ្ចូលនូវកត្តាទាំងអស់ដែលអ្នកចូលរួមក្នុងទីផ្សារនឹងពិចារណានៅក្នុងការកំណត់តម្លៃ។ ភស្តុតាងដ៏ល្អបំផុតសម្រាប់តម្លៃសមស្របរបស់ឧបករណ៍ហិរញ្ញវត្ថុមួយនៅពេលទទួលស្គាល់ជាលើកដំបូង ជាទូទៅគឺជាតម្លៃប្រតិបត្តិការ មានន័យថា ជាតម្លៃសមស្របនៃផលតបស្នងបានផ្តល់ឱ្យ ឬបានទទួល។

ប្រសិនបើធនាគារកំណត់ថា តម្លៃសមស្របនៅពេលទទួលស្គាល់ ជាលើកដំបូង ខុសពីតម្លៃប្រតិបត្តិការ ហើយតម្លៃសមស្របនេះពុំមានភស្តុតាងមកបញ្ជាក់ តាមរយៈសម្រង់តម្លៃក្នុងទីផ្សារសកម្ម ចំពោះទ្រព្យសកម្ម ឬបំណុលដែលស្រដៀងគ្នា ឬក៏តាមរយៈបច្ចេកទេសវាយតម្លៃ ដែលក្នុងនោះទិន្នន័យដែលមិនអាចអង្កេតបាន ពាក់ព័ន្ធនឹងការវាស់វែង ត្រូវបានសន្មតថាមិនសារវន្ត ដូច្នេះឧបករណ៍ហិរញ្ញវត្ថុត្រូវវាស់វែងជាលើកដំបូងតាមតម្លៃសមស្រប ដោយកែតម្រូវតាមរយៈការពន្យារនូវភាពខុសគ្នារវាងតម្លៃ សមស្របនៅពេលទទួលស្គាល់ជាលើកដំបូង និងតម្លៃប្រតិបត្តិការ។ បន្ទាប់មកទៀត ភាពខុសគ្នានោះគឺត្រូវទទួលស្គាល់នៅក្នុង ចំណេញ ឬខាត ផ្អែកលើអាយុកាលរបស់ឧបករណ៍នោះ ក៏ប៉ុន្តែមិនឱ្យ យូរជាងការវាយតម្លៃតាមរយៈទិន្នន័យទីផ្សារដែលអាចអង្កេតបាន ឬនៅពេលបញ្ចប់ប្រតិបត្តិការនោះទេ។

ប្រសិនបើទ្រព្យសកម្ម ឬបំណុលដែលត្រូវបានវាស់វែងតាមតម្លៃសមស្រប មានតម្លៃលក់ និងតម្លៃទិញនោះធនាគារវាស់វែង ទ្រព្យសកម្ម និងស្ថានភាពវែងតាមតម្លៃលក់ ហើយវាស់វែងបំណុល និងស្ថានភាពខ្លីតាមតម្លៃទិញ។

សំណុំទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុដែលមានហានិភ័យទីផ្សារ និងហានិភ័យឥណទាន ដែលត្រូវបានចាត់ចែងដោយ ធនាគារ តាមមូលដ្ឋានចំនួនសុទ្ធដែលមានហានិភ័យទីផ្សារ ឬហានិភ័យឥណទាន ត្រូវបានវាស់វែងតាមមូលដ្ឋាននៃតម្លៃ ដែលនឹងទទួលបានដោយការលក់ទ្រព្យសកម្មដែលមាន ស្ថានភាពវែង (ឬការទូទាត់សងក្នុងការផ្ទេរទ្រព្យសកម្មសុទ្ធដែលមាន ស្ថានភាពខ្លី) សម្រាប់ហានិភ័យជាក់លាក់។ ការកែតម្រូវត្រឹមកម្រិតទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ មានន័យថា ការកែតម្រូវតម្លៃលក់-ទិញ ឬការកែតម្រូវហានិភ័យឥណទាន ដែលឆ្លុះបញ្ចាំងពីការវាស់វែងតាមមូលដ្ឋានតម្លៃសុទ្ធ គឺត្រូវបានបែងចែក តាមទ្រព្យសកម្ម និងបំណុលនីមួយៗ តាមមូលដ្ឋានការកែតម្រូវហានិភ័យដែលពាក់ព័ន្ធ នៃឧបករណ៍ហិរញ្ញវត្ថុនីមួយៗ នៃទ្រព្យសកម្ម និងបំណុលនោះ។

តម្លៃសមស្របនៃបំណុលហិរញ្ញវត្ថុមានលក្ខណៈអាចទាមទារសងតាមតម្រូវការ (ឧទាហរណ៍ ប្រាក់បញ្ញើចរន្ត) គឺមិនត្រូវតិចជាងចំនួនទឹកប្រាក់ដែលត្រូវបង់តាមតម្រូវការទេ ដោយត្រូវធ្វើអប្បហារចាប់ពីថ្ងៃដំបូងដែលចំនួនទឹកប្រាក់អាចត្រូវបានបង់។

ធនាគារទទួលស្គាល់ការផ្ទេររវាងកម្រិតនៃឋានានុក្រមតម្លៃសមស្រប នៅចុងការិយបរិច្ឆេទនៃរបាយការណ៍អំឡុងពេលដែលការផ្លាស់ប្តូរបានកើតឡើង។

ឱនភាពនៃតម្លៃ

ធនាគារទទួលស្គាល់សំវិធានធនលើការរំពឹងទុកលើការខាតបង់ឥណទាន ចំពោះឧបករណ៍ហិរញ្ញវត្ថុ ដែលមិនបានវាស់វែងតាម FVTPL ដូចខាងក្រោម៖

- ទ្រព្យសកម្មហិរញ្ញវត្ថុ គឺជាឧបករណ៍បំណុល និង
- កិច្ចសន្យាឥណទានដែលបានបោះផ្សាយ។

ពុំមានការខាតបង់លើឱនភាពនៃតម្លៃត្រូវបានទទួលស្គាល់នៅក្នុងការវិនិយោគមូលធនឡើយ។

ធនាគារវាស់វែងសំវិធានធនលើការខាតបង់ តាមចំនួនដែលស្មើនឹងការរំពឹងទុកលើការខាតបង់ឥណទាន ពេញអាយុកាល លើកលែងគណនីខាងក្រោមដែលត្រូវវាស់វែងតាមការរំពឹងទុកលើការខាតបង់ឥណទានរយៈពេល ១២ ខែ៖

- ការវិនិយោគលើមូលបត្របំណុល ដែលត្រូវបានកំណត់ថាមានហានិភ័យឥណទានទាប នាកាលបរិច្ឆេទរបាយការណ៍ និង
- ឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀត (ក្រៅពីភតិសន្យាត្រូវទទួល) ដែលហានិភ័យឥណទានមិនបានកើនឡើងជាសារវន្ត ចាប់តាំងពីការទទួលស្គាល់លើកដំបូង។

ការរំពឹងទុកលើការខាតបង់ឥណទាន ១២ ខែ គឺជាផ្នែកនៃការរំពឹងទុកលើការខាតបង់ឥណទាន ដែលបណ្តាលមកពីព្រឹត្តិការណ៍ខកខានសងប្រាក់ក្នុងរយៈពេល ១២ ខែ បន្ទាប់ពីកាលបរិច្ឆេទរបាយការណ៍។ ឧបករណ៍ហិរញ្ញវត្ថុដែលបានទទួលស្គាល់តាមការរំពឹងទុកលើការខាតបង់ឥណទាន ១២ ខែ ត្រូវបានចាត់ទុកជា "ឧបករណ៍ហិរញ្ញវត្ថុស្ថិតក្នុងដំណាក់កាលទី១"។

ការរំពឹងទុកលើការខាតបង់ឥណទានមួយអាយុកាល (Life time ECL) គឺជាការរំពឹងទុកលើការខាតបង់ឥណទាន ដែលអាចបណ្តាលមកពីព្រឹត្តិការណ៍ខកខានសងប្រាក់ ក្នុងរយៈពេលនៃអាយុកាលរំពឹងទុក (expected life) នៃឧបករណ៍ហិរញ្ញវត្ថុ។ ឧបករណ៍ហិរញ្ញវត្ថុ ដែលបានទទួលស្គាល់តាមការរំពឹងទុកលើការខាតបង់ឥណទានពេញមួយអាយុកាល ប៉ុន្តែមិនមែនជាឥណទានដែលមានឱនភាពនៃតម្លៃ (credit impaired) ត្រូវបានចាត់ទុកជា "ឧបករណ៍ហិរញ្ញវត្ថុស្ថិតនៅក្នុងដំណាក់កាលទី ២។

នៅកាលបរិច្ឆេទនៃរបាយការណ៍ ធនាគារវាយតម្លៃថាតើហានិភ័យឥណទាននៃឧបករណ៍ហិរញ្ញវត្ថុ បានកើនឡើងជាសារវន្តចាប់តាំងពីការទទួលស្គាល់លើកដំបូង។ ធ្វើការកំណត់ពីការកើនឡើងនូវហានិភ័យឥណទានជាសារវន្ត ដោយផ្អែកលើស្ថានភាពនៃឧបករណ៍ហិរញ្ញវត្ថុ អ្នកខ្ចី និងទីតាំងភូមិសាស្ត្រ។

ធនាគារធ្វើការពិចារណាថា ការកើនឡើងនៃហានិភ័យឥណទានជាសារវន្តកើតឡើងនោពេលទ្រព្យសកម្មមានការខកខានសងលើសពី ៣០ថ្ងៃនៃថ្ងៃកំណត់។ ចំនួនថ្ងៃផុតកំណត់ការសង ត្រូវរាប់ចាប់តាំងពីកាលបរិច្ឆេទផុតកំណត់ដំបូងបង្អស់ ដែលចំនួនទឹកប្រាក់សងមិនទាំងអស់មិនទាន់បានទទួល។ កាលបរិច្ឆេទផុតកំណត់សង ត្រូវបានកំណត់ដោយមិនរួមបញ្ចូលទៅលើពេលវេលាអនុគ្រោះណាមួយសម្រាប់អតិថិជនឡើយ។

ប្រសិនបើហានិភ័យឥណទានមិនបានកើនឡើងជាសារវន្ត ចាប់តាំងពីការទទួលស្គាល់លើកដំបូង នោះសំវិធានធនលើការបាត់បង់ ត្រូវបានវាស់វែងតាមតម្លៃស្មើនឹងការរំពឹងទុកលើការខាតបង់ឥណទាន ១២ ខែ។

ការវាស់វែងការរំពឹងទុកលើការខាតបង់ឥណទាន

ការរំពឹងទុកលើការខាតបង់ឥណទាន គឺជាការប៉ាន់ស្មានប្រូបាប៊ីលីតេមធ្យមនៃការបាត់បង់ឥណទាន ។ ការរំពឹងទុកលើការខាតបង់ឥណទាន ត្រូវបានវាស់វែងដូចខាងក្រោម៖

- ទ្រព្យសកម្មហិរញ្ញវត្ថុដែលមិនមានឱនភាពនៃតម្លៃនាកាលបរិច្ឆេទរាយការណ៍៖ ជាតម្លៃបច្ចុប្បន្ននៃកង្វះសាច់ប្រាក់ទាំងអស់ (ពោលគឺភាពខុសគ្នារវាងលំហូរទឹកប្រាក់ដែលជំពាក់ ធនាគារស្របតាមកិច្ចសន្យា និងលំហូរទឹកប្រាក់ដែលធនាគាររំពឹងទុកថានឹងទទួលបាន)។
- ទ្រព្យសកម្មហិរញ្ញវត្ថុដែលមានឱនភាពនៃតម្លៃនាកាលបរិច្ឆេទរាយការណ៍៖ ជាភាពខុសគ្នារវាងតម្លៃយោងដុល និងតម្លៃបច្ចុប្បន្ននៃលំហូរទឹកប្រាក់ដែលរំពឹងទុកនាពេលអនាគត។
- កិច្ចសន្យាឥណទានដែលនៅសល់៖ ជាតម្លៃបច្ចុប្បន្ននៃភាពខុសគ្នារវាងលំហូរទឹកប្រាក់តាមកិច្ចសន្យាដែលជំពាក់ធនាគារ ប្រសិនបើអ្នកកាន់កាប់កិច្ចសន្យាឥណទានបានដកឥណទានប្រើ និងលំហូរទឹកប្រាក់ដែលធនាគាររំពឹងទុកថានឹងទទួលបាន។

និយមន័យនៃការខកខានសង

ធនាគារចាត់ទុកទ្រព្យសកម្មហិរញ្ញវត្ថុដែលមានការខកខានសងនៅពេលដែល៖

- អ្នកខ្ចីមិនមានលទ្ធភាពសងចំពោះកាតព្វកិច្ចឥណទានរបស់ខ្លួនទាំងស្រុង ដោយមិនពឹងផ្អែកទៅលើការលក់ទ្រព្យដាក់ធានាដើម្បីទូទាត់សង (ប្រសិនបើមានទ្រព្យដាក់ធានា) ឬ
- អ្នកខ្ចីមានថ្ងៃដែលហួសការកំណត់សងលើសពី ឬស្មើនឹង ៩០ ថ្ងៃ សម្រាប់កម្ចីរយៈពេលវែង ឬមានថ្ងៃដែលហួសកាលកំណត់សងលើសពី ឬស្មើនឹង ៣១ ថ្ងៃ សម្រាប់កម្ចីរយៈពេលខ្លីទៅលើកាតព្វកិច្ចជាសារវន្តណាមួយរបស់ធនាគារ ឬ
- នៅពេលអ្នកខ្ចីនិងរៀបចំឡើងវិញនូវកម្ចី ដែលជាលទ្ធផលនៃការក្សៀយធន ដោយសារតែអសមត្ថភាពសង ក្នុងកាតព្វកិច្ចឥណទាន។

ទិន្នន័យ ការសន្មត និងបច្ចេកទេសប្រើសម្រាប់ការវាយតម្លៃឱនភាពនៃតម្លៃ

សមាសធាតុសំខាន់ៗ ក្នុងការវាស់វែងការរំពឹងទុកលើការខាតបង់ឥណទាន គឺបានមកពីអថេរដូចខាងក្រោម៖

- ប្រូបាប៊ីលីតេនៃការខកខានសង (“PD”);
- ការបាត់បង់ដែលបណ្តាលមកពីការខកខានសង (“LGD”) និង
- ទំហំនៃការខកខានសង (“EAD”)

ECL សម្រាប់សមតុល្យក្នុងដំណាក់កាលទី ១ ត្រូវបានគណនាដោយផលគុណនៃ PD ១២ ខែ នឹង LGD នឹង EAD។ ECL ពេញអាយុកាល ត្រូវបានគណនាដោយផលគុណនៃ PD ពេញអាយុកាល នឹង LGD នឹង EAD។

គំរូស្ថិតិត្រូវបានប្រើប្រាស់ដើម្បីវិភាគទិន្នន័យប្រមូលបាន រួចបង្កើតនូវការប៉ាន់ស្មាន PD ពេញអាយុកាល ដែលនៅសល់ និងថាតើ សមតុល្យទាំងនោះរំពឹងថាប្រែប្រួលយ៉ាងណាលើរយៈពេលនោះ។

LGD គឺជាតវិយាបទនៃភាពអាចបាត់បង់ប្រសិនបើមានការខកខានសង។ ធនាគារប៉ាន់ស្មានលក្ខខណ្ឌ LGD យោងតាមប្រវត្តិ នៃអត្រាការប្រមូលត្រលប់ពីអតិថិជនខកខានសង។ គំរូ LGD ត្រូវបានពិចារណាលើរចនាសម្ព័ន្ធអាទិភាពនៃការទាមទារសំណង វិស័យដែលអតិថិជនស្ថិតនៅ ចំណាយលើការប្រមូលពីទ្រព្យបញ្ចាំ ដែលជាផ្នែកមួយនៃទ្រព្យសកម្មហិរញ្ញវត្ថុ។ សម្រាប់ឥណទាន ដែលការពារដោយទ្រព្យអនុបាតឥណទានធៀបនឹងតម្លៃទ្រព្យបញ្ចាំ (“LTV”) គឺជាលក្ខខណ្ឌមួយក្នុងការកំណត់ LGD។ ការប៉ាន់ស្មាន LGD ត្រូវបានវាស់វែងសម្រាប់វិស័យផ្សេងៗគ្នា ហើយសម្រាប់ឥណទានគេហដ្ឋាន គឺអាស្រ័យលើការប្រែប្រួលតម្លៃអចលនទ្រព្យ។ តម្លៃទាំងនោះនឹងត្រូវបានគណនាដោយអប្បហារ ដោយផ្អែកលើអត្រាការប្រាក់ប្រសិទ្ធភាព។

EAD តំណាងឱ្យតម្លៃសមតុល្យនៅពេលមានការខកខានសង។ ធនាគារទាញយក EAD ពីសមតុល្យបច្ចុប្បន្នរបស់អតិថិជន និងភាពអាចប្រែប្រួលលើសមតុល្យបច្ចុប្បន្នពីការបង់សង ដែលអនុញ្ញាតតាមកិច្ចសន្យា និងកើតចេញពីការបង់រំលស់។ EAD នៃទ្រព្យសកម្មហិរញ្ញវត្ថុ គឺតម្លៃយោងដុលនៅពេលមានការខកខានសង។

សម្រាប់កាតព្វកិច្ចឱ្យខ្ចី EAD គឺសមតុល្យអនាគតដែលអាចដកប្រើប្រាស់តាមកិច្ចសន្យា ដែលត្រូវបានប៉ាន់ស្មានតាមការសង្កេតពីប្រវត្តិ និងការព្យាករណ៍នាពេលខាងមុខ។ សម្រាប់ទ្រព្យសកម្មហិរញ្ញវត្ថុខ្លះ EAD ត្រូវបានកំណត់ដោយគំរូនៃសមតុល្យដែលអាចកើតឡើងនៅពេលវេលាផ្សេងគ្នាដោយប្រើបច្ចេកទេសស្ថិតិ។

ដូចការរៀបរាប់ខាងលើ ដោយផ្អែកលើការប្រើប្រាស់ PD ១២ ខែ សម្រាប់ទ្រព្យសកម្មហិរញ្ញវត្ថុដំណាក់កាលទី១ ធនាគារវាស់វែងការរំពឹងទុកលើការខាតបង់ឥណទាន ដោយពិចារណាលើហានិភ័យនៃការខូចខាតលើរយៈពេលពេញលេញនៃកិច្ចសន្យា (រួមបញ្ចូលទាំងរយៈពេលពន្យាប្រសិនបើមាន) ដែលមានហានិភ័យលើឥណទាន ទោះបីជាក្នុងគោលបំណងគ្រប់គ្រងហានិភ័យឥណទានក៏ដោយធនាគារពិចារណាលើរយៈពេលដែលវែងជាង។ រយៈពេល ដែលវែងបំផុត គឺគិតត្រឹមថ្ងៃ ដែលធនាគារមានសិទ្ធិដើម្បីទាមទារការសងត្រឡប់នៃឥណទាន ឬបញ្ចប់កិច្ចសន្យាផ្តល់ឥណទាន ឬការធានា ។

ទ្រព្យសកម្មហិរញ្ញវត្ថុដែលបានរៀបចំឡើងវិញ

ប្រសិនបើលក្ខខណ្ឌនៃទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានចរចា ឬកែតម្រូវ ឬទ្រព្យសកម្មហិរញ្ញវត្ថុដែលមានស្រាប់ ត្រូវបានជំនួសដោយទ្រព្យសកម្មហិរញ្ញវត្ថុថ្មីដោយសារស្ថានភាពលំបាកផ្នែកហិរញ្ញវត្ថុរបស់អតិថិជននោះការវាយតម្លៃត្រូវបានធ្វើឡើង ដើម្បីវាយតម្លៃថាតើទ្រព្យសកម្មហិរញ្ញវត្ថុគួរតែត្រូវឈប់ទទួលស្គាល់ ឬទេ ហើយ ECL ត្រូវបានវាស់វែងដូចខាងក្រោម៖

- ប្រសិនបើការរៀបចំឡើងវិញ មិននាំឱ្យឈប់ទទួលស្គាល់ទ្រព្យសកម្មដែលមានស្រាប់ទេ នោះលំហូរទឹកប្រាក់ដែលរំពឹងទុកថាកើតមានពីទ្រព្យសកម្មហិរញ្ញវត្ថុដែលបានកែតម្រូវ ត្រូវបានបញ្ចូលនៅក្នុងការគណនាកង្វះខាតនៃ សាច់ប្រាក់ពីទ្រព្យសកម្មដែលមានស្រាប់។
- ប្រសិនបើការរៀបចំឡើងវិញ នាំឱ្យមានការឈប់ទទួលស្គាល់ទ្រព្យសកម្មដែលមានស្រាប់ នោះតម្លៃសមស្រប រំពឹងទុកនៃទ្រព្យសកម្មថ្មីនោះត្រូវបានចាត់ទុកជាលំហូរទឹកប្រាក់ចុងក្រោយទទួលបានពីទ្រព្យសកម្មហិរញ្ញវត្ថុ បច្ចុប្បន្ននៅពេលដែលឈប់ទទួលស្គាល់។ ចំនួនទឹកប្រាក់នេះត្រូវបានបញ្ចូលទៅក្នុងការគណនាកង្វះខាតសាច់ប្រាក់ពី ទ្រព្យសកម្មហិរញ្ញវត្ថុបច្ចុប្បន្ន ដែលត្រូវបានធ្វើអប្បហារពីកាលបរិច្ឆេទរំពឹងទុកនៃការឈប់ទទួលស្គាល់ ទៅកាលបរិច្ឆេទរាយការណ៍ ដោយប្រើអត្រាការប្រាក់ប្រសិទ្ធភាពដើមនៃទ្រព្យសកម្មហិរញ្ញវត្ថុបច្ចុប្បន្ន ។

ទ្រព្យសកម្មហិរញ្ញវត្ថុដែលមានឱនភាពតម្លៃ

នៅកាលបរិច្ឆេទរាយការណ៍នីមួយៗ ធនាគារវាយតម្លៃថាតើទ្រព្យសកម្មហិរញ្ញវត្ថុដែលបានកត់ត្រាតាមរំលស់ថ្លៃដើម និងបំណុលហិរញ្ញវត្ថុដែលបានកត់ត្រាតាម FVOCI មានឱនភាពនៃតម្លៃ ឬទេ (ដែលត្រូវបានកំណត់ជា "ទ្រព្យសកម្មហិរញ្ញវត្ថុដំណាក់កាលទី ៣")។ ទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានចាត់ទុកថាមានឱនភាពនៃតម្លៃ នៅពេលដែលព្រឹត្តិការណ៍មួយ ឬច្រើនបានកើតឡើង ដែលនាំឱ្យមានផលប៉ះពាល់ជាអវិជ្ជមានទៅលើលំហូរទឹកប្រាក់នាពេលអនាគតដែលរំពឹងទុក នៃទ្រព្យសកម្មហិរញ្ញវត្ថុ។

ភស្តុតាងដែលបញ្ជាក់ថាទ្រព្យសកម្មហិរញ្ញវត្ថុមានឱនភាពនៃតម្លៃ រួមមានទិន្នន័យដែលអាចអង្កេតបានដូចខាងក្រោម៖

- ការលំបាកផ្នែកហិរញ្ញវត្ថុយ៉ាងខ្លាំងរបស់អតិថិជន ឬអ្នកបោះផ្សាយ
- ការបំពានកិច្ចសន្យា ដូចជាការខកខានមិនបានសង ឬហួសកាលកំណត់
- ការរៀបចំឡើងវិញលើលក្ខខណ្ឌនៃការផ្តល់ឥណទានដល់អតិថិជន ដែលធនាគារមិនយល់ព្រម
- អតិថិជនទំនងនឹងក្ស័យធន ឬត្រូវរៀបចំហិរញ្ញវត្ថុឡើងវិញជាថ្មី
- ការបាត់បង់ទីផ្សារសកម្មសម្រាប់មូលបត្រដោយសារតែការលំបាកផ្នែកហិរញ្ញវត្ថុ។

ឥណទានដែលត្រូវបានរៀបចំឡើងវិញ ដោយសារតែភាពមិនប្រក្រតីនៅក្នុងលក្ខខណ្ឌរបស់អតិថិជន ត្រូវបានចាត់ទុកជាឥណទានមានឱនភាពនៃតម្លៃ លុះត្រាតែមានភស្តុតាងបញ្ជាក់ថាហានិភ័យនៃការមិនទទួលបានលំហូរទឹកប្រាក់តាមកិច្ចសន្យាបានថយចុះ ជាសារវន្ត និងមិនមានសុចនាករណ៍ផ្សេងទៀតដែលនាំឱ្យមានឱនភាពនៃតម្លៃ។ បន្ថែមលើនេះ ឥណទានដែលហួសកាលកំណត់សង ៩០ ថ្ងៃ ឬលើសពីនេះ ត្រូវបានចាត់ទុកជាឥណទានមានឱនភាពនៃតម្លៃ ទោះបីជានិយមន័យនៃការហួសកាលកំណត់សងដែលច្បាប់បានកំណត់ផ្សេងគ្នាក៏ដោយ ។

សំវិធានធនសម្រាប់ការរំពឹងទុកលើការខាតបង់ឥណទាន នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ

សំវិធានធននៃការរំពឹងទុកលើការខាតបង់ឥណទាន ត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ សម្រាប់ទ្រព្យសកម្មហិរញ្ញវត្ថុ ដែលវាស់វែងតាមរំលស់ថ្លៃដើម ដោយធ្វើការកាត់កងពីតម្លៃយោងដុលនៃទ្រព្យសកម្ម។

ការលុបចោល

ឥណទាន និងបុរេប្រទានផ្តល់ដល់អតិថិជនត្រូវបានលុបចេញពីបញ្ជី (មួយផ្នែក ឬទាំងស្រុង) នៅពេលមិនមានការរំពឹងទុកថាអាចប្រមូលបានមកវិញនូវទ្រព្យសកម្មហិរញ្ញវត្ថុនោះទាំងស្រុង។ ករណីនេះមានជាទូទៅ នៅពេលធនាគារកំណត់ថាអ្នកខ្ចីពុំមានទ្រព្យសកម្ម ឬប្រភពចំណូលណាដែលអាចបង្កើតបាននូវលំហូរទឹកប្រាក់គ្រប់គ្រាន់ ដើម្បីទូទាត់សងនូវចំនួនដែលត្រូវលុបចេញពីបញ្ជី។ ការវាយតម្លៃនេះ ត្រូវធ្វើឡើងតាមកម្រិតទ្រព្យសកម្មនីមួយៗ។

ទឹកប្រាក់ប្រមូលបានមកវិញលើចំនួនដែលបានលុបចេញពីបញ្ជី ត្រូវបញ្ចូលទៅក្នុងខ្ទង់ "ការខាតបង់សុទ្ធពីឱនភាពនៃតម្លៃឧបករណ៍ហិរញ្ញវត្ថុ" នៅក្នុងចំណេញ ឬខាត និង OCI។

ទ្រព្យសកម្មហិរញ្ញវត្ថុដែលបានលុបចេញពីបញ្ជី នៅតែតម្រូវឱ្យមានសកម្មភាពទាមទារសងមកវិញ ដើម្បីអនុលោមតាមនីតិវិធីរបស់ធនាគារ ក្នុងការប្រមូលទឹកប្រាក់ដែលនៅជំពាក់។

៤.២ សាច់ប្រាក់

សាច់ប្រាក់រួមមានសាច់ប្រាក់ក្នុងដៃ និងសមតុល្យនៅធនាគារ រួមទាំងប្រាក់បញ្ញើតាមការតម្រូវ។

៤.៣ ប្រាក់បញ្ញើជាមួយធនាគារផ្សេង

ប្រាក់បញ្ញើជាមួយធនាគារផ្សេង គឺត្រូវបានកំណត់តាមថ្លៃដើមរំលស់ដកឱនភាពតម្លៃនៃចំនួនទឹកប្រាក់ដែលមិនអាចប្រមូលបាន។

៤.៤ ប្រាក់តម្កល់តាមច្បាប់

ប្រាក់តម្កល់តាមច្បាប់ ត្រូវបានរក្សាទុកនៅធនាគារជាតិនៃកម្ពុជាស្របតាមច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា និងត្រូវបានកំណត់ជាភាគរយនៃដើមទុនអប្បបរមា និងប្រាក់បញ្ញើរបស់អតិថិជនដែលតម្រូវដោយធនាគារជាតិនៃកម្ពុជា។

៤.៥ ឥណទាន និងបុរេប្រទាន

"ឥណទាន និងបុរេប្រទាន" ដែលបង្ហាញនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ រួមបញ្ចូលឥណទាន និងបុរេប្រទាន ដែលត្រូវបានវាស់វែងតាមរំលស់ថ្លៃដើម។ ឥណទាន និងបុរេប្រទានត្រូវបានវាស់វែងលើកដំបូងតាមតម្លៃសមស្រប បូកចំណាយប្រតិបត្តិការដែលកើតឡើងដោយផ្ទាល់ ហើយនាពេលបន្ទាប់ត្រូវកត់ត្រាតាមរំលស់ថ្លៃដើម ដោយប្រើវិធីសាស្ត្រអត្រាការប្រាក់ប្រសិទ្ធភាព។

៤.៦ ការវិនិយោគផ្សេង

ការវិនិយោគផ្សេងទៀត ត្រូវបានកត់ត្រាតាមតម្លៃដើម ដកឱនភាពនៃតម្លៃដែលមិនអាចប្រមូលមកវិញបាន។

៤.៧ ដើមទុន

ភាគហ៊ុនធម្មតា ត្រូវបានចាត់ថ្នាក់ជាមូលធន។ ថ្លៃដើមបន្ថែមផ្ទាល់ក្នុងការបញ្ចេញភាគហ៊ុន ត្រូវបានទទួលស្គាល់ដោយកាត់ចេញពីមូលធនបន្ទាប់ពីដកពន្ធរួច។ ភាគហ៊ុនដទៃទៀតត្រូវបានចាត់ថ្នាក់ជាមូលធន និង/ឬ បំណុល ផ្អែកលើសមាសធាតុសេដ្ឋកិច្ចនៃឧបករណ៍ទាំងនោះ។ ការបែងចែកទៅអ្នកកាន់កាប់ឧបករណ៍ហិរញ្ញវត្ថុដែលត្រូវបានចាត់ថ្នាក់ជាឧបករណ៍មូលធន ត្រូវបានទូទាត់ដោយផ្ទាល់ពីមូលធន។

៤.៨ ការខាតបង់បង្គរ

ការខាតបង់បង្គររួមមានចំណេញ ឬខាតក្នុងការិយបរិច្ឆេទឆ្នាំចាស់ និងការិយបរិច្ឆេទបច្ចុប្បន្ន។

៤.៩ ទុនបម្រុងតាមបទប្បញ្ញត្តិ

ទុនបម្រុងតាមបទប្បញ្ញត្តិត្រូវបានបង្កើតលើភាពខុសគ្នា រវាងសំវិធានធន ស្របតាម ស.រ.ទ.ហ.អ.ក និងសំវិធានធនតាមបទប្បញ្ញត្តិស្របតាមប្រកាសរបស់ធនាគារជាតិនៃកម្ពុជា លេខ ធ៧-០១៧-៣៤៤ ចុះថ្ងៃទី១ ខែធ្នូ ឆ្នាំ២០១៧ និងសារាចរណែនាំ លេខធ៧-០១៨-០០១ ស.រ.ឆ.ណ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៨ ស្តីពីចំណាត់ថ្នាក់។ ហានិភ័យឥណទាន និងសំវិធានធនលើឱនភាពនៃតម្លៃ សម្រាប់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ។ ស្របតាមប្រការ ៧៣ គ្រឹះស្ថានត្រូវប្រៀបធៀបសំវិធានធន ដែលគណនាតាមប្រការ ៤៩ ដល់ ប្រការ ៧១ ជាមួយនឹងសំវិធានធនដែលគណនាតាមប្រការ ៧២ និងត្រូវកត់ត្រាដូចខាងក្រោម៖

(i) ក្នុងករណីដែលសំវិធានធនតាមបទប្បញ្ញត្តិ ដែលគណនាតាមប្រការ ៧២ ទាបជាងសំវិធានធនដែលគណនាតាមប្រការ ៤៩ ដល់ ប្រការ ៧១ នោះគ្រឹះស្ថានត្រូវកត់ត្រាសំវិធានធន ដែលត្រូវគណនាអនុលោមតាម ស.រ.ទ.ហ.អ.ក និង

(ii) ក្នុងករណីដែលសំវិធានធនតាមបទប្បញ្ញត្តិ ដែលគណនាតាមប្រការ ៧២ ខ្ពស់ជាងសំវិធានធនដែលគណនាតាមប្រការ ៤៩ ដល់ ប្រការ ៧១ នោះគ្រឹះស្ថានត្រូវកត់ត្រាសំវិធានធន ដែលត្រូវគណនាតាម ស.រ.ទ.ហ.អ.ក និងផ្ទេរចំនួនលម្អៀងនោះពី ប្រាក់ចំណេញរក្សាទុក ឬគណនីខាតបង្គរទៅទុនបម្រុងតាមបទប្បញ្ញត្តិ ក្នុងខ្ទង់មូលនិធិភាគទុននិកនៃរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។

ទុនបម្រុងតាមបទប្បញ្ញត្តិមិនត្រូវបានបញ្ចូលក្នុងការគណនាមូលធនផ្ទាល់សុទ្ធរបស់ធនាគារឡើយ។

៤.១០ ទ្រព្យសម្បត្តិ និងបរិក្ខារ

ការទទួលស្គាល់ និងការវាស់វែង

ផ្នែកនៃទ្រព្យសម្បត្តិ និងបរិក្ខារត្រូវបានវាស់វែងតាមតម្លៃដើម ដករំលស់បង្គរ និងការខាតបង់លើឱនភាពនៃតម្លៃបង្គរ។

ចំណាយថ្លៃដើមរួមបញ្ចូលទាំងការចំណាយដោយផ្ទាល់ទៅលើការទិញទ្រព្យ និងការចំណាយដោយផ្ទាល់ផ្សេងៗទៀត ក្នុងការនាំយកទ្រព្យសកម្មទៅក្នុងលក្ខខណ្ឌដែលអាចប្រើប្រាស់ដែលបានគ្រោងទុក និងថ្លៃដើមនៃការរុះរើ និងផ្លាស់ប្តូរទីកន្លែង និងការស្តារទីតាំង ដែលពួកគេស្ថិតនៅ។ ថ្លៃដើមនៃទ្រព្យកម្មដែលបានសាងសង់ដោយខ្លួនឯង ត្រូវរួមបញ្ចូលទាំងថ្លៃដើមសម្ភារៈ និងកម្លាំងពលកម្មផ្ទាល់ផងដែរ។ ចំពោះទ្រព្យសកម្មដែលមានលក្ខណៈគ្រប់គ្រាន់ ការចំណាយលើប្រាក់កម្ចីត្រូវបានធ្វើមូលធនកម្មស្របតាម គោលនយោបាយគណនេយ្យលើថ្លៃដើមប្រាក់កម្ចី។ ថ្លៃដើមក៏អាចរួមបញ្ចូលទាំងការផ្ទេរមូលធន ដែលជាចំណេញ ឬខាតណាមួយ ផងដែរ លើការការពារហានិភ័យលំហូរសាច់ប្រាក់ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ចំពោះរូបិយប័ណ្ណបរទេសទាក់ទងនឹងការទិញទ្រព្យសម្បត្តិ និងបរិក្ខារ។

ការទិញសូហ្វវែរដែលមានសារៈសំខាន់ចំពោះមុខងារដែលទាក់ទងនឹងបរិក្ខារ ត្រូវបានធ្វើមូលធនកម្មជាផ្នែកមួយនៃបរិក្ខារនោះ។

ប្រសិនបើផ្នែកជាសារវន្តណាមួយនៃទ្រព្យសម្បត្តិ និងបរិក្ខារទាំងនោះ មានអាយុកាលប្រើប្រាស់ខុសពីគ្នា ផ្នែកទាំងនោះត្រូវបានដាក់ ជាផ្នែកដោយឡែក (សមាសភាពចម្បង) នៃទ្រព្យសម្បត្តិ និងបរិក្ខារ។

ចំណាយបន្ទាប់

ចំណេញ ឬខាតពីការលក់នៃទ្រព្យ និងបរិក្ខារណាមួយ ត្រូវបានកំណត់ដោយភាពខុសគ្នារវាងសាច់ប្រាក់ទទួលបានពីការលក់ និងតម្លៃយោងនៃផ្នែកនោះ ហើយត្រូវបានទទួលស្គាល់ជាចំណូលផ្សេងៗ "ចំណូលផ្សេងៗ" និង "ចំណាយផ្សេងៗ" នៅក្នុងចំណេញ ឬខាត។

ថ្លៃដើមនៃការផ្លាស់ប្តូរធាតុមួយផ្នែកនៃទ្រព្យសម្បត្តិ និងបរិក្ខារ ដែលបានទទួលស្គាល់រួចមកហើយ ត្រូវបានបូកបញ្ចូល នៅក្នុងតម្លៃយោងនៃផ្នែកនោះ ប្រសិនបើវាអាចមានលទ្ធភាពផ្តល់នូវអត្ថប្រយោជន៍សេដ្ឋកិច្ច នាពេលអនាគតដល់ធនាគារ ហើយតម្លៃរបស់វាអាចធ្វើការវាស់វែងបានដោយភាពអាចជឿជាក់បាន។ តម្លៃយោង នៃធាតុដែលបានជំនួសនោះ ត្រូវឈប់ទទួលស្គាល់ជា ចំណេញ ឬខាត។ រាល់ចំណាយក្នុងការថែទាំប្រចាំថ្ងៃផ្សេងៗ ត្រូវបានទទួលស្គាល់ជាចំណេញ ឬខាត នៅក្នុងរបាយការណ៍លទ្ធផលក្នុងការិយបរិច្ឆេទដែលបានកើតឡើង។

រំលស់

រំលស់ គឺផ្អែកទៅលើថ្លៃដើមនៃទ្រព្យសកម្ម ដកតម្លៃសំណល់របស់វា។ សមាសធាតុសំខាន់ៗ នៃទ្រព្យសកម្មនីមួយៗ ត្រូវបានវាយតម្លៃ ហើយប្រសិនបើសមាសធាតុមួយមានអាយុកាលប្រើប្រាស់ខុសគ្នាពីទ្រព្យសកម្មដែលនៅសល់ សមាសធាតុនោះត្រូវបានធ្វើឡើងដាច់ដោយឡែក។

រំលស់ ត្រូវបានទទួលស្គាល់ថាជាការចំណាយនៅក្នុងរបាយការណ៍ចំណេញ ឬខាតដោយប្រើវិធីសាស្ត្ររំលស់ថេរលើអាយុកាល ប្រើប្រាស់ដែលបានប៉ាន់ស្មាននៃសមាសធាតុនីមួយៗ នៃទ្រព្យសម្បត្តិ និងបរិក្ខារ។

ទ្រព្យសកម្មដែលបានជួល ត្រូវបានរំលស់រយៈពេលជួល ឬអាយុកាលប្រើប្រាស់របស់វាមួយណាដែលខ្លីជាងលើកលែងតែមាន ហេតុផលច្បាស់លាស់ថាធនាគារនឹងទទួលបានកម្មសិទ្ធិនៅចុងបញ្ចប់នៃរយៈពេលនៃការជួល។ ដីទំនេរមិនត្រូវបានរំលសល់នោះទេ។

រំលស់ ត្រូវបានទទួលស្គាល់ចាប់ពីកាលបរិច្ឆេទដែលទ្រព្យ និងបរិក្ខារត្រូវបានតម្លើង និងអាចប្រើប្រាស់បាន ឬទ្រព្យសកម្មដែលបានសាងសង់ ចាប់ពីការិយបរិច្ឆេទដែលទ្រព្យសកម្មនោះត្រូវបានបញ្ចប់ និងអាចប្រើប្រាស់បាន។

ការប៉ាន់ស្មានអាយុកាលប្រើប្រាស់សម្រាប់ការិយបរិច្ឆេទបច្ចុប្បន្នមានដូចខាងក្រោម៖

	ឆ្នាំ
ការកែលម្អលើដី	អាយុកាលសេដ្ឋកិច្ច ឬរយៈពេលកិច្ចសន្យារយៈពេលខ្លី
គ្រឿងសង្ហារឹម និងគ្រឿងបរិក្ខារ	៥
បរិក្ខារការិយាល័យ	៥
បរិក្ខារកុំព្យូទ័រ និងព័ត៌មានវិទ្យា	៣
យានយន្ត	៥

វិធីសាស្ត្ររំលស់ លើអាយុកាលប្រើប្រាស់ និងតម្លៃសំណល់ ត្រូវបានវាយតម្លៃនាចុងការិយបរិច្ឆេទនៃរបាយការណ៍ និងនិយ័តភាព ប្រសិនបើសមស្រប។

៤.១១ ទ្រព្យសកម្មអរូបី

ទ្រព្យសកម្មអរូបី ដែលរួមមានថ្លៃដើមអាជ្ញាបណ្ណកុំព្យូទ័រដែលបានទិញ និងថ្លៃដើមពាក់ព័ន្ធផ្សេងទៀត ត្រូវបានកត់ត្រាតាមថ្លៃដើម ដករំលស់បង្គរ និងការខាតបង់លើឱនភាពនៃតម្លៃបង្គរ ប្រសិនបើមាន។ អាជ្ញាបណ្ណកុំព្យូទ័រដែលបានទិញត្រូវបានធ្វើមូលធនកម្ម តាមមូលដ្ឋានថ្លៃដើម ដែលបានកើតឡើងក្នុងការទិញកម្មវិធីជាក់លាក់នោះមកប្រើប្រាស់។

ទ្រព្យសកម្មអរូបីត្រូវបានដករំលស់ទៅតាមការប៉ាន់ស្មានអាយុកាលប្រើប្រាស់ពី ៣ ឆ្នាំ តាមវិធីសាស្ត្ររំលស់ថេរ។

ថ្លៃដើមពាក់ព័ន្ធនឹងការបង្កើត ឬថែទាំកុំព្យូទ័រសូហ្វវែរ ត្រូវបានទទួលស្គាល់ជាចំណាយនៅពេលកើតឡើង។

៤.១២ ទ្រព្យសកម្មផ្សេងៗ

ទ្រព្យសកម្មផ្សេងៗ ត្រូវបានកត់ត្រាតាមតម្លៃដើម ដកឱនភាពនៃតម្លៃ ប្រសិនបើមាន។

៤.១៣ ឱនភាពនៃតម្លៃរបស់ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ

តម្លៃយោងនៃទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុរបស់ធនាគារ ក្រៅពីពន្ធពន្យារជាទ្រព្យសកម្ម ត្រូវបានត្រួតពិនិត្យឡើងវិញនៅរាល់ការិយបរិច្ឆេទរាយការណ៍នីមួយៗ ដើម្បីកំណត់ថាតើមានសញ្ញាណណាមួយដែលបង្ហាញថា ទ្រព្យសកម្មទាំងនោះមានឱនភាពនៃតម្លៃ ឬទេ។ ប្រសិនបើមានសញ្ញាណនោះកើតឡើង នោះការប៉ាន់ស្មានលើតម្លៃដែលអាច ប្រមូលមកវិញបានរបស់ទ្រព្យសកម្មត្រូវបានធ្វើឡើង។ ចំពោះទ្រព្យសកម្មអរូបីដែលមានអាយុកាលប្រើប្រាស់មិនកំណត់ ឬមិនទាន់អាចប្រើប្រាស់បាន តម្លៃដែលអាចប្រមូល មកវិញបានត្រូវធ្វើការប៉ាន់ស្មានជារៀងរាល់ឆ្នាំក្នុងពេលតែមួយ។ ការខាតបង់លើឱនភាពនៃតម្លៃ ត្រូវបានទទួលស្គាល់ ប្រសិនបើតម្លៃយោងរបស់ទ្រព្យសកម្ម ឬឯកតាបង្កើតសាច់ប្រាក់ ធំជាងការប៉ាន់ស្មានតម្លៃដែលអាចប្រមូលមកវិញបាន។

តម្លៃដែលអាចប្រមូលមកវិញបានរបស់ទ្រព្យសកម្ម ឬឯកតាបង្កើតសាច់ប្រាក់ គឺជាតម្លៃដែលធំជាងរវាងតម្លៃប្រើប្រាស់ និងតម្លៃសមស្រប ដកចំណាយដើម្បីលក់ចេញ។ ក្នុងការប៉ាន់ប្រមាណតម្លៃប្រើប្រាស់ ការប៉ាន់ស្មានលំហូរទឹកប្រាក់នាពេលអនាគត ត្រូវបានធ្វើអប្បហារទៅនឹងតម្លៃបច្ចុប្បន្ន ដោយប្រើអត្រាការប្រាក់មុនបង់ពន្ធ ដែលឆ្លុះបញ្ចាំងការប៉ាន់ប្រមាណតម្លៃពេលវេលាក្នុងលក្ខខណ្ឌទីផ្សារបច្ចុប្បន្ន និងហានិភ័យជាក់លាក់សម្រាប់ទ្រព្យសកម្មទាំងនោះ ឬឯកតាបង្កើតសាច់ប្រាក់។

សម្រាប់គោលបំណងនៃការធ្វើតេស្តលើឱនភាពនៃតម្លៃ ទ្រព្យសកម្មត្រូវបានដាក់បញ្ចូលគ្នាជាក្រុមតូចៗ ដែលអាចបង្កើតសាច់ប្រាក់ បានពីការបន្តការប្រើប្រាស់ ដោយមិនពឹងផ្អែកខ្លាំងលើលំហូរទឹកប្រាក់នៃទ្រព្យសកម្ម ឬឯកតាបង្កើតសាច់ប្រាក់។

ការខាតបង់លើឱនភាពនៃតម្លៃ ត្រូវបានទទួលស្គាល់ជាចំណេញ ឬខាត។ ការខាតបង់លើឱនភាពនៃតម្លៃ នៃ ឯកតាបង្កើតសាច់ប្រាក់ ត្រូវបានបែងចែកដោយ កាត់បន្ថយតម្លៃយោងនៃតម្លៃកេរ្តិ៍ឈ្មោះរបស់ឯកតាបង្កើតសាច់ប្រាក់ (ក្រុមនៃឯកតាបង្កើតសាច់ប្រាក់) ជាមុន ហើយបន្ទាប់មកដើម្បីកាត់បន្ថយតម្លៃយោងនៃទ្រព្យសកម្មដទៃទៀតនៅក្នុងឯកតាបង្កើតសាច់ប្រាក់ (ក្រុមនៃឯកតាបង្កើតសាច់ប្រាក់) លើមូលដ្ឋានសមាមាត្រ។

ការខាតបង់លើឱនភាពនៃតម្លៃ ដែលទទួលស្គាល់ក្នុងពេលកន្លងផុតទៅ ត្រូវបានប៉ាន់ប្រមាណរាល់កាលបរិច្ឆេទនៃការរាយការណ៍ ថាតើមានសញ្ញាណណាមួយដែលការខាតបង់បានថយចុះ ឬលែងមានការខាតបង់តទៅទៀត។ ការខាតបង់លើឱនភាពនៃតម្លៃ ត្រូវកត់ត្រាបញ្ច្រាសមកវិញ ប្រសិនបើមានការប្រែប្រួលតម្លៃប៉ាន់ស្មានដែលប្រើប្រាស់ដើម្បីកំណត់តម្លៃដែលអាចប្រមូលមកវិញបាន។ ការខាតបង់លើឱនភាពនៃតម្លៃត្រូវបានកត់ត្រាបញ្ច្រាសមកវិញ ត្រឹមកម្រិតមួយដែលមិនធ្វើឱ្យតម្លៃយោងរបស់ទ្រព្យសកម្មនេះ មិនលើសពីតម្លៃយោងដែលត្រូវកំណត់ (ដករំលស់) ក្នុងករណីពុំមានការទទួលស្គាល់ការខាតបង់លើឱនភាពនៃតម្លៃ។

៤.១៤ ភតិសន្យាជួល

នៅពេលចាប់ផ្តើមកិច្ចសន្យា ធនាគារធ្វើការវាយតម្លៃថាតើកិច្ចសន្យាមួយមានទម្រង់ជាភតិសន្យាដែរ ឬទេ។ កិច្ចសន្យាជាទម្រង់មាន ភតិសន្យា ប្រសិនបើកិច្ចសន្យាផ្តល់សិទ្ធិគ្រប់គ្រងការប្រើប្រាស់ទ្រព្យសកម្មជាក់លាក់មួយក្នុងរយៈពេលកំណត់មួយ ជាថ្នូរនឹងតម្លៃតបស្នង ។

ដើម្បីវាយតម្លៃថាតើកិច្ចសន្យាផ្តល់សិទ្ធិគ្រប់គ្រងការប្រើប្រាស់ទ្រព្យសកម្មជាក់លាក់ ធនាគារធ្វើការវាយតម្លៃ ថាតើ៖

- កិច្ចសន្យាមានជាប់ពាក់ព័ន្ធនឹងការប្រើប្រាស់ទ្រព្យសកម្មជាក់លាក់ ឬទេ ដែលនេះអាចបញ្ជាក់យ៉ាងជាក់លាក់ ឬ ប្រយោលហើយគួរមានលក្ខណៈរូបវន្តដោយឡែក ឬតំណាងសមត្ថភាពផលិតសារវន្ត របស់ទ្រព្យសកម្មនោះ។ ប្រសិនបើអ្នកផ្គត់ផ្គង់មានសិទ្ធិផ្តល់ទ្រព្យសកម្មជំនួសជាសារវន្តក្នុងរយៈពេលប្រើប្រាស់ នោះទ្រព្យសកម្មមិនមែនមាន លក្ខណៈជាទ្រព្យសកម្មជាក់លាក់នោះទេ
- ធនាគារ មានសិទ្ធិទទួលបានអត្ថប្រយោជន៍សេដ្ឋកិច្ចជាសារវន្ត ពីការប្រើប្រាស់ទ្រព្យសកម្ម ក្នុងរយៈពេលនៃការ ប្រើប្រាស់ និង
- ធនាគារមានសិទ្ធិបញ្ជាការប្រើប្រាស់ទ្រព្យសកម្ម។ ធនាគារមានសិទ្ធិនេះ នៅពេលដែលធនាគារមានសិទ្ធិសម្រេចចិត្ត ដែលពាក់ព័ន្ធនឹងការផ្លាស់ប្តូរអំពីរបៀប និងគោលបំណងក្នុងការប្រើប្រាស់ទ្រព្យសកម្ម។ ក្នុងករណីដែលការសម្រេចចិត្ត ទាំងអស់អំពីរបៀប និងគោលបំណងនៃការប្រើប្រាស់ ទ្រព្យសកម្មត្រូវបានកំណត់ជាមុន នោះ ធនាគារមានសិទ្ធិបញ្ជាការ ប្រើប្រាស់ទ្រព្យសកម្ម ប្រសិនបើ៖
  - > ធនាគារមានសិទ្ធិធ្វើប្រតិបត្តិការលើទ្រព្យសកម្ម ឬ
  - > ធនាគារបានរៀបចំទ្រព្យសកម្មទៅតាមវិធីដែលកំណត់ជាមុនពីរបៀប និងគោលបំណងដែលទ្រព្យសកម្ម នោះនឹងត្រូវបានប្រើប្រាស់។

គោលនយោបាយនេះអនុវត្តចំពោះកិច្ចសន្យាដែលបានព្រមព្រៀង ឬបានធ្វើការផ្លាស់ប្តូរ ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០១៩ មកប៉ុណ្ណោះ។

នៅពេលចាប់ផ្តើមកិច្ចសន្យា ឬវាយតម្លៃឡើងវិញលើកិច្ចសន្យាដែលមានទម្រង់ជាភតិសន្យា និងសមាសធាតុ ដែលមិនមែនភតិសន្យា ធនាគារបែងចែកតម្លៃតបស្នងនៅក្នុងកិច្ចសន្យាចំពោះសមាសធាតុនៃភតិសន្យា នីមួយៗ និងសមាសធាតុដែលមិនមែនភតិសន្យា ដោយ ផ្អែកតាមតម្លៃឯកតានីមួយៗ។ ក៏ប៉ុន្តែ ចំពោះការជួលដី និងអគារដែលធនាគារជាអ្នកជួល ធនាគារមិនបែងចែកសមាសធាតុមិនមែន ភតិសន្យានោះទេ ហើយសមាសធាតុភតិសន្យា និងមិនមែនភតិសន្យាត្រូវបានចាត់ទុកថាជាសមាសធាតុភតិសន្យា។

ភតិសន្យាក្នុងករណីដែលធនាគារជាអ្នកជួល

ការរៀបចំឱ្យមានសិទ្ធិក្នុងការប្រើប្រាស់ទ្រព្យសកម្ម ប្រសិនបើបំពេញតាមលក្ខខណ្ឌមួយក្នុងចំណោមខាងក្រោម៖

- អ្នកទិញមានសមត្ថភាព ឬសិទ្ធិធ្វើប្រតិបត្តិការលើទ្រព្យសកម្ម ខណៈពេលដែលទទួលបាន ឬគ្រប់គ្រងលើសពីបរិមាណ ដែលមិនសារវន្ត
- អ្នកទិញមានសមត្ថភាព ឬសិទ្ធិក្នុងការគ្រប់គ្រងលើការចូលទៅដល់ទ្រព្យសកម្ម ខណៈដែលទទួលបាន ឬគ្រប់គ្រងលើស ពីបរិមាណដែលមិនសារវន្ត ឬ
- ដំណើរហេតុ និងកាលៈទេសៈបានបង្ហាញថា វាមានលក្ខណៈតិចតួចដែលភាគីដទៃទៀតនឹងទទួលបានច្រើនជាង បរិមាណដែលមិនសារវន្ត ហើយតម្លៃក្នុងមួយឯកតាមិនត្រូវបានកំណត់ក្នុងមួយឯកតានៃទិន្នផលទេហើយក៏មិនស្មើនឹង តម្លៃទីផ្សារបច្ចុប្បន្ន ក្នុងមួយឯកតានៃលទ្ធផលដែរ។

ធនាគារទទួលស្គាល់សិទ្ធិប្រើប្រាស់ទ្រព្យសកម្ម និងបំណុលភតិសន្យា នៅកាលបរិច្ឆេទចាប់ផ្តើមភតិសន្យា។ សិទ្ធិប្រើប្រាស់ទ្រព្យសកម្ម ត្រូវបានវាស់វែងតាមថ្លៃដើម រួមមានថ្លៃដើមដំបូងនៃបំណុលភតិសន្យា និងនិយ័តភាពសម្រាប់ការចំណាយភតិសន្យាដែលធ្វើឡើង នៅថ្ងៃចាប់ផ្តើមភតិសន្យា ឬមុនថ្ងៃចាប់ផ្តើមភតិសន្យា បូកថ្លៃដើមផ្ទាល់ដំបូងដែលបានកើតឡើង និងការប៉ាន់ស្មានចំណាយក្នុងការរុះរើ និងដកចេញនូវទ្រព្យសកម្ម ឬស្តារឡើងវិញនូវទ្រព្យសកម្ម ឬទីតាំង ដកប្រាក់លើកទឹកចិត្តភតិសន្យាដែលទទួលបាន។

សិទ្ធិប្រើប្រាស់ទ្រព្យសកម្មត្រូវបានដករំលស់នាពេល តាមវិធីសាស្ត្ររំលស់ថេរ ចាប់ពីកាលបរិច្ឆេទចាប់ផ្តើមភតិសន្យា រហូតដល់ចុងបញ្ចប់នៃ អាយុកាលប្រើប្រាស់នៃសិទ្ធិប្រើប្រាស់ទ្រព្យសកម្ម ឬនៅចុងកាលបរិច្ឆេទនៃភតិសន្យាមួយណាកើតមុន។ អាយុកាលប្រើប្រាស់នៃ សិទ្ធិប្រើប្រាស់ទ្រព្យសកម្ម ត្រូវបានកំណត់តាមមូលដ្ឋានដូចគ្នានឹងទ្រព្យ និងបរិក្ខារ។ បន្ថែមលើនេះ សិទ្ធិប្រើប្រាស់ទ្រព្យសកម្ម ត្រូវបានកាត់បន្ថយជាប្រចាំទៅតាមការខាតបង់ឱនភាពនៃតម្លៃ និងកែតម្រូវសម្រាប់ការវាស់វែងឡើងវិញលើបំណុលភតិសន្យា។

ការប៉ាន់ស្មានអាយុកាលប្រើប្រាស់សម្រាប់អំឡុងការិយបរិច្ឆេទបច្ចុប្បន្ន មានដូចខាងក្រោម៖

- អគារ និងការិយាល័យសាខា រយៈពេលកិច្ចសន្យា

បំណុលភតិសន្យា ត្រូវបានវាស់វែងដំបូងតាមតម្លៃបច្ចុប្បន្ននៃការទូទាត់ភតិសន្យាដែលមិនទាន់បានបង់ នៅពេលចាប់ផ្តើមភតិសន្យា និងត្រូវបានធ្វើអប្បហារដោយប្រើអត្រាការប្រាក់ជាក់ស្តែងនៅក្នុងភតិសន្យា ឬករណីដែលអត្រាការប្រាក់នោះមិនអាចកំណត់បានភ្លាមៗ ត្រូវធ្វើទៅតាមអត្រាការប្រាក់កម្ចីបន្ថែមរបស់អ្នកជួល។ ជាទូទៅ ធនាគារប្រើប្រាស់អត្រាកម្ចីបន្ថែមធ្វើជាអត្រាអប្បហារ។

ការទូទាត់ភតិសន្យាដែលបញ្ចូលនៅក្នុងការវាស់វែងបំណុលភតិសន្យារួមមាន៖

- ការទូទាត់ភតិសន្យាថេរ រួមទាំងការទូទាត់ក្នុងទម្រង់ថេរ
- ការប្រែប្រួលនៃការទូទាត់ភតិសន្យាអថេរ ដោយផ្អែកលើសន្ទស្សន៍ ឬអត្រា នៅកាលបរិច្ឆេទចាប់ផ្តើមភតិសន្យា
- ចំនួនដែលរំពឹងថានឹងត្រូវទូទាត់ ក្រោមការធានាតម្លៃនៅសល់ និង
- តម្លៃទិញក្រោមជម្រើសនៃការទិញ ដែលធនាគារមានហេតុផលជាក់លាក់ក្នុងការអនុវត្ត។ ការទូទាត់ភតិសន្យា នៅក្នុងអំឡុងពេលដែលមានជម្រើសក្នុងការបន្ត ប្រសិនបើធនាគារមានហេតុផលជាក់លាក់ក្នុងការបន្ត និងការពិន័យ លើការបញ្ចប់ភតិសន្យាមុនកាលកំណត់ លើកលែងតែធនាគារមានហេតុផលច្បាស់លាស់ថានឹងមិនបញ្ចប់ភតិសន្យា មុនកាលកំណត់។

បំណុលភតិសន្យាត្រូវបានវាស់វែងតាមរំលស់ថ្លៃដើម ដោយប្រើវិធីសាស្ត្រអត្រាការប្រាក់ប្រសិទ្ធភាព។ បំណុលភតិសន្យាត្រូវបាន វាស់វែងឡើងវិញនៅពេលមានការកែប្រែរយៈពេលនៃភតិសន្យា ការផ្លាស់ប្តូរលើការវាយតម្លៃសម្រាប់ជម្រើសក្នុងការទិញទ្រព្យសកម្ម ការប្រែប្រួលការទូទាត់ភតិសន្យានាពេលអនាគត ដែលកើតឡើងពីការប្រែប្រួលនៃសន្ទស្សន៍ ឬអត្រាណាមួយ ឬប្រសិនបើ មានការកែប្រែចំនួនប៉ាន់ស្មានដែលរំពឹងថានឹងត្រូវទូទាត់លើការធានាតម្លៃដែលនៅសល់។

នៅពេលដែលបំណុលភតិសន្យាត្រូវបានវាស់វែងតាមវិធីសាស្ត្រនេះ ការកែតម្រូវ ត្រូវបានធ្វើឡើងលើតម្លៃយោងនៃសិទ្ធិប្រើប្រាស់ទ្រព្យសកម្ម ឬក៏ទទួលស្គាល់ក្នុងចំណេញ ឬខាត បើសិនជាសិទ្ធិប្រើប្រាស់ទ្រព្យសកម្ម ត្រូវបានបញ្ចុះរហូតដល់មានតម្លៃសូន្យ។

ភតិសន្យាមានរយៈខ្លី និងភតិសន្យាលើទ្រព្យសកម្មដែលមានតម្លៃទាប

ធនាគារ មិនទទួលស្គាល់សិទ្ធិប្រើប្រាស់ទ្រព្យសកម្ម និងបំណុលភតិសន្យារយៈពេលខ្លីដូចជា ការជួលម៉ាស៊ីនដែលមានរយៈពេលតិចជាង ១២ ខែ និងភតិសន្យាលើទ្រព្យសកម្មដែលមានតម្លៃទាប ដែលរួមមានបរិក្ខារព័ត៌មានវិទ្យា។ ធនាគារទទួលស្គាល់ចំណាយលើការជួលទាំងនេះតាមមូលដ្ឋានរំលស់ថេរ ទៅតាមរយៈពេលនៃភតិសន្យា។

៤.១៥ អត្ថប្រយោជន៍និយោជិត

អត្ថប្រយោជន៍និយោជិតរយៈពេលខ្លី

អត្ថប្រយោជន៍និយោជិតរយៈពេលខ្លីត្រូវបានចំណាយ នៅពេលដែលសេវាកម្មត្រូវបានផ្តល់ជូន។ ចំនួនដែលរំពឹងទុកថានឹងត្រូវចំណាយ ត្រូវបានទទួលស្គាល់ជាបំណុល ប្រសិនបើធនាគារមានកាតព្វកិច្ចតាមផ្លូវច្បាប់ ឬកាតព្វកិច្ចប្រយោលនាពេលបច្ចុប្បន្ន ក្នុងការទូទាត់ចំណាយ ដែលជាលទ្ធផលនៃការងារដែលបានបំពេញរួចមកហើយដោយនិយោជិត ហើយកាតព្វកិច្ចនោះអាចធ្វើការប៉ាន់ស្មានបានដោយភាពជឿជាក់។

អត្ថប្រយោជន៍និយោជិតរយៈពេលវែង

កាតព្វកិច្ចរបស់ធនាគារចំពោះអត្ថប្រយោជន៍និយោជិតរយៈពេលវែង គឺជាចំណាយលើអត្ថប្រយោជន៍ ដែលនិយោជិតត្រូវទទួលបាន ពីការបំពេញការងារក្នុងការិយបរិច្ឆេទកន្លងផុតទៅ និងបច្ចុប្បន្ន។ អត្ថប្រយោជន៍ និយោជិតរយៈពេលវែង ត្រូវបានធ្វើអប្បហារទៅតម្លៃបច្ចុប្បន្ន។ ការវាស់វែងសារជាថ្មីត្រូវបានទទួលស្គាល់ជាចំណេញ ឬខាត ដែលចំណាយនេះបានកើតឡើង។

៤.១៦ ការប្រាក់

អត្រាការប្រាក់ប្រសិទ្ធភាព

ចំណូលការប្រាក់ និងចំណាយការប្រាក់ត្រូវបានទទួលស្គាល់នៅក្នុងចំណេញ ឬខាត ដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព។ "អត្រាការប្រាក់ប្រសិទ្ធភាព" គឺជាអត្រាដែលអាចធ្វើអប្បហារសាច់ប្រាក់ដែលរំពឹងថានឹងទូទាត់ ឬនឹងត្រូវទទួលតាមរយៈអាយុកាល រំពឹងទុករបស់ឧបករណ៍ហិរញ្ញវត្ថុនោះ ឱ្យមកស្មើនឹង៖

- តម្លៃយោងដុលរបស់ទ្រព្យសកម្មហិរញ្ញវត្ថុ ឬ
- រំលស់ថ្លៃដើមរបស់បំណុលហិរញ្ញវត្ថុ។

នៅពេលគណនាអត្រាការប្រាក់ប្រសិទ្ធភាពសម្រាប់ឧបករណ៍ហិរញ្ញវត្ថុ ក្រៅពីទ្រព្យដែលបានទិញ ឬទ្រព្យសកម្ម ដែលមានឱនភាពនៃ តម្លៃនៅពេលទិញ ធនាគារធ្វើការប៉ាន់ស្មានលើលំហូរទឹកប្រាក់នាពេលអនាគតដោយពិចារណាវាល់លក្ខខណ្ឌទាំងអស់របស់ កិច្ចសន្យាឧបករណ៍ហិរញ្ញវត្ថុ ប៉ុន្តែមិនរាប់បញ្ចូលនូវការខាតបង់ឥណទាន ដែលរំពឹងទុកនោះទេ (ECL)។ សម្រាប់ទ្រព្យសកម្ម ដែលទិញ ឬទ្រព្យសកម្មហិរញ្ញវត្ថុដែលមានឱនភាពនៃតម្លៃនៅពេលទិញ អត្រាការប្រាក់ប្រសិទ្ធភាពដែលបានកែតម្រូវហានិភ័យ ឥណទាន ត្រូវបានគណនា ដោយប្រើលំហូរទឹកប្រាក់ប៉ាន់ស្មាននាពេលអនាគត រួមបញ្ចូលទាំងការខាតបង់ឥណទានដែលរំពឹងទុក (ECL)។

ការគណនាអត្រាការប្រាក់ប្រសិទ្ធភាព រួមបញ្ចូលនូវថ្លៃដើមប្រតិបត្តិការ និងកម្រៃទាំងអស់ដែលបានបង់ ឬទទួលដែលជាផ្នែកនៃ អត្រាការប្រាក់ប្រសិទ្ធភាព។ ថ្លៃដើមប្រតិបត្តិការរួមមាន ការចំណាយបន្ថែមដែលពាក់ព័ន្ធផ្ទាល់ទៅនឹងការទិញ ឬការបោះផ្សាយ ទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ។

រំលស់ថ្លៃដើម និងតម្លៃយោងដុល

រំលស់ថ្លៃដើមរបស់ទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ គឺជាចំនួនដែលទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ ត្រូវបានវាស់វែងនៅពេលទទួលស្គាល់ជាលើកដំបូង ដកការទូទាត់សងប្រាក់ដើម បូក ឬដករំលស់បង្គរដោយប្រើអត្រាការប្រាក់ប្រសិទ្ធភាព ចំពោះភាពខុសគ្នារវាងចំនួនដែលទទួលស្គាល់ជាលើកដំបូង និងចំនួននៅពេលដល់កាលកំណត់ និងត្រូវធ្វើនិយ័តភាពចំពោះសំវិធានធនលើ ការខាតបង់ឥណទានដែលបានរំពឹងទុកចំពោះទ្រព្យសកម្មហិរញ្ញវត្ថុ។

តម្លៃយោងដុលរបស់ទ្រព្យសកម្មហិរញ្ញវត្ថុ គឺជារំលស់ថ្លៃដើមរបស់ទ្រព្យសកម្មហិរញ្ញវត្ថុ មុនពេលកែតម្រូវសំវិធានធនសម្រាប់ ការខាតបង់ឥណទានដែលបានរំពឹងទុក។

ការគណនាចំណូលការប្រាក់ និងចំណាយការប្រាក់

អត្រាការប្រាក់ប្រសិទ្ធភាពរបស់ទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ ត្រូវបានគណនានៅពេលទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុជាលើកដំបូង។ ក្នុងការគណនាចំណូលការប្រាក់ និងចំណាយការប្រាក់ អត្រាការប្រាក់ប្រសិទ្ធភាពត្រូវបាន ប្រើផ្អែកលើតម្លៃយោងដុលរបស់ទ្រព្យសកម្ម (នៅពេលដែលទ្រព្យសកម្មមិនត្រូវបានចាត់ទុកថាមានឱនភាពនៃតម្លៃ) ឬរំលស់ថ្លៃដើម នៃបំណុល។ អត្រាការប្រាក់ប្រសិទ្ធភាពត្រូវធ្វើការកែប្រែឡើងវិញ ដោយការប៉ាន់ស្មានឡើងវិញនូវលំហូរទឹកប្រាក់របស់ឧបករណ៍ហិរញ្ញវត្ថុដែលមានអត្រាការប្រាក់ប្រែប្រួល ដើម្បីឆ្លុះបញ្ចាំងពីការផ្លាស់ប្តូររបស់អត្រាការប្រាក់ទីផ្សារ។ អត្រាការប្រាក់ប្រសិទ្ធភាពក៏ ត្រូវធ្វើការកែប្រែឡើងវិញ សម្រាប់ការកែតម្រូវតម្លៃសមស្របនៃឧបករណ៍ការពារ នៅកាលបរិច្ឆេទដែលរំលស់ត្រូវបានចាប់ផ្តើម កែតម្រូវ។

ចំពោះទ្រព្យសកម្មហិរញ្ញវត្ថុដែលមានឱនភាពនៃតម្លៃ បន្ទាប់ពីបានទទួលស្គាល់ជាលើកដំបូង ចំណូលការប្រាក់ត្រូវបានគណនាដោយ ប្រើអត្រាការប្រាក់ប្រសិទ្ធភាព ផ្អែកលើរំលស់ថ្លៃដើម របស់ទ្រព្យសកម្មហិរញ្ញវត្ថុ។ ប្រសិនបើទ្រព្យសកម្មហិរញ្ញវត្ថុលែងមានឱនភាព នៃតម្លៃ នោះការគណនាការប្រាក់ត្រូវផ្អែកលើមូលដ្ឋានតម្លៃដុលវិញ។

ចំពោះទ្រព្យសកម្មហិរញ្ញវត្ថុដែលមានឱនភាពនៃតម្លៃ ចាប់តាំងពីទទួលស្គាល់ជាលើកដំបូង ចំណូលការប្រាក់ត្រូវបានគណនាដោយ ប្រើអត្រាការប្រាក់ប្រសិទ្ធភាពដែលត្រូវបានកែតម្រូវនូវហានិភ័យ ផ្អែកលើរំលស់ថ្លៃដើមនៃទ្រព្យសកម្មហិរញ្ញវត្ថុនោះ។ ការគណនា ចំណូលការប្រាក់នេះ មិនត្រូវប្តូរទៅមូលដ្ឋានតម្លៃដុលវិញនោះទេ ទោះបីជាហានិភ័យឥណទានរបស់ទ្រព្យសកម្មនោះ មានភាព ប្រសើរក៏ដោយ។

ការបង្ហាញ

ចំណូលការប្រាក់ត្រូវបានគណនាដោយប្រើវិធីសាស្រ្តការប្រាក់ប្រសិទ្ធភាព ដែលបានបង្ហាញនៅក្នុងចំណេញ ឬខាត និង លទ្ធផលលម្អិតផ្សេងៗ រួមបញ្ចូលការប្រាក់លើទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុដែលបានវាស់វែងតាមរំលស់ថ្លៃដើម។

ចំណាយការប្រាក់ត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗ រួមបញ្ចូលបំណុលហិរញ្ញវត្ថុ ដែលបានវាស់វែងតាមរំលស់ថ្លៃដើម។

៤.១៧ កម្រៃ និងជើងសារ

ចំណូល និងចំណាយកម្រៃ និងជើងសារ ដែលជាផ្នែកនៃអត្រាការប្រាក់ប្រសិទ្ធភាព របស់ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ ត្រូវបានរួមបញ្ចូលទៅក្នុងអត្រាការប្រាក់ប្រសិទ្ធភាព។

ចំណូលកម្រៃ និងជើងសារផ្សេងទៀតរួមបញ្ចូលទាំងថ្លៃសេវាកម្ម ត្រូវបានទទួលស្គាល់នៅពេលបានបំពេញសេវាកម្ម។

កិច្ចសន្យាជាមួយអតិថិជនដែលទទួលស្គាល់ជាឧបករណ៍ហិរញ្ញវត្ថុ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ អាចមានវិសាលភាព ដោយផ្នែកនៅក្នុង ស.រ.ហ.អ.ក ៩ និងដោយផ្នែកនៅក្នុង ស.រ.ហ.អ.ក ១៥ ។ ក្នុងករណីនេះ ជាដំបូងធនាគារត្រូវអនុវត្ត ស.រ.ហ.អ.ក ៩ ដើម្បីបែងចែក និងវាស់វែងផ្នែកនៃកិច្ចសន្យា ដែលចាត់ចូលនៅក្នុងវិសាលភាពនៃ ស.រ.ហ.អ.ក ៩ ហើយបន្ទាប់មកអនុវត្ត ស.រ.ហ.អ.ក ១៥ ចំពោះផ្នែកដែលនៅសេសសល់។

កម្រៃ និងជើងសារ ត្រូវបានបង្ហាញសុទ្ធនៅក្នុងរបាយការណ៍ចំណូលលម្អិត។

៤.១៨ ការទទួលស្គាល់ចំណាយ

ចំណាយគឺត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណូលលម្អិត នៅពេលការថយចុះនៃអត្ថប្រយោជន៍ផ្នែកសេដ្ឋកិច្ចនាពេលអនាគតបានជាប់ទាក់ទងទៅនឹងការថយចុះនៅក្នុងទ្រព្យសកម្ម ឬការកើនឡើងនៃបំណុលដែលបានកើតឡើងដែលអាចត្រូវបាន វាស់វែងយ៉ាងត្រឹមត្រូវ។ ចំណាយត្រូវបានទទួលស្គាល់របាយការណ៍ចំណូលលម្អិតលើមូលដ្ឋានពាក់ព័ន្ធផ្ទាល់រវាងថ្លៃដើមកើតឡើង និង ចំណូលជាក់លាក់លើមូលដ្ឋាននីតិវិធីជាប្រព័ន្ធ និងការបែងចែកនៅពេលអត្ថប្រយោជន៍សេដ្ឋកិច្ចត្រូវបានរំពឹងទុកថានឹងកើតឡើង កាលបរិច្ឆេទគណនេយ្យ និងពាក់ព័ន្ធនឹងចំណូលទូលំទូលាយ ឬចំណូលមិនផ្ទាល់ដែលបានកំណត់ ឬភ្លាមៗនៅពេលដែរចំណាយ មិនមានផ្តល់នូវអត្ថប្រយោជន៍ផ្នែកសេដ្ឋកិច្ចនាពេលអនាគត ឬអត្ថប្រយោជន៍សេដ្ឋកិច្ចគ្មានគុណភាព សម្រាប់ការទទួលស្គាល់នៅក្នុង របាយការណ៍ស្ថានភាពហិរញ្ញវត្ថុជាទ្រព្យសកម្ម។

ចំណាយនៅក្នុងរបាយការណ៍ចំណូលលម្អិតគឺត្រូវបានបង្ហាញដោយប្រើប្រាស់លក្ខណៈវិធីសាស្ត្រនៃចំណាយ។ ថ្លៃដើមប្រតិបត្តិការ តំណាងឱ្យចំណាយសេវា សេវាពាណិជ្ជកម្ម និងសេវាជើងសារដែលកើតឡើងពីការស្វែងរកប្រាក់ចំណូល។ ចំណាយបន្ទាប់បន្សំ គឺជាថ្លៃដើមដែលអាចមកពីការគ្រប់គ្រងរដ្ឋបាលទីផ្សារការលក់ និងសកម្មភាពអាជីវកម្មផ្សេងៗទៀតរបស់ធនាគារ។

៤.១៩ សំវិធានធន

សំវិធានធន ត្រូវបានទទួលស្គាល់នៅពេលធនាគារមានកាតព្វកិច្ចស្របច្បាប់ ឬប្រយោល ដែលជាលទ្ធផលនៃព្រឹត្តិការណ៍កន្លងមក ដែលវាទំនងជាមានលំហូរចេញនៃប្រភពសេដ្ឋកិច្ចរបស់ធនាគារ និងចំនួនទឹកប្រាក់ដែលអាចប៉ាន់ស្មានបាន។ ការកំណត់លំហូរចេញ នៃពេលវេលា ឬចំនួនទឹកប្រាក់នៅតែអាចមានភាពមិនច្បាស់លាស់។

នៅពេលមានកាតព្វកិច្ចស្រដៀងគ្នា ដែលអាចនឹងតម្រូវអោយមានលំហូរចេញសាច់ប្រាក់ ដើម្បីបំពេញនូវកាតព្វកិច្ច ត្រូវបានកំណត់ ដោយពិចារណាទៅលើថ្នាក់នីមួយៗ នៃកាតព្វកិច្ចនោះជាក្រុម។ សំវិធានធនត្រូវបានគេទទួលស្គាល់ទោះបីជាលទ្ធភាពនៃលំហូរចេញ ទាក់ទងទៅនឹងធាតុណាមួយដែលបានរួមបញ្ចូលនៅក្នុងប្រភេទនៃកាតព្វកិច្ចដូចគ្នាអាចកើតមានឡើងតិចតួចក៏ដោយ។

សំវិធានធនត្រូវបានវាស់វែងឡើងវិញតាមតម្លៃបច្ចុប្បន្ននៃការចំណាយដែលរំពឹងថានឹងតម្រូវឱ្យទូទាត់នូវកាតព្វកិច្ចដោយប្រើអត្រាពន្ធមុនដែលឆ្លុះបញ្ចាំងពីការវាយតម្លៃទីផ្សារបច្ចុប្បន្នអំពីតម្លៃពេលវេលានៃប្រាក់ និងហានិភ័យជាក់លាក់ចំពោះកាតព្វកិច្ច។ ការកើនឡើង នៃសំវិធានធនដោយសារពេលវេលាកន្លងផុតត្រូវបានទទួលស្គាល់ថាជាចំណាយការប្រាក់។

៤.២០ ពន្ធលើប្រាក់ចំណូល

ការចំណាយលើពន្ធដែលបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណូលលម្អិត រួមមានការបូកសរុបនៃពន្ធពន្យារ និងពន្ធបច្ចុប្បន្ន ដែលមិនបានទទួលស្គាល់ក្នុងរបាយការណ៍ចំណូលលម្អិត ឬរបាយការណ៍មូលធន។

ពន្ធប្រាក់ចំណូលលើទ្រព្យសកម្ម និង/ឬបំណុល រួមមានកាតព្វកិច្ច ឬការទាមទារពីអាជ្ញាធរសារពើពន្ធដែលទាក់ទងនឹងចុងការិយបរិច្ឆេទនៃរបាយការណ៍បច្ចុប្បន្ន ឬពីពេលកន្លងមក ដែលមិនបានទូទាត់នាការិយបរិច្ឆេទនៃរបាយការណ៍នោះ។ ពន្ធបច្ចុប្បន្ន គឺបំណុលលើប្រាក់ចំណេញជាប់ពន្ធដែលខុសពីប្រាក់ចំណេញ ឬខាតក្នុងរបាយការណ៍ហិរញ្ញវត្ថុ។ ការគណនាពន្ធបច្ចុប្បន្ន គឺផ្អែកលើអត្រាពន្ធ និងច្បាប់ពន្ធដែលត្រូវបានអនុម័ត ឬត្រូវបានអនុម័តនៅពេលបន្ទាប់ នាចុងការិយបរិច្ឆេទនៃរបាយការណ៍។

ពន្ធពន្យាលើប្រាក់ចំណូល ត្រូវបានគណនាដោយប្រើប្រាស់វិធីសាស្ត្របំណុលលើភាពខុសគ្នាបណ្តោះអាសន្ន រវាងទឹកប្រាក់យោង នៃទ្រព្យសកម្ម និងបំណុល និងមូលដ្ឋានពន្ធ។

ពន្ធពន្យាលើទ្រព្យសកម្ម និងបំណុលត្រូវបានគណនាដោយមិនគិតអប្បហារ នៅអត្រាពន្ធដែលរំពឹងថានឹងអនុវត្តទៅតាម រយៈពេលនៃការទទួលស្គាល់របស់ពួកគេ ដោយសារអត្រាពន្ធទាំងនោះត្រូវបានអនុម័ត ឬអនុម័តនៅពេលបន្ទាប់នៅចុងការិយបរិច្ឆេទនៃរបាយការណ៍។

ពន្ធពន្យាលើទ្រព្យសកម្ម ត្រូវបានទទួលស្គាល់ដើម្បីពង្រីកវិសាលភាពដែលប្រហែលជា មានការខាតបង់ ឬភាពខុសគ្នា បណ្ដោះអាសន្នដែលកាត់កងបាន នឹងអាចប្រើប្រាស់បានដើម្បីកាត់កងនឹងប្រាក់ចំណូលជាប់ពន្ធនាពេលអនាគត។ ការវាយតម្លៃនេះ គឺផ្អែកលើការព្យាករណ៍របស់ធនាគារទៅលើលទ្ធផលប្រតិបត្តិការនាពេលអនាគត ដែលត្រូវបានកែតម្រូវសម្រាប់ប្រាក់ចំណូល និងការចំណាយដែលមិនជាប់ពន្ធ និងការកំណត់ជាក់លាក់លើការប្រើប្រាស់ការខាតបង់ពន្ធដែលមិនបានប្រើណាមួយ និងពន្ធ ត្រូវបង់។ ពន្ធពន្យាលើបំណុល តែងតែត្រូវបានទទួលស្គាល់ទាំងអស់។

ពន្ធពន្យាលើទ្រព្យសកម្ម និងបំណុលអាចកាត់កង បានតែនៅពេលធនាគារមានសិទ្ធិ និងគោលបំណងក្នុងការទូទាត់ពន្ធបច្ចុប្បន្ន លើទ្រព្យសកម្ម និងបំណុលពីអាជ្ញាធរពន្ធដារដូចគ្នា។

ការផ្លាស់ប្ដូរពន្ធពន្យាលើទ្រព្យសកម្ម និងបំណុលត្រូវបានទទួលស្គាល់ជាផ្នែកនៃពន្ធលើប្រាក់ចំណូល ឬចំណាយនៅក្នុងរបាយការណ៍ ចំណូលលម្អិត លើកលែងតែនៅពេលដែលពន្ធទាំងនោះ មានការទាក់ទងនឹងផ្នែកទាំងអស់ដែលត្រូវបាន ទទួលស្គាល់នៅក្នុង របាយការណ៍ចំណូលលម្អិតផ្សេងទៀត (ដូចជាការវាយតម្លៃដីឡើងវិញ) ឬមូលធនក្នុងករណីណាមួយ ពេលពន្ធពន្យារដែលទាក់ទង ក៏ត្រូវទទួលស្គាល់នៅក្នុងរបាយការណ៍ចំណូលលម្អិតផ្សេងទៀត ឬរបាយការណ៍មូលធន។

៤.២១ បុគ្គលទាក់ទិន

បុគ្គលទាន់ទិន គឺជាបុគ្គល ឬអង្គភាពដែលមានទំនាក់ទំនងជាមួយធនាគារ។ ប្រតិបត្តិការបុគ្គលទាក់ទិន គឺជាការផ្ទេរធនធាន សេវាកម្ម ឬកាតព្វកិច្ចរវាងធនាគារ និងភាគីពាក់ព័ន្ធរបស់ខ្លួនទោះបីជាបានគិតថ្លៃ ឬមិនបានគិតថ្លៃ។

ក). បុគ្គល ឬមនុស្សដែលជិតស្និតជាមួយបុគ្គលនៃគ្រួសារនោះ គឺមានការពាក់ព័ន្ធប្រសិនបើបុគ្គលនោះ
  - (i). គ្រប់គ្រង ឬចូលរួមក្នុងការគ្រប់គ្រងលើធនាគារ
  - (ii). មានឥទ្ធិពលខ្លាំងលើធនាគារ ឬ
  - (iii). គឺជាសមាជិកនៃក្រុមប្រឹក្សាភិបាលជាន់ខ្ពស់របស់ធនាគារដែលកាន់កាប់ធនាគារ។

ខ). អង្គភាពដែលចាត់ចូលជាភាគីពាក់ពន្ធ័នៃធនាគារ លុះត្រាតែចូលក្នុងលក្ខខណ្ឌដូចខាងក្រោម៖
  - (i). អង្គភាព និងធនាគារគឺជាសមាជិកនៃសម្ព័ន្ធធនាគារតែមួយ
  - (ii). អង្គភាពមួយដែលជាការចូលរួម ឬការបណ្ដាក់ទុនរួមគ្នានៃអង្គភាពផ្សេងទៀត
  - (iii). អង្គភាពទាំងពីរធ្វើការបណ្ដាក់ទុនរួមលើភាគីទីបីដូចគ្នា
  - (iv). អង្គភាពមួយគឺជាភាគហ៊ុនរួមនៃអង្គភាពភាគីទីបី និងអង្គភាពផ្សេងទៀតគឺជាអង្គភាពរួមបញ្ចូលគ្នានៃភាគីទីបី
  - (v). អង្គភាព គឺជាគម្រោងអត្ថប្រយោជន៍ក្រោយការងារសម្រាប់អត្ថប្រយោជន៍របស់និយោជិកទាំងធនាគារ ឬអង្គភាពដែលទាក់ទងនឹងធនាគារ
  - (vi). អង្គភាពត្រូវបានគ្រប់គ្រង ឬគ្រប់គ្រងរួមគ្នាដោយបុគ្គលដែលបានបញ្ជាក់នៅក្នុង (i) ខាងលើ
  - (vii). បុគ្គលដែលបានកំណត់អត្តសញ្ញាណនៅក្នុង (ក.i) ខាងលើមានឥទ្ធិពលគួរឱ្យកត់សម្គាល់លើអង្គភាព ឬជាសមាជិកនៃក្រុមប្រឹក្សាភិបាលសំខាន់ដែលកំពុងកាន់កាប់ធនាគារ ឬអង្គភាព
  - (viii). អង្គភាព ឬសមាជិកនៃសម្ព័ន្ធ ដែលជាផ្នែកមួយផ្ដល់នូវសេវាកម្មគ្រប់គ្រងសំខាន់ៗ ដល់ធនាគារ ឬធនាគារមេ។

៤.២២ ព្រឹត្តិការណ៍ក្រោយការិយបរិច្ឆទនៃរបាយការណ៍

ធនាគារកំណត់យកព្រឹត្តិការណ៍បន្ទាប់ពីចុងការិយបរិច្ឆេទនៃរបាយការណ៍នីមួយៗ ដែលចាត់ទុកថាព្រឹត្តិការណ៍ទាំងនោះ ទាំងអំណោយផល និងមិនអំណោយផលដែលកើតឡើងនៅរវាងចុងការិយបរិច្ឆេទនៃរបាយការណ៍ និងកាលបរិច្ឆេទដែល របាយការណ៍ហិរញ្ញវត្ថុត្រូវបានអនុម័តឱ្យចេញផ្សាយ។ របាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ត្រូវបានធ្វើនិយ័តកម្មដើម្បីឆ្លុះបញ្ចាំងអំពី ព្រឹត្តិការណ៍ទាំងនោះ ដែលបានភស្តុតាងបន្ថែមលើលក្ខខណ្ឌដែលកើតមានឡើងនាចុងការិយបរិច្ឆេទនៃរបាយការណ៍។ ព្រឹត្តិការណ៍ មិនបានកែតម្រូវបន្ទាប់ពីចុងបញ្ចប់ការិយបរិច្ឆេទរាយការណ៍ ត្រូវបានលាតត្រដាងនៅក្នុងកំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ ប្រសិនបើវាមានភាពជាសារវន្ត។

៥. គណនេយ្យប៉ាន់ស្មាន ការសន្មត និងការវិនិច្ឆ័យ

ការប៉ាន់ស្មាន នឹងសន្មតធ្វើឡើងតាមរយៈបទពិសោធន៍ប្រវត្តិសាស្រ្ត និងកត្តាពាក់ព័ន្ធផ្សេងៗ។ លទ្ធផលជាក់ស្តែងប្រហែលជា ខុសពីការប៉ាន់ស្មានទាំងនោះ។ ការប៉ាន់ស្មាន និងមូលដ្ឋាននៃកាសន្មតត្រូវបាន ត្រួតពិនិត្យឡើងវិញតាមមូលដ្ឋានបន្តរនិរន្តភាព។ ការពិនិត្យឡើងវិញនៃការប៉ាន់ស្មានគណនេយ្យគឺត្រូវបានទទួលស្គាល់នៅក្នុង កំឡុងពេលដែលការប៉ាន់ស្មានត្រូវបានត្រួតពិនិត្យឡើងវិញ។ ប្រសិនបើការត្រួតពិនិត្យឡើងវិញមានឥទ្ធិពលលើតែអំឡុងពេលនោះទេ ឬនៅក្នុងអំឡុងពេលនៃការពិនិត្យឡើងវិញ និងនៅពេលអនាគត និងប្រសិនបើការពិនិត្យឡើងវិញនេះប៉ះពាល់ទាំងពេលបច្ចុប្បន្ន និងពេលអនាគត។

ការវិនិច្ឆ័យសំខាន់ៗក្នុងការអនុវត្តន៍គោលនយោបាយគណនេយ្យ

ខាងក្រោមនេះ គឺជាសន្មតគណនេយ្យជាក់លាក់ ក្រៅពីការវិនិច្ឆ័យលើការប៉ាន់ស្មាន ដែលត្រូវបានបង្ហាញដាច់ដោយឡែក ដូចខាងក្រោម គណៈគ្រប់គ្រងបានអនុវត្តនៅក្នុងដំណើរការនៃការអនុវត្តគោលនយោបាយគណនេយ្យរបស់ធនាគារ ហើយមានឥទ្ធិពល យ៉ាងខ្លាំងទៅលើចំនួនទឹកប្រាក់ដែលត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

រូបិយប័ណ្ណគោល

ដោយផ្អែកលើខ្លឹមសារសេដ្ឋកិច្ចនៃកាលៈទេសៈជាមូលដ្ឋានទាក់ទងទៅនឹងធនាគារ គណៈគ្រប់គ្រងបានកំណត់ រូបិយប័ណ្ណគោល របស់ធនាគារជាប្រាក់ដុល្លារអាមេរិក។ ដុល្លារអាមេរិក គឺជារូបិយប័ណ្ណ នៃបរិយាកាសសេដ្ឋកិច្ចចម្បងដែលធនាគារធ្វើប្រតិបត្តការ ហើយវាជារូបិយប័ណ្ណដែលមានឥទ្ធិពលសំខាន់ទៅលើឥណទានទៅឱ្យអតិថិជន និងចំណូលការប្រាក់។

ការវាយតម្លៃគំរូអាជីវកម្ម

ធនាគារប្រើគំរូនិងការសន្មតផ្សេងៗគ្នាក្នុងការប៉ាន់ស្មាន ECL។ ការវិនិច្ឆ័យត្រូវបានអនុវត្តក្នុងការកំណត់គំរូសមស្របបំផុតសម្រាប់ប្រភេទទ្រព្យសម្បត្តិនីមួយៗ ក៏ដូចជាសម្រាប់កំណត់ការសន្មតដែលបានប្រើនៅក្នុងគំរូទាំងនេះរួមទាំងការសន្មតដែលទាក់ទងនឹង កត្តាជំរុញហានិភ័យនៃហានិភ័យឥណទាន។

សំវិធានធននៃការបាត់បង់ឥណទានរំពឹងទុកលើទ្រព្យសកម្មហិរញ្ញវត្ថុតាមចំណាយរំលស់។ សំវិធានធនលើការខាតបង់ឥណទាន ដែលរំពឹងទុកសម្រាប់ទ្រព្យសកម្មហិរញ្ញវត្ថុដែលត្រូវបានវាស់វែងតាមចំណាយរំលស់ តម្រូវឱ្យមានការប្រើប្រាស់គំរូស្មុគស្មាញ និងការសន្មតសំខាន់ៗអំពីស្ថានភាពសេដ្ឋកិច្ចនាពេលអនាគត និងឥរិយាបថឥណទាន (ឧទាហរណ៍លទ្ធភាពអតិថិជនខកខាន និងការខាតបង់នៃលទ្ធផល)។

ការវិនិច្ឆ័យសំខាន់ៗមួយចំនួនត្រូវបានតម្រូវផងដែរក្នុងការអនុវត្តតម្រូវការគណនេយ្យសម្រាប់វាស់វែង ECL ដូចជា៖

- កំណត់លក្ខណៈវិនិច្ឆ័យនៃការកើនឡើងគួរឱ្យកត់សម្គាល់នៃហានិភ័យឥណទាន
- ការជ្រើសរើសគំរូសមស្រប និងការសន្មតសម្រាប់ការវាស់វែង ECL
- ការបង្កើតចំនួន និងសេណារីយ៉ូដែលយោងទៅការិយបរិច្ឆេទខាងមុខសម្រាប់រាល់ប្រភេទផលិតផល/ ទីផ្សារ និងECL របស់ធនាគារ
- ការបង្កើតក្រុមរបស់ទ្រព្យសកម្មហិរញ្ញវត្ថុស្រដៀងគ្នាក្នុងគោលបំណងនៃការវាស់វែង ECL។

ភតិសន្យា

ការវាយតម្លៃថាតើការរៀបចំ រួមបញ្ចូលនូវភតិសន្យាអាស្រ័យលើសមាសធាតុដែលពាក់ព័ន្ធ ឬទេ។ ការរៀបចំមាន ឬរួមមាន ភតិសន្យា នៅពេលដែលភតិសន្យាពេញលេញ ប្រសិនបើការរៀបចំអាស្រ័យទៅលើទ្រព្យសកម្មជាក់លាក់ ឬទ្រព្យសកម្ម ហើយបានបញ្ចូលទៅក្នុងទ្រព្យសកម្មដែលមានសិទ្ធិប្រើប្រាស់។

ចំណាយពន្ធលើប្រាក់ចំណូល

ធនាគារនឹងទទួលស្គាល់នូវបំណុលសម្រាប់ការចំណាយពន្ធដែលរំពឹងទុកដោយផ្អែកលើការប៉ាន់ប្រមាណថា ពន្ធនោះត្រូវបានកំណត់ តាមរយៈការបកស្រាយបច្ចុប្បន្នរបស់ក្រុមប្រឹក្សាភិបាលតាមច្បាប់ពន្ធផ្សេងៗ ដែលជាកម្មវត្ថុនៃការប្រែប្រួលតាមកាលវេលាកំណត់។ ការកំណត់ចុងក្រោយនៃចំណាយពន្ធ នឹងត្រូវធ្វើឡើងបន្ទាប់ពីមានការត្រួតពិនិត្យដោយអគ្គនាយកដ្ឋានពន្ធដារ។ នៅពេលលទ្ធផលពន្ធចុងក្រោយខុសគ្នាពីចំនួនទឹកប្រាក់ដែលត្រូវបានទទួលស្គាល់ដំបូង ភាពខុសគ្នានេះនឹងជះឥទ្ធិពលដល់សំវិធានធនពន្ធនៅក្នុងឆ្នាំហិរញ្ញវត្ថុដែលបានកំណត់។

ការទទួលស្គាល់ពន្ធពន្យាលើទ្រព្យសកម្ម

ពន្ធពន្យារទ្រព្យសកម្មអាចត្រូវបានទទួលស្គាល់ ដោយផ្អែកលើការវាយតម្លៃនៃភាពដែលអាចកើតឡើង ដែលប្រាក់ចំណូលជាប់ពន្ធ នាពេលអនាគតនឹងអាចមានសម្រាប់ទូទាត់លម្អៀងបណ្តោះអាសន្ន និងការខាតជាប់ពន្ធយោងពីមុនមកអាចនឹងត្រូវបានប្រើប្រាស់។ បន្ថែមពីនេះទៅទៀត ការវិនិច្ឆ័យសំខាន់ៗគឺទាមទារអោយមានការវាយតម្លៃលើ ផលប៉ះពាល់នៃផ្លូវច្បាប់ ឬសេដ្ឋកិច្ច ឬភាពមិនច្បាស់លាស់នៅក្នុងយុត្តាធិការពន្ធដាផ្សេងៗទៀត។

ការទទួលស្គាល់លើសំវិធានធន និងយថាភាព

ការវិនិច្ឆ័យត្រូវបានអនុវត្តដោយគណៈគ្រប់គ្រងដើម្បីបែងចែករវាងសំវាធានធន និងយថាភាព។ គោលនយោបាយលើការទទួលស្គាល់សំវិធានធន និងយថាភាពគឺត្រូវបានបង្ហាញនៅក្នុងកំណត់សម្គាល់ ៤.១៩ និងការបង្ហាញដែលពាក់ព័ន្ធដែលត្រូវបានបកស្រាយ នៅក្នុងកំណត់សម្គាល់២៩ ទាក់ទងនឹងនីតិវិធីច្បាប់ផ្សេងៗរបស់ធនាគារ។ ការប៉ាន់ស្មានរបស់ធនាគារអំពីចំណាយដែលអាចកើត មានប្រហែលកើតចេញពីការទាមទារ និងយថាភាពដែលត្រូវបានបង្កើតឡើងនៅក្នុងការពីគ្រោះយោបល់ និងសម្របសម្រួលជាមួយ អ្នកប្រឹក្សាយោបល់ផ្ទៃក្នុងរបស់ធនាគារ ដែលដើតួជាមេធាវីការពារក្តីផ្នែកច្បាប់របស់ធនាគារ ដោយផ្អែកលើការវិភាគលើលទ្ធផល ដែលអាចកើតមាន។ ទោះបីជាធនាគារមិនជឿថាប្រតិបត្តិការកំពុងដំណើរការក៏ដោយ ដូចដែលបានបង្ហាញនៅក្នុងកំណត់សម្គាល់៣០ និងមានផលប៉ះពាល់អវិជ្ជមានជាសារវន្តទៅលើស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារ។ វាអាចទៅរួចដែលលទ្ធផលនាពេលអនាគតរបស់ប្រតិបត្តិការអាចមានផលប៉ះពាល់ជាសារវន្តតាមរយៈការផ្លាស់ប្តូរនៅក្នុងការប៉ាន់ស្មាន ឬប្រសិទ្ធិភាពនៃយុទ្ធសាស្ត្រដែលទាក់ទងទៅនឹងនីតិវិធីទាំងនោះ។

ប្រភពសំខាន់ៗ នៃភាពមិនច្បាស់លាស់នៃការប៉ាន់ស្មាន

ខាងក្រោមនេះគឺជាការសន្មតសំខាន់ៗទាក់ទងទៅនឹងការព្យួយបារម្ភនាពេលអនាគតនិងប្រភពគន្លឹះផ្សេងទៀតនៃភាពមិនប្រាកដប្រជានៃការប៉ាន់ស្មាននៅចុងបញ្ចប់នៃរយៈពេលរបាយការណ៍នីមួយៗដែលមានហានិភ័យគួរឱ្យកត់សម្គាល់ក្នុងការបង្កឱ្យមានការកែ សម្រួលទៅនឹងចំនួនទឹកប្រាក់នៃទ្រព្យសកម្មនិងបំណុលក្នុងឆ្នាំហិរញ្ញវត្ថុបន្ទាប់។

ការវាស់វែងតម្លៃសមស្រប

ក្រុមប្រឹក្សាភិបាលប្រើបច្ចេកទេសក្នុងការវាយតម្លៃ ដើម្បីកំណត់តម្លៃសមស្របនៃឧបករណ៍ហិរញ្ញវត្ថុ (ពេលដែលសម្រង់តម្លៃនៅក្នុងទីផ្សារសកម្មមិនមាន) រួមទាំងទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ។ ទាំងនេះពាក់ព័ន្ធ នឹងការប៉ាន់ស្មាន និងការសន្មតដែលស្របជាមួយនឹង អ្នកចូលរួមដាក់តម្លៃទីផ្សារ។ ក្រុមប្រឹក្សាភិបាលពឹងផ្អែកទៅលើការសន្មតទៅលើទិន្នន័យដែលអាចសង្កេតតាមដែលអាចធ្វើទៅបាន ក៏ប៉ុន្តែករណីទាំងនេះមិនមែនកើតមានឡើងរហូតនោះទេ។ ក្នុងករណីនេះ ក្រុមប្រឹក្សាភិបាលប្រើប្រាស់ព័ត៌មានដែលអាចកើតមានឡើងញឹកញាប់បំផុត។

តម្លៃសមស្របដែលបានប៉ាន់ស្មាន អាចខុសគ្នាពីតម្លៃជាក់ស្តែងដែលនឹងត្រូវទទួលបានក្នុងប្រតិបត្តិការជំហោងដៃ នាការិយបរិច្ឆេទ នៃរបាយការណ៍។

សំវិធានធនឥណទានផ្តល់ដល់អតិថិជន

ធនាគារប្រើម៉ាទ្រីសសំវិធានធនដើម្បីគណនាសំវិធានធនឥណទានផ្តល់ដល់អតិថិជន។ អត្រាការសំវិធានធន គឺផ្អែកលើកាលបរិច្ឆេទ ផុតកំណត់ក្នុងការបែងចែកអតិថិជនជាក្រុមផ្សេងៗគ្នាដែលមានលំនាំនៃការខាតបង់ស្រដៀងគ្នា។ ម៉ាទ្រីសនៃសំវិធានធន ដំបូងឡើយ គឺផ្អែកលើអត្រាប្រវត្តិសាស្ត្រដែលអាចកំណត់បានរបស់ធនាគារ។ ធនាគារបានវាស់វែងទៅលើម៉ាទ្រីស ដើម្បីកែប្រែតម្លៃ អាចស្តារមកវិញបានលើការខាតបង់ឥណទានជាប្រវត្តិសាស្ត្រ។ រាល់កាលបរិច្ឆេទនៃរបាយការណ៍អត្រាប្រវត្តិសាស្ត្រដែលអាចកំណត់ បានត្រូវបានធ្វើបច្ចុប្បន្នភាពដែលបានកំណត់។

ការវាស់វែងទៅលើទំនាក់ទំនងរវាងអត្រាប្រវត្តិសាស្ត្រដែលអាចកំណត់បាន និងសំវិធានធនរបស់ឥណទានដែលផ្តល់ដល់អតិថិជន គឺត្រូវបានវាស់វែងជាក់ស្តែង។ តម្លៃនៃសំវិធានធនរបស់ឥណទានផ្តល់ដល់អតិថិជន គឺងាយនឹងរងការផ្លាស់ប្តូរតាមកាលៈទេសៈ។ ការខាតបង់ឥណទានជាប្រវត្តិសាស្ត្ររបស់ធនាគារ អាចមិនតំណាងឱ្យភាពគ្មានលទ្ធភាពសងជាក់ស្តែងក្នុងពេលអនាគតរបស់ អតិថិជន។ ការគណនាសំវិធានធន ពិចារណាលើការប្រើប្រាស់ព័ត៌មានសមស្រប និងយោងទៅការិយបរិច្ឆេទខាងមុខ ដោយផ្អែកលើ ការសន្មតលើបម្រែបម្រួលពេលអនាគតនៃអ្នកអនុវត្តសេដ្ឋកិច្ចផ្សេងគ្នាហើយរបៀបដែលអ្នកអនុវត្តសេដ្ឋកិច្ចជះឥទ្ធិពលលើគ្នាទៅវិញទៅមក ដែលអាចបណ្តាលឱ្យមានភាពខុសគ្នានៃកម្រិតនៃការខាតបង់សំវិធានធន។ ផលប៉ះពាល់នៃសំវិធានធនលើឥណទានផ្តល់ដល់ អតិថិជនរបស់ធនាគារ គឺត្រូវបានបង្ហាញនៅក្នុងកំណត់សំគាល់លេខ១០។

ការប៉ាន់ស្មានអាយុកាលនៃការប្រើប្រាស់របស់ទ្រព្យសកម្ម

អាយុកាលនៃការប្រើប្រាស់នៃទ្រព្យសកម្មរបស់ធនាគារ ជាមួយនឹងអាយុកាលច្បាស់លាស់ត្រូវបានប៉ាន់ស្មាន ផ្អែកលើរយៈពេល ដែលទ្រព្យសម្បត្តិត្រូវបានគេរំពឹងថាអាចប្រើបាន។ អាយុកាលនៃការប្រើប្រាស់នៃទ្រព្យសម្បត្តិ និងបរិក្ខាររបស់ធនាគារដែលបាន ប៉ាន់ស្មាន និងសិទ្ធិក្នុងការប្រើប្រាស់ទ្រព្យសកម្ម ត្រូវបានត្រួតពិនិត្យឡើងវិញយ៉ាងទៀងទាត់ ហើយត្រូវបានធ្វើបច្ចុប្បន្នភាព ប្រសិនបើការប៉ាន់ស្មានខុសពីការប៉ាន់ស្មានកន្លងមក ដោយសារតែរូបរាង និងគុណភាព ភាពហួសសម័យនៃបច្ចេកវិទ្យា និងពាណិជ្ជកម្ម រួមទាំងច្បាប់ ឬកម្រិតនៃការប្រើប្រាស់ទ្រព្យសកម្មរបស់ធនាគារ។ បន្ថែមពីនេះ ការប៉ាន់ស្មានអាយុកាល នៃការប្រើប្រាស់ គឺផ្អែកលើភាពស្រដៀងគ្នានៃទ្រព្យសកម្មទាំងនោះ។ ទោះបីជាយ៉ាងណាក៏ ដោយវាអាចទៅរួចដែលលទ្ធផលនាពេលអនាគតនៃប្រតិបត្តិការដែលអាចមានផលប៉ះពាល់ជាសារវន្ត ដោយផ្លាស់ប្តូរការប៉ាន់ស្មានដែលបានកើតឡើងដោយសារផ្លាស់ប្តូរកត្តា ទាំងឡាយដែលបានបកស្រាយពីខាងលើ។ ចំនួនទឹកប្រាក់ និងរយៈពេលនៃចំណាយដែលបានកត់ត្រាសម្រាប់រាល់កាលបរិច្ឆេទដែល នឹងប៉ះពាល់ ដោយសារការផ្លាស់ប្តូរនូវកត្តាទាំងនេះ រួមទាំងកាលៈទេសៈផងដែរ។ ការកាត់បន្ថយនូវអាយុកាលនៃការប្រើប្រាស់ ដែលបានប៉ាន់ស្មានរបស់ទ្រព្យសម្បត្តិ និងសិទ្ធិក្នុងប្រើប្រាស់ទ្រព្យសកម្ម ធ្វើឱ្យកើនឡើងនូវទទួលស្គាល់ចំណាយប្រតិបត្តិការ និងថយចុះនូវទ្រព្យសកម្មរយៈពេលវែង។

ឱនភាពទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ

ឱនភាពនៃតម្លៃកើតមានឡើងនៅពេលតម្លៃយោងនៃទ្រព្យសកម្ម ឬឯកតាបង្កើតសាច់ប្រាក់មានចំនួនលើសពីចំនួនដែលអាចស្តារមកវិញបាន គឺដោយយកតម្លៃសមស្របដកចំណាយក្នុងការលក់ និងតម្លៃក្នុងការប្រើប្រាស់។ ការគណនាតម្លៃសមស្របដកចំណាយក្នុង ការលក់ផ្អែកលើទិន្នន័យដែលអាចរកបានពីប្រតិបត្តិការលក់ ដែលបានចងនឹងប្រតិបត្តិការលក់ក្នុងតម្លៃទីផ្សារនៃទ្រព្យសម្បត្តិស្រដៀងគ្នា ឬតម្លៃទីផ្សារដែលអាចសង្កេតបានដកការចំណាយបន្ថែម សម្រាប់ការលក់ទ្រព្យសកម្ម។ ការគណនាតម្លៃប្រើប្រាស់ គឺផ្អែកលើគំរូ លំហូរសាច់ប្រាក់អប្បហារ។ លំហូរសាច់ប្រាក់ ដែលបានមកពីគម្រោងថវិការហើយដែលមិនរាប់បញ្ចូលសកម្មភាពរៀបចំរចនាសម្ព័ន្ធ ដែលធនាគារមិនទាន់បានធ្វើ ឬការវិនិយោគនាពេលអនាគតដែលនឹងធ្វើឱ្យប្រតិបត្តិការទ្រព្យសកម្មនៃឯកតាបង្កើតសាច់ប្រាក់ដែលត្រូវធ្វើ តេស្តមានភាពប្រសើរឡើង។ ចំនួនទឹកប្រាក់ដែលអាចស្តារមកវិញមានឥទ្ធិពលខ្លាំង ដោយសារអត្រាអប្បហារដែលត្រូវប្រើប្រាស់ សម្រាប់គំរូលំហូរសាច់ប្រាក់ ដែលធ្វើអប្បហារ ក៏ដូចជាអត្រាលំហូរសាច់ប្រាក់នាពេលអនាគតដែលរំពឹងទុក និងអត្រាកំណើន ដែលត្រូវបានប្រើសម្រាប់គោលបំណងគណនាការប៉ាន់ស្មាន។

៦. ការបន្តនិរន្តភាព

របាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារត្រូវបានរៀបចំឡើងលើការសន្មតថាធនាគារនឹងបន្តនិរន្តភាពអាជិវកម្មរបស់ខ្លួនបាន។ មូលដ្ឋាននៃការសន្មតគឺផ្អែកលើមូលដ្ឋានដែលធនាគារមិនមានបំណង ឬតម្រូវការក្នុងការផ្លាស់ប្តូរ ឬកាត់បន្ថយទំហំអាជីវកម្មរបស់ខ្លួនឡើយ។

ធនាគារបានជួបប្រទះជាមួយការខាតបង់ដែលបានកើតឡើងជាបន្តបន្ទាប់ដែលមានចំនួនទឹកប្រាក់សរុប ៤៩.៦៧១ ដុល្លារអាមេរិក គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ (ឆ្នាំ២០១៩៖ មានចំនួន ១.១៤៥.៥៦០ ដុល្លារអាមេរិក)។ កត្តាទាំងនេះបង្ហាញពីភាព មិនប្រាកដប្រជាជាសារវន្តអាចបង្កឱ្យមានការសង្ស័យអំពីសមត្ថភាពរបស់ក្រុមហ៊ុនក្នុងការបន្តនិរន្តភាព ប្រសិនបើគ្មានការគាំទ្រផ្នែក ហិរញ្ញវត្ថុពីម្ចាស់ភាគហ៊ុនរបស់ខ្លួន ក្នុងកំឡុងពេលដែលធនាគារខិតខំជម្រុញប្រតិបត្តិការក្នុងការស្វែងរកប្រាក់ចំណេញ។

ក្រុមប្រឹក្សាភិបាលជឿជាក់យ៉ាងមុតមាំថាវាជាការសមស្របក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនដោយផ្អែកលើមូលដ្ឋាននិរន្តភាពនៃដំណើរការអាជីវកម្ម ដោយមានការគាំទ្រផ្នែកហិរញ្ញវត្ថុចាំបាច់ដើម្បីឱ្យធនាគារអាចបន្តនិរន្តភាពអាជីវកម្មបាន។ លើសពីនេះទៀត ធនាគារមានគោលបំណងក្នុងការបង្កើនផលប័ត្រកម្ចីរបស់ខ្លួន ដើម្បីបង្កើននូវចំណូលការប្រាក់របស់ខ្លួនជាពិសេស ឥណទានបុគ្គល - ឥណទានទិញផ្ទះ និងឡានតាមរយៈការសហការជាមួយអ្នកអភិវឌ្ឍន៍ខាងវិស័យអចលនទ្រព្យ និងអ្នកចែកចាយ រថយន្ត។

របាយការណ៍ហិរញ្ញវត្ថុមិនរាប់បញ្ចូលការនិយ័តកម្មទាក់ទងទៅនឹងការធ្វើឱ្យប្រសើរឡើងវិញ និងការចាត់ថ្នាក់នៃចំនួនទ្រព្យសម្បត្តិ ដែលបានកត់ត្រាក៏ដូច ជាចំនួនទឹកប្រាក់ និងការចាត់ថ្នាក់បំណុលដែលអាចជាចាំបាច់គួរប្រើជាមូលដ្ឋាននិរន្តភាពនៃដំណើរការ អាជីវកម្មសម្រាប់ការរៀបចំ របាយការណ៍ហិរញ្ញវត្ថុ។

៧. សាច់ប្រាក់-សុទ្ធ

សាច់ប្រាក់ត្រូវបានវិភាគដូចខាងក្រោម៖

	ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០		ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩	
	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ ២.៤)	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ ២.៤)
សាច់ប្រាក់ក្នុងដៃ	១៤.១២៨.២២៨	៥៧.១៤៨.៦៨២	៤.១៩៥.៥០៦	១៦.៩៣៣.៦៨៧
សាច់ប្រាក់ជាមួយធនាគារផ្សេងៗ	៥៤.២៧០.១៦១	២១៩.៥២២.៨០១	៥៧.១៦០.៨៨០	២៣២.៩៣០.៥៨៦
សាច់ប្រាក់បានបង្ហាញលើរបាយការណ៍លំហូរសាច់ប្រាក់	៦៨.៣៩៨.៣៨៩	២៧៦.៦៧១.៤៨៣	៦១.៣១៦.៣៨៦	២៤៩.៨៦៤.២៧៣
ដកៈសំវិធានធនឱនភាពតម្លៃ	(៣៣.៤៣៤)	(១៣៥.២៤០)	(៦១.៨៧៣)	(២៥២.១៣៣)
	៦៨.៣៦៤.៩៥៥	**២៧៦.៥៣៦.២៤៣**	**៦១.២៥៤.៥១៣**	**២៤៩.៦១២.១៤០**

សាច់ប្រាក់ជាមួយធនាគារផ្សេងគឺជាគណនីចរន្តដែលមិនទទួលបានការប្រាក់នោះទេ។

បម្រែបម្រួលនៃសំវិធានធនលើការខាតបង់លើឱនភាពនៃតម្លៃមានដូចខាងក្រោម៖

	ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០		ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩	
	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ ២.៤)	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ ២.៤)
នាថ្ងៃទី១ ខែ មករា	៦១.៨៧៣	២៥២.១៣៣	១.៦៩៦	៦.៨១៤
(ការបង្វែរមកវិញ)/សំវិធានធនបន្ថែម	(២៨.៤៣៩)	(១១៥.៩៤៦)	៦០.១៧៧	២៤៣.៨៣៧
លម្អៀងពីការប្តូររូបិយប័ណ្ណ	-	(៩៤៧)	-	១.៤៨២
នាថ្ងៃទី៣១ ខែធ្នូ	**៣៣.៤៣៤**	**១៣៥.២៤០**	**៦១.៨៧៣**	**២៥២.១៣៣**

៨. ប្រាក់បញ្ញើជាមួយធនាគារផ្សេង

	ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០		ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩	
	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ ២.៤)	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ ២.៤)
ប្រាក់បញ្ញើមានកាលកំណត់ (មិនមែនជាសាច់ប្រាក់សមមូល)	៦.៤០៥.៨៧៥	២៥.៩១១.៧៦៤	១៨.០៥៨.០៨១	៧៣.៥៨៦.១៨០
	៦.៤០៥.៨៧៥	**២៥.៩១១.៧៦៤**	**១៨.០៥៨.០៨១**	**៧៣.៥៨៦.១៨០**

ប្រាក់បញ្ញើនៅធនាគារនានា មានកាលកំណត់ចាប់ពី ៣ ខែ ដល់ ៦ ខែ (ឆ្នាំ២០១៩៖ ៣ខែ ដល់ ៦ខែ) ហើយទទួលបានអត្រាការប្រាក់ចន្លោះពី ២% ទៅ ៤% (ឆ្នាំ២០១៩ ៖ ២% ទៅ ៤%) ក្នុងមួយឆ្នាំ។ ចំណូលការប្រាក់បានទទួលការប្រាក់ដែលមានចំនួនទឹកប្រាក់ ១.១៨០.២២៧ ដុល្លារអាមេរិក (ឆ្នាំ២០១៩៖ មានចំនួន ២៧៧.៣៥៦ ដុល្លារអាមេរិក) បានបង្ហាញនៅក្នុងកំណត់សម្គាល់ ២២ ជាផ្នែកមួយនៃប្រាក់តម្កល់ជាមួយធនាគារផ្សេង។

៩. ប្រាក់តម្កល់តាមច្បាប់

		ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០		ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩	
		ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ ២.៤)	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ ២.៤)
ប្រាក់តម្កល់ធានាលើដើមទុន	ក	៧.៥០០.០០០	៣០.៣៣៧.៥០០	៧.៥០០.០០០	៣០.៥៦២.៥០០
ប្រាក់បម្រុងកាតព្វកិច្ចលើប្រាក់បញ្ញើរបស់អតិថិជន	ខ	១៣.២៧១.១៨០	៥៣.៦៨១.៩២៣	១៦.២៧១.១៣៥	៦៦.៣០៤.៨៧៥
		២០.៧៧១.១៨០	**៨៤.០១៩.៤២៣**	**២៣.៧៧១.១៣៥**	**៩៦.៨៦៧.៣៧៥**

ក. ប្រាក់តម្កល់ធានាលើដើមទុន

យោងតាមប្រកាសរបស់ធនាគារជាតិនៃកម្ពុជាលេខ ធ៧-០១-១៣៦ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០០១ ធនាគារ តម្រូវឱ្យរក្សា ប្រាក់តម្កល់តាមច្បាប់ចំនួន ១០% នៃដើមទុនរបស់ខ្លួន។ ប្រាក់តម្កល់នេះ គឺមិនអាចប្រើប្រាស់ក្នុងប្រតិបត្តិការប្រចាំថ្ងៃរបស់ខ្លួនបានឡើយ ប៉ុន្តែធនាគារអាចដកវិញបាន នៅពេលដែលធនាគារសម្រេចចិត្តឈប់ធ្វើអាជីវកម្ម នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយស្ម័គ្រចិត្ត។ ប្រាក់តម្កល់ធានាដើមទុន ទទួលបានអត្រាការប្រាក់ 0% ទៅ 0.0៦% (ឆ្នាំ២០១៩៖: 0% ទៅ 0.៤៨%) ក្នុងមួយឆ្នាំ ដែលមានចំនួនទឹកប្រាក់ ២១.២៩៥ ដុល្លារអាមេរិក (ឆ្នាំ២០១៩៖ មានចំនួនទឹកប្រាក់ ៤៧.១៩៥ ដុល្លារអាមេរិក) ដូចបានបង្ហាញនៅក្នុងកំណត់សម្គាល់ ២២។

ខ. ប្រាក់បម្រុងកាតព្វកិច្ច

ប្រាក់បម្រុងកាតព្វកិច្ច គឺជាទុនបម្រុងអប្បបរមាដែលត្រូវបានគណនាតាមអត្រា ៨% ចំពោះរូបបិយវត្ថុជាប្រាក់រៀល និង ១២.៥០% ចំពោះរូបិយប័ណ្ណផ្សេងៗ នៃចំនួនទឹកប្រាក់សរុប នៃប្រាក់បញ្ញើរបស់អតិថិជន ប្រាក់បញ្ញើរបស់ធនាគារអនិវាសនជន និងប្រាក់បញ្ញើ គ្រឹះស្ថានហិរញ្ញវត្ថុ និងប្រាក់កម្ចីលើអនិវាសនជន។ យោងតាមប្រកាសរបស់ធនាគារជាតិនៃកម្ពុជា លេខ ធ៧-០១៨-២៨២ ប្រ.ក. ស្តីពីការរក្សា ទុនបម្រុងកាតព្វកិច្ចចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៨ សម្រាប់ប្រាក់បញ្ញើ និងការខ្ចីរបស់ធនាគារពាណិជ្ជ ប្រាក់បម្រុងកាតព្វកិច្ចជាប្រាក់រៀល និងរូបិយប័ណ្ណផ្សេងមិនទទួលបានការប្រាក់ទេ។

នៅថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២០ ធនាគារជាតិនៃកម្ពុជា បានចេញសេចក្តីថ្លែងការណ៍ ដោយប្រកាសកាត់បន្ថយអត្រាទុនបម្រុងកាតព្វកិច្ច មកត្រឹម ៧% ចំពោះប្រាក់បញ្ញើ និងប្រាក់កម្ចីជាប្រាក់រៀល និងរូបិយប័ណ្ណផ្សេងៗ ដើម្បីចូលរួមកាត់បន្ថយផលប៉ះពាល់ពីការឆ្លងរាលដាលជម្ងឺកូវីដ-១៩ មកលើសេដ្ឋកិច្ចកម្ពុជា។

១០. ឥណទានផ្តល់អតិថិជន-សុទ្ធ

	ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០		ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩	
	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ ២.៤)	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ ២.៤)
ឥណទានពាណិជ្ជកម្ម				
ឥណទានវិបារូបន៍	៥.៦៩២.៥៤៣	២៣.០២៦.៣៣៦	៨.២២០.១៤៤	៣៣.៤៩៧.០៨៧
ឥណទានរយៈពេលខ្លី	៧.១២២.៦៦៥	២៨.៨១១.១៨០	-	-
ឥណទានរយៈពេលវែង	-	-	៧.០៥៦.៤០៩	២៨.៧៥៤.៨៦៧
ឥណទានអ្នកប្រើប្រាស់				
ឥណទានវិបារូបន៍	២៦.៥២៦.៧៥៥	១០៧.៣០០.៧២៤	១២.៨៧៩.៨១៨	៥២.៣៦៣.០០៨
ឥណទានរយៈពេលខ្លី	១០.៧៥៧.៤០៧	៤៣.៥១៣.៧១១	៩.៥៤៤.១៣១	៣៩.០១៤.៥៨៤
ឥណទានរយៈពេលវែង	២៣.២៩៨.៦៨០	៩៤.២៤៣.១៦១	១៤.៦៣៧.៦៩០	៥៩.៦៤៨.៥៨៧
ឥណទានសម្ព័ន្ធញាតិ	១.២៣៧.១៤២	៥.០០៤.២៤០	១៥.៤៣២.៤១៧	៦២.៨៨៧.០៩៩
	៧៤.៦៣៥.១៩២	**៣០១.៨៩៩.៣៥២**	**៦៧.៧៧០.៦០៩**	**២៧៦.១៦៥.២៣២**
ដក៖ សំវិធានធនលើការខាតបង់លើឱនភាពនៃតម្លៃ	(១២៧.១០០)	(៥១៤.១២០)	(៥៩.៥៨៣)	(២៤២.៨០១)
ឥណទាននិងបុរេប្រទានផ្តល់ដល់អតិថិជន-សុទ្ធ	**៧៤.៥០៨.០៩២**	**៣០១.៣៨៥.២៣២**	**៦៧.៧១១.០២៦**	**២៧៥.៩២២.៤៣១**

សំវិធានធនលើការខាតបង់លើឱនភាពនៃតម្លៃ ដែលបានទទួលស្គាល់ក្នុងចំណេញ ឬខាតត្រូវបានសង្ខេបដូចខាងក្រោម៖

	ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០		ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩	
	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ ២.៤)	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ ២.៤)
ការខាតបង់សុទ្ធលើឱនភាពនៃតម្លៃនៃឥណទាន និងបុរេប្រទាន	៦៧.៥១៧	២៧៥.២៦៧	២៣.៧៤១	៩៦.១៩៩
ការខាតបង់សុទ្ធលើឱនភាពនៃតម្លៃនៃសមតុល្យធនាគារផ្សេងៗ (កំណត់សម្គាល់ ៧)	(២៨.៤៣៩)	(១១៥.៩៤៦)	៦០.១៧៧	២៤៣.៨៣៧
ការខាតបង់សុទ្ធលើឱនភាពនៃតម្លៃនៃការវិនិយោគផ្សេងៗ (កំណត់សម្គាល់ ១១)	៣.៥៩៦	១៤.៦៦១	៥១៨	២.០៩៩
	៤២.៦៧៤	**១៧៣.៩៨២**	**៨៤.៤៣៦**	**៣៤២.១៣៥**

បម្រែបម្រួលនៃសំវិធានធនលើការខាតបង់លើឱនភាពនៃតម្លៃនៃឥណទាន និងបុរេប្រទានផ្តល់ដល់អតិថិជន មានដូចខាងក្រោម៖

	ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០		ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩	
	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ ២.៤)	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ ២.៤)
នាថ្ងៃទី១ ខែមករា	៥៩.៥៨៣	២៤២.៨០១	៣៥.៨៤២	១៤៤.០១៣
សំវិធានធនបន្ថែមសម្រាប់ការិយបរិច្ឆេទ	៦៧.៥១៧	២៧៥.២៦៧	២៣.៧៤១	៩៦.១៩៩
លម្អៀងពីការប្តូររូបិយប័ណ្ណ	-	(៣.៩៤៨)	-	២.៥៨៩
នាថ្ងៃទី៣១ ខែធ្នូ	**១២៧.១០០**	**៥១៤.១២០**	**៥៩.៥៨៣**	**២៤២.៨០១**

ឥណទាន និងបុរេប្រទានផ្តល់ដល់អតិថិជនដុល ដែលមានកាលកំណត់ដូចខាងក្រោម៖

	ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០		ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩	
	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ ២.៤)	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ ២.៤)
រយៈពេល ១ ខែ	១០.៩៩៩.៩៤៩	៤៤.៤៩៤.៧៩៤	៧.០០០.០០០	២៨.៥២៥.០០០
> ១ ទៅ ៣ ខែ	១៣.៦៧៧.៧០៩	៥៥.៣២៦.៣៣៣	១.០០៩.៨០៦	៤.១១៤.៩៥៩
> ៣ ទៅ ៦ ខែ	១៤.៦៦៥.៥៦៣	៥៩.៣២២.២០២	៣.០៨៨.៧៣៣	១២.៥៨៦.៥៨៧
> ៦ ទៅ ១២ ខែ	១១.៧៦៦.៩៨២	៤៧.៥៩៧.៤៤២	៣៤.៩៧៧.៩៧១	១៤២.៥៣៥.២៣២
> ១ ទៅ ៣ ឆ្នាំ	១៤.១៨៩.៨០៥	៥៧.៣៩៧.៧៦១	៣១.៣០៣	១២៧.៥៦០
> ៣ ទៅ ៥ ឆ្នាំ	៧.២២៥.៨៣៤	២៩.២២៨.៤៩៩	២១.១៦៣.៥៩១	៨៦.២៤១.៦៣៤
លើសពី ៥ ឆ្នាំ	២.១០៩.៣៥០	៨.៥៣២.៣២១	៤៩៩.២០៥	២.០៣៤.២៦០
	៧៤.៦៣៥.១៩២	**៣០១.៨៩៩.៣៥២**	**៦៧.៧៧០.៦០៩**	**២៧៦.១៦៥.២៣២**

១១. ការវិនិយោគផ្សេងៗ

	ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០		ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩	
	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ ២.៤)	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ ២.៤)
ការវិនិយោគផ្សេងៗកត់ត្រាតាមរំលស់ថ្លៃដើម (*)	២៣.២៦៦.៣៧៧	៩៤.១១២.៤៩៥	២២.៥២៧.៧៨៣	៩១.៨០០.៧១៦
ដក៖ សំវិធានធនលើការខាតបង់លើឱនភាពនៃតម្លៃ	(១៣៩.១១០)	(៥៦២.៧០០)	(១៣៥.៥១៤)	(៥៥២.២២០)
	២៣.១២៧.២៦៧	**៩៣.៥៤៩.៧៩៥**	**២២.៣៩២.២៦៩**	**៩១.២៤៨.៤៩៦**

* ការវិនិយោគនេះ គឺតំណាងឱ្យប្រាក់តម្កល់ក្នុងការទិញមាសនៅក្រុមហ៊ុន Asia Investment and Financial Services Sole Co. Ltd. ដែលជាភាគទុនិករបស់ធនាគារ ដែលក្នុងនោះក្រុមហ៊ុន Asia Investment and Financial Services Sole Co. Ltd យល់ព្រមឱ្យការប្រាក់ចំនួន ៦% ក្នុងមួយឆ្នាំ។

បម្រែបម្រួលនៃសំវិធានធនលើការខាតបង់លើឱនភាពនៃតម្លៃមានដូចខាងក្រោម៖

	ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០		ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩	
	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ ២.៤)	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ ២.៤)
នាថ្ងៃទី១ ខែមករា	១៣៥.៥១៤	៥៥២.២២០	១៣៤.៩៩៦	៥៤២.៤១៤
សំវិធានធនបន្ថែមសម្រាប់ការិយបរិច្ឆេទ	៣.៥៩៦	១៤.៦៦១	៥១៨	២.០៩៩
លម្អៀងពីការប្តូររូបិយប័ណ្ណ	-	(៤.១៨១)	-	៧.៧០៧
នាថ្ងៃទី៣១ ខែធ្នូ	**១៣៩.១១០**	**៥៦២.៧០០**	**១៣៥.៥១៤**	**៥៥២.២២០**

១២. ទ្រព្យសកម្មអរូបី

	កម្មវិធីកុំព្យូទ័រ	
	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ ២.៤)
សមតុល្យយោងដុល		
សមតុល្យថ្ងៃទី១ ខែមករា ឆ្នាំ២០២០	១.១៨៥.១៥៥	៤.៨២៩.៥០៧
ទិញបន្ថែម	៣៩.២៣៧	១៦៤.១០៥
ផ្ទេរពីទ្រព្យសម្បត្តិ និងបរិក្ខារ	១២៩.២៤៦	៥២២.៨០០
លម្អៀងពីការប្តូររូបិយប័ណ្ណ	-	(៤០.៩៤៦)
សមតុល្យថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០	១.៣៥៣.៦៣៨	៥.៤៧៥.៤៦៦
រំលស់បង្គរ		
សមតុល្យថ្ងៃទី១ ខែមករា ឆ្នាំ២០២០	៣២៨.៩៩៨	១.៣៤០.៦៦៧
រំលស់ទ្រព្យសកម្មអរូបី	៤០៩.៤៤៥	១.៦៦៩.៣០៧
លម្អៀងពីការប្តូររូបិយប័ណ្ណ	-	(២២.៩៧២)
សមតុល្យថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០	៧៣៨.៤៤៣	២.៩៨៧.០០២
សមតុល្យយោងថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០	**៦១៥.១៩៥**	**២.៤៨៨.៤៦៤**
សមតុល្យយោងដុល		
សមតុល្យថ្ងៃទី១ ខែមករា ឆ្នាំ២០១៩	១៣៨.៥៧៧	៥៥៦.៨០២
ទិញបន្ថែម	១.០៤៦.៥៧៨	៤.២៤០.៧៣៤
លម្អៀងពីការប្តូររូបិយប័ណ្ណ	-	៣១.៩៧១
សមតុល្យថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩	១.១៨៥.១៥៥	៤.៨២៩.៥០៧
រំលស់បង្គរ		
សមតុល្យថ្ងៃទី១ ខែមករា ឆ្នាំ២០១៩	១៩.២២៥	៧៧.២៤៦
រំលស់ទ្រព្យសកម្មអរូបី	៣០៩.៧៧៣	១.២៥៥.២០០
លម្អៀងពីការប្តូររូបិយប័ណ្ណ	-	៨.២២១
សមតុល្យថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩	៣២៨.៩៩៨	១.៣៤០.៦៦៧
សមតុល្យយោងថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩	**៨៥៦.១៥៧**	**៣.៤៨៨.៨៤០**

១៣. ទ្រព្យសម្បត្តិ និងបរិក្ខារ

	ការកែលម្អអគារ	គ្រឿងសង្ហារឹម និង គ្រឿងបរិក្ខារ	បរិក្ខារការិយាល័យ	បរិក្ខារកុំព្យូទ័រ និង ព័ត៌មានវិទ្យា	យានយន្ត	ទ្រព្យកំពុងបង្កើត	សរុប	
	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ ២.៤)
សមតុល្យយោងដុល								
សមតុល្យថ្ងៃទី១ ខែមករា ឆ្នាំ២០២០	៤២២.៤២៦	៨.៥២២	២៧៣.២៩២	៣០៤.៥១៩	៥០.៣៥០	៤៤៦.៦៣៣	១.៥០៥.៧៤២	៦.១៣៥.៨៩៩
ទិញបន្ថែម	៧៦.៤៨៥	៥.៧៦៤	៤.៩៧៤	៤៥៤.៩៤៤	-	២.៦៩៥.៨៤០	៣.២៣៨.០០៧	១៣.២០១.៣៥៥
ផ្ទេរ (*)	៩៦.៤៩៤	១០.៤៧៩	៧៣.១៣៦	៥៤.៨៩៩	-	(២៣៥.០០៨)	-	-
ផ្ទេរទៅទ្រព្យសកម្មអរូបី (*)	-	-	-	-	-	(១២៩.២៤៦)	(១២៩.២៤៦)	(៥២២.៨០០)
ធ្វើចំណាត់ថ្នាក់ឡើងជាទ្រព្យសកម្មផ្សេងៗ (**)	-	-	-	-	-	(១១.៥៥០)	(១១.៥៥០)	(៤៦.៧២០)
លម្អៀងពីការប្តូររូបិយប័ណ្ណ	-	-	-	-	-	-	-	(១៤៨.៧៨៩)
សមតុល្យថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០	**៥៩៥.៤០៥**	**២៤.៧៦៥**	**៣៥១.៤០២**	**៨១៤.៣៦២**	**៥០.៣៥០**	**២.៧៦៦.៦៦៩**	**៤.៦០២.៩៥៣**	**១៨.៦១៨.៩៤៥**
រំលស់បង្គរ								
សមតុល្យថ្ងៃទី១ ខែមករាឆ្នាំ២០២០	១១៩.៣៣៩	១.៨៥៤	៥៦.៦៩២	៨៣.៣៣១	១៤.០៨៥	-	២៧៥.៣០១	១.១២១.៨៥២
ចំណាយរំលស់ក្នុងការិយបរិច្ឆេទ	១០៩.៦៩៥	៤.៥៣៧	៦៩.៩២២	១៧៩.៨៩៥	១០.០៧០	-	៣៧៤.១១៩	១.៥២៥.២៨៣
លម្អៀងពីការប្តូររូបិយប័ណ្ណ	-	-	-	-	-	-	-	(២០.២៣១)
សមតុល្យថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០	**២២៩.០៣៤**	**៦.៣៩១**	**១២៦.៦១៤**	**២៦៣.២២៦**	**២៤.១៥៥**	**-**	**៦៤៩.៤២០**	**២.៦២៦.៩០៤**
សមតុល្យយោង ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០	**៣៦៦.៣៧១**	**១៨.៣៧៤**	**២២៤.៧៨៨**	**៥៥១.១៣៦**	**២៦.១៩៥**	**២.៧៦៦.៦៦៩**	**៣.៩៥៣.៥៣៣**	**១៥.៩៩២.០៤១**

(*) ការផ្ទេរដែលទាក់ទងទៅនឹងការជួសជុលការិយាល័យកណ្តាលក្នុងការិយបរិច្ឆេទ។

(**) ការធ្វើចំណាត់ថ្នាក់ឡើងវិញទាក់ទងនឹងកាត ATM ដែលត្រូវបានទទួលស្គាល់ដំបូងថាជាទ្រព្យសកម្មថេរហើយត្រូវបានធ្វើចំណាត់ថ្នាក់ឡើងវិញទៅបញ្ជីសារពើភណ្ឌក្រោមទ្រព្យសកម្មផ្សេងៗ។

	ការកែលម្អអគារ	គ្រឿងសង្ហារឹម និង គ្រឿងបរិក្ខារ	បរិក្ខារការិយាល័យ	បរិក្ខារកុំព្យូទ័រ និង ព័ត៌មានវិទ្យា	យានយន្ត	ទ្រព្យកំពុងបង្កើត	សរុប	
	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ ២.៤)
សមតុល្យយោងដុល								
សមតុល្យថ្ងៃទី១ ខែមករា ឆ្នាំ២០១៩	៤២០.១៣៨	៥.១៧៥	១២៦.៩២១	៧០.៦១២	៤៩.០០០	-	៦៧១.៨៤៦	២.៦៩៩.៤៧៧
ទិញបន្ថែម	២.២៨៨	៣.៣៤៧	១៤៦.៣៧១	២៣៥.៤៦៣	១.៣៥០	៤៤៦.៦៣៣	៨៣៥.៤៥២	៣.៣៨៥.២៥២
លុបចោល	-	-	-	(១.៥៥៦)	-	-	(១.៥៥៦)	(៦.៣០៥)
លម្អៀងពីការប្តូររូបិយប័ណ្ណ	-	-	-	-	-	-	-	៥៧.៤៧៥
សមតុល្យថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩	**៤២២.៤២៦**	**៨.៥២២**	**២៧៣.២៩២**	**៣០៤.៥១៩**	**៥០.៣៥០**	**៤៤៦.៦៣៣**	**១.៥០៥.៧៤២**	**៦.១៣៥.៨៩៩**
រំលស់បង្គរ								
សមតុល្យថ្ងៃទី១ ខែមករា ឆ្នាំ២០១៩	៣៤.៩៣២	៤៣១	១០.៥២២	៩.៧៥៩	៤.០៨៣	-	៥៩.៧២៧	២៣៩.៩៨៣
រំលស់ក្នុងការិយបរិច្ឆេទ	៨៤.៤០៧	១.៤២៣	៤៦.១៧០	៧៤.១៧៦	១០.០០២	-	២១៦.១៧៨	៨៧៥.៩៥៣
លុបចោល	-	-	-	(៦០៤)	-	-	(៦០៤)	(២.៤៤៧)
លម្អៀងពីការប្តូររូបិយប័ណ្ណ	-	-	-	-	-	-	-	៨.៣៦៣
សមតុល្យថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩	**១១៩.៣៣៩**	**១.៨៥៤**	**៥៦.៦៩២**	**៨៣.៣៣១**	**១៤.០៨៥**	**-**	**២៧៥.៣០១**	**១.១២១.៨៥២**
សមតុល្យយោងថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩	**៣០៣.០៨៧**	**៦.៦៦៨**	**២១៦.៦០០**	**២២១.១៨៨**	**៣៦.២៦៥**	**៤៤៦.៦៣៣**	**១.២៣០.៤៤១**	**៥.០១៤.០៤៧**

១៤. សិទ្ធិប្រើប្រាស់ទ្រព្យសកម្ម

	ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០		ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩	
	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ ២.៤)	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ ២.៤)
សិទ្ធិប្រើប្រាស់ទ្រព្យសកម្ម	២.៤៥៤.៩៥៣	៩.៩៣០.២៨៥	១.៧៤៨.៨៥៤	៧.១២៦.៥៨០
	២.៤៥៤.៩៥៣	**៩.៩៣០.២៨៥**	**១.៧៤៨.៨៥៤**	**៧.១២៦.៥៨០**

ធនាគារ បានជួលអគារសំរាប់ប្រើប្រាស់ជាការិយាល័យកណ្តាល និងសាខា។ ព័ត៌មានអំពីការជួល ដែលធនាគារជាអ្នកជួលត្រូវបានបង្ហាញ ដូចខាងក្រោម។ ព័ត៌មានពាក់ព័ន្ធទៅនឹងបំណុលភតិសន្យាត្រូវបានបង្ហាញនៅក្នុងកំណត់សម្គាល់ ១៩។

	ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០		ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩	
	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ ២.៤)	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ ២.៤)
អគារការិយាល័យ				
សមតុល្យយោងដុល				
សមតុល្យនាថ្ងៃទី១ ខែមករា	១.៩៣៧.៩៤៨	៧.៨៩៧.១៣៨	៣៩៩.៨៤៥	១.៦០៦.៥៧៧
ទិញបន្ថែម	៩៥៤.៧៥៦	៣.៨៩២.៥៤០	១.៥៣៨.១០៣	៦.២៣២.៣៩៣
លម្អៀងពីការប្តូររូបិយប័ណ្ណ	-	(៨៨.៦៩០)	-	៥៨.១៦៨
សមតុល្យថ្ងៃទី៣១ ខែធ្នូ	**២.៨៩២.៧០៤**	**១១.៧០០.៩៨៨**	**១.៩៣៧.៩៤៨**	**៧.៨៩៧.១៣៨**
រំលស់បង្គរ				
សមតុល្យនាថ្ងៃទី១ ខែមករា	១៨៩.០៩៤	៧៧០.៥៥៨	៥៨.១៥៩	២៣៣.៦៨៣
រំលស់ទ្រព្យសកម្មរូបីក្នុងការិយបរិច្ឆេទ	២៤៨.៦៥៧	១.០១៣.៧៧៥	១៣០.៩៣៥	៥៣០.៥៤៩
លម្អៀងពីការប្តូររូបិយប័ណ្ណ	-	(១៣.៦៣០)	-	៦.៣២៦
សមតុល្យថ្ងៃទី៣១ ខែធ្នូ	**៤៣៧.៧៥១**	**១.៧៧០.៧០៣**	**១៨៩.០៩៤**	**៧៧០.៥៥៨**
សមតុល្យយោងនាថ្ងៃទី៣១ ខែធ្នូ	**២.៤៥៤.៩៥៣**	**៩.៩៣០.២៨៥**	**១.៧៤៨.៨៥៤**	**៧.១២៦.៥៨០**

១៥. ទ្រព្យសកម្មផ្សេងៗ

	ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០		ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩	
	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ ២.៤)	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ ២.៤)
បុរេប្រទានសម្រាប់ការវិនិយោគនាពេលអនាគត (*)	៤៧.៣០០.០០០	១៩១.៣២៨.៥០០	-	-
ការទូទាត់ជាមុនទៅម្ចាស់ភាគហ៊ុន (**)	២០.០០០.០០០	៨០.៩០០.០០០	-	-
ចំណាយបង់កក់	៨០៧.៥១៨	៣.២៦៦.៤១១	៧៩២.៧០០	៣.២៣០.២៥២
ប្រាក់តម្កល់ធានា (***)	៥០៤.៨៧១	២.០៤២.២០៣	-	-
សន្និធិ	៤៨.៧៥៩	១៩៧.២៣០	២១.១៩៩	៨៦.៣៨៦
	៦៨.៦៦១.១៤៨	**២៧៧.៧៣៤.៣៤៤**	**៨១៣.៨៩៩**	**៣.៣១៦.៦៣៨**

(*) នៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២០ ធនាគារបានទិញភាគហ៊ុនដែលមានតម្លៃសរុប ៤៧.៣ លានដុល្លារអាមេរិក ដែលស្មើនឹង ១២៥.០៣៦.៥២០ ភាគហ៊ុននៅក្នុងក្រុមហ៊ុន BCPG Public Company Limited (“BCPG”). ដែលជាក្រុមហ៊ុនដែលបានចុះបញ្ជី ក្នុងផ្សារភាគហ៊ុនថៃ (“SET”). ពីភាគីសម្ព័ន្ធញាត្តិចំនួនបី ដែលជាវិនិយោគិនដំបូងដែលទទួលបានការអនុញ្ញាត្តិទិញជាភាគហ៊ុនថ្មី របស់ក្រុមហ៊ុន BCPG តាមរយៈការរៀបចំដាក់ប្រាក់ឯកជនដែលបានធ្វើឡើងនៅថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២០។ ចំនួនទឹកប្រាក់នៃ តម្លៃទិញចូលត្រូវបានផ្ទេរដោយធនាគារទៅឱ្យភាគីសម្ព័ន្ធញាត្តិទាំង

បីនាកាលបរិច្ឆេទដដែល។ នៅក្រោមការរៀបចំនៃកិច្ចសន្យា សិទ្ធិលើការកាន់កាប់ភាគហ៊ុនរបស់ក្រុមហ៊ុន BCPG នឹងត្រូវបានប្រគល់ជូនដោយវិនិយោគិនដំបូងទៅឱ្យ ធនាគារតាមការិយបរិច្ឆេទ ខាងក្រោមដោយអនុលោមតាមបទប្បញ្ញត្តិការិយបរិច្ឆេទរបស់ SET ដែលបានកំណត់សម្រាប់ការវិនិយោគឯកជននេះ៖

- នៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២១ ចំនួន ២៥%នៃចំនួនទឹកប្រាក់សរុបនៃភាគហ៊ុនដែលបានទិញ និង
- នៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២១ ចំនួន ៧៥%នៃចំនួនទឹកប្រាក់សរុបដែលនៅសល់នៃភាគហ៊ុនដែលបានទិញ។

ដូចនេះហើយ នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ គណៈគ្រប់គ្រងបានធ្វើចំណាត់ថ្នាក់ទៅលើចំនួនទឹកប្រាក់ដែលបានទូទាត់ទៅឱ្យ ភាគីសម្ព័ន្ធញាត្តិទាំងបីក្នុងនាមជាបុរេប្រទាន។

បន្ទាប់មកទៀត នៅថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១ ធនាគារបានបញ្ចប់ការទិញភាគហ៊ុនរបស់ខ្លួនពីក្រុមហ៊ុន BCPG ហើយទទួលបានការសងប្រាក់ត្រឡប់មកវិញនៃតម្លៃទិញតាមរយៈគណនីធនាគារនៅប្រទេសរបស់ខ្លួន។

នៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២១ ធនាគារបានធ្វើការជូនដំណឹងដល់ធនាគារជាតិនៃកម្ពុជា អំពីលក្ខណៈនៃប្រតិបត្តិការនេះ។

(**) តំណាងឱ្យការទូទាត់ជាមុនទៅឱ្យម្ចាស់ភាគហ៊ុនដែលបានធ្វើឡើងក្នុងការទិញដីនៅខេត្តព្រះសីហនុ។ គិតត្រឹមកាលបរិច្ឆេទ នៃការចេញផ្សាយនៃរបាយការណ៍ហិរញ្ញវត្ថុ ដំណើរការនៃទិញចូលនេះមិនទាន់បានបញ្ចប់នៅឡើយទេ។

(***) ទាំងនេះបង្ហាញអំពីគណនី escrow ដែលជាការធានាទៅលើ Mastercard ដែលតម្រូវឱ្យរក្សាទុកដោយធនាគារ។

១៦. ប្រាក់បញ្ញើរបស់ធនាគារផ្សេងៗ

	ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០		ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩	
	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ ២.៤)	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ ២.៤)
ប្រាក់តម្កល់តាមតម្រូវការ	៩.១១៤.០៩៦	៣៦.៨៦៦.៥១៩	៣២១.៨៤៣	១.៣១១.៥១០
គណនីសន្សំមានកាលកំណត់	៦.៥៦៦.៤០៤	២៦.៥៦១.១០៤	-	-
	១៥.៦៨០.៥០០	**៦៣.៤២៧.៦២៣**	**៣២១.៨៤៣**	**១.៣១១.៥១០**

ប្រាក់បញ្ញើរបស់ធនាគារផ្សេងៗ ត្រូវបានវិភាគដូចខាងក្រោម៖

	ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០		ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩	
	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ ២.៤)	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ ២.៤)
ក. តាមរយៈកាលកំណត់				
ក្នុងកំឡុងពេល ១ខែ	៩.១១៤.០៩៦	៣៦.៨៦៦.៥១៩	៣២១.៨៤៣	១.៣១១.៥១០
> ១ខែ ទៅ ៣ខែ	៥២០.៧៥៤	២.១០៦.៤៥០	-	-
> ៣ខែ ទៅ ៦ខែ	៣.០០៧.៦០៣	១២.១៦៥.៧៥៤	-	-
> ៦ខែ ទៅ ១២ខែ	៣.០៣៨.០៤៧	១២.២៨៨.៩០០	-	-
	១៥.៦៨០.៥០០	**៦៣.៤២៧.៦២៣**	**៣២១.៨៤៣**	**១.៣១១.៥១០**

	ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០		ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩	
	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ ២.៤)	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ ២.៤)
ខ. តាមទំនាក់ទំនង៖				
សម្ព័ន្ធញាតិ	១.៦៧៧.៤១០	៦.៧៨៥.១២៣	៣១១.៩២៣	១.២៧១.០៨៦
មិនមែនសម្ព័ន្ធញាតិ	១៤.០០៣.០៩០	៥៦.៦៤២.៥០០	៩.៩២០	៤០.៤២៤
	១៥.៦៨០.៥០០	**៦៣.៤២៧.៦២៣**	**៣២១.៨៤៣**	**១.៣១១.៥១០**

	ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០		ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩	
	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ ២.៤)	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ ២.៤)
គ. វិភាគនិវាសនដ្ឋាន៖				
និវាសនជន	៨.១២៩.៩៦៥	៣២.៨៨៥.៧០៨	៣១១.៩២៣	-
អនិវាសនជន	៧.៥៥០.៥៣៥	៣០.៥៤១.៩១៥	៩.៩២០	១.៣១១.៥១០
	១៥.៦៨០.៥០០	**៦៣.៤២៧.៦២៣**	**៣២១.៨៤៣**	**១.៣១១.៥១០**

ឃ. តាមអត្រាការប្រាក់ (ក្នុងមួយឆ្នាំ)៖

	ឆ្នាំ២០២០	ឆ្នាំ២០១៩
គណនីសន្សំមានកាលកំណត់	២.៥០%-២.៧៥%	គ្មាន
ប្រាក់បញ្ញើតាមតម្រូវការ	០%-១%	គ្មាន

១៧. ប្រាក់បញ្ញើរបស់អតិថិជន

	ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០		ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩	
	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ ២.៤)	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ ២.៤)
គណនីសន្សំ	៨៨.៨៣៦.៥០០	៣៥៩.៣៤៣.៦៤៣	៣០.៣១៣.៦៥៤	១២៣.៥២៨.១៤០
គណនីសន្សំមានកាលកំណត់	៥៨.៤២៨.៦២៧	២៣៦.៣៤៣.៧៩៦	៤២.៣៦៣.១១៩	១៧២.៦២៩.៧១០
គណនីចរន្ត	២៧.១១៥.០៣២	១០៩.៦៨០.៣០៤	៤៧.១៨៨.០៩៧	១៩២.២៩១.៤៩៥
ប្រាក់បញ្ញើមានកម្រិត	-	-	៥០.០០០	២០៣.៧៥០
	១៧៤.៣៨០.១៥៩	**៧០៥.៣៦៧.៧៤៣**	**១១៩.៩១៤.៨៧០**	**៤៨៨.៦៥៣.០៩៥**

ប្រាក់បញ្ញើរបស់អតិថិជន ត្រូវបានវិភាគដូចខាងក្រោម៖

	ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០		ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩	
	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ ២.៤)	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ ២.៤)
ក. តាមកាលកំណត់៖				
រយៈពេល ១ ខែ	៨៦.៧៦៤.៦៩៨	៣៥០.៩៦៣.២០៣	៨៩.៥៦១.២៦២	៣៦៤.៩៦២.១៤៣
> ១ ទៅ ៣ ខែ	១៧.៦៧២.៤០៦	៧១.៤៨៤.៨៨២	១៥.៨៦២.៩៦៤	៦៤.៦៤១.៥៧៨
> ៣ ទៅ ៦ ខែ	៤៧.០៦៥.៧៩២	១៩០.៣៨១.១២៩	៧៣១.០៦៨	២.៩៧៩.១០២
> ៦ ទៅ ១២ ខែ	១៩.៨៨៩.០៩០	៨០.៤៥១.៣៦៩	១២.០៧៣.៩៥៣	៤៩.២០១.៣៥៨
>លើសពី ១២ ខែ	២.៩៨៨.១៧៣	១២.០៨៧.១៦០	១.៦៨៥.៦២៣	៦.៨៦៨.៩១៤
	១៧៤.៣៨០.១៥៩	**៧០៥.៣៦៧.៧៤៣**	**១១៩.៩១៤.៨៧០**	**៤៨៨.៦៥៣.០៩៥**
ខ. តាមនិវាសនដ្ឋាន៖				
និវាសនជន	១៦០.៩៤៤.៤១៦	៦៥១.០២០.១៦៣	៤០.៥២២.៣៨៩	១៦៥.១២៨.៧៣៥
អនិវាសនជន	១៣.៤៣៥.៧៤៣	៥៤.៣៤៧.៥៨០	៧៩.៣៩២.៤៨១	៣២៣.៥២៤.៣៦០
	១៧៤.៣៨០.១៥៩	**៧០៥.៣៦៧.៧៤៣**	**១១៩.៩១៤.៨៧០**	**៤៨៨.៦៥៣.០៩៥**
គ. តាមទំនាក់ទំនង៖				
សម្ព័ន្ធញាតិ	១៣៤.៥១៤	៥៤៤.១០៩	-	-
មិនមែនសម្ព័ន្ធញាតិ	១៧៤.២៤៥.៦៤៥	៧០៤.៨២៣.៦៣៤	១១៩.៩១៤.៨៧០	៤៨៨.៦៥៣.០៩៥
	១៧៤.៣៨០.១៥៩	**៧០៥.៣៦៧.៧៤៣**	**១១៩.៩១៤.៨៧០**	**៤៨៨.៦៥៣.០៩៥**

ប្រាក់បញ្ញើរបស់អតិថិជនទាំងអស់នេះទទួលអត្រាការប្រាក់ប្រចាំឆ្នាំដូចខាងក្រោម៖

	ឆ្នាំ២០២០	ឆ្នាំ២០១៩
គណនីសន្សំ	០.៥%	១%
គណនីសន្សំមានកាលកំណត់	១.៥០%-៦.២៥%	២.០០% - ៦.០០%
គណនីចរន្ត	០%-១%	គ្មាន
ប្រាក់បញ្ញើមានកម្រិត	គ្មាន	គ្មាន

១៨. បំណុលភតិសន្យា

	ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០		ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩	
	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ ២.៤)	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ ២.៤)
វិភាគតាមកាលកំណត់ - លំហូរទឹកប្រាក់តាមកិច្ចសន្យាមិនទាន់ធ្វើអប្បហារ				
តិចជាង ១ ឆ្នាំ	៣៧៧.៤១០	១.៥២៦.៦២៣	២៥៤.២៩៣	១.០៣៦.២៤៤
១ ឆ្នាំ ទៅ ៥ ឆ្នាំ	១.១៦៣.១៣៥	៤.៧០៤.៨៨១	២.២១៨.៥៤៥	៩.០៤០.៥៧១
ច្រើនជាង ៥ ឆ្នាំ	១.៩២៨.០០០	៧.៧៩៨.៧៦០	-	-
បំណុលភតិសន្យាសរុបមិនទាន់ធ្វើអប្បហារ	**៣.៤៦៨.៥៤៥**	**១៤.០៣០.២៦៤**	**២.៤៧២.៨៣៨**	**១០.០៧៦.៨១៥**

	ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០		ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩	
	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ ២.៤)	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ ២.៤)
តម្លៃបច្ចុប្បន្ននៃបំណុលភតិសន្យា				
រយៈពេលខ្លី	២៣៣.៣១១	៩៤៣.៧៤៣	១៥៥.១៣៨	៦៣២.១៨៧
រយៈពេលវែង	២.២៧៤.១២០	៩.១៩៨.៨១៥	១.៥៦៦.៣៣២	៦.៣៨២.៨០៣
	២.៥០៧.៤៣១	**១០.១៤២.៥៥៨**	**១.៧២១.៤៧០**	**៧.០១៤.៩៩០**

	ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០		ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩	
	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ ២.៤)	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ ២.៤)
ចំនួនដែលបានទទួលស្គាល់នៅក្នុងរបាយការណ៍ ចំណេញ ឬខាត				
ការប្រាក់លើបំណុលភតិសន្យា	១២២.៦៦៤	៥០០.១០១	៤៨.២០៨	១៩៥.៣៣៩
ចំណាយទាក់ទងនឹងភតិសន្យារយៈពេលខ្លី	៤១.៧០៨	១៧០.០៤៤	១៣.៥២២	៥៤.៧៩១
	១៦៤.៣៧២	**៦៧០.១៤៥**	**៦១.៧៣០**	**២៥០.១៣០**

	ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០		ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩	
	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ ២.៤)	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ ២.៤)
ចំនួនដែលត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ លំហូរទឹកប្រាក់				
លំហូរទឹកប្រាក់ភតិសន្យាសរុប	២៩១.៤៥៩	១.១៨៨.២៧៨	២១៣.១១៨	៨៦៨.៤៥៦
	២៩១.៤៥៩	**១.១៨៨.២៧៨**	**២១៣.១១៨**	**៨៦៨.៤៥៦**

១៩. បំណុលផ្សេងៗ

	ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០		ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩	
	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ ២.៤)	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ ២.៤)
ចំណាយបង្គរ និងបំណុលផ្សេងៗ	៤៤០.៣០៩	១.៧៨១.០៥០	៤៤៥.៣២៧	១.៨១៤.៧០៨
បំណុលពន្ធផ្សេងទៀត	១៧៣.៨៥៩	៧០៣.២៦០	៦៨.៥៥៨	២៧៩.៣៧៣
	៦១៤.១៦៨	**២.៤៨៤.៣១០**	**៥១៣.៨៨៥**	**២.០៩៤.០៨១**

២០. ពន្ធលើប្រាក់ចំណូល

ចំណាយពន្ធលើប្រាក់ចំណូល

ដោយអនុលោមតាមច្បាប់ស្តីពីពន្ធដារនៃប្រទេសកម្ពុជា ធនាគារមានកាតព្វកិច្ចក្នុងការបង់ពន្ធលើប្រាក់ចំណូល ("ToI") នូវចំនួន ណាមួយដែលខ្ពស់ជាងរវាង អត្រា ២០% នៃប្រាក់ចំណូលដែលជាប់ពន្ធ ឬក៏ពន្ធអប្បបរមាដែលមានអត្រា ១%។

	ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០		ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩	
	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ ២.៤)	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ ២.៤)
ចំណាយពន្ធលើប្រាក់ចំណូលបច្ចុប្បន្ន	១៩៥.៥៥២	៧៩៧.២៦៦	២២៧.៩១៧	៩២៣.៥២០
(ចំណូល) /ចំណាយពន្ធពន្យា	(៤២.៨១៣)	(១៧៤.៥៤៩)	៩៨.៧២១	៤០០.០១៧
	១៥២.៧៣៩	**៦២២.៧១៧**	**៣២៦.៦៣៨**	**១.៣២៣.៥៣៧**

ការផ្ទៀងផ្ទាត់រវាងចំណាយពន្ធលើប្រាក់ចំណូល និងគណនេយ្យចំណេញ

	ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០		ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩	
	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ ២.៤)	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ ២.៤)
ចំណេញមុនបង់ពន្ធលើប្រាក់ចំណូល	៥៩២.៤៨៦	១.៤៦៥.៨៤៥	១.៤៦៥.៨៤៥	៥.៩៣៩.៦០៤
ពន្ធលើប្រាក់ចំណូលដោយប្រើអត្រាតាមបទប្បញ្ញត្តិ ២០%	១១៨.៤៩៧	៤៨៣.១១៣	២៩៣.១៦៩	១.១៨៧.៩២១
ចំណាយមិនអាចកាត់ចោលបាន	៣៤.៥២១	១៤០.៧៤១	៣៣.៤៦៩	១៣៥.៦១៦
ចំណាយពន្ធលើប្រាក់ចំណូល	**១៥៣.០១៨**	**៦២៣.៨៥៤**	**៣២៦.៦៣៨**	**១.៣២៣.៥៣៧**

លិខិតប្រកាសពន្ធរបស់ធនាគារត្រូវឆ្លងកាត់ការត្រួតពិនិត្យដោយអគ្គនាយកដ្ឋានពន្ធដារ។ ដោយសារតែការអនុវត្តច្បាប់ពន្ធ និង បទប្បញ្ញត្តិលើប្រតិបត្តិការជាច្រើនប្រភេទដែលមានការបង្ហាញពីចំនួនខុសគ្នាៗ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុអាចត្រូវបានផ្លាស់ប្តូរ នៅពេលក្រោយតាមការកំណត់ចុងក្រោយដោយអគ្គនាយកដ្ឋានពន្ធដារ។

ប្រព័ន្ធពន្ធដារនៅកម្ពុជា គឺនៅថ្មី និងកំណត់ដោយពន្ធជាច្រើន។ ច្បាប់ជាញឹកញាប់មានការផ្លាស់ប្តូរ ហើយមិនសូវច្បាស់លាស់ និងអាស្រ័យលើការបកស្រាយ។ ជាញឹកញាប់ការបកស្រាយផ្សេងគ្នាកើតមានក្នុងចំណោមអាជ្ញាធរពន្ធដារនិងក្នុងដែនយុត្តាធិការជាច្រើន។ ពន្ធ គឺត្រូវការត្រួតពិនិត្យនិងស៊ើបអង្កេតដោយអាជ្ញាធរជាច្រើន ដែលស្របតាមច្បាប់ក្នុងការដាក់ពិន័យដ៏ធ្ងន់ធ្ងរ ទណ្ឌកម្ម និងពិន័យការប្រាក់។

កត្តាខាងលើនេះអាចបង្កើតហានិភ័យពន្ធនៅកម្ពុជា ច្រើនជាងនៅប្រទេសដទៃទៀត។ គណៈគ្រប់គ្រងជឿជាក់ថាបំណុលពន្ធត្រូវបានផ្តល់គ្រប់គ្រាន់ដោយផ្អែកលើការបកស្រាយនៃច្បាប់ពន្ធ។ ទោះជាយ៉ាងណា អាជ្ញាធរពាក់ព័ន្ធអាចមានការបកស្រាយផ្សេងគ្នា ហើយការប៉ះពាល់អាចធ្ងន់ធ្ងរ។

ពន្ធអប្បបរមា

អនុលោមតាមច្បាប់សារពើពន្ធនៃព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុនមានកាតព្វកិច្ចបង់ពន្ធលើប្រាក់ចំណេញ ដោយគណនាតាមអត្រា ២០% នៃប្រាក់ចំណេញជាប់ពន្ធ ឬក៏បង់ពន្ធអប្បបរមាដោយគណនាតាមអត្រា ១% នៃប្រាក់ចំណូលនៅពេលដែលពន្ធមួយណាមានចំនួនធំជាង។

ពន្ធពន្យាលើទ្រព្យសកម្ម-សុទ្ធ

	ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០		ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩	
	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ ២.៤)	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ ២.៤)
ពន្ធពន្យាលើទ្រព្យសកម្ម	៦១០.២៤៣	២.៤៦៨.៤៣៣	៤២៦.២១០	១.៧៣៦.៨០៦
ពន្ធពន្យាលើបំណុល	(៤៩០.៩៩១)	(១.៩៨៦.០៥៨)	(៣៤៩.៧៧១)	(១.៤២៥.៣១៧)
	១១៩.២៥២	**៤៨២.៣៧៥**	**៧៦.៤៣៩**	**៣១១.៤៨៩**

ពន្ធពន្យារជាទ្រព្យកម្ម/(បំណុល) រួមមានគណនីដូចខាងក្រោម៖

	ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០		ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩	
	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ ២.៤)	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ ២.៤)
បំណុលភតិសន្យា	៥០១.៤៨៦	២.០២៨.៥១១	៣៤៤.២៩៤	១.៤០២.៩៩៨
សំវិធានធនលើការខាតបង់លើឱនភាពនៃតម្លៃ	៦០.៣៩៩	២៤៤.៣១៤	៥១.៣៩៤	២០៩.៤៣១
រំលស់ទ្រព្យរូបី និងរំលស់ទ្រព្យអរូបី	៣៧.៥៧៩	១៥២.០០៧	៦.០៥៥	២៤.៦៧៤
ចំណូលបង្គរ	១០.៧៧៩	៤៣.៦០១	២៤.១០៧	៩៨.២៣៦
សំវិធានធនលើអត្ថប្រយោជន៍បុគ្គលិក	-	-	៣៦០	១.៤៦៧
សិទ្ធិប្រើប្រាស់ទ្រព្យសកម្ម	(៤៩០.៩៩១)	(១.៩៨៦.០៥៨)	(៣៤៩.៧៧១)	(១.៤២៥.៣១៧)
	១១៩.២៥២	**៤៨២.៣៧៥**	**៧៦.៤៣៩**	**៣១១.៤៨៩**

បម្រែបម្រួលនៃពន្ធពន្យា - សុទ្ធ មានដូចខាងក្រោម៖

	ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០		ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩	
	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ ២.៤)	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ ២.៤)
នាថ្ងៃទី១ ខែមករា	៧៦.៤៣៩	៣១១.៤៨៩	១៧៥.១៦០	៧០៣.៧៩៣
ទទួលស្គាល់ក្នុងរបាយការណ៍ចំណេញ ឬ ខាត	៤២.៨១៣	១៧៤.៥៤៩	(៩៨.៧២១)	(៤០០.០១៧)
លម្អៀងពីការប្តូររូបិយប័ណ្ណ	-	(៣.៦៦៣)	-	៧.៧១៣
នាថ្ងៃទី៣១ ខែធ្នូ	**១១៩.២៥២**	**៤៨២.៣៧៥**	**៧៦.៤៣៩**	**៣១១.៤៨៩**

បំណុលពន្ធលើប្រាក់ចំណូល

	ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០		ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩	
	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ ២.៤)	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ ២.៤)
នាថ្ងៃទី១ ខែមករា	១៧៥.៨៣៨	៧១៦.៥៤០	-	-
ទទួលស្គាល់ក្នុងរបាយការណ៍ចំណេញ ឬ ខាត	១៩៩.៥៥២	៧៩៧.២៦៦	២២៧.៩១៧	៩២៣.៥២០
ពន្ធលើប្រាក់ចំណូលបានបង់	(២៧៦.៨៥៣)	(១.១២៨.៧៣០)	(៥២.០៧៩)	(២១១.០២៤)
លម្អៀងពីការប្តូររូបិយប័ណ្ណ	-	(២.៦៧៤)	-	៤.០៤៤
នាថ្ងៃទី៣១ ខែធ្នូ	**៩៨.៥៣៧**	**៣៨២.៤០២**	**១៧៥.៨៣៨**	**៧១៦.៥៤០**

២១. ដើមទុន

	ឆ្នាំ២០២០			ឆ្នាំ២០១៩		
	% នៃ កម្មសិទ្ធិ	ចំនួន ភាគហ៊ុន	ទឹកប្រាក់ ដុល្លារអាមេរិក	% នៃ កម្មសិទ្ធិ	ចំនួន ភាគហ៊ុន	ទឹកប្រាក់ ដុល្លារអាមេរិក
ក្រុមហ៊ុន Asia Investment and Financial Services Sole Co. Ltd.	៦០%	៤៥.០០០.០០០	៤៥.០០០.០០០	៦០%	៤៥.០០០.០០០	៤៥.០០០.០០០
លោក. Yim Leak	៤០%	៣០.០០០.០០០	៣០.០០០.០០០	-	-	-
ក្រុមហ៊ុន Paradise Investment Co. Ltd	-	-	-	១៥%	១១.២៥០.០០០	១១.២៥០.០០០
ក្រុមហ៊ុន PrimeStreet Advisory Co. Ltd.	-	-	-	២៥%	១៨.៧៥០.០០០	១៨.៧៥០.០០០
	១០០%	**៧៥.០០០.០០០**	**៧៥.០០០.០០០**	**១០០%**	**៧៥.០០០.០០០**	**៧៥.០០០.០០០**
សមមូលពាន់រៀល (កំណត់សម្គាល់ ២.៤)			**៣០០.០០០.០០០**			**៣០០.០០០.០០០**

ចំនួនភាគហ៊ុនដែលបានចុះបញ្ជីសរុបមានចំនួន ៧៥.០០០.០០០ ភាគហ៊ុន (ឆ្នាំ២០១៩៖ ៧៥.០០០.០០០ ភាគហ៊ុន) ដែលមានតម្លៃស្មើ ១ ដុល្លារអាមេរិក ក្នុងមួយភាគហ៊ុន។ ភាគហ៊ុនទាំងអស់ ត្រូវបានបោះផ្សាយ និងបានបង់គ្រប់ចំនួន។

នៅក្នុងឆ្នាំ២០២០ ភាគទុនិកចាស់ ក្រុមហ៊ុន Paradise Investment Co. Ltd និង ក្រុមហ៊ុន Prime Street Advisory Co. Ltd បានលក់ចំណែកមូលធនរបស់ពួកគេដែលមានក្នុងធនាគារចំនួន ១១.២៥០.០០០ និង ១៨.៧៥០.០០០ ភាគហ៊ុនរៀងខ្លួន ទៅឱ្យលោកយឹម លក្ខណ៍ ដែលជាប្រធានក្រុមប្រឹក្សាភិបាល នៅតំណែចារីក។ នៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២០ ធនាគារបានផ្ញើរលិខិត ទៅកាន់ធនាគារជាតិនៃកម្ពុជា ស្នើសុំធ្វើការផ្លាស់ប្តូរភាគទុនិក ហើយក៏បានទទួលការអនុម័តពីធនាគារជាតិនៃកម្ពុជា នៅថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២០។ ធនាគារបានធ្វើការកែតម្រូវលក្ខន្តិកៈរបស់ខ្លួនដែលមានការអនុម័តនៅថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០២១ ។

២២. ចំណូលការប្រាក់

	ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០		ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩	
	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ ២.៤)	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ ២.៤)
ឥណទាន និងបុរេប្រទាន	៤.៤៥២.៥១៥	១៨.១៥២.៩០៤	៣.៥៤៦.១៦៧	១៤.៣៦៩.០៦៩
ការវិនិយោគផ្សេងៗ	១.៣៧៤.៣២០	៥.៦០៣.១០៣	១.៣៦៨.៧៥០	៥.៥៤៦.១៧៥
ប្រាក់បញ្ញើនៅធនាគារផ្សេងៗ	១.១៨០.២២៧	៤.៨១១.៧៨៤	២៧៧.៣៥៦	១.១២៣.៨៤៦
ប្រាក់បញ្ញើតាមបទប្បញ្ញត្តិ	២១.២៩៥	៨៦.៨២០	៤៧.១៩៥	១៩១.២៣៤
	៧.០២៨.៣៥៧	**២៨.៦៥៤.៦១១**	**៥.២៣៩.៤៦៨**	**២១.២៣០.៣២៤**

២៣. ចំណាយការប្រាក់

	ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០		ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩	
	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ ២.៤)	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ ២.៤)
ប្រាក់បញ្ញើមានកាលកំណត់ និងចរន្ត	៣.១៦៣.៥៤២	១២.៨៩៧.៧៦១	៥៥៦.៨១១	២.២៥៦.១៩៨
គណនីសន្សំ	២០៨.០៣៣	៨៤៨.១៥០	២១៤.៩៦៦	៨៧១.០៤២
បំណុលភតិសន្យា	១២២.៦៦៤	៥០០.១០១	៤៨.២០៨	១៩៥.៣៣៩
	៣.៤៩៤.២៣៩	**១៤.២៤៦.០១២**	**៨១៩.៩៨៥**	**៣.៣២២.៥៧៩**

២៤. ចំណូលកម្រៃ និងជើងសារ-សុទ្ធ

	ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០		ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩	
	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ ២.៤)	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ ២.៤)
សេវាផ្ទេរប្រាក់ចេញចូល	៣៤៤.៤៣៨	១.៤០៤.២៧៤	១៧៩.៤០៤	៧២៦.៩៤៧
កម្រៃផ្សេងៗ	៤៩.៣៣៨	២០១.១៥១	៥៤.៦៦២	២២១.៤៩០
	៣៩៣.៧៧៦	**១.៦០៥.៤២៥**	**២៣៤.០៦៦**	**៩៤៨.៤៣៧**

២៥. ចំណូលផ្សេងៗ

	ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០		ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩	
	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ ២.៤)	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ ២.៤)
ចំណេញលើការប្តូររូបិយបណ្ណបរទេស	៧៣.៥៩៤	៣០០.០៤៣	៤០.៨៧៦	១៦៥.៦៣០
	៧៣.៥៩៤	**៣០០.០៤៣**	**៤០.៨៧៦**	**១៦៥.៦៣០**

២៦. ចំណាយបុគ្គលិក

	ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០		ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩	
	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ ២.៤)	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ ២.៤)
ប្រាក់បៀវត្ស និងប្រាក់ឈ្នួល	១.២៩០.៧៥១	៥.២៦២.៣៩២	៧៨៤.២៧៨	៣.១៧៧.៨៩៤
អត្ថប្រយោជន៍បន្ថែម	១០.១៣៣	៤១.៣១២	១.៧៣៣	៧.០២២
អត្ថប្រយោជន៍ផ្សេងៗ	៦៥.៨០៥	២៦៨.២៨៨	២៣.២៨១	៩៤.៣៣៦
	១.៣៦៦.៦៨៩	**៥.៥៧១.៩៩២**	**៨០៩.២៩២**	**៣.២៧៩.២៥២**

២៧. រំលស់ទ្រព្យរូបី និងរំលស់ទ្រព្យអរូបី

	ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០		ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩	
	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ ២.៤)	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ ២.៤)
រំលស់លើទ្រព្យសកម្មអរូបី	៤០៩.៤៤៥	១.៦៦៩.៣០៧	៣០៩.៧៧៣	១.២៥៥.២០០
រំលស់លើទ្រព្យសម្បត្តិ និងបរិក្ខារ	៣៧៤.១១៩	១.៥២៥.២៨៣	២១៦.១៧៨	៨៧៥.៩៥៣
រំលស់លើសិទ្ធិប្រើប្រាស់ទ្រព្យសកម្ម	២៤៨.៦៥៧	១.០១៣.៧៧៥	១៣០.៩៣៥	៥ ៣០.៥៤៩
	១.០៣២.២២១	**៤.២០៨.៣៦៥**	**៦៥៦.៨៨៦**	**២.៦៦១.៧០២**

២៨. ចំណាយប្រតិបត្តិការផ្សេងៗ

	ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០		ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩	
	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ ២.៤)	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ ២.៤)
ការបរិច្ចាគ	២០២.២០០	៨២៤.៣៦៩	១៥០.០០០	៦០៧.៨០០
សេវាវិជ្ជាជីវៈ	១៩៦.២៤៦	៨០០.០៩៥	១.០៤៧.៣៦១	៤.២៤៣.៩០៧
ចំណាយពន្ធផ្សេងៗ	១១២.៣៣៥	៤៥៧.៩៩០	១៩៦.៦៤៩	៧៩៦.៨២២
ជួសជុល និងថែទាំ	១០៨.៥៨០	៤៤២.៦៨១	៥៦.៩៧០	២៣០.៨៤២
សេវាអាជ្ញាប័ណ្ណ	៦៩.៣១៦	២៨២.៦០១	៤៨.៣៨៣	១៩៦.០៤៨
ចំណាយទឹកភ្លើង	៤៤.០៩៧	១៧៩.៧៨៣	៣០.៣៧៩	១២៣.០៩៦
បរិក្ខារការិយាល័យ	៤៩.៣៤២	២០១.១៦៧	១៨.២៨៨	៧៤.១០៣
ថ្លៃជួលការិយាល័យ	៤១.៧០៨	១៧០.០៤៤	១៣.៥២២	៥៤.៧៩១
ចំណាយសន្តិសុខ	២០.៦៦៨	៨៤.២៦៣	១៤.១១៩	៥៧.២១០
ការធ្វើដំណើរ និងការកំសាន្ត	១៩.៤២១	២១.៤៧៤	៨.៩៤០	៣៦.២២៥
ចំណាយធានារ៉ាប់រង	១៦.១៨០	៦៥.៩៦៦	១២.០២២	៤៨.៧១៣
ចំណាយទំនាក់ទំនង	១១.៥១៧	៤៦.៩៥៥	១០.៩៨៤	៤៤.៥០៨
សេវាស៊ើបអង្កេតឥណទាន	១១.១៦២	៤៥.៥០៧	១០.៨២៣	៤៣.៨៥៦
ទំនាក់ទំនងសាធារណៈ ទីផ្សារ និងផ្សាយពាណិជ្ជកម្ម	៩.៩២៨	៤០.៤៧៦	១៣.២០៦	៥៣.៥១១
ការចំណាយលើការស្នាក់នៅ	៩.៤២៣	៣៨.៤១៨	១១.២៨៦	៤៥.៧៣០
តែម និងប្រៃសណីយ៍	៥.៤៦០	២២.២៦០	២៧៥	១.១១៤
ទំនាក់ទំនង	៥.២៦៧	៧៩.១៧៩	១០.៤៥២	៤២.៣៥២
ចំណាយលើសមាជិកភាព	៤.១៨៥	១៧.០៦២	២.១០១	៨.៥១៥
ខាតបង់ពីការប្តូររូបិយប័ណ្ណបរទេស	២.២៤១	៩.១៣៧	១.៥២០	៦.១៥៨
ចំណាយផ្សេងៗ	២៨.១៤២	១១៤.៧៣៥	២០.៦៨៦	៨៣.៨១៨
	៩៦៧.៤១៨	**៣.៩៤៤.១៦២**	**១.៦៧៧.៩៦៦**	**៦.៧៩៩.១១៩**

២៩. កិច្ចសន្យា និងយថាភាព

យថាភាពនៃបំណុល និងកិច្ចសន្យា

នៅក្នុងដំណើរការអាជីវកម្មធម្មតា ធនាគារធ្វើការសន្យាផ្សេងៗគ្នា និងភាពជាក់លាក់នៃយថាភាព ជាមួយសំណងតាមច្បាប់ដល់អតិថិជន របស់ធនាគារ។ ពុំមានការខាតបង់ជាសារវន្ត ត្រូវបានរំពឹងទុកពី ប្រតិបត្តិការណាដែលរួមមាន៖

	ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០		ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩	
	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ ២.៤)	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ ២.៤)
ផ្នែកមិនទាន់ប្រើប្រាស់នៃឥណទាន	១.២៨៩.៦០២	៥.២១៦.៤៤០	២.៦០៦.០៤៦	១០.៥៤១.៤៥៦
គណនីធានារបស់ធនាគារ	៤០០.០០០	១.៦១៨.០០០	៦២០.០០០	២.៥០៧.៩០០
ផ្សេងៗ	-	-	២៨១.៧៧៥	១.១៣៩.៧៨០
	១.៦៨៩.៦០២	**៦.៨៣៤.៤៤០**	**៣.៥០៧.៨២១**	**១៤.១៨៩.១៣៦**

បម្រែបម្រួលនៃសំវិធានធនលើការខាត់បង់លើការធានាកិច្ចហិរញ្ញវត្ថុក្រៅតារាងតុល្យការ មានដូចខាងក្រោម៖

	ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០		ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩	
	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ ២.៤)	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ ២.៤)
នាថ្ងៃទី១ ខែមករា	៤.៤៥៦	១៨.១៥៨	-	-
(បង្វិលមកវិញ)/ សំវិធានធនសម្រាប់ការិយបរិច្ឆេទ	(២.១០៤)	(៨.៥៧៨)	៤.៤៥៦	១៨.០៥៦
លម្អៀងពីការប្តូររូបិយប័ណ្ណ	-	(៦៦)	-	១០២
នាថ្ងៃទី៣១ ខែធ្នូ	**២.៣៥២**	**៩.៥១៤**	**៤.៤៥៦**	**១៨.១៥៨**

យថាភាពលើពន្ធ

ពន្ធត្រូវបានស្ថិតនៅក្រោមការត្រួតពិនិត្យ និងតាមដានអង្កេតដោយក្រុមអាជ្ញាធរ ដែលផ្តល់សិទ្ធិដោយច្បាប់ក្នុងការដាក់ពិន័យដាក់ ទណ្ឌកម្ម និងគិតការប្រាក់។ ការអនុវត្តច្បាប់ និងបទប្បញ្ញត្តិពន្ធលើប្រតិបត្តិការច្រើនប្រភេទអាចប្រឈមនឹងបំណកស្រាយផ្សេងៗ។

បញ្ហាទាំងនេះអាចបង្កើតឱ្យមានហានិភ័យពន្ធ នៅក្នុងព្រះរាជាណាចក្រកម្ពុជាមានលក្ខណៈជាសារវន្តជាងនៅប្រទេសដទៃទៀត។ គណៈគ្រប់គ្រងជឿជាក់ថា ការធ្វើសំវិធានធនមានលក្ខណៈគ្រប់គ្រាន់ ដោយផ្អែកទៅលើការបកស្រាយនៃនីតិកម្មពន្ធ។ ក៏ប៉ុន្តែ អាជ្ញាធរជាប់ពាក់ព័ន្ធអាចនឹងមានបំណកស្រាយខុសគ្នា ហើយផលប៉ះពាល់អាចមានលក្ខណៈជាសារវន្ត។

នៅថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២០ ធនាគារបានទទួលលិខិតពីអគ្គនាយកដ្ឋានពន្ធដារ ("អ.ព.ដ") ជូនដំណឹងពីការចុះធ្វើសវនកម្មពេញលេញ សម្រាប់ឆ្នាំសារពើពន្ធពី ២០១៨ ដល់ ២០១៩ នាថ្ងៃចេញរបាយការណ៍នេះសវនកម្មពន្ធដារកំពុងតែបន្តដំណើរការនៅឡើយ។

៣០. សមតុល្យ និងប្រតិបត្តិការរបស់ភាគីសម្ព័ន្ធញ្ញាត្តិ

ធនាគារបានធ្វើប្រតិបត្តិការមួយចំនួនជាមួយភាគីសម្ព័ន្ធញ្ញាត្តិក្នុងដំណើរការអាជីវកម្មធម្មតា។ បរិមាណប្រតិបត្តិការភាគីសម្ព័ន្ធញ្ញាត្តិ សមតុល្យនៅជំពាក់នៅដំណាច់ឆ្នាំ ចំណាយ និងចំណូលពាក់ព័ន្ធក្នុងការិយបរិច្ឆេទមានដូចខាងក្រោម៖

ភាគីសម្ព័ន្ធញ្ញាត្តិ និងទំនាក់ទំនង

ទំនាក់ទំនង	ភាគីសម្ព័ន្ធញ្ញាត្តិ
ក្រុមហ៊ុនមេផ្ទាល់	យោងតាមកំណត់សម្គាល់ ២១
សម្ព័ន្ធញាតិ	ក្រុមហ៊ុនស្ថិតក្រោមភាគទុនិកធំបំផុតតែមួយ
គណៈគ្រប់គ្រងសំខាន់ៗ	រាល់អភិបាលនៃធនាគារ ដែលជាអ្នកធ្វើការសម្រេចចិត្តសំខាន់ៗ ដែលទាក់ទង ទៅនឹងទិសដៅយុទ្ធសាស្ត្រ និងបុគ្គលិកគ្រប់គ្រងជាន់ខ្ពស់របស់ធនាគារ (រួមបញ្ចូល ទាំងសមាជិកគ្រួសារ)

ឥណទាន និងបុរេប្រទានផ្តល់ដល់ភាគីសម្ព័ន្ធញ្ញាត្តិ

	ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០		ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩	
	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ ២.៤)	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ ២.៤)
ឥណទាន និងបុរេប្រទាន	១.២៣៧.១៤២	៥.០០៤.២៤០	១៥.៤៣២.៤១៧	៦២.៨៨៧.០៩៩
	១.២៣៧.១៤២	**៥.០០៤.២៤០**	**១៥.៤៣២.៤១៧**	**៦២.៨៨៧.០៩៩**

ប្រាក់បញ្ញើរបស់ភាគីសម្ព័ន្ធញ្ញាត្តិ

	ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០		ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩	
	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ ២.៤)	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ ២.៤)
ប្រាក់បញ្ញើរបស់ធនាគារផ្សេងៗ	១.៦៧៧.៤១០	៦.៧៨៥.១២៣	៣១១.៩២៣	១.២៧១.០៨៦
ប្រាក់បញ្ញើរបស់អតិថិជន	១៣៤.៥១៤	៥៤៤.១០៩	-	-
	១.៨១១.៩២៤	**៧.៣២៩.២៣២**	**៣១១.៩២៣**	**១.២៧១.០៨៦**

បុរេប្រទានទៅឱ្យភាគីសម្ព័ន្ធញ្ញាត្តិ

	ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០		ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩	
	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ ២.៤)	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ ២.៤)
បុរេប្រទានទៅឱ្យភាគីសម្ព័ន្ធញ្ញាត្តិ	៤៧.៣០០.០០០	១៩១.៣២៨.៥០០	-	-
	៤៧.៣០០.០០០	**១៩១.៣២៨.៥០០**	**-**	**-**

ការបង់មុនឱ្យភាគទុនិក

	ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០		ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩	
	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ ២.៤)	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ ២.៤)
លោក យឹម លក្ខណ៍	២០.០០០.០០០	៨០.៩០០.០០០	-	-
	២០.០០០.០០០	**៨០.៩០០.០០០**	-	-

លាភការរបស់បុគ្គលិកគណៈគ្រប់គ្រងសំខាន់ៗ

	ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០		ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩	
	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ ២.៤)	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ ២.៤)
ប្រាក់ខែ និងអត្ថប្រយោជន៍	៥៣៨.៣៣០	២.១៩៤.៧៧១	២២៦.០៨៦	៩១៦.១០២
	៥៣៨.៣៣០	**២.១៩៤.៧៧១**	**២២៦.០៨៦**	**៩១៦.១០២**

៣១. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ

ក. សេចក្តីផ្តើម និងទស្សនៈទូទៅ

ធនាគារប្រឈមមុខនឹងហានិភ័យឧបករណ៍ហិរញ្ញវត្ថុដូចខាងក្រោម៖

- ហានិភ័យឥណទាន
- ហានិភ័យទីផ្សារ
- ហានិភ័យសាច់ប្រាក់ងាយស្រួល និង
- ហានិភ័យប្រតិបត្តិការ

កំណត់សម្គាល់នេះ បង្ហាញពីព័ត៌មានស្តីពី ហានិភ័យនីមួយៗ ខាងលើរបស់ធនាគារ ដែលមានគោលដៅ គោលការណ៍ណែនាំ និងវិធានការរបស់ធនាគារ ដើម្បីវាស់វែង និងចាត់ចែងនូវហានិភ័យដែលកើតឡើង និងការគ្រប់គ្រងនូវដើមទុនរបស់ធនាគារ។

មុខងារគ្រប់គ្រងហានិភ័យ និងរចនាសម្ព័ន្ធអភិបាលកិច្ច

ក្រុមប្រឹក្សាភិបាលរបស់ធនាគារមានការទទួលខុសត្រូវទាំងស្រុងសម្រាប់ការបង្កើត និងត្រួតពិនិត្យលើក្របខ័ណ្ឌគ្រប់គ្រងហានិភ័យរបស់ធនាគារ។ ក្រុមប្រឹក្សាភិបាលបានបង្កើតគណៈកម្មាធិការគ្រប់គ្រង ទ្រព្យសកម្ម និងទទួលខុសត្រូវក្នុងការអនុម័ត និងត្រួតពិនិត្យគោលនយោបាយ គ្រប់គ្រងហានិភ័យរបស់ធនាគារ។

គោលនយោបាយគ្រប់គ្រងហានិភ័យរបស់ធនាគារ ត្រូវបានបង្កើតឡើងដើម្បីកំណត់លក្ខណៈ និងវិភាគហានិភ័យ ដែលធនាគារបានប្រឈម ដើម្បីកំណត់ និងគ្រប់គ្រងហានិភ័យឱ្យបានសមស្រប និងតាមដានហានិភ័យ និងការប្រកាន់ខ្ជាប់នូវដែនកំណត់។ គោលនយោបាយ និងប្រព័ន្ធគ្រប់គ្រងហានិភ័យ ត្រូវបានពិនិត្យឡើងវិញជាប្រចាំដើម្បីឆ្លុះបញ្ចាំងពីការផ្លាស់ប្តូរលក្ខខណ្ឌទីផ្សារ និងសកម្មភាពរបស់ធនាគារ។ ធនាគារ តាមរយៈស្តង់ដារនៃការបណ្តុះបណ្តាល ការគ្រប់គ្រង និងនីតិវិធីគ្រប់គ្រងរបស់ខ្លួន គឺក្នុងគោលបំណងអភិវឌ្ឍន៍ត្រួតពិនិត្យដែលមានវិន័យ និងបង្កើតការត្រួតពិនិត្យស្ថានភាពដែលបុគ្គលិកទាំងអស់យល់ពីតួនាទី និងកាតព្វកិច្ចរបស់ពួកគេ ។

ខ. ហានិភ័យឥណទាន

ហានិភ័យឥណទាន គឺជាហានិភ័យនៃការខាតបង់ផ្នែកហិរញ្ញវត្ថុរបស់ធនាគារ ប្រសិនបើអតិថិជនឬភាគីម្ខាងទៀត មិនមានលទ្ធភាពបំពេញកាតព្វកិច្ចទៅតាមកិច្ចសន្យា ហើយហានិភ័យជាចម្បងនេះ គឺកើតចេញតាមរយៈការផ្តល់ ឥណទាន និងបុរេប្រទានដល់អតិថិជន ធនាគារនានា និងការវិនិយោគលើបំណុល។ សម្រាប់គោលបំណងរាយការណ៍អំពីការគ្រប់គ្រងហានិភ័យធនាគារធ្វើការពិចារណា និងដាក់រួមបញ្ចូលនូវ ធាតុទាំងអស់នៃហានិភ័យឥណទានដែលប្រឈម ឧទាហរណ៍ ហានិភ័យតាមកាតព្វកិច្ចរបស់បុគ្គលម្នាក់ៗ តាមតំបន់ និងហានិភ័យតាម វិស័យសេដ្ឋកិច្ច។

ហានិភ័យឥណទាន គឺជាការខាតបង់ហិរញ្ញវត្ថុរបស់ធនាគារ ប្រសិនបើអ្នកខ្ចី ឬដៃគូពាណិជ្ជកម្មខកខានមិនបានបំពេញកាតព្វកិច្ច លើការបង់ប្រាក់ដើមចំពោះឥណទាន និងបុរេប្រទាន ។

ការគ្រប់គ្រងហានិភ័យឥណទាន

ក្រុមប្រឹក្សាភិបាល បានបង្កើតគណៈកម្មាធិការឥណទានធនាគារ សម្រាប់ត្រួតពិនិត្យហានិភ័យឥណទាន។ នាយកដ្ឋានឥណទាន ដោយឡែកត្រូវរាយការណ៍ជូនគណៈកម្មាធិការឥណទាន ដែលទទួលខុសត្រូវក្នុងការគ្រប់គ្រងហានិភ័យឥណទានរួមមានដូច ខាងក្រោម។

- *ការរៀបចំគោលនយោបាយឥណទាន* ក្នុងការពិគ្រោះយោបល់ជាមួយអង្គភាពអាជីវកម្មដែល រួមមានតម្រូវការ ទ្រព្យបញ្ចាំ ការវាយតម្លៃឥណទាន ការដាក់ចំណាត់ថ្នាក់ហានិភ័យ និងការធ្វើរបាយការណ៍ ការរៀបចំឯកសារ និងនីតិវិធីនៃច្បាប់ និងអនុលោមតាមតម្រូវការបទប្បញ្ញត្តិ និងច្បាប់។
- *ការបង្កើតរចនាសម្ពន្ធ័សិទ្ធិអំណាច* សម្រាប់ការអនុម័ត និងបន្តឥណទាន។ ដែនកំណត់នៃសិទ្ធិអំណាច ត្រូវបាន ចាត់ចែងសម្រាប់មន្ត្រីឥណទាននៃអង្គភាពអាជីវកម្ម។ ឥណទានដែលមានទំហំធំ តម្រូវឱ្យមានការអនុម័តពីផ្នែក ឥណទានធនាគារ ប្រធានផ្នែកឥណទាន គណៈកម្មាធិការឥណទាន ឬក្រុមប្រឹក្សាភិបាល។
- *ធ្វើការត្រួតពិនិត្យ និងវាយតម្លៃហានិភ័យឥណទាន៖* អ្នកគ្រប់គ្រងឥណទានរបស់ធនាគារវាយតម្លៃរាល់ហានិភ័យ ឥណទានដែលហួសកម្រិតកំណត់មុនពេលដែលឥណទាននានាត្រូវបានផ្តល់ជូន អតិថិជនដោយអង្គភាពអាជីវកម្ម ដែលពាក់ព័ន្ធ។ ការបន្ត និងការពិនិត្យឡើងវិញនៃឥណទាន គឺស្ថិតនៅក្រោមដំណើរការត្រួតពិនិត្យដូចគ្នា។
- *កម្រិតលើការប្រឈម* ដែលកើតពីដៃគូភាគី ភូមិសាស្ត្រ និងឧស្សាហកម្ម (សម្រាប់ឥណទាន និងបុរេប្រទាន ការជានាហិរញ្ញវត្ថុ និងការប្រឈមប្រហាក់ប្រហែល) និងដោយអ្នកចេញប័ណ្ណ ការចាត់ថ្នាក់ឥណទាន ហានិភ័យ ទីផ្សារងាយស្រួល និងតំបន់ (សម្រាប់មូលបត្រវិនិយោគ)។
- *ការអភិវឌ្ឍន៍ និងការការពារ ចំណាត់ថ្នាក់ហានិភ័យរបស់ធនាគារ* ដើម្បីបង្ហាញពីចំណាត់ថ្នាក់ដោយផ្អែកតាមកម្រិត ហានិភ័យនៃការមិនទូទាត់សង។ ក្របខណ្ឌកំណត់ហានិភ័យបច្ចុប្បន្នរួមមាន ៥ ថ្នាក់ ដែលឆ្លុះបញ្ចាំងពីកម្រិតខុសៗ គ្នានៃហានិភ័យ។ ការទទួលខុសត្រូវចំពោះការកំណត់ចំណាត់ថ្នាក់ហានិភ័យ គឺអាស្រ័យលើការអនុម័តចុងក្រោយ ដោយនាយកប្រតិបត្តិ ឬគណៈកម្មាធិការ ប្រសិនបើសមរម្យ។ ចំណាត់ថ្នាក់ហានិភ័យ ត្រូវឆ្លងកាត់ការត្រួតពិនិត្យ ជាប្រចាំ ដោយអ្នកគ្រប់គ្រងហានិភ័យរបស់ធនាគារ។
- *ការអភិវឌ្ឍ និងរក្សាដំណើរការរបស់ធនាគារសម្រាប់វាស់វែង ECL៖* នេះរួមបញ្ចូលទាំងដំណើរការសម្រាប់៖
  > ការអនុម័តដំបូង ការបញ្ជាក់ពីភាពត្រឹមត្រូវ និងការធ្វើតេស្តទិន្នន័យថយក្រោយ (Back - testing) នៃម៉ូដែល ដែលបានប្រើ
  > កំណត់ និងតាមដានការកើនឡើងហានិភ័យឥណទានជាសារវន្ត និងការបង្កើតព័ត៌មាននៃការប្រមើលអនាគត។
- *ការពិនិត្យឡើងវិញនូវអនុលោមភាព* របស់អង្គភាពអាជីវកម្ម ទៅនឹងកម្រិតហានិភ័យដែលបានព្រមព្រៀងរួមទាំង សហគ្រាសដែលបានជ្រើសរើស ហានិភ័យប្រទេស និងប្រភេទផលិតផល។ របាយការណ៍ទៀងទាត់ស្តីពីគុណភាព ឥណទាន ត្រូវបានផ្តល់ជូនដល់អ្នកគ្រប់គ្រងឥណទានរបស់ធនាគារ ដែលអាចតម្រូវឱ្យមានវិធានការកែតម្រូវ សមស្របដែលត្រូវអនុវត្ត។ ទាំងនេះរាប់បញ្ចូលទាំងរបាយការណ៍ដែលមានការប៉ាន់ស្មានសំវិធានធនលើ ECL។
- *ការផ្តល់ដំបូន្មាន ការណែនាំ និងជំនាញឯកទេស* ដល់អង្គភាពអាជីវកម្មដើម្បីលើកកម្ពស់ការអនុវត្តឱ្យមាន ប្រសិទ្ធភាពបំផុតនៅទូទាំងធនាគារក្នុងការគ្រប់គ្រងហានិភ័យឥណទាន។

អង្គភាពអាជីវកម្មនីមួយៗ តម្រូវឱ្យអនុវត្តគោលនយោបាយ និងនីតិវិធីឥណទានរបស់ធនាគារដោយមានការអនុម័តពីអាជ្ញាធរ ឥណទានដើម្បីផ្ទេរសិទ្ធិពីគណៈកម្មាធិការឥណទានធនាគារ។ អង្គភាពអាជីវកម្មនីមួយៗ មានប្រធានផ្នែកហានិភ័យឥណទាន ដែលរាយការណ៍អំពីបញ្ហាទាក់ទងនឹងឥណទានដល់អ្នកគ្រប់គ្រងមូលដ្ឋាន និងគណៈកម្មាធិការឥណទានធនាគារ។ អង្គភាពអាជីវកម្មនីមួយៗ ទទួលខុសត្រូវចំពោះគុណភាព និងដំណើរការនៃផលបត្រឥណទានរបស់ខ្លួន និង ត្រួតពិនិត្យ និងគ្រប់គ្រងហានិភ័យ ឥណទានទាំងអស់នៅក្នុងផលបត្ររបស់ខ្លួន រួមទាំងបែបបទ ដែលមានការអនុម័តពីការិយាល័យកណ្តាល។

សវនកម្មផ្ទៃក្នុងនៃអង្គភាពអាជីវកម្ម និងដំណើរការរបស់អ្នកគ្រប់គ្រងឥណទានធនាគារត្រូវបានធ្វើដោយសវនកម្មផ្ទៃក្នុង ។

ការប្រមូលផ្តុំហានិភ័យ

ក្រុមប្រឹក្សាភិបាលធនាគារបានបង្កើត គណៈកម្មាធិការឥណទានរបស់ធនាគារសម្រាប់ត្រួតពិនិត្យទៅលើហានិភ័យឥណទាន។ អគ្គនាយកដ្ឋានឥណទានរបស់ធនាគារដាច់ដោយឡែក រាយការណ៍ទៅកាន់គណៈកម្មាធិការឥណទានរបស់ធនាគារដែលទទួលខុសត្រូវទៅលើការគ្រប់គ្រងហានិភ័យឥណទាន របស់ធនាគារ ប្រូករួម និងខាងក្រោម។

តារាងខាងក្រោមបង្ហាញពីការប្រឈមនឹងហានិភ័យអតិបរមារបស់ធនាគារ ចំពោះហានិភ័យឥណទានក្នុងតារាងតុល្យការ និងឧបករណ៍ហិរញ្ញវត្ថុក្រៅតារាងតុល្យការ ដោយមិនគិតពីទ្រព្យបញ្ចាំ ឬការពង្រឹង ឥណទានដទៃទៀត។ សម្រាប់ទ្រព្យសកម្មក្នុងតារាងតុល្យការ ការប្រឈមនឹងហានិភ័យឥណទាន ស្មើនឹងតម្លៃយោងរបស់វា។ ចំពោះបំណុលយថាភាព ការប្រឈមនឹងហានិភ័យឥណទានអតិបរមា គឺជាចំនួនអតិបរិមាដែលធនាគារត្រូវបង់ ប្រសិនបើកាតព្វកិច្ចនៃឧបករណ៍ហិរញ្ញវត្ថុត្រូវបានស្នើសុំ។ ចំពោះកិច្ចសន្យាឥណទាន ការប្រឈមទៅនឹងហានិភ័យឥណទានអតិបរមា គឺជាចំនួនទឹកប្រាក់គ្រប់គ្រាន់នៃឥណទានដែលមិនទាន់ដកចេញដោយអតិថិជន។

ការប្រឈមនឹងប្រភេទហានិភ័យឥណទាន

	ការប្រឈមនឹងហានិភ័យឥណទានអតិបរមា	ការប្រឈមនឹងហានិភ័យឥណទានអតិបរមា	ការដាក់ទ្រព្យបញ្ចាំ/ការពង្រឹងឥណទាន	ផ្នែកខ្លះនៃទ្រព្យបញ្ចាំ/ការពង្រឹងឥណទាន	មិនមានការធានានិងគ្មានទ្រព្យបញ្ចាំ/ការពង្រឹងឥណទាន
	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ ២.៤)	%	%	%
ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០					
ធាតុនានាក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ					
សាច់ប្រាក់ – ដុល	៦៨.៣៩៨.៣៨៩	២៧៦.៦៧១.៤៨៣	-	-	១០០%
ប្រាក់បញ្ញើជាមួយធនាគារនានា - ដុល	៦.៤០៥.៨៧៥	២៥.៩១១.៧៦៤	-	-	១០០%
បាក្រតម្កល់បទប្បញ្ញត្តិ	២០.៧៧១.១៨០	៨៤.០១៩.៤២៣	-	-	១០០%
ឥណទាន និងបុរេប្រទានផ្តល់ដល់អតិថិជន - ដុល	៧៤.៦៣៥.១៩២	៣០១.៨៩៩.៣៥២	៨៣%	-	១៧%
ការវិនិយោគផ្សេងៗ - ដុល	២៣.២៦៦.៣៧៧	៩៤.១១២.៤៩៥	-	-	១០០%
ប្រាក់តម្កល់ធានា	៥០៤.៨៧១	២.០៤២.២០៣	-	-	១០០%
សរុប	**១៩៣.៩៨១.៨៨៤**	**៧៨៤.៦៥៦.៧២០**			
ធាតុនានាក្រៅរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ					
បំណុលយថាភាព	៤០០.០០០	១.៦១៨.០០០	១០០%	-	-
កិច្ចសន្យា	១.២៨៩.៦០២	៥.២១៦.៤៤០	៨០%	-	២០%
សរុប	**១.៦៨៩.៦០២**	**៦.៨៣៤.៤៤០**			

	ការប្រឈមនឹងហានិភ័យឥណទានអតិបរមា	ការប្រឈមនឹងហានិភ័យឥណទានអតិបរមា	ការដាក់ទ្រព្យបញ្ចាំ/ការពង្រឹងឥណទាន	ផ្នែកខ្លះនៃទ្រព្យបញ្ចាំ/ការពង្រឹងឥណទាន	មិនមានការធានានិងគ្មានទ្រព្យបញ្ចាំ/ ការពង្រឹងឥណទាន
	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ ២.៤)	%	%	%
ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩					
ធាតុនានាក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ					
សាច់ប្រាក់ – ដុល	៦១.៣១៦.៣៨៦	២៤៩.៨៦៤.២៧៣	-	-	១០០%
ប្រាក់បញ្ញើជាមួយធនាគារនានា - ដុល	១៨.០៥៨.០៨១	៧៣.៥៨៦.៦៨០	-	-	១០០%
ប្រាក់តម្កល់បទប្បញ្ញត្តិ	២៣.៧៧១.១៣៥	៩៦.៨៦៧.៣៧៥	-	-	១០០%
ឥណទាន និងបុរេប្រទានផ្តល់ដល់អតិថិជន - ដុល	៦៧.៧៧០.៦០៩	២៧៦.១៦៥.២៣២	៧៤%	-	២៦%
ការវិនិយោគផ្សេងៗ - ដុល	២២.៥២៧.៧៨៣	៩១.៨០០.៧១៦	-	-	១០០%
សរុប	**១៩៣.៤៤៣.៩៩៤**	**៧៨៨.២៨៤.២៧៦**			
ធាតុនានាក្រៅរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ					
បំណុលយថាភាព	៩០១.៧៧៥	៣.៦៤៧.៦៨០	៦៩%	-	៣១%
កិច្ចសន្យា	២.៦០៦.០៤៦	១០.៥៤១.៤៥៦	៦២%	-	៣៨%
សរុប	**៣.៥០៧.៨២១**	**១៤.១៨៩.១៣៦**			

ការប្រមូលផ្តុំហានិភ័យវិភាគតាមប្រភេទអាជីវកម្ម

ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០	សាច់ប្រាក់ – ដុល	ប្រាក់បញ្ញើជាមួយធនាគារនានា - ដុល	ឥណទាន និងបុរេប្រទានផ្តល់ដល់អតិថិជន - ដុល	ការវិនិយោគផ្សេងៗ - ដុល	ប្រាក់តម្កល់បទបញ្ញត្តិ	ប្រាក់តម្កល់ធានា	សរុប
	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក
ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន និងទូរគមនាគមន៍	-	-	១៩.០៤១.១៥៣	-	-	-	១៩.០៤១.១៥៣
សណ្ឋាគារ និងភោជនីយដ្ឋាន	-	-	៣៩៧.៤៩៤	-	-	-	៣៩៧.៤៩៤
អចលនទ្រព្យ	-	-	២៩.៣១២.២៦២	-	-	-	២៩.៣១២.២៦២
ការសាងសង់	-	-	៤.៧៩៩.៧៣៥	-	-	-	៤.៧៩៩.៧៣៥
គ្រឹះស្ថានហិរញ្ញវត្ថុ	៦៨.៣៩៨.៣៨៩	៦.៤០៥.៨៧៥	-	-	២០.៧៧១.១៨០	-	៩៥.៥៧៥.៤៤៤
ឥណទានបុគ្គលិក	-	-	១.៣០៤.១២៨	-	-	-	១.៣០៤.១២៨
ផ្សេងៗ	-	-	១៩.៧៨០.៤២០	២៣.២៦៦.៣៧៧	-	៥០៤.៨៧១	៤៣.៥៥១.៦៦៨
សរុប	៦៨.៣៩៨.៣៨៩	៦.៤០៥.៨៧៥	៧៤.៦៣៥.១៩២	២៣.២៦៦.៣៧៧	២០.៧៧១.១៨០	៥០៤.៨៧១	១៩៣.៩៨១.៨៨៤
សរុប (ពាន់រៀល កំណត់សម្គាល់ ២.៤)	**២៧៦.៦៧១.៤៨៣**	**២៥.៩១១.៧៦៤**	**៣០១.៨៩៩.៣៥២**	**៩៤.១១២.៤៩៥**	**៨៤.០១៩.៤២៣**	**២.០៤២.២០៣**	**៧៨៤.៦៥៦.៧២០**

ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩	សាច់ប្រាក់ – ដុល	ប្រាក់បញ្ញើជាមួយធនាគារនានា - ដុល	ឥណទាន និងបុរេប្រទានផ្តល់ដល់អតិថិជន - ដុល	ការវិនិយោគផ្សេងៗ - ដុល	បាក្រ់តម្កល់បទប្បញ្ញត្តិ	សរុប
	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក
ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន និងទូរគមនាគមន៍	-	-	១៤.០០៦.១៨៩	-	-	១៤.០០៦.១៨៩
ពាណិជ្ជកម្ម	-	-	៤៦.២៦០	-	-	៤៦.២៦០
អចលនទ្រព្យ	-	-	៣១.៣៩៧.៤៨១	-	-	៣១.៣៩៧.៤៨១
គ្រឹះស្ថានហិរញ្ញវត្ថុ	៦១.៣១៦.៣៨៦	១៨.០៥៨.០៨១	-	-	២៣.៧៧១.១៣៥	១០៣.១៤៥.៦០២
ឥណទានបុគ្គលិក	-	-	៥៥០.៦០១	-	-	៥៥០.៦០១
ផ្សេងៗ	-	-	២១.៧៧០.០៧៨	២២.៥២៧.៧៨៣	-	៤៤.២៩៧.៨៦១
សរុប	៦១.៣១៦.៣៨៦	១៨.០៥៨.០៨១	៦៧.៧៧០.៦០៩	២២.៥២៧.៧៨៣	២៣.៧៧១.១៣៥	១៩៣.៤៤៣.៩៩៤
សរុប (ពាន់រៀល កំណត់សម្គាល់ ២.៤)	**២៤៩.៨៦៤.២៧៣**	**៧៣.៥៨៦.៦៨០**	**២៧៦.១៦៥.២៣២**	**៩១.៨០០.៧១៦**	**៩៦.៨៦៧.៣៧៥**	**៧៨៨.២៨៤.២៧៦**

ការប្រមូលផ្តុំហានិភ័យវិភាគតាមនិវាសដ្ឋាន និងទំនាក់ទំនង និងការប្រឈមទៅនឹងហានិភ័យឥណទាន និងបុរេប្រទានធំៗ៖

	ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០		ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩	
	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ ២.៤)	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ ២.៤)
វិភាគតាមនិវាសដ្ឋាន៖				
និវាសនជន	៧៤.៦៣៥.១៩២	៣០១.៨៩៩.៣៥២	៦៧.៧៧០.៦០៩	២៧៦.១៦៥.២៣២
វិភាគតាមទំនាក់ទំនង៖				
អតិថិជនខាងក្រៅ	៧២.០៩៣.៩២១	២៩១.៦១៩.៩១១	៥១.៧៨៧.៥៩១	២១១.០៣៤.៤៣៤
ឥណទានបុគ្គលិក	១.៣០៤.១២៩	៥.២៧៥.២០២	៥៥០.៦០១	២.២៤៣.៦៩៩
សម្ព័ន្ធញាតិ	១.២៣៧.១៤២	៥.០០៤.២៣៩	១៥.៤៣២.៤១៧	៦២.៨៨៧.០៩៩
	៧៤.៦៣៥.១៩២	**៣០១.៨៩៩.៣៥២**	**៦៧.៧៧០.៦០៩**	**២៧៦.១៦៥.២៣២**
តាមហានិភ័យ៖				
ហានិភ័យទំហំធំ (*)	៣៦.០១៧.៤៧៥	១៤៥.៦៩០.៦៨៧	៤៩.០៨៨.៨៧៧	២០០.០៣៧.១៧៤
មិនមែនហានិភ័យទំហំធំ	៣៨.៦១៧.៧១៧	១៥៦.២០៨.៦៦៥	១៨.៦៨១.៧៣២	៧៦.១២៨.០៥៨
	៧៤.៦៣៥.១៩២	**៣០១.៨៩៩.៣៥២**	**៦៧.៧៧០.៦០៩**	**២៧៦.១៦៥.២៣២**
តាមស្ថានភាពឥណទាន៖				
រៀបចំឡើងវិញ (**)	៥.៦៧៤.៣៣៧	២២.៩៥២.៦៩៣	-	-
មិនរៀបចំឡើងវិញ	៦៨.៩៦០.៨៥៥	២៧៨.៩៤៦.៦៥៩	៦៧.៧៧០.៦០៩	២៧៦.១៦៥.២៣២
	៧៤.៦៣៥.១៩២	**៣០១.៨៩៩.៣៥២**	**៦៧.៧៧០.៦០៩**	**២៧៦.១៦៥.២៣២**

(*) ហានិភ័យទំហំធំ ត្រូវបានកំណត់ដោយប្រកាសរបស់ធនាគារជាតិនៃកម្ពុជា ថាជាហានិភ័យដុលនៃសមតុល្យសរុបនៃឥណទាន និង បុរេប្រទានជាមួយអ្នកទទួលផលតែមួយដែលមានចំនួនលើសពី ១០% នៃទ្រព្យសម្បត្តិសុទ្ធរបស់ធនាគារ។ ផលប៉ះពាល់នេះ គឺខ្ពស់ជាង ឥណទាន ឬកិច្ចសន្យាដែលនៅសល់ និងឥណទាន ឬកិច្ចសន្យាដែលបានអនុម័ត។

(**) ឥណទានរៀបចំឡើងវិញ គឺជាឥណទានដែលមានលក្ខខណ្ឌនៃកិច្ចសន្យាដើមត្រូវបានកែប្រែដើម្បីផ្តល់ការអនុគ្រោះដល់សមភាគី ដែលមានស្ថានភាពលំបាកផ្នែកហិរញ្ញវត្ថុបណ្តោះអាសន្ន ។

ទ្រព្យបញ្ចាំ

ខណៈពេលដែលការប្រឈមនឹងហានិភ័យអតិបរមារបស់ធនាគារ គឺជាតម្លៃយោងរបស់ទ្រព្យសកម្ម ឬក្នុងករណីឧបករណ៍ហិរញ្ញវត្ថុនៅក្រៅ តារាងតុល្យការ គឺចំនួនទឹកប្រាក់ដែលបានធានា ការសន្យាផ្តល់ឱ្យ ការទទួលយក ឬការយល់ព្រម ហានិភ័យទាំងនោះ ទំនងអាចទាបជាង ដោយសារតែការកាត់កងទ្រព្យបញ្ចាំ ការធានាឥណទាន និងសកម្មភាពផ្សេងទៀតដើម្បីកាត់បន្ថយហានិភ័យ។

ការពិពណ៌នាអំពីទ្រព្យបញ្ចាំសម្រាប់ប្រភេទនៃទ្រព្យសកម្មហិរញ្ញវត្ថុនីមួយៗ ត្រូវបានបង្ហាញដូចខាងក្រោម៖

សាច់ប្រាក់ និងសាច់ប្រាក់សមមូល ប្រាក់បញ្ញើជាមួយធនាគារនានា និងការវិនិយោគផ្សេងៗ

ទ្រព្យបញ្ចាំជាទូទៅមិនត្រូវបានស្វែងរកសម្រាប់ទ្រព្យសកម្មទាំងនេះទេ។

ឥណទាន និងបុរេប្រទានផ្តល់ដល់អតិថិជន បំណុលយថាភាព និងការសន្យា

ឥណទាន និងបុរេប្រទានផ្តល់ដល់អតិថិជន បំណុលយថាភាព និងការសន្យា ជាធម្មតាត្រូវមានដាក់ជាទ្រព្យបញ្ចាំក្នុងកម្រិតណាមួយ។ ជាពិសេសហានិភ័យលើឥណទានគេហដ្ឋាន ជាទូទៅត្រូវបានធានាពេញលេញដោយគេហដ្ឋាន។

តារាងខាងក្រោមនេះសង្ខេបអំពីការធានាលើទ្រព្យសកម្មហិរញ្ញវត្ថុរបស់ខ្លួន៖

ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០	ទ្រព្យបញ្ចាំ/ការពង្រឹងឥណទាន				ឥណទានពុំមានការធានា	សរុប
	ទ្រព្យ	ទ្រព្យសកម្មចល័ត	គណនីសន្សំមានកាលកំណត់	ផ្សេងៗ		
	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក
ឥណទាន និងបុរេប្រទានផ្តល់ដល់អតិថិជន - ដុល	៦២.១៦៤.២៣១	-	-	-	១២.៤៧០.៩៦១	៧៤.៦៣៥.១៩២
បំណុលយថាភាព	-	-	៤០០.០០០	-	-	៤០០.០០០
កិច្ចសន្យា	១.០២៩.៣៦៥	-	-	-	២៦០.២៣៧	១.២៨៩.៦០២
	៦៣.១៩៣.៥៩៦	-	៤០០.០០០	-	១២.៧៣១.១៩៨	៧៦.៣២៤.៧៩៤
សមមូលពាន់រៀល (កំណត់សម្គាល់ ២.៤)	២៥៥.៦១៨.០៩៦	-	១.៦១៨.០០០	-	៥១.៤៩៧.៦៩៦	៣០៨.៧៣៣.៧៩២
ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩						
ឥណទាន និងបុរេប្រទានផ្តល់ដល់អតិថិជន - ដុល	៥០.៤៣៥.១៩៤	-	-	-	១៧.៣៣៥.៤១៥	៦៧.៧៧០.៦០៩
បំណុលយថាភាព	៦២០.០០០	-	-	-	២៨១.៧៧៥	៩០១.៧៧៥
កិច្ចសន្យា	១.៦០៦.០៤៦	-	-	-	១.០០០.០០០	២.៦០៦.០៤៦
	៥២.៦៦១.២៤០	-	-	-	១៨.៦១៧.១៩០	៧១.២៧៨.៤៣០
សមមូលពាន់រៀល (កំណត់សម្គាល់ ២.៤)	២១៤.៥៩៤.៥៥៣	-	-	-	៧៥.៨៦៥.០៤៩	២៩០.៤៥៩.៦០២

គុណភាពនៃឥណទាន និងបុរេប្រទានផ្តល់ដល់អតិថិជន -ដុល

ដោយអនុលោមតាមសេចក្តីណែនាំរបស់ធនាគារជាតិនៃកម្ពុជា លេខ ធ៧-០១៧-៣៤៤ ចំណាត់ថ្នាក់ឥណទាននីមួយៗ យោងទៅតាមគុណភាពឥណទានដូចខាងក្រោម៖

ឥណទានធម្មតា៖

ឥណទានដែលនៅសល់ ត្រូវបានទូទាត់សងទាន់ពេលវេលា និងមិនជាប់សង្ស័យសម្រាប់ការទូទាត់សងនាពេលអនាគត។ ការទូទាត់សង ត្រូវបានធ្វើឡើងតាមកិច្ចសន្យា ហើយអតិថិជនមិនបង្ហាញពីភាពទន់ខ្សោយ នៃលទ្ធភាពក្នុងការទូទាត់សង អាជីវកម្ម លំហូរទឹកប្រាក់ និងស្ថានភាពហិរញ្ញវត្ថុនោះឡើយ។

ឥណទានឃ្លាំមើល៖

ឥណទានដែលនៅក្នុងចំណាត់ថ្នាក់នេះ ត្រូវបានការពារនាពេលបច្ចុប្បន្ន ហើយប្រហែលជាមិនអាចហួសកាលកំណត់ទេ ប៉ុន្តែវាបង្ហាញពីភាពទន់ខ្សោយដែលអាចជះឥទ្ធិពលយ៉ាងធ្ងន់ធ្ងរដល់ការទូទាត់សងរបស់កូនបំណុលនៅកាលបរិច្ឆេទនា ពេលអនាគត ប្រសិនបើមិនបានកែតម្រូវឱ្យបានទាន់ពេលវេលា និងយកចិត្តទុកដាក់ពីគ្រឹះស្ថាន។

ភាពទន់ខ្សោយនេះរាប់បញ្ចូល ប៉ុន្តែមិនត្រូវបានកំណត់ចំពោះនិន្នាការថយចុះនៃប្រតិបត្តិការអាជីវកម្មរបស់ដៃគូភាគី ឬ ស្ថានភាពហិរញ្ញវត្ថុរបស់ខ្លួន និងស្ថានភាពសេដ្ឋកិច្ច និងលក្ខខណ្ឌទីផ្សារដែល អាចប៉ះពាល់ដល់ប្រាក់ចំណេញ និង លទ្ធភាពទូទាត់សងនាពេលអនាគតរបស់ខ្លួន ឬស្ថានភាពកាន់តែយ៉ាប់យ៉ឺននៃទ្រព្យបញ្ចាំ។ ចំណាត់ថ្នាក់នេះមាន សនិទានភាពផ្ទាល់ខ្លួនយ៉ាងច្បាស់លាស់ ហើយមិនគួរប្រើជាការសម្របសម្រួលរវាងឥណទានធម្មតា និងឥណទាន ក្រោមស្តង់ដារទេ។

ឥណទានក្រោមស្តង់ដារ៖

ឥណទានដែលបានចាត់ថ្នាក់នៅក្នុងចំណាត់ថ្នាក់នេះ បង្ហាញពីភាពទន់ខ្សោយគួរឱ្យកត់សម្គាល់ ហើយមិនត្រូវបានការពារ គ្រប់គ្រាន់ដោយអាជីវកម្មបច្ចុប្បន្ន ឬស្ថានភាពហិរញ្ញវត្ថុ និងលទ្ធភាពសងរបស់កូនបំណុលទេ។ និយាយឱ្យចំទៅប្រភពដើមនៃ ការសងបំណុល គឺមិនគ្រប់គ្រាន់ដើម្បីទូទាត់បំណុលនោះទេ ដោយមិនគិតពីប្រាក់ចំណូលដែលបានមកពីប្រភពបន្ទាប់បន្សំ ដូចជាលក់ទ្រព្យបញ្ចាំជាដើម។

កត្តាដែលនាំឱ្យមានចំណាត់ថ្នាក់ឥណទានក្រោមស្តង់ដារួមមាន៖

- កូនបំណុលគ្មានលទ្ធភាពដើម្បីបំពេញតាមលក្ខខណ្ឌនៃការទូទាត់សងប្រាក់តាមកិច្ចសន្យា
- ស្ថានភាពសេដ្ឋកិច្ច និងទីផ្សារមិនអំណោយផល ដែលអាចជះឥទ្ធិពលយ៉ាងធ្ងន់ធ្ងរដល់អាជីវកម្ម និងប្រាក់ ចំណេញរបស់ដៃគូភាគីនាពេលអនាគត
- ស្ថានភាពហិរញ្ញវត្ថុទន់ខ្សោយ និង / ឬ អសមត្ថភាពរបស់ដៃគូភាគីដើម្បីបង្កើតលំហូរទឹកប្រាក់គ្រប់គ្រាន់ដើម្បី បំពេញការទូទាត់សង
- ភាពលំបាកដែលបានជួបប្រទះដោយដៃគូភាគី ក្នុងការទូទាត់សងឥណទានផ្សេងទៀត ដែលផ្តល់ដោយ គ្រឹះស្ថាន ឬដោយស្ថាប័នផ្សេងៗទៀត នៅពេលមានព័ត៌មានអាចប្រើប្រាស់បាន និង
- ការបំពានលើកិច្ចព្រមព្រៀងហិរញ្ញវត្ថុដោយដៃគូភាគី ។

ឥណទានជាប់សង្ស័យ៖

ឥណទានដែលបានចាត់ថ្នាក់នៅក្នុងប្រភេទនេះ បង្ហាញពីភាពទន់ខ្សោយធ្ងន់ធ្ងរជាងចំណាត់ថ្នាក់ឥណទានក្រោមស្តង់ដារ ដែលការប្រមូលបានមកវិញគ្រប់ចំនួន ផ្អែកលើមូលដ្ឋាននៃដំណើរហេតុដែលមានស្រាប់ លក្ខខណ្ឌ ឬតម្លៃនៃទ្រព្យបញ្ចាំមានការ សង្ស័យខ្ពស់ ឬមិនអាចអាចប្រមូលបានវិញ។ ការរំពឹងទុកថានឹងបាត់បង់គឺខ្ពស់ ទោះបីជាចំនួនពិតប្រាកដនៅមិនទាន់បាន កំណត់សម្រាប់ពេលនេះក៏ដោយ។

ឥណទានខាតបង់៖

ឥណទានដែលត្រូវបានចាត់ថ្នាក់ថាជាការបាត់បង់ គឺនៅពេលដែលវាមិនអាចប្រមូលបានមកវិញ ហើយការទូទាត់សងវិញអាចមានចំនួនតិចតួច ឬប្រមូលមិនបានសោះ។

ការទទួលស្គាល់លើការរំពឹងទុកលើការខាតបង់ឥណទាន

ធនាគារអនុវត្តវិធីសាស្រ្ត ៣ ដំណាក់កាល ដោយផ្អែកលើការផ្លាស់ប្តូរគុណភាពឥណទានចាប់តាំងពីមានការទទួលស្គាល់ដំបូង៖

វិធីសាស្រ្ត ៣ ដំណាក់កាល	ដំណាក់កាលទី ១	ដំណាក់កាលទី ២	ដំណាក់កាលទី ៣
	ដំណើរការ	ក្រោមដំណើរការ	មិនដំណើរការ
ការទទួលស្គាល់ឥណទានដែលរំពឹងថានឹងបាត់បង់	រំពឹងថានឹងបាត់បង់រយៈពេល ១២ ខែ	រំពឹងថានឹងបាត់បង់ពេញអាយុកាល	រំពឹងថានឹងបាត់បង់ពេញអាយុកាល
លក្ខណៈវិនិច្ឆ័យ	មិនមានការកើនឡើងជាសារវន្តលើហានិភ័យឥណទានទេ	ហានិភ័យឥណទានដែលបានកើនឡើងជាសារវន្ត	ឥណទានដែលមានឱនភាព
មូលដ្ឋាននៃការគណនាចំណូលជាប្រាក់ចំណេញ	តម្លៃយោងដុល	តម្លៃយោងដុល	តម្លៃយោងដុល

ធនាគារវាស់វែងលើការរំពឹងទុកលើការខាតបង់ឥណទាន ដោយប្រើវិធីសាស្រ្តទូទៅ។ វិធីសាស្រ្តទូទៅរួមមាន ការញែកអតិថិជនចេញជា ៣ ដំណាក់កាលផ្សេងៗគ្នា ដោយយោងទៅតាមលក្ខណៈវិនិច្ឆ័យដំណាក់កាល ដោយធ្វើការវាយតម្លៃហានិភ័យឥណទាន។ លើការរំពឹងទុក លើការខាតបង់ឥណទាន រយៈពេល ១២ ខែ នឹងត្រូវបានគណនាសម្រាប់ដំណាក់កាលទី ១ ខណៈការរំពឹងទុកលើការខាតបង់ ឥណទានពេញអាយុកាល នឹងត្រូវបានគណនាសម្រាប់ដំណាក់កាលទី ២ និងដំណាក់កាលទី ៣។ នាការិយបរិច្ឆេទរាយការណ៍នីមួយៗ ធនាគារនឹងវាយតម្លៃហានិភ័យឥណទានទៅតាមគណនីនីមួយៗ បើប្រៀបធៀបនឹងកម្រិតហានិភ័យនៅពេលផ្តល់ឱ្យ។

ឥណទានរយៈពេលវែង (ច្រើនជាងមួយឆ្នាំ)

ដំណាក់កាល	ស្ថានភាពហានិភ័យឥណទាន	ចំណាត់ថ្នាក់	ចំនួនថ្ងៃហួសកាលកំណត់	សុចនាករណ៍នៃការយឺតយ៉ាវ
១	មិនមានការកើនឡើងជាសារវន្តលើហានិភ័យឥណទានទេ	ឥណទានធម្មតា	០ ដល់ ៣០ ថ្ងៃ	ដំណើរការ
២	ហានិភ័យឥណទានបានកើនឡើងជាសារវន្ត	ឥណទានឃ្លាំមើល	៣០ ដល់ ៩០ ថ្ងៃ	ក្រោមដំណើរការ
៣	ឥណទានមានឱនភាព	ឥណទានក្រោមស្តង់ដារ	៩០ ដល់ ១៨០ ថ្ងៃ	មិនដំណើរការ
		ឥណទានជាប់សង្ស័យ	១៨០ ដល់ ៣៦០ ថ្ងៃ	
		ឥណទានខាតបង់	លើសពី ៣៦០ ថ្ងៃ	

ឥណទានរយៈពេលខ្លី (១ ឆ្នាំ ឬតិចជាង)

ដំណាក់កាល	ស្ថានភាពហានិភ័យឥណទាន	ចំណាត់ថ្នាក់	ចំនួនថ្ងៃហួសកាលកំណត់	សុចនាករណ៍នៃការយឺតយ៉ាវ
១	មិនមានការកើនឡើងជាសារវន្តលើហានិភ័យឥណទានទេ	ឥណទានធម្មតា	០ ដល់ ១៤ ថ្ងៃ	ដំណើរការ
២	ហានិភ័យឥណទានបានកើនឡើងជាសារវន្ត	ឥណទានឃ្លាំមើល	១៥ ដល់ ៣០ ថ្ងៃ	ក្រោមដំណើរការ
៣	ឥណទានមានឱនភាព	ឥណទានក្រោមស្តង់ដារ	៣១ ដល់ ៦០ ថ្ងៃ	មិនដំណើរការ
		ឥណទានជាប់សង្ស័យ	៦១ ដល់ ៩០ ថ្ងៃ	
		ឥណទានខាតបង់	លើសពី ៩១ ថ្ងៃ	

ធនាគារនឹងប្រើប្រាស់ចំនួនថ្ងៃហួសកាលកំណត់សង និងចំណាត់ថ្នាក់របស់ធនាគារជាតិនៃកម្ពុជា សម្រាប់លក្ខណៈវិនិច្ឆ័យក្នុងការបែងចែកដំណាក់កាល។ ដូចគ្នានេះផងដែរ ធនាគារនឹងបង្កើតការដាក់ពិន្ទុឥណទាន ឬធាតុដែលអាចប៉ាន់ស្មានបាននាពេលអនាគត នៅពេលមានព័ត៌មានកាន់តែងាយស្រួលរក។ នៅពេលអនុវត្តប្រព័ន្ធដាក់ពិន្ទុឥណទាន កម្រិតហានិភ័យធ្លាក់ចុះទ្វេដង ឬច្រើនជាងនេះ បើប្រៀបធៀបទៅនឹងកម្រិតហានិភ័យនៅពេលផ្តល់ឱ្យ គណនីត្រូវចាត់ថ្នាក់នៅដំណាក់កាលទី ២។

សម្រាប់ទ្រព្យសកម្មហិរញ្ញវត្ថុដែលមានលក្ខណៈរយៈពេលខ្លី វិធីសាស្រ្តសាមញ្ញនឹងត្រូវបានអនុម័ត នៅពេលដែលវាមិនតម្រូវឱ្យមានលក្ខណៈវិនិច្ឆ័យជាជំហានៗ។ នៅក្នុងករណីនេះវានឹងត្រូវបានបែងចែកជាឥណទានដំណើរការ (ដំណាក់កាលទី ១) ឬឥណទាន មិនដំណើរការ។

តារាងខាងក្រោមសង្ខេបពីគុណភាពឥណទាននៃហិរញ្ញប្បទានដុលរបស់ធនាគារ ដោយយោងតាមចំណាត់ថ្នាក់ខាងលើ។

	ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០			
	ដំណាក់កាលទី ១	ដំណាក់កាលទី ២	ដំណាក់កាលទី ៣	សរុប
	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក
ឥណទាន និងបុរេប្រទានផ្តល់ដល់អតិថិជនតាម រំលស់ថ្លៃដើម				
ឥណទានធម្មតា	៧៤.៦៣៥.១៩២	-	-	៧៤.៦៣៥.១៩២
ឥណទានឃ្លាំមើល	-	-	-	-
ឥណទានក្រោមស្តង់ដារ	-	-	-	-
ឥណទានជាប់សង្ស័យ	-	-	-	-
តម្លៃយោង	៧៤.៦៣៥.១៩២	-	-	៧៤.៦៣៥.១៩២
សំវិធានធនខាតបង់	(១២៧.១០០)	-	-	(១២៧.១០០)
ចំនួនទឹកប្រាក់យោង	**៧៤.៥០៨.០៩២**	-	-	**៧៤.៥០៨.០៩២**
សមមូលពាន់រៀល (កំណត់សម្គាល់ ២.៤)	**៣០១.៣៨៥.២៣២**	-	-	**៣០១.៣៨៥.២៣២**

	ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩			
	ដំណាក់កាលទី ១	ដំណាក់កាលទី ២	ដំណាក់កាលទី ៣	សរុប
	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក
ឥណទាន និងបុរេប្រទានផ្តល់ដល់អតិថិជនតាម រំលស់ថ្លៃដើម				
ឥណទានធម្មតា	៦៧.៧៧០.៦០៩	-	-	៦៧.៧៧០.៦០៩
ឥណទានឃ្លាំមើល	-	-	-	-
ឥណទានក្រោមស្តង់ដារ	-	-	-	-
ឥណទានជាប់សង្ស័យ	-	-	-	-
តម្លៃយោង	៦៧.៧៧០.៦០៩	-	-	៦៧.៧៧០.៦០៩
សំវិធានធនខាតបង់	(៥៩.៥៨៣)			(៥៩.៥៨៣)
ចំនួនទឹកប្រាក់យោង	**៦៧.៧១១.០២៦**	-	-	**៦៧.៧១១.០២៦**
សមមូលពាន់រៀល (កំណត់សម្គាល់ ២.៤)	**២៧៥.៩២២.៤៣១**	-	-	**២៧៥.៩២២.៤៣១**

ការដាក់បញ្ចូលព័ត៌មានលើការប៉ាន់ស្មានអនាគត

ធនាគារដាក់បញ្ចូលព័ត៌មានលើការប្រមើលអនាគត ដោយការវាយតម្លៃទាំងលើថាតើ ហានិភ័យឥណទានរបស់ឧបករណ៍ហិរញ្ញវត្ថុ បានកើនឡើងជាសារវន្តចាប់តាំងពីការទទួលស្គាល់ដំបូង និងការវាស់វែង ECL។

ព័ត៌មានខាងក្រៅដែលត្រូវបានពិចារណារួមមានទិន្នន័យសេដ្ឋកិច្ច និងការព្យាករណ៍ដែលបានបោះពុម្ពផ្សាយដោយស្ថាប័នរដ្ឋាភិបាល និងអាជ្ញាធររូបិយវត្ថុនៅក្នុងបណ្តាប្រទេសដែលធនាគារធ្វើប្រតិបត្តិការដែលមានអង្គការអន្តរជាតិធំៗ ដូចជាមូលនិធិរូបិយវត្ថុអន្តរជាតិ និង វិស័យឯកជន និងការសិក្សារបស់អ្នកព្យាករណ៍។

ធនាគារបានកំណត់ និងចងក្រងឯកសារគន្លឹះនៃហានិភ័យឥណទាន និងឥណទានខាតបង់សម្រាប់ផលបត្រ ឧបករណ៍ហិរញ្ញវត្ថុ ស្របតាមប្រទេសនីមួយៗ ហើយប្រើការវិភាគទិន្នន័យប្រវត្តិសាស្ត្រ បានប៉ាន់ស្មានទំនាក់ទំនងរវាងអថេរម៉ាក្រូសេដ្ឋកិច្ច និងហានិភ័យឥណទាន និង ឥណទានខាតបង់។

ឆ្លើយតបទៅនឹងការរីករាលដាលនៃជំងឺរាតត្បាតCOVID-១៩ ធនាគារបានកំណត់ថាចក្ខុវិស័យសេដ្ឋកិច្ចសម្រាប់ឆ្នាំខាងមុខគឺរង ផលប៉ះពាល់យ៉ាងខ្លាំងពីរោគរាតត្បាត ដូច្នេះហើយទើបបង្កើតសេណារីយ៉ូសេដ្ឋកិច្ច (និងការបាត់បង់) ថ្មីហើយអនុវត្តការគ្រប់គ្រង លើកន្លែងណាដែល ចាំបាច់។

ធនាគារបានកែលម្អការព្យាករណ៍សេដ្ឋកិច្ចរបស់ខ្លួនដែលត្រូវបានប្រើជាធាតុចូលទៅក្នុងការរំពឹងទុកលើការខាតបង់ឥណទាន នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ ធ្លាក់ចុះពីឆ្នាំ២០១៩។

ក្នុងគោលបំណងនៃការគណនាការរំពឹងទុកលើការខាតបង់ឥណទាន ដើម្បីឆ្លុះបញ្ចាំងអំពីបរិយាកាសបច្ចុប្បន្ន ធនាគារ បានពិចារណា លើសេណារីយ៉ូសេដ្ឋកិច្ចដែលបានសង្កត់ធ្ងន់ក្នុងកំឡុងពេលជំងឺរាតត្បាត COVID-១៩ ដោយពិនិត្យមើលឡើងវិញនូវលទ្ធផលនៃ ប្រូបាប៊ីលីតេ (PWO) ដើម្បីបង្កើតព្រំដែន ខាងលើអព្យាក្រឹត និងក្រោម នៃ ECL។ អ្នកគ្រប់គ្រងរបស់ធនាគារ បានអនុវត្ត ទម្ងន់ប្រូបាប៊ីលីតេនៅលើសេណារីយ៉ូទាំងបីដើម្បីកំណត់ការរំពឹងទុកលើការខាតបង់ឥណទាន នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០។

គណនីកើតឡើងពីការរំពឹងទុកលើការខាតបង់ឥណទាន

សំវិធានធនលើការខាតបង់

តារាងខាងក្រោមបង្ហាញពីការផ្ទៀងផ្ទាត់ លើសំវិធានធនខាតបង់តាមការចាត់ថ្នាក់ឧបករណ៍ហិរញ្ញវត្ថុនាដើម និងចុងការិយបរិច្ឆេទ។

	ឆ្នាំ២០២០			
	ដំណាក់កាលទី ១	ដំណាក់កាលទី ២	ដំណាក់កាលទី ៣	សរុប
	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក
ឥណទាន និងបុរេប្រទានផ្តល់ដល់អតិថិជនតាម រំលស់ថ្លៃដើម				
នាថ្ងៃទី១ ខែមករា	៥៩.៥៨៣	-	-	៥៩.៥៨៣
ទ្រព្យសកម្មហិរញ្ញវត្ថុដំបូង ឬបានទិញថ្មី	៦៧.៥១៧	-	-	៦៧.៥១៧
នាថ្ងៃទី៣១ ខែធ្នូ	១២៧.១០០	-	-	១២៧.១០០
នាថ្ងៃទី៣១ ខែធ្នូ សមមូលពាន់រៀល (កំណត់សម្គាល់ ២.៤)	៥១៤.១២០	-	-	៥១៤.១២០

	ឆ្នាំ២០១៩			
	ដំណាក់កាលទី ១	ដំណាក់កាលទី ២	ដំណាក់កាលទី ៣	សរុប
	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក
ឥណទាន និងបុរេប្រទានផ្ដល់ដល់អតិថិជនតាម រំលស់ថ្លៃដើម				
នាថ្ងៃទី១ ខែមករា	៣៥.៨៤២	-	-	៣៥.៨៤២
ទ្រព្យសកម្មហិរញ្ញវត្ថុដំបូង ឬបានទិញថ្មី	២៣.៧៤១	-	-	២៣.៧៤១
នាថ្ងៃទី៣១ ខែធ្នូ	៥៩.៥៨៣	-	-	៥៩.៥៨៣
នាថ្ងៃទី៣១ ខែធ្នូ សមមូលពាន់រៀល (កំណត់សម្គាល់ ២.៤)	២៤២.៨០១	-	-	២៤២.៨០១

គ. ហានិភ័យទីផ្សារ

ហានិភ័យទីផ្សារគឺជាហានិភ័យដែលមានការផ្លាស់ប្តូរតម្លៃទីផ្សារ - ឧទាហរណ៍ អត្រាការប្រាក់ អត្រាប្តូរប្រាក់បរទេស និងតម្លៃមូលធន - នឹងមានផលប៉ះពាល់ដល់ប្រាក់ចំណូលរបស់ធនាគារ ឬតម្លៃនៃការកាន់កាប់ឧបករណ៍ហិរញ្ញវត្ថុ។ គោលបំណងនៃការគ្រប់គ្រងហានិភ័យទីផ្សារ គឺដើម្បីគ្រប់គ្រង និងត្រួតពិនិត្យហានិភ័យទីផ្សារតាមប៉ារ៉ាម៉ែត្រដែលអាចទទួលយកបាន ខណៈពេលដែលមានការបង្កើននូវ ប្រសិទ្ធភាពក្នុងការទទួលបានចំណូលមកវិញ។

ហានិភ័យអត្រាការប្រាក់

ហានិភ័យអត្រាការប្រាក់ សំដៅលើការខាតបង់នូវប្រាក់ចំណូលការប្រាក់សុទ្ធ ដោយសារតែការប្រែប្រួលនៃកម្រិតអត្រាការប្រាក់ និងការផ្លាស់ប្តូរនៅក្នុងសមាសភាពនៃទ្រព្យសកម្ម និងបំណុល។ ហានិភ័យអត្រាការប្រាក់ ត្រូវបានចាត់ចែងតាមរយៈ ការត្រួតពិនិត្យយ៉ាងហ្មត់ចត់ លើចំណូលនៃការបណ្តាក់ទុន តម្លៃសមស្រប និងតម្លៃដើមនៃមូលនិធិ។ សក្តានុពលនៃការធ្លាក់ចុះ ចំណូលការប្រាក់សុទ្ធ បណ្តាលមកពីការប្រែប្រួលអត្រាការប្រាក់ដែលខុសប្រក្រតី បានត្រួតពិនិត្យដោយធៀបទៅនឹងកម្រិតអាច ទទួលយកបាននៃហានិភ័យ។

តារាងខាងក្រោមនេះសង្ខេបពីហានិភ័យអត្រាការប្រាក់របស់ធនាគារ។ តារាងនេះចង្អុលបង្ហាញពីរយៈពេលដែលឧបករណ៍ហិរញ្ញវត្ថុកំណត់ថ្លៃឡើងវិញ ឬមានកាលកំណត់ណាមួយណាដែលកើតឡើងមុន។

នាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២០	រហូតដល់ ១ ខែ	> ១ - ៣ ខែ	> ៣ – ៦ ខែ	> ៦ – ១២ ខែ	> ១ - ៥ ឆ្នាំ	លើសពី ៥ ឆ្នាំ	ពុំមាន ការប្រាក់	សរុប	អត្រា ការប្រាក់
	ដុល្លារ អាមេរិក	ដុល្លារ អាមេរិក	ដុល្លារ អាមេរិក	ដុល្លារ អាមេរិក	ដុល្លារ អាមេរិក	ដុល្លារ អាមេរិក	ដុល្លារ អាមេរិក	ដុល្លារ អាមេរិក	%
ទ្រព្យសកម្ម ហិរញ្ញវត្ថុ									
សាច់ប្រាក់ - សុទ្ធ	-	-	-	-	-	-	៦៨.៣៦៤.៩៥៥	៦៨.៣៦៤.៩៥៥	0%
ប្រាក់បញ្ញើនៅធនាគារផ្សេងៗ	-	៦.៤០៥.៨៧៥	-	-	-	-	-	៦.៤០៥.៨៧៥	២%-៤%
ប្រាក់តម្កល់ធានាដើមទុន	-	-	-	-	-	៧.៥០០.០០០	-	៧.៥០០.០០០	0% - 0.0៦%
ឥណទាន និង សំវិធានធន ផ្តល់ដល់អតិថិជន – សុទ្ធ	១០.៩៨៣.៩០៩	១៣.៦៥៦.៣៥៤	១៤.៦៣០.១៤៨	១០.៧៣៧.១៦៧	២១.៣៨៣.៧៤៩	២.១០៥.៩៣២	១.០១០.៨៣៣	៧៤.៥០៨.០៩២	៥%-១២%
ការវិនិយោគផ្សេងៗ – សុទ្ធ	-	-	២៣.១២៧.២៦៧	-	-	-	-	២៣.១២៧.២៦៧	៦%
	១០.៩៨៣.៩០៩	**២០.០៦២.២២៩**	**៣៧.៧៥៧.៤១៥**	**១០.៧៣៧.១៦៧**	**២១.៣៨៣.៧៤៩**	**៩.៦០៥.៩៣២**	**៦៩.៣៧៥.៧៨៨**	**១៧៩.៩០៦.១៨៩**	
បំណុល ហិរញ្ញវត្ថុ									
ប្រាក់បញ្ញើពីធនាគារផ្សេងៗ	-	៥២០.៧៥៤	៣.០០៧.៦០៣	៣.០៣៨.០៤៧	-	-	៩.១១៤.០៩៦	១៥.៦៨០.៥០០	0%-២.៧៥%
ប្រាក់បញ្ញើពីអតិថិជន	៧៣.៥០៤.៩៩៨	១៧.៦៧២.៤០៦	៤៧.០៦៥.៧៩២	១៩.៨៨៩.០៩០	២.៩៨៨.១៧៣	-	១៣.២៥៩.៧០០	១៧៤.៣៨០.១៥៩	0%-៦.២៥%
បំណុលភតិសន្យា	១៨.៤៨២	៣៧.១៨៩	៨៤.១៥៦	១១៥.៦៩៩	៧០៦.០៨៦	១.៥៤៥.៨១៩	-	២.៥០៧.៤៣១	៦%
បំណុលផ្សេងៗ	-	-	-	-	-	-	៤៤០.៣០៩	៤៤០.៣០៩	គ្មាន
	៧៣.៥២៣.៤៨០	**១៨.២៣០.៣៤៩**	**៥០.១៥៧.៥៥១**	**២៣.០៤២.៨៣៦**	**៣.៦៩៤.២៥៩**	**១.៥៤៥.៨១៩**	**២២.៨១៤.១០៥**	**១៩៣.០០៨.៣៩៩**	
សរុបគំលាតការប្រាក់	(៦២.៥៣៩.៥៧១)	១.៨៣១.៨៨០	(១២.៤០០.១៣៦)	(១២.៣០៥.៦៦៩)	១៧.៦៨៩.៤៩០	៨.០៦០.១១៣	៤៦.៥៦១.៦៨៣	(១៣.១០២.២១០)	
សមមូលពាន់រៀល (កំណត់សម្គាល់ ២.៤)	(២៥២.៩៧២.៥៦៥)	៧.៤០៩.៩៥៥	(៥០.១៥៨.៥៥០)	(៤៩.៧៧៦.៤៣១)	៧១.៥៥៣.៩៨៧	៣២.៦០៣.១៥៧	១៨៨.៣៤២.០០៨	(៥២.៩៩៨.៤៣៩)	

នាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៩	រហូតដល់ ១ ខែ	> ១ - ៣ ខែ	> ៣ – ៦ ខែ	> ៦ – ១២ ខែ	> ១ - ៥ ឆ្នាំ	លើសពី ៥ ឆ្នាំ	ពុំមាន ការប្រាក់	សរុប	អត្រា ការប្រាក់
	ដុល្លារ អាមេរិក	ដុល្លារ អាមេរិក	ដុល្លារ អាមេរិក	ដុល្លារ អាមេរិក	ដុល្លារ អាមេរិក	ដុល្លារ អាមេរិក	ដុល្លារ អាមេរិក	ដុល្លារ អាមេរិក	%
ទ្រព្យសកម្មហិរញ្ញវត្ថុ									
សាច់ប្រាក់ - សុទ្ធ	-	-	-	-	-	-	៦១.២៥៤.៥១៣	៦១.២៥៤.៥១៣	0%
ប្រាក់បញ្ញើនៅធនាគារផ្សេងៗ	-	-	១៨.០៥៨.០៨១	-	-	-	-	១៨.០៥៨.០៨១	២%-៤%
ប្រាក់តម្កល់ធានាដើមទុន	-	-	-	-	-	៧.៥០០.០០០	-	៧.៥០០.០០០	0% - 0.៤៨%
ឥណទាន និងសំវិធានធនផ្តល់ដល់អតិថិជន–សុទ្ធ	៦.៩៩៣.០៧០	១.០០៩.៨០៦	៣.០៨៣.២០៩	១៩.៥២៧.១៦៩	២១.១៦៦.៨០៦	៤៩៨.៥៤៩	១៥.៤៣២.៤១៧	៦៧.៧១១.០២៦	៦%-១២%
ការវិនិយោគផ្សេងៗ–សុទ្ធ	-	-	-	២២.៣៩២.២៦៩	-	-	-	២២.៣៩២.២៦៩	៦%
	៦.៩៩៣.០៧០	**១.០០៩.៨០៦**	**២១.១៤១.២៩០**	**៤១.៩១៩.៤៣៨**	**២១.១៦៦.៨០៦**	**៧.៩៩៨.៥៤៩**	**៧៦.៦៨៦.៩៣០**	**១៧៦.៩១៥.៨៨៩**	
បំណុលហិរញ្ញវត្ថុ									
ប្រាក់បញ្ញើពីធនាគារផ្សេងៗ	-	-	-	-	-	-	៣២១.៨៤៣	៣២១.៨៤៣	-
ប្រាក់បញ្ញើពីអតិថិជន	៤២.៣២៣.១៦៥	១៥.៨៦២.៩៦៤	៧៣១.០៦៨	១២.០៧៣.៩៥៣	១.៦៨៥.៦២៣	-	៤៧.២៣៨.០៩៧	១១៩.៩១៤.៨៧០	១%-៦%
បំណុលភតិសន្យា	-	-	-	១៥៥.១៣៨	១.៥៦៦.៣៣២	-	-	១.៧២១.៤៧០	៦%
បំណុលផ្សេងៗ	៤៤៥.៣២៧	-	-	-	-	-	-	៤៤៥.៣២៧	គ្មាន
	៤២.៧៦៨.៤៩២	**១៥.៨៦២.៩៦៤**	**៧៣១.០៦៨**	**១២.២២៩.០៩១**	**៣.២៥១.៩៥៥**	**-**	**៤៧.៥៥៩.៩៤០**	**១២២.៤០៣.៥១០**	
សរុបគំលាតការប្រាក់	**(៣៥.៧៧៥.៤២២)**	**(១៤.៨៥៣.១៥៨)**	**២០.៤១០.២២២**	**២៩.៦៩០.៣៤៧**	**១៧.៩១៤.៨៥១**	**៧.៩៩៨.៥៤៩**	**២៩.១២៦.៩៩០**	**៥៤.៥១២.៣៧៩**	
សមមូលពាន់រៀល (កំណត់សម្គាល់ ២.៤)	**(១៤៥.៧៨៤.៨៤៥)**	**(៦០.៥២៦.៦១៩)**	**៨៣.១៧១.៦៥៥**	**១២០.៩៨៨.១៦៤**	**៧៣.០០៣.០១៨**	**៣២.៥៩៤.០៨៧**	**១១៨.៦៩២.៤៨៤**	**២២២.១៣៧.៩៤៤**	

ហានិភ័យរូបិយប័ណ្ណបរទេស

ហានិភ័យរូបិយប័ណ្ណ គឺជាហានិភ័យដែលតម្លៃនៃឧបករណ៍ហិរញ្ញវត្ថុមានការប្រែប្រួល បណ្តាលមកពីការប្រែប្រួលអត្រាប្តូររូបិយប័ណ្ណបរទេស។

ការប្រមូលផ្តុំហានិភ័យរូបិយប័ណ្ណ

ចំនួនទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុ តាមប្រភេទនៃរូបិយប័ណ្ណមានដូចខាងក្រោម៖

	ប្រភេទនៃរូបិយប័ណ្ណ			
	សមមូលដុល្លារអាមេរិក			
ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០	ពាន់រៀល	ដុល្លារអាមេរិក	ផ្សេងៗ	សរុប
ទ្រព្យសកម្មហិរញ្ញវត្ថុ				
សាច់ប្រាក់ - ដុល	២២៦.៨៣៣	៦៨.១៥៣.៨៤៥	១៧.៧១១	៦៨.៣៩៨.៣៨៩
ប្រាក់បញ្ញើនៅធនាគារផ្សេងៗ	-	៦.៤០៥.៨៧៥	-	៦.៤០៥.៨៧៥
ប្រាក់បញ្ញើតាមបទប្បញ្ញត្តិ	៦.១៨០	២០.៧៦៥.០០០	-	២០.៧៧១.១៨០
ឥណទាន និងបុរេប្រទានផ្តល់ដល់អតិថិជន - ដុល	១០២.៨១១	៧៤.៥៣២.៣៨១	-	៧៤.៦៣៥.១៩២
ការវិនិយោគផ្សេងៗ - ដុល	-	២៣.២៦៦.៣៧៧	-	២៣.២៦៦.៣៧៧
ប្រាក់តម្កល់ធានាដើមទុន	-	៥០៤.៨៧១	-	៥០៤.៨៧១
	៣៣៥.៨២៤	**១៩៣.៦២៨.៣៤៩**	**១៧.៧១១**	**១៩៣.៩៨១.៨៨៤**
បំណុលហិរញ្ញវត្ថុ				
ប្រាក់បញ្ញើពីធនាគារផ្សេងៗ	-	១៥.៦៨០.៥០០	-	១៥.៦៨០.៥០០
ប្រាក់បញ្ញើពីអតិថិជន	៤៨.៨៧០	១៧៤.៣៣១.២៨៩	-	១៧៤.៣៨០.១៥៩
បំណុលភតិសន្យា	-	២.៥០៧.៤៣១	-	២.៥០៧.៤៣១
បំណុលផ្សេងៗ	-	៤៤០.៣០៩	-	៤៤០.៣០៩
	៤៨.៨៧០	**១៩២.៩៥៩.៥២៩**	-	**១៩៣.០០៨.៣៩៩**
ស្ថានភាពទ្រព្យសកម្មសុទ្ធ	**២៨៦.៩៥៤**	**៦៦៨.៨២០**	**១៧.៧១១**	**៩៧៣.៤៨៥**
សមមូលពាន់រៀល (កំណត់សម្គាល់ ២.៤)	**១.១៦០.៧២៩**	**២.៧០៥.៣៧៧**	**៧១.៦៤១**	**៣.៩៣៧.៧៤៧**

	ប្រភេទនៃរូបិយប័ណ្ណ			
	សមមូលដុល្លារអាមេរិក			
ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩	ពាន់រៀល	ដុល្លារអាមេរិក	ផ្សេងៗ	សរុប
ទ្រព្យសកម្មហិរញ្ញវត្ថុ				
សាច់ប្រាក់ - ដុល	៨០.៨០១	៦១.១០២.០៣៧	១៣៣.៥៤៨	៦១.៣១៦.៣៨៦
ប្រាក់បញ្ញើនៅធនាគារផ្សេងៗ-ដុល	-	១៨.០៥៨.០៨១	-	១៨.០៥៨.០៨១
ប្រាក់បញ្ញើតាមបទប្បញ្ញត្តិ	៦.១៣៥	២៣.៧៦៥.០០០	-	២៣.៧៧១.១៣៥
ឥណទាន និងបុរេប្រទានផ្តល់ដល់អតិថិជន - ដុល	-	៦៧.៧៧០.៦០៩	-	៦៧.៧៧០.៦០៩
ការវិនិយោគផ្សេងៗ - ដុល	-	២២.៥២៧.៧៨៣	-	២២.៥២៧.៧៨៣
	៨៦.៩៣៦	**១៩៣.២២៣.៥១០**	**១៣៣.៥៤៨**	**១៩៣.៤៤៣.៩៩៤**
បំណុលហិរញ្ញវត្ថុ				
ប្រាក់បញ្ញើពីធនាគារផ្សេងៗ	-	៣២១.៨៤៣	-	៣២១.៨៤៣
ប្រាក់បញ្ញើពីអតិថិជន	៣៧.៤៨៨	១១៩.៨៧៧.៣៨២	-	១១៩.៩១៤.៨៧០
បំណុលភតិសន្យា	-	១.៧២១.៤៧០	-	១.៧២១.៤៧០
បំណុលផ្សេងៗ	-	៤៤៥.៣២៧	-	៤៤៥.៣២៧
	៣៧.៤៨៨	**១២២.៣៦៦.០២២**	-	**១២២.៤០៣.៥១០**
ស្ថានភាពទ្រព្យសកម្មសុទ្ធ	**៤៩.៤៤៨**	**៧០.៨៥៧.៤៨៨**	**១៣៣.៥៤៨**	**៧១.០៤០.៤៨៤**
សមមូលពាន់រៀល (កំណត់សម្គាល់ ២.៤)	**២០១.៥០១**	**២៨៨.៧៤៤.២៦៤**	**៥៤៤.២០៨**	**២៨៩.៤៨៩.៩៧៣**

ការវិភាគរំញោច

សន្មតថា ហានិភ័យអថេរផ្សេងទៀតនៅតែថេរជានិច្ច ការប្រែប្រួលនៃការប្តូររូបិយប័ណ្ណបរទេសសម្រាប់ ធនាគារនាកាលបរិច្ឆេទ រាយការណ៍ត្រូវបានសង្ខេបដូចខាងក្រោម (ដោយបង្ហាញតែរូបិយប័ណ្ណដែលមានចំនួនច្រើនជាង ៥% នៃស្ថានភាពដំបូងសុទ្ធ ត្រូវបាន បង្ហាញជារូបិយប័ណ្ណជាក់លាក់របស់វានៅក្នុងតារាងខាងក្រោម។ សម្រាប់រូបិយប័ណ្ណផ្សេងទៀត ការលាតត្រដាងទាំងនេះត្រូវបានដាក់ជាក្រុមផ្សេងៗ)៖

	ឆ្នាំ២០២០		ឆ្នាំ២០១៩	
	- ១%	+ ១%	- ១%	+ ១%
	រំលស់	ការកើនឡើង	រំលស់	ការកើនឡើង
	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក
ខ្មែររៀល	(២.៨០៨)	២.៨០៨	(៤៤៩)	៤៤៩
ផ្សេងៗ	(១៧៧)	១៧៧	(១.៣៣៥)	១.៣៣៥
	(២.៩៨៥)	**២.៩៨៥**	**(១.៧៨៤)**	**(១.៧៨៤)**
សមមូលពាន់រៀល (កំណត់សម្គាល់ ២.៤)	**(១២.០៧៤)**	**១២.០៧៤**	**(៧.២៧០)**	**(៧.២៧០)**

ឃ. ហានិភ័យសាច់ប្រាក់ងាយស្រួល

"ហានិភ័យសាច់ប្រាក់ងាយស្រួល" គឺជាហានិភ័យដែលធនាគារនឹងជួបផលលំបាកក្នុងការបំពេញកាតព្វកិច្ច ពាក់ព័ន្ធនឹងបំណុលហិរញ្ញវត្ថុ របស់ខ្លួន ដែលត្រូវបានទូទាត់តាមរយៈជាសាច់ប្រាក់ ឬទ្រព្យសកម្មហិរញ្ញវត្ថុផ្សេងទៀត។ ហានិភ័យសាច់ប្រាក់ងាយស្រួល កើតឡើង ពីភាពមិនស៊ីគ្នាទៅនឹងពេលវេលា និងចំនួនលំហូរទឹកប្រាក់ដែលមាននៅក្នុងប្រតិបត្តិការ និងការវិនិយោគរបស់ធនាគារ។

ការគ្រប់គ្រងហានិភ័យសាច់ប្រាក់ងាយស្រួល

ធនាគារ គ្រប់គ្រងសាច់ប្រាក់ងាយស្រួលរបស់ខ្លួនតាមរយៈគណៈកម្មាធិការគ្រប់គ្រងទ្រព្យសកម្ម បំណុល ដែលទទួលខុសត្រូវក្នុង ការបង្កើតគោលនយោបាយសាច់ប្រាក់ងាយស្រួល និងត្រួតពិនិត្យសាច់ប្រាក់ងាយស្រួលជាប្រចាំ។ តម្រូវការទ្រព្យសកម្មងាយស្រួល អប្បបរមា ត្រូវបានបង្កើតឡើងដើម្បីធានាថាអនុបាតនៃទ្រព្យសកម្មងាយស្រួល និងបំណុលដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ត្រូវទទួលបានកម្រិតអប្បបរមាគ្រប់ពេលវេលា។

តារាងខាងក្រោមសង្ខេបពីទ្រព្យសកម្ម និងបំណុលរបស់ធនាគារ ដោយផ្អែកលើកាលកំណត់កិច្ចសន្យាដែលនៅសល់។ លំហូរទឹកប្រាក់ដែលបានរំពឹងទុកលើទ្រព្យសកម្ម និងបំណុលទាំងនេះ អាចខុសជាសារវន្តពីអ្វីដែលបានបង្ហាញនៅក្នុងតារាង។ ឧទាហរណ៍ ប្រាក់បញ្ញើរបស់អតិថិជនមិនត្រូវបានរំពឹងថានឹងត្រូវដកបានភ្លាមៗ នោះទេ។

នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០	រហូតដល់ ១ ខែ	> ១ - ៣ ខែ	> ៣ – ៦ ខែ	> ៦ – ១២ ខែ	> ១ - ៥ ឆ្នាំ	លើសពី ៥ ឆ្នាំ	ពុំមាន ការប្រាក់	សរុប
	ដុល្លារ អាមេរិក	ដុល្លារ អាមេរិក	ដុល្លារ អាមេរិក	ដុល្លារ អាមេរិក	ដុល្លារ អាមេរិក	ដុល្លារ អាមេរិក	ដុល្លារ អាមេរិក	ដុល្លារ អាមេរិក
បំណុលហិរញ្ញវត្ថុ								
ប្រាក់បញ្ញើរបស់ធនាគារផ្សេងៗ	-	៥២០.៧៥៤	៣.០០៧.៦០៣	៣.០៣៨.០៤៧	-	-	៩.១១៤.០៩៦	១៥.៦៨០.៥០០
ប្រាក់បញ្ញើរបស់អតិថិជន	៥៩.៦៤៩.៦៦៦	១៧.៦៧២.៤០៦	៤៧.០៦៥.៧៩២	១៩.៨៨៩.០៩០	២.៩៨៨.១៧៣	-	២៧.១១៥.០៣២	១៧៤.៣៨០.១៥៩
បំណុលភតិសន្យា-មិនអប្បហា	៣១.៤៥០	៦២.៩០២	៩៤.៣៥៣	១៨៨.៧០៥	១.១៦៣.១៣៥	១.៩២៨.០០០	-	៣.៤៦៨.៥៤៥
បំណុលផ្សេងៗ	-	-	-	-	-	-	៤៤០.៣០៩	៤៤០.៣០៩
	៥៩.៦៨១.១១៦	**១៨.២៥៦.០៦២**	**៥០.១៦៧.៧៤៨**	**២៣.១១៥.៨៤២**	**៤.១៥១.៣០៨**	**១.៩២៨.០០០**	**៣៦.៦៦៩.៤៣៧**	**១៩៣.៩៦៩.៥១៣**
ទ្រព្យសកម្មហិរញ្ញវត្ថុ								
សាច់ប្រាក់ - ដុល	-	-	-	-	-	-	៦៨.៣៩៨.៣៨៩	៦៨.៣៩៨.៣៨៩
ប្រាក់បញ្ញើជាមួយធនាគារផ្សេងៗ	-	៦.៤០៥.៨៧៥	-	-	-	-	-	៦.៤០៥.៨៧៥
ឥណទាន និងបុរេប្រទានផ្តល់ដល់អតិថិជន - ដុល	១០.៩៩៩.៩៤៩	១៣.៦៧៧.៧០៩	១៤.៦៦៥.៥៦៣	៩.៩៩៦.១៤៩	២១.៤១៥.៦៣៩	២.១០៩.៣៥០	១.៧៧០.៨៣៣	៧៤.៦៣៥.១៩២
វិនិយោគផ្សេងៗ -ដុល	-	-	២៣.២៦៦.៣៧៧	-	-	-	-	២៣.២៦៦.៣៧៧
	១០.៩៩៩.៩៤៩	**២០.០៨៣.៥៨៤**	**៣៧.៩៣១.៩៤០**	**៩.៩៩៦.១៤៩**	**២១.៤១៥.៦៣៩**	**២.១០៩.៣៥០**	**៧០.១៦៩.២២២**	**១៧២.៧០៥.៨៣៣**
គំលាតវិភាគអាយុកាល	៤៨.៦៨១.១៦៧	(១.៨២៧.៥២២)	១២.២៣៥.៨០៨	១៣.១១៩.៦៩៣	(១៧.២៦៤.៣៣១)	(១៨១.៣៥០)	(៣៣.៤៩៩.៧៨៥)	២១.២៦៣.៦៨០
សមមូលពាន់រៀល (កំណត់សម្គាល់ ២.៤)	១៩៦.៩១៥.៣២១	(៧.៣៩២.៣២៦)	៤៩.៤៩៣.៨៤៣	៥៣.០៦៩.១៥៩	(៦៩.៨៣៤.២១៩)	(៧៣៣.៥៦១)	(១៣៥.៥០៦.៦៣០)	៨៦.០១១.៥៨៧

នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩	រហូតដល់ ១ ខែ	> ១ - ៣ ខែ	> ៣ – ៦ ខែ	> ៦ – ១២ ខែ	> ១ - ៥ ឆ្នាំ	លើសពី ៥ ឆ្នាំ	ពុំមាន ការប្រាក់	សរុប
	ដុល្លារ អាមេរិក	ដុល្លារ អាមេរិក	ដុល្លារ អាមេរិក	ដុល្លារ អាមេរិក	ដុល្លារ អាមេរិក	ដុល្លារ អាមេរិក	ដុល្លារ អាមេរិក	ដុល្លារ អាមេរិក
បំណុលហិរញ្ញវត្ថុ								
ប្រាក់បញ្ញើរបស់ធនាគារផ្សេងៗ	-	-	-	-	-	-	៣២១.៨៤៣	៣២១.៨៤៣
ប្រាក់បញ្ញើរបស់អតិថិជន	៤២.៣២៣.១៦៥	១៥.៨៦២.៩៦៤	៧៣១.០៦៨	១២.០៧៣.៩៥៣	១.៦៨៥.៦២៣	-	៤៧.២៣៨.០៩៧	១១៩.៩១៤.៨៧០
បំណុលភតិសន្យា-មិនអប្បហា	១៨.៣៣៣	៤២.៩០២	៦៤.៣៥៣	១២៨.៧០៥	២.២១៨.៥៤៥	-	-	២.៤៧២.៨៣៨
បំណុលផ្សេងៗ	-	-	-	-	-	-	៤៤៥.៣២៧	៤៤៥.៣២៧
	៤២.៣៤១.៤៩៨	**១៥.៩០៥.៨៦៦**	**៧៩៥.៤២១**	**១២.២០២.៦៥៨**	**៣.៩០៤.១៦៨**	**-**	**៤៨.០០៥.២៦៧**	**១២៣.១៥៤.៨៧៨**
ទ្រព្យសកម្មហិរញ្ញវត្ថុ								
សាច់ប្រាក់ - ដុល	-	-	-	-	-	-	៦១.៣១៦.៣៨៦	៦១.៣១៦.៣៨៦
ប្រាក់បញ្ញើជាមួយធនាគារផ្សេងៗ	-	-	១៨.០៥៨.០៨១	-	-	-	-	១៨.០៥៨.០៨១
ឥណទាន និងបុរេប្រទានផ្តល់ដល់អតិថិជន-ដុល	៧.០០០.០០០	១.០០៩.៨០៦	៣.០៨៨.៧៣៣	១៩.៥៤៥.៥៥៤	២១.១៩៤.៨៩៤	៤៩៩.២០៥	១៥.៤៣២.៤១៧	៦៧.៧៧០.៦០៩
វិនិយោគផ្សេងៗ-ដុល	-	-	-	២២.៥២៧.៧៨៣	-	-	-	២២.៥២៧.៧៨៣
	៧.០០០.០០០	**១.០០៩.៨០៦**	**២១.១៤៦.៨១៤**	**៤២.០៧៣.៣៣៧**	**២១.១៩៤.៨៩៤**	**៤៩៩.២០៥**	**៧៦.៧៤៨.៨០៣**	**១៦៩.៦៧២.៨៥៩**
គំលាតវិភាគអាយុកាល	**៣៥.៣៤១.៤៩៨**	**១៤.៨៩៦.០៦០**	**(២០.៣៥១.៣៩៣)**	**(២៩.៨៧០.៦៧៩)**	**(១៧.២៩០.៧២៦)**	**-**	**(២៨.៧៤៣.៥៣៦)**	**(៤៦.៥១៧.៩៨១)**
សមមូលពាន់រៀល (កំណត់សម្គាល់ ២.៤)	**១៤៤.០១៦.៦០៤**	**៦០.៧០១.៤៤៥**	**(៨២.៩៣១.៩២៦)**	**(១២១.៧២៣.០១៧)**	**(៧០.៤៥៩.៧០៨)**	**-**	**(១១៧.១២៩.៩០៩)**	**(១៨៩.៥៦០.៧៧៣)**

### ង.	ហានិភ័យប្រតិបត្តិការ

ហានិភ័យប្រតិបត្តិការ គឺជាហានិភ័យនៃការបាត់បង់ផ្ទាល់ ឬប្រយោលដែលកើតមានឡើងពីការខ្វះខាត ឬការអនុវត្តមិនមានប្រសិទ្ធភាព នូវនីតិវិធីដំណើរការផ្ទៃក្នុង បុគ្គលិក ឬប្រព័ន្ធ ឬពីកត្តាខាងក្រៅ។ ហានិភ័យនេះ ត្រូវបានគ្រប់គ្រងតាមរយៈការបង្កើតប្រព័ន្ធដំណើរការគ្រប់គ្រងប្រតិបត្តិការ ការត្រួតពិនិត្យ និងការរាយការណ៍ឱ្យបានត្រឹមត្រូវពីសកម្មភាពអាជីវកម្ម តាមរយៈអង្គភាពគ្រប់គ្រង និងគាំទ្រដែលឯករាជ្យពីអង្គភាពអាជីវកម្ម និងគណៈគ្រប់គ្រង។ ទាំងនេះរួមមាន ហានិភ័យខាងផ្នែកច្បាប់ អនុលោមភាពតាមគណនេយ្យ និងការក្លែងបន្លំ។

ការគ្រប់គ្រងលើហានិភ័យប្រតិបត្តិការរបស់ធនាគារ តម្រូវឱ្យបង្កើតនូវរចនាសម្ព័ន្ធតួនាទី និងវិធីសាស្ត្រនៃការគ្រប់គ្រងរបស់អង្គភាព ឱ្យបានច្បាស់លាស់។ គោលការណ៍ និងវិធានការត្រួតពិនិត្យផ្ទៃក្នុងជាច្រើន ត្រូវបានអនុវត្ត រួមមានការបង្កើតអ្នកមានសិទ្ធិចុះហត្ថលេខា ប្រព័ន្ធត្រួតពិនិត្យយ៉ាងហ្មត់ចត់ ការរៀបចំនូវនីតិវិធី និងឯកសារសំអាងនានា ព្រមទាំងការអនុវត្តតាមបទប្បញ្ញត្តិ និងតម្រូវការ តាមច្បាប់នានា។ ដំណើរការទាំងនេះត្រូវបានត្រួតពិនិត្យជាប្រចាំឆ្នាំ ដើម្បីឆ្លើយតបទៅនឹងហានិភ័យប្រតិបត្តិការ ដែលអាចកើតឡើង នៅក្នុងប្រតិបត្តិការអាជីវកម្មរបស់ធនាគារ។

### ច.	ការគ្រប់គ្រងដើមទុន

ដើមទុនបទប្បញ្ញត្តិ

គោលដៅរបស់ធនាគារក្នុងការគ្រប់គ្រងដើមទុន មានន័យទូលំទូលាយជាង "មូលធន" ដែលបង្ហាញក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។ ការគ្រប់គ្រងដើមទុនមានដូចខាងក្រោម៖

- អនុលោមតាមតម្រូវការដើមទុនដែលកំណត់ដោយធនាគារជាតិ
- ការពារលទ្ធភាពរបស់ធនាគារដើម្បីបន្តនិរន្តរ៍ភាពអាជីវកម្ម ដូចនេះ ធនាគារអាចបន្តផ្តល់ផលប្រយោជន៍ដល់ភាគទុនិក និងអត្ថប្រយោជន៍របស់ភាគីដែលពាក់ព័ន្ធនឹងធនាគារ និង
- រក្សាមូលដ្ឋានដើមទុនរឹងមាំ ដើម្បីគាំទ្រដល់ការអភិវឌ្ឍន៍អាជីវកម្ម។

គោលនយោបាយរបស់ធនាគារ គឺធានាឱ្យបាននូវមូលដ្ឋានដើមទុនរឹងមាំដើម្បីរក្សានូវទំនុកចិត្តទីផ្សារ និងដើម្បីធានាស្ថេរភាពនៃការអភិវឌ្ឍន៍យូរអង្វែងរបស់អាជីវកម្ម។ ផលប៉ះពាល់ទៅលើកម្រិតដើមទុនលើភាគលាភរបស់ភាគទុនិក ក៏ត្រូវបានទទួលស្គាល់ ហើយ ធនាគារបានទទួលស្គាល់នូវតម្រូវការដើម្បីធានាបាននូវតុល្យភាពរវាងភាគលាភខ្ពស់ដែលអាចនឹងកើតមានឡើងជាមួយនឹងប្រាក់ បម្រុងកម្រិតខ្ពស់អត្ថប្រយោជន៍ និងការធានាដែលផ្តល់ដោយស្ថានភាពដើមទុនល្អ។

ការបែងចែកដើមទុន

ការបែងចែកដើមទុនរវាងប្រតិបត្តិការ និងសកម្មភាពជាក់លាក់ គឺត្រូវបានគ្រប់គ្រងដោយកម្រិតភាគលាភដែលទទួលបានពីការបែងចែកនោះជាទីផ្សារដែលខ្លួនមានអតិភាព ប្រសិនបើមាន។ ដើមទុនដែលបានបែងចែកទៅតាមប្រតិបត្តិការ ឬសកម្មភាពនីមួយៗ ត្រូវផ្អែកទៅតាមដើមទុនដែលកំណត់ដោយច្បាប់។

៣២. តម្លៃសមស្របនៃទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុ

ឧបករណ៍ហិរញ្ញវត្ថុរួមមានទ្រព្យសកម្មហិរញ្ញវត្ថុ បំណុលហិរញ្ញវត្ថុ និងឧបករណ៍ហិរញ្ញវត្ថុដែលបានបង្ហាញនៅក្នុងកំណត់សម្គាល់ ៤.១។ ធនាគារមានក្របខ័ណ្ឌ និងគោលនយោបាយដែលបានបង្កើតឡើងដែលផ្តល់ការណែនាំទាក់ទងនឹងការពិចារណាជាក់ស្តែងលើ គោលការណ៍ និងវិធីសាស្ត្រវិភាគសម្រាប់ការបង្កើតការវាយតម្លៃប្រុងប្រយ័ត្នចំពោះឧបករណ៍ហិរញ្ញវត្ថុដែលបានវាស់វែងដោយតម្លៃសមស្រប។

តម្លៃសមស្រប គឺជាថ្លៃ ដែលត្រូវទទួលដើម្បីលក់ទ្រព្យសកម្ម ឬបានទូទាត់ ដើម្បីផ្ទេរបំណុលទៅតាមលំដាប់លំដោយនៅក្នុង ប្រតិបត្តិការ រវាងអ្នកចូលរួមក្នុងទីផ្សារនៅកាលបរិច្ឆេទនៃការវាស់វែងក្នុងទីផ្សារចម្បងឬប្រសិនអវត្តមានទីផ្សារដែលមានការបើក ច្រើនបំផុតរបស់ធនាគារបានទទួល នៅកាលបរិច្ឆេទនោះ។

ការវាយតំលៃឧបករណ៍ហិរញ្ញវត្ថុត្រូវបានកំណត់ដោយការយោងទៅលើតម្លៃដែលបានដកស្រង់នៅក្នុងទីផ្សារសកម្ម ឬដោយប្រើ បច្ចេកទេសវាយតម្លៃដោយផ្អែកលើធាតុចូលដែលអាចអង្កេតបាន ឬមិនអាចអង្កេតបាន។ ការវិនិច្ឆ័យរបស់គណៈគ្រប់គ្រងត្រូវបាន អនុវត្តក្នុងការជ្រើសរើស និងអនុវត្តប៉ារ៉ាម៉ែត្រសមស្រប ការសន្មត និងគំរូបច្ចេកទេស ដែលការបញ្ចូលប៉ារ៉ាម៉ែត្រខ្លះ ឬទាំងអស់មិនត្រូវបានគេសង្កេតឃើញក្នុងការទទួលបានតម្លៃសមស្រប។

និយ័តកម្មលើការវាយតម្លៃ គឺជាផ្នែកសំខាន់មួយក្នុងដំណើរការវាយតម្លៃ។ ការធ្វើនិយ័តកម្មលើការវាយតម្លៃ គឺដើម្បីឆ្លុះបញ្ចាំងអំពីភាព មិនច្បាស់លាស់ក្នុងការវាយតម្លៃជាទូទៅចំពោះផលិតផលដែលមិនសូវស្គាល់ដារ មិនសូវមានការជួញដូរ និងមានលក្ខណៈ ស្មុគស្មាញ។ ក្នុងការធ្វើនិយ័តកម្មលើការវាយតម្លៃ ធនាគារអនុវត្តតាមវិធីសាស្ត្រក្នុងការពិចារណាលើកត្តាមួយចំនួនដូចជា សាច់ប្រាក់ ងាយស្រួល ការផ្សព្វផ្សាយការដេញថ្លៃ និងតម្លៃដែលមិនអាចអង្កេតបាន រួមទាំងធាតុចូលក្នុងទីផ្សារ ហើយនិងភាពមិនច្បាស់លាស់ក្នុង ការសន្មត និងប៉ារ៉ាម៉ែត្រ។

ធនាគារបន្តលើកកម្ពស់លើការកែលម្អរ សុពលភាពនៃវិធីសាស្ត្រ និងដំណើរការរបស់ខ្លួនជាបន្តបន្ទាប់ ដើម្បីធានាថាការវាយតម្លៃ ត្រូវបានឆ្លុះបញ្ចាំង។ គំរូនៃការវាយតម្លៃគឺមានសុពលភាពទាំងខាងក្នុង និងខាងក្រៅ ដែលត្រូវបានត្រួតពិនិត្យជាប្រចាំដើម្បីធានាថាគំរូ ទាំងនោះសមស្របសម្រាប់គោលបំណងនៃការប្រើប្រាស់។

ធនាគារបានធ្វើចំណាត់ថ្នាក់លើឧបករណ៍ហិរញ្ញវត្ថុរបស់ខ្លួន ដែលត្រូវបានវាស់វែងតាមតម្លៃសមស្របដោយអនុលោមតាមឋានានុក្រម ដូចខាងក្រោម ដើម្បីឆ្លុះបញ្ចាំងពីសារៈសំខាន់នៃធាតុចូលក្នុងដំណើរការនៃការវាស់វែងតម្លៃសមស្រប។

- **កម្រិតទី១** ធាតុចូលនៃវិធីសាស្ត្រវាយតម្លៃ គឺត្រូវបានដកស្រងតម្លៃ (មិនបានធ្វើនិយ័តកម្ម) សម្រាប់ការកំណត់ទីផ្សារសកម្ម នៃទ្រព្យសម្បត្តិ និងបំណុល។
- **កម្រិតទី២** ធាតុចូលក្នុងវិធីសាស្ត្រនៃការវាយតម្លៃរួមមាន៖
  - តម្លៃដែលបានដកស្រង់សម្រាប់ទ្រព្យសកម្ម និងបំណុលប្រហាក់ប្រហែលគ្នានៅក្នុងទីផ្សារសកម្ម ឬ
  - តម្លៃដែលបានដកស្រង់សម្រាប់កំណត់អត្តសញ្ញាណ ឬទ្រព្យសកម្ម និងបំណុលប្រហាក់ប្រហែលគ្នានៅក្នុង ទីផ្សារអកម្ម ឬ
  - ធាតុចូលដែលអាចអង្កេតបានរបស់ទ្រព្យសកម្ម ឬបំណុល ទោះបីដោយផ្ទាល់ ឬដោយប្រយោល សម្រាប់ លក្ខខណ្ឌពេញលេញនៃឧបករណ៍ហិរញ្ញវត្ថុ។
- **កម្រិតទី៣** ធាតុចូលមួយ ឬច្រើនក្នុងវិធីសាស្ត្រវាយតម្លៃ គឺមិនអាចអង្កេតបាន និងការវាស់វែងនៃតម្លៃសមស្របសំខាន់ៗ។

ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុត្រូវបានចាត់ថ្នាក់ជាកម្រិតទី១ នៅពេលដែលការវាយតម្លៃគឺផ្អែកលើតម្លៃដែលបាន ដកស្រង់សម្រាប់ការកំណត់អត្តសញ្ញាណទ្រព្យសកម្ម ឬបំណុលក្នុងទីផ្សារសកម្ម។

ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុត្រូវបានគេចាត់ទុកថាត្រូវបានគេដកស្រង់នៅក្នុងទីផ្សារសកម្ម ប្រសិនបើតម្លៃដែលមាន ស្រាប់ពីការចេញផ្សាយ និងប្រភពដែលអាចទុកចិត្ត ហើយតម្លៃទាំងនោះតំណាងឱ្យប្រតិបត្តិការទីផ្សារជាក់ស្តែង និងទៀងទាត់ដែលផ្អែកលើប្រតិបត្តិការជំហោងដៃ។

នៅពេលដែលតម្លៃសមស្របត្រូវបានកំណត់ដោយប្រើប្រាស់តម្លៃដែលបានដកស្រង់របស់ទ្រព្យសកម្ម ឬបំណុលស្រដៀងគ្នានៅក្នុង ទីផ្សារសកម្ម ឬ តម្លៃដែលបានដកស្រង់របស់ទ្រព្យសកម្ម ឬបំណុលដែលអាចកំណត់អត្តសញ្ញាណបាន ដែលស្រដៀងគ្នានៅក្នុងទីផ្សារអសកម្ម ដូចជាទ្រព្យសកម្ម និងបំណុលដែលបានចាត់ថ្នាក់ជាកម្រិតទី ២។ ក្នុងករណីដែលមិនមានតម្លៃដែលបានដកស្រង់នៅឡើយ ធនាគារកំណត់តម្លៃសមស្របដោយផ្អែកលើបច្ចេកទេសក្នុងការវាយតម្លៃ ដោយប្រើប៉ារ៉ាម៉ែត្រទីផ្សារជាធាតុចូល។ បច្ចេកទេស វាយតម្លៃភាគច្រើនប្រើទិន្នន័យទីផ្សារដែលអាចអង្កេតបាន រួមបញ្ចូល ប៉ុន្តែមិនកំណត់ខ្សែកោងតម្លៃមូលធន អត្រាប្តូរប្រាក់ និងអត្រា ប្តូរប្រាក់បរទេស។

ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុត្រូវបានចាត់ថ្នាក់ជាកម្រិតទី៣ ប្រសិនបើការវាយតម្លៃរបស់វារួមបញ្ចូលទាំងធាតុចូល សំខាន់ៗ ដោយមិនផ្អែកលើទិន្នន័យទីផ្សារដែលអាចអង្កេតបាន។ ធាតុចូលទាំងនោះគឺត្រូវបានកំណត់ដោយផ្អែកលើធាតុចូលដែល អាចអង្កេតបាននៃលក្ខណៈស្រដៀងគ្នាការអង្កេតកន្លងមក ឬបច្ចេកទេសវិភាគដទៃទៀត។

ប្រសិនបើមិនមានតម្លៃ ឬតម្លៃដកស្រង់របស់ឧបករណ៍ហិរញ្ញវត្ថុ ឬឧបករណ៍ប្រហាក់ប្រហែល នោះតម្លៃសមស្របនឹងកើតមានឡើង តាមរយៈការប្រើប្រាស់បច្ចេកទេសវាយតម្លៃ ឬគំរូទីផ្សារ។ ការវិនិច្ឆ័យអាចតម្រូវឱ្យមានការវាយតម្លៃសម្រាប់តម្រូវការក្នុងការធ្វើនិយ័តកម្មលើការវាយតម្លៃ ដើម្បីឆ្លុះបញ្ចាំងឱ្យបានត្រឹមត្រូវលើប៉ារ៉ាមែត្រដែលមិនអាចអង្កេតបាន។ គំរូនៃការវាយតម្លៃក៏អាចត្រូវបាន វាយតម្លៃលើទិន្នន័យនៃប្រតិបត្តិការពាក់ព័ន្ធ ដូចជាកាលកំណត់ជាដើម។ ធាតុចូលបន្ទាប់មកត្រូវបានគេយកជាគោល និងត្រូវបានចាត់ចែងដើម្បីទទួលបានតម្លៃសមស្រប។

ធនាគារមិនមានចំនួនទឹកប្រាក់របស់ឧបករណ៍ហិរញ្ញវត្ថុសំខាន់ៗ ត្រូវបានវាស់វែងតាមតម្លៃសមស្របនោះឡើយ។

ឧបករណ៍ហិរញ្ញវត្ថុមិនត្រូវបានវាស់វែងតាមតម្លៃសមស្រប

នាកាលបរិច្ឆេទនៃរបាយការណ៍ តម្លៃសមស្របនៃឧបករណ៍ហិរញ្ញវត្ថុរបស់ធនាគារ គឺប្រហាក់ប្រហែលទៅនឹងតម្លៃយោងរបស់វា។

តម្លៃសមស្របដែលបានប៉ាន់ស្មាន គឺផ្អែកទៅលើវិធីសាស្រ្ត និងការសន្មតដូចខាងក្រោមៈ

ឥណទាន និងបុរេប្រទាន

តម្លៃសមស្របរបស់ឥណទាន និងបុរេប្រទានគឺផ្អែកលើប្រតិបត្តិការទីផ្សារដែលអាចអង្កេតបាន។ នៅពេលដែលមិនមានប្រតិបត្តិការ ទីផ្សារដែលអាចអង្កេតបាន តម្លៃសមស្របគឺត្រូវបានប៉ាន់ស្មានដោយប្រើប្រាស់គំរូនៃការវាយតម្លៃ ដូចជាបច្ចេកទេសលំហូរសាច់ប្រាក់ ដែលបានធ្វើអប្បហារ។ ការបញ្ចូលបច្ចេកទេសវាយតម្លៃ រួមបញ្ចូលទាំងអាយុកាលនៃការខាតបង់ឥណទានដែលបានរំពឹងទុក អត្រាការប្រាក់ អត្រានៃការទូទាត់ និងប្រភពដើម ឬការពង្រីកទីផ្សារបន្ទាប់។ ចំពោះឥណទានដែលមានឱនភាពទៅលើការខាតបង់ តម្លៃនៃទ្រព្យបញ្ចាំ តម្លៃសមស្របគឺត្រូវបានវាស់វែងដោយផ្អែកទៅលើតម្លៃនៃវត្ថុបញ្ចាំមូលដ្ឋាន។

ការដាក់បញ្ចូលគំរូ អាចរួមបញ្ចូលទាំងទិន្នន័យពីឥតិយជន និងព័ត៌មានដែលបានទទួលពីអ្នកចូលរួមទីផ្សារផ្សេងៗ ដោយរួមបញ្ចូល ទាំងប្រតិបត្តិការដំបូង និងប្រតិបត្តិការបន្ទាប់។ តម្លៃយោងរបស់វា គឺប្រហាក់ប្រហែលទៅតម្លៃសមស្របនាកាលបរិច្ឆេទនៃ របាយការណ៍។

ប្រាក់បញ្ញើ និងការដាក់ប្រាក់ជាមួយធនាគារផ្សេងៗ

ប្រាក់បញ្ញើ និងការដាក់ប្រាក់ជាមួយធនាគារផ្សេងៗរួមបញ្ចូលទាំងគណនីចរន្តដែលមិនទទួលបានការប្រាក់ គណនីសន្សំ និងគណនីបញ្ញើរយៈពេលខ្លី។ តម្លៃសមស្របរបស់ប្រាក់បញ្ញើ និងការដាក់ប្រាក់ជាមួយធនាគារផ្សេងៗគឺប្រហាក់ប្រហែលទៅនឹងតម្លៃយោងនាការិយបរិច្ឆេទនៃរបាយការណ៍ ដោយសារតែកាលកំណត់រយៈពេលខ្លីរបស់ឧបករណ៍ហិរញ្ញវត្ថុទាំងនេះ។

ការវិនិយោគផ្សេងៗ

នេះតំណាងឱ្យប្រាក់តម្កល់សម្រាប់ទិញមាសពីក្រុមហ៊ុន Asia Investment and Financial Services Sole Co. Ltd. ជាម្ចាស់ភាគហ៊ុន ដែលក្រុមហ៊ុន Asia Investment and Financial Services Sole Co. Ltd.បានយល់ស្របក្នុងការផ្តល់ជូននូវការ ធានាត្រឡប់ក្នុងអត្រា ៦%ក្នុងមួយឆ្នាំដែលត្រូវបានវាស់វែងតាមថ្លៃដើមរំលស់ព្រោះតម្លៃសមស្របរបស់វាមិនអាចវាស់វែងជាក់ស្តែង បានឡើយ។

ប្រាក់បញ្ញើរបស់ធនាគារផ្សេងៗ និងប្រាក់បញ្ញើរបស់អតិថិជន

តម្លៃសមស្របរបស់ប្រាក់បញ្ញើ និងការដាក់ប្រាក់ជាមួយធនាគារផ្សេងៗ និងគ្រឹះស្ថានហិរញ្ញវត្ថុ រួមទាំងប្រាក់បញ្ញើរបស់អតិថិជន ដែលមានកាលកំណត់តិចជាងមួយឆ្នាំ ប្រហាក់ប្រហែលទៅនឹងតម្លៃយោងរបស់វាដោយសារតែកាលកំណត់ដែលមានរយៈពេលខ្លី របស់ឧបករណ៍ហិរញ្ញវត្ថុទាំងនេះ។

តម្លៃសមស្របរបស់ប្រាក់បញ្ញើ និងការដាក់ប្រាក់ជាមួយធនាគារផ្សេងៗ និងគ្រឹះស្ថានហិរញ្ញវត្ថុ រួមទាំងប្រាក់បញ្ញើរបស់អតិថិជន ជាមួយនឹងកាលកំណត់ដែលនៅសល់ មានរយៈពេលលើសពីមួយឆ្នាំ គឺត្រូវបានរំពឹងទុកថា នឹងប្រហាក់ប្រហែលទៅនឹងតម្លៃយោង របស់វាដោយសារតែធនាគារបានផ្តល់នូវអត្រាការប្រាក់ស្រដៀងគ្នានៃឧបករណ៍ហិរញ្ញវត្ថុ ជាមួយនឹងកាលកំណត់ និងលក្ខខណ្ឌ ស្រដៀងគ្នា។

តម្លៃសមស្របដែលបានប៉ាន់ស្មានរបស់ប្រាក់បញ្ញើដែលមិនមានកាលកំណត់ ព្រមទាំងប្រាក់បញ្ញើមិនទទួលបានការប្រាក់ ប្រាក់បញ្ញើ ដែលត្រូវបង់តាមតំរូវការគឺជាចំនួនទឹកប្រាក់ដែលត្រូវបង់នៅកាលបរិច្ឆេទរបាយការណ៍។

ទ្រព្យសកម្មផ្សេងៗ និងបំណុលផ្សេងៗ

តម្លៃយោងរបស់ទ្រព្យសកម្មហិរញ្ញវត្ថុផ្សេងៗ និងបំណុលហិរញ្ញវត្ថុផ្សេងៗ ត្រូវបានសន្មតតាមរយៈតម្លៃសមស្របប្រហាក់ប្រហែល របស់ដោយសារជាតុគណនីទាំងនេះមិនមានភាពជាសារវន្តទាក់ទងនិងការផ្លាស់ប្តូរទីផ្សារអត្រាការប្រាក់។

៣៣. ការចាត់ថ្នាក់នៃចំនួនទឹកប្រាក់ប្រៀបធៀប

ចំនួនទឹកប្រាក់ជាក់លាក់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុដែលត្រូវប្រៀបធៀប និងលាតត្រដាងកំណត់សម្គាល់ ត្រូវបានធ្វើការចាត់ថ្នាក់ អនុលោមតាមការបង្ហាញនៅក្នុងការិយបរិច្ឆេទ។ គណៈគ្រប់គ្រងជឿជាក់ថា ការចាត់ថ្នាក់ទាំងនេះនឹងឆ្លុះបញ្ចាំងឱ្យកាន់តែល្អប្រសើរនូវលក្ខណៈនៃប្រតិបត្តិការ និងមិនធ្វើឱ្យប៉ះពាល់ដល់របាយការណ៍ចំណេញ ឬខាតក្នុងការិយបរិច្ឆេទមុនឡើយ។

សេចក្តីសង្ខេបនៃការផ្លាស់ប្តូរក្នុងចំណេញ ឬខាតកើតមានឡើងដោយសារការចាត់ថ្នាក់ឡើងវិញ ត្រូវបានបង្ហាញដូចខាងក្រោម៖

	ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ (បានថ្លែងពីមុន)	ផលប៉ះពាល់លើការធ្វើចំណាត់ថ្នាក់ឡើងវិញ	ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ (បានធ្វើចំណាត់ថ្នាក់ឡើងវិញ)
	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក
សេវា និងកម្រៃជើងសារ-សុទ្ធ	២៦៧.៨៤៤	(៣៣.៧៧៨)	២៣៤.០៦៦
ចំណាយបុគ្គលិក	(៧៩៣.១៥៥)	(១៦.១៣៧)	(៨០៩.២៩២)
ចំណាយប្រតិបត្តិការផ្សេងៗ	(១.៧២៧.៨៨១)	៤៩.៩១៥	(១.៦៧៧.៩៦៦)
ផលប៉ះពាល់សរុបលើប្រាក់ចំណេញក្នុងឆ្នាំ	**(២.២៥៣.១៩២)**	**-**	**(២.២៥៣.១៩២)**

៣៤. ព្រឹត្តិការណ៍ក្រោយការិយបរិច្ឆេទនៃរបាយការណ៍

លើកលែងតែផលប៉ះពាល់ដែលកំពុងបន្ត នៃជំងឺកូវីដ១៩ ដូចដែលបានលាតត្រដាង នៅក្នុងកំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ១ ពុំមានព្រឹត្តិការណ៍សំខាន់កើតមានឡើង ចន្លោះកាលបរិច្ឆេទនៃការរាយការណ៍ និងកាលបរិច្ឆេទនៃការអនុម័តអោយប្រើប្រាស់ របាយការណ៍ហិរញ្ញវត្ថុនោះទេ ដែលតម្រូវឱ្យកែតម្រូវ ឬលាតត្រដាងដែលត្រូវធ្វើឡើងនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុឡើយ។

៣៥. ការអនុម័តនៃរបាយការណ៍ហិរញ្ញវត្ថុ

របាយការណ៍ហិរញ្ញវត្ថុគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ និងសម្រាប់ដំណាច់ឆ្នាំនេះត្រូវបានអនុម័តដោយក្រុមប្រឹក្សាភិបាលនៅថ្ងៃ ទី២៨ ខែឧសភា ឆ្នាំ២០២១។

ប៊ី.អាយ.ស៊ី (ខេមបូឌា) ប៊ែង ម.ក

អគារលេខ ៤៦២ មហាវិថីព្រះមុនីវង្ស
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា

www.bicbank.com.kh

ផ្នែកបម្រើសេវាអតិថិជន

០២៣ ៩០១ ៣៣៨